# ថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១

## ពលករ១៤នាក់ ឃាត់ខ្លួនភ្លាមៗ ក្រោយគេចវេះមិនព្រមធ្វើចត្តាឡីស័ក

https://news.sabay.com.kh/ ព្រហស្បតិ៍, 25 កុម្ភៈ 2021 12:09

ពលករខ្មែរ ១៤នាក់ដែលឆ្លងដែនពីប្រទេសថៃ ត្រូវបានឃាត់ខ្លួនភ្លាមៗ ក្រោយរកឃើញថាពួកគាត់បានគេចវេះមិនព្រមធ្វើចត្តាឡីស័ក។ នាល្ងាចថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២១ កម្លាំងសមត្ថកិច្ចចម្រុះសហការជាមួយកម្លាំងអន្តរាគមន៍បានឃាត់ខ្លួនពលករឆ្លងដែនពីប្រទេសថៃចំនួន១៤នាក់ មានប្រុស៧នាក់ និងស្រី៥នាក់ ព្រមទាំងក្មេង២នាក់ ស្ថិតនៅភូមិភ្នំតូច ឃុំពេជ្រចិន្តា ស្រុកភ្នំព្រឹក ខេត្តបាត់ដំបងបញ្ជូនទៅមណ្ឌលចត្តាឡីស័ក ។ គួរឲ្យដឹងថា ពលករទាំងនេះ ត្រូវបានសមត្ថកិច្ចដឹកតាមរថយន្តទូរីស១២កៅអី យកមកកាន់មណ្ឌលចត្រាឡីស័ក ស្រុកភ្នំព្រឹក ៕ អត្ថបទ ៖ Art

## ឃាត់បានពលករវិលត្រឡប់ពីថៃទៀតហើយ មិនគួរដើរកាត់ព្រៃទេ

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៧ ខែ កុម្ភៈ ឆ្នាំ ២០២១ ម៉ោង ១៥:៣៧

ខេត្តបន្ទាយមានជ័យ ៖ កម្លាំងចម្រុះជួរមុខប្រចាំនៅបន្ទាត់ព្រំដែនភូមិទំនប់ក៥ សង្កាត់ និងក្រុងប៉ោយប៉ែតបានឃាត់ពលការិនីវិលត្រឡប់ពីថៃចំនួន៣នាក់ បញ្ជូនទៅធ្វើចត្តាឡីស័ក នៅសៀលថ្ងៃទី២៧ កុម្ភៈ នេះ។ ពលការិនីទាំង៣នាក់ខាងលើ ១-ឈ្មោះញ៉ែត យ៉ា អាយុ៤១ឆ្នាំ, ២-ឈ្មោះមុី ភក្ត្រា អាយុ៣៧ឆ្នាំ ទាំង២នាក់នេះមានទីលំនៅភូមិសាលាដែង ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ និង៣-ឈ្មោះឈីន សៀងហៃ អាយុ៣១ឆ្នាំ មានទីលំនៅភូមិតាណាលឃុំក្លឿងរាយ ស្រុកកញ្ច្រៀច ខេត្តព្រៃវែង។

លោកអនុសេនីយ៍ឯក ស៊ាសៅឌី នាយប៉ុស្តិ៍ព្រៃគប់នៃនគរបាលការពារព្រំដែនគោកលេខ៩១១ប្រាប់កោះសន្តិភាពថា យោងកាសាកសួរពលការិនីទាំង៣នាក់ប្រាប់ថា ពួកគាត់ទើបវិលត្រឡប់ពីក្រុងបាងកកដោយខ្លួនឯងគ្មានអ្នកនាំផ្លូវទេ។ ប្រភពថា ពួកគាត់បាននាំគ្នាជិះរថយន្តឈ្នួលពីក្រុងបាងកក មកកាន់ព្រំដែន ។ លុះមកដល់ផ្លូវកៅស៊ូទី២ ជិតព្រំដែនក្នុងស្រុកអារញ្ញ ខេត្តស្រះកែវ ឈមទឹកដីកម្ពុជា ក្រុងប៉ោយប៉ែត អ្នកបើកបររថយន្តឈ្នួលថៃឲ្យចុះដើរមកប្រទេសដោយខ្លួនឯង ទើបជួបសមត្ថកិច្ចចម្រុះឃាត់យកទៅធ្វើចត្តាឡីស័ក នៅសាលាបឋមសិក្សាព្រហ្មនិមិត្តតាមវិធានការរបស់ក្រសួងសុខាភិបាលតែម្តង។ ការឆ្លងព្រំដែនចេញ-ចូលប្រទេសទាំងប្រថុយប្រថានបែបនេះ និងមានហានិភ័យខ្ពស់នៅពេលណាមួយមិនខានព្រោះកន្លងមកធ្លាប់មានពលករជួបគ្រោះអកុសលជាន់មីនបន្សល់ពីសម័យសង្គ្រាមរងរបួសរួចទៅហើយ៕

## ពលករឆ្លងដែនចេញពីប្រទេសថៃចូលមកស្រុកកំណើតបានកើនឡើងដល់ជាង៩000នាក់ គិតត្រឹមថ្ងៃទី២៦ខែកុម្ភៈ

https://www.kampucheathmey.com/ on February 27, 2021By Sokhom Khon

គិតត្រឹមថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១ តាមតំបន់ព្រំដែននានាក្នុងខេត្តបាត់ដំបងបានទទួលពលករខ្មែរសរុបចំនួន៩៦១៦នាក់ ក្នុងនោះពលករប្រុសស្រីក្មេងចាស់ដែលបានឆ្លងដែនពីប្រទេសថៃចូលមកស្រុកកំណើតនៅថ្ងៃទី២៦ខែកុម្ភៈ ឆ្នាំ២០២១ ដើម្បីជួបជុំសាច់ញាតិក្នុងឱកាសបុណ្យចូលឆ្នាំប្រពៃណីខ្មែរសរុបចំនួន១៨៤នាក់។ ដោយឡែកពលករដែលបានបញ្ចប់ការធ្វើចត្តាឡីស័កអនុញ្ញាតឲ្យវិលត្រឡប់ទៅកាន់លំនៅស្ថានរៀងៗវិញ នៅថ្ងៃដដែលមានចំនួន៣២២នាក់ នេះបើយោងតាមការបញ្ជាក់ពីអាជ្ញាធរខេត្ត។ មន្ត្រីរដ្ឋបាលខេត្តបានបន្ថែមថា ក្រៅពីការទទួលពលករដែលឆ្លងដែនតាមច្រកត្រង់មិនគេចវេះ អាជ្ញាធរក៏កំពុងជំរុញការបង្កើនកម្លាំងដាក់ពង្រាយការពារត្រួតពិនិត្យយ៉ាងតឹងតែងផងដែរទៅលើពលករខ្មែរដែលឆ្លងដែនខុសច្បាប់នៅតាមបន្ទាត់ព្រំដែនកម្ពុជា ថៃ នៅក្នុងភូមិ

សាស្ត្ររបស់ខ្លួន។ ប្រសិនបើរកឃើញថាពលករដែលចេញឬចូលខុសច្បាប់និងត្រូវនាំខ្លួនយកទៅកាន់មណ្ឌលចត្តាឡីស័កជាបន្ទាន់ភ្លាម។ ដោយឡែកក្នុងករណីរកឃើញមេខ្យល់នឹងត្រូវនាំខ្លួនឲ្យធ្វើចត្តាឡីស័កតាមការកំណត់រួចរាល់ហើយ និងបញ្ជូនទៅផ្តន្ទាទោសតាមច្បាប់ដោយមិនលើកលែងឡើយ។

លោក ងួន វតនៈ ប្រធានគណៈបញ្ជាការឯកភាពខេត្តបានបញ្ជាក់ដែរថា ភូមិសាស្ត្រដែលមេខ្យល់តែងនាំពលករចេញឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃនិងត្រឡប់ពីប្រទេសថៃចូលមកប្រទេសកំណើតវិញនោះ មាននៅតាមបណ្តាច្រករបៀងនានាជាច្រើនផងដែរមានដូចជាតំបន់ព្រំដែនស្រុកកំរៀង,ស្រុកភ្នំព្រឹក និងស្រុកសំពៅលូន។ លោកបន្តថា កន្លងមកសមត្ថកិច្ចបានបង្រ្កាបឃាត់ខ្លួនមេខ្យល់បានជាបន្តបន្ទាប់បានបញ្ជូនទៅកាន់តុលាការសរុបចំនួន៣៩នាក់រួចមកហើយលើសំណុំរឿង២១ករណី៕ អត្ថបទ ៖ សៅ សារិទ្ធ

## ពលករខ្មែរ វិលពីប្រទេសថៃ ទៅភូមិកំណើត នៅខេត្តសៀមរាប បានទទួលអំណោយ លើកដំបូង ពីអភិបាលខ្លួន

https://www.rasmeinews.com/ 28 February, 20210

**ដោយៈ ប.ជ័យ / បន្ទាយមានជ័យៈ** *ពលករខ្មែរ វិលពីធ្វើការស៊ីឈ្នួល នៅប្រទេសថៃ ហើយត្រូវពិនិត្យ និងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកម្រិត១ វិទ្យាល័យមង្គលបូរី ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ រយៈពេលកំណត់ ១៤ ថ្ងៃ មុនពេលបន្តធ្វើដំណើរ ទៅភូមិកំណើត នៅខេត្តសៀមរាប ទើបបានទទួលអំណោយ លើកដំបូង ពីអភិបាលខេត្តសៀមរាប របស់ខ្លួន។*

លោក វ័ន្ន ដាស៊ីណង់ អភិបាលស្រុកមង្គលបូរី បានអោយដឹង កាលពីរសៀល ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ ដោយលោក និងក្រុមការងារ សូមថ្លែងអំណរគុណ ចំពោះលោក ទៀ សីហា អភិបាលខេត្តសៀមរាប និងលោកស្រី បានឧត្តម្ភថវិកា ជូនដល់ពលករខ្មែរ វិលត្រឡប់ពីប្រទេសថៃ ហើយមានលំនៅ រស់នៅ នៅខេត្តសៀមរាប ចំនួន ២៨នាក់ ។ លោក បានបន្តថាៈ ក្នុងពលករម្នាក់ៗ ទទួលថវិកាពីក្រុមការងារ របស់លោកអភិបាលខេត្ត ក្នុងម្នាក់ៗ ចំនួន ៥ ម៉ឺនរៀល ។ ពួកគេបាននឹងកំពុងបន្តស្នាក់នៅ មណ្ឌលចត្តាឡីស័ក កម្រិត១ វិទ្យាល័យមង្គលបូរី (របស់រដ្ឋបាល ខេត្តបន្ទាយមានជ័យ)។ ក្នុងនោះ លោកអភិបាល ខេត្តសៀមរាប ក៏បានឧបត្ថម្ភថវិកា ដល់គណៈកម្មការគ្រប់គ្រងមណ្ឌល ចំនួន ២លានរៀលផងដែរ ៕/V

## ឃាត់ពលករខ្មែរ៣នាក់បញ្ជូនមកមណ្ឌល ធ្វើចត្តាឡីស័កវិញ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 26/02/2021

**បាត់ដំបង ៖** កម្លាំងអន្តរាគមន៍ ឈរជើងតាមខ្សែបន្ទាត់ព្រំដែន ក្នុងស្រុកសំពៅលូន ចំណុច ប៉ុស្តិ៍នគរបាលការពារព្រំដែន ក្នុងភូមិសាស្ត្រស្លាបឆ្វេងដៃ ច្រកទ្វារព្រំដែនអន្តរជាតិ (គីឡូ១៣) ស្រុកសំពៅលូន នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២១នេះ បានឃាត់ពលករខ្មែរឆ្លងដែន មកពីប្រទេសថៃ ចំនួន ៣ នាក់ (ស្រី១នាក់) ដែលគេចវេះមិនព្រមចូលធ្វើចត្តាឡីស័ក ហើយជិះតាមរថយន្ត យកមកកាន់មណ្ឌលចត្តាឡីស័ក មណ្ឌលសាលារៀន ៣២ ស្រុកសំពៅលូនវិញ ៕

## នគរបាលស្រុកឆ្លូងចុះផ្សព្វផ្សាយផលប៉ះពាល់នៃគ្រឿងញៀន និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋតាមខ្នងផ្ទះ

http://cambodiapolice.com/policekh/ 11:50 am 27 កុម្ភៈ 2021

ក្រចេះ ៖ នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២១ វេលាម៉ោង៧និង១៥នាទី កម្លាំងជំនាញសណ្តាប់ធ្នាប់បានសហការជាមួយជំនាញប្រឆាំងបទល្មើសគ្រឿងញៀនចុះផ្សព្វផ្សាយដល់ប្រជពលរដ្ឋតាមខ្នងផ្ទះនៅចំណុចភូមិកល្វាធំឃុំព្រែកសាម៉ាន់ ស្រុកឆ្លូង ខេត្តក្រចេះ ។ សមត្ថកិច្ចបានផ្សព្វផ្សាយដូចខាងក្រោម៖

- បង្ការទប់ស្កាត់ការប្រើប្រាស់ និងជួញដូរគ្រឿងញៀនគ្រប់ប្រភេទ។
-ផ្សព្វផ្សាយពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀន។
-ផ្សព្វផ្សាយបង្ការទប់ស្កាត់ល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ។
-ផ្សព្វផ្សាយបង្ការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងកុមារ។
-ផ្សព្វផ្សាយប្រឆាំការជួញដូរមនុស្ស
-ផ្សព្វផ្សាយបង្ការ ទប់ស្កាត់គ្រោះថ្នាក់សង្គមផ្សេងៗ។
-ផ្សព្វផ្សាយបង្ការ ទប់ស្កាត់បទល្មើសចោរកម្មគ្រប់ប្រភេទ។
-ផ្សព្វផ្សាយអំពីការបង្ការ និងការពន្លត់អគ្គីភ័យ
-ផ្សព្វផ្សាយផលប៉ះពាល់គ្រឿងយុទ្ធភណ្ឌមិនទាន់ផ្ទុះ. ។
-ផ្សព្វផ្សាយគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពទាំង ៩ចំណុច។

ក្នុងនោះដែរកម្លាំងប៉ុស្តិ៍បានណែនាំប្រ ជាពលរដ្ឋសំអាតខ្លួនប្រាណ និងអនាម័យអោយបានល្អ លាងដៃនឹងអាល់កុល ដែល ឬសាប៊ូអោយបានញឹកញាប់ ដើម្បីទប់ស្កាត់ការពារការឆ្លងរាលដាលជំងឺ Covid-១៩ ។ ប្រតិបត្តិការខាងលើ កម្លាំងធ្វើបានចំនួន២៥ខ្នងផ្ទះ ប្រជាពលរដ្ឋចូលរួមសរុបចំនួន៤៨ នាក់ ស្រី២៥នាក់ ក្នុងនោះបានចែកខិត្តប័ណ្ណ(គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពទាំង ៧ចំណុច) ចែកខិតបណ្ណ័បានចំនួន៤៨សន្លឹក ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៩៣នាក់ ស្រី ៤០នាក់ ក្នុងនោះកុមារា នាក់ ២កុមារី ១នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។
2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣៥នាក់ ស្រី ១៥នាក់ កុមារា ១នាក់ កុមារី ១នាក់។
3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៦នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ០០នាក់។
4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤២នាក់ ស្រី ១៩នាក់ កុមារា ០០នាក់ កុមារី ០០នាក់។
5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៩៣នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥១នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៤២នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ដោយ៖ ធូ កុសល

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃសៅរ៍ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៥៤នាក់ ស្រី ២៧នាក់ ក្នុងនោះកុមារា នាក់ ២កុមារី ៥នាក់ មានដូចខាងក្រោម៖

1- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

2- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣៣នាក់ ស្រី ១៩នាក់ កុមារា ២នាក់ កុមារី ៥នាក់។

3- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

4- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៧នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

5- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៥៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣៧នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ១៧នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ដោយ៖ ធូ កុសល

## នាំពលករលួចឆ្លងដែនតាមច្រករបៀង ជាប់ខេត្តប៉ៃលិន ៩នាក់ គេចវេះធ្វើចត្តាឡីស័ក ទៅដល់ផ្ទះនៅស្រុកមោងឫស្សី មកធ្វើចត្តាឡីស័ក

http://btv.com.kh/ 28/02/2021

បាត់ដំបង៖ ពលករខ្មែរទើបត្រឡប់មកពីប្រទេសថៃ លួចឆ្លងដែនខុសច្បាប់តាមច្រករបៀងជាប់ខេត្តប៉ៃលិន ចំនួន៩នាក់ រស់នៅក្នុងស្រុកមោងឫស្សី ខេត្តបាត់ដំបង ដែលបានគេចវេះពីការធ្វើចត្តាឡីស័ក ហើយត្រូវមន្ត្រីសុខាភិបាល និងអាជ្ញាធរស្រុក ទៅនាំខ្លួនមកធ្វើចត្តាឡីស័ក ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ។

យោងតាមគណនីហ្វេសប៊ុកមួយឈ្មោះ Tep Han ដែលត្រូវបានគេដឹងថា ជារបស់លោក ទេព ហន អភិបាលស្រុកមោងឫស្សី បានបង្ហោះនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១នេះថា “ថ្ងៃនេះពលករមកពីប្រទេសថៃ ចូលតាមច្រករបៀងគេចពីសមត្ថកិច្ច(ច្រកព្រំ ខេត្តប៉ៃលិន) មកដល់ភូមិអង្គ្រង ឃុំជ្រៃ ស្រុកមោងឫស្សី ចំនួន៩នាក់ ស្រី ៦នាក់ បាននាំពួកគាត់យកមកធ្វើចត្តាឡីស័ក នៅមណ្ឌលពេទ្យបង្អែកមោងឫស្សី” ។ ពាក់ព័ន្ធនឹងការនាំពលករលួចឆ្លងដែនខុសច្បាប់តាមការអូសទាញរបស់ពួកមេខ្យល់គេចវេសពីការធ្វើចត្តាឡីស័ក គឺត្រូវបានអាជ្ញាធរខេត្តបាត់ដំបង ពិសេសសមត្ថកិច្ចការពារព្រំដែនក៏បានឃាត់ជាបន្តបន្ទាប់ផងដែរ ដើម្បីនាំពួកគេទៅធ្វើចត្តាឡីស័ក ដើម្បីចូលរួមទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ ៕អត្ថបទ ៖ សុខរិទ្ធ

# ការធ្វើចំណាកស្រុកមានកម្រិតកាន់តែខ្ពស់ ធ្វើឱ្យកុមារតូចត្រូវបានទុកឱ្យជីដូនមើលថែ

https://www.postkhmer.com/ ម៉ុំ គន្ធា | Publication date 26 February 2021 | 08:59 ICT

**ភ្នំពេញៈ** អង្គការទស្សនៈពិភពលោកនៅកម្ពុជាបានរកឃើញថា ការធ្វើចំណាកស្រុកឆ្លងប្រទេស មុនពេលមានការរីករាលដាលនៃជំងឺកូវីដ ១៩ និងការជំរុញឱ្យមានការធ្វើចំណាកស្រុកក្នុងប្រទេស ក៏មានកម្រិតកាន់តែខ្ពស់ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារតែមានកំណើន នៃវិស័យកាត់ដេរ និងការអភិវឌ្ឍសេដ្ឋកិច្ចយ៉ាងខ្លាំងក្លានៅក្នុងរាជធានីភ្នំពេញ បានធ្វើឱ្យកុមារតូចៗត្រូវបានទុកឱ្យនៅជាមួយជីដូនជាអ្នកមើលថែ។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់អង្គការទស្សនៈពិភពលោកនៅកម្ពុជា ពីម្សិលមិញបានលើកឡើងថា ការវិវឌ្ឍទាំង២ នេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ជីវិតគ្រួសារនៅតាមជនបទរាប់រយរាប់ពាន់គ្រួសារនៅក្នុងប្រទេសកម្ពុជា។ អង្គការនេះបញ្ជាក់ថា៖ «ចំនួនកុមារកាន់តែច្រើនឡើងៗមានឪពុកម្ដាយម្នាក់ ឬទាំង ២ នាក់ បានចាកចេញពីភូមិកំណើតរបស់ពួកគេ ដើម្បីស្វែងរកឱកាសថ្មី សម្រាប់គ្រួសារដោយទុកកូនៗឱ្យសមាជិកគ្រួសារមើលថែ ដែលភាគច្រើនជាជីដូនខាងម្ដាយ»។

យោងតាមការសិក្សាស្រាវជ្រាវរបស់អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (IOM) ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកបញ្ហានេះមានកាន់តែច្រើនឡើង ហើយជីដូនបានទទួលយកតួនាទីចម្បងជាអ្នកផ្ដល់ការថែទាំក្នុងគ្រួសារ ដែលស្ទើរតែ ២ ភាគ ៣ ឬ ៦៤% នៃគ្រួសារនៅក្នុងប្រទេស។

តាមការស្ទង់មតិមួយដែលធ្វើឡើងដោយអង្គការទស្សនៈពិភពលោកក្នុងឆ្នាំ ២០២០ មានជីដូនចូលរួមតែ ៦៧% ដែលបានដឹងអំពីការអនុវត្តដែលល្អបំផុតទាំង ៥ ក្នុងការផ្ដល់ចំណីអាហារល្អដល់ទារក និងកុមារ និង ៤៧% បានអនុវត្តវិធីដែលអាចបង្កគ្រោះថ្នាក់ចំនួន ៤ ឬច្រើនជាងនេះដែលអាចជះឥទ្ធិពលអវិជ្ជមានដល់ម្ដាយ និងកុមារ។ លើសពីនេះ ជីដូនចំនួន ៣០ ភាគរយ ដែលបានផ្ដល់បទសម្ភាសឱ្យអង្គការទស្សនៈពិភពលោកបាននិយាយថា ពួកគាត់មានអារម្មណ៍ធុញថប់ និងអស់កម្លាំង និង ៤៧ ភាគរយ មានអារម្មណ៍មិនសប្បាយចិត្ត ឬធ្លាក់ទឹកចិត្តយ៉ាងតិចម្ដង។ អង្គការដដែលនេះសង្កត់ធ្ងន់ថា៖ «ជីដូនត្រូវបានគេចាត់ទុកដូចជា ព្រះរស់ និងមានឥទ្ធិពលច្រើនទៅលើអ្នកថែទាំងទៃ»។

លោកស្រី ឱ យឿន អាយុ ៥២ ឆ្នាំ រស់នៅក្នុងស្រុកសំរោង ខេត្តកំពង់ស្ពឺជាអ្នកនៅមើលថែចៅចំនួន ៤ នាក់ ក្នុងនោះមានអាយុ ៣ ខែ ១៨ ខែ ៩ ឆ្នាំ និងអាយុ ១០ ឆ្នាំ ដែលចៅៗទាំងនេះជាកូនរបស់កូនស្រីទាំង ២ របស់គាត់ ដែលកំពុងធ្វើការនៅតាមរោងចក្រ។ លោកស្រីថ្លែងថា៖ «ខ្ញុំក្រោកពីម៉ោង ៥ ព្រឹកហើយចម្អិនម្ហូបឱ្យចៅ និងកូនរបស់ខ្ញុំ។ ខ្ញុំមើលថែពួកគាត់។ ការងារបន្ទាប់របស់ខ្ញុំ គឺរៀបចំអុស និងធ្វើស្រែ។ ខ្ញុំក៏ជួយបោកសម្លៀកបំពាក់ឲ្យសមាជិកទាំងអស់ក្នុងគ្រួសារផងដែរ»។

ចំណែកលោកស្រី គឹម ស្រេង អាយុ ៥០ ឆ្នាំ ជាអ្នកមើលថែចៅចំនួន ៣ នាក់ ដែលមានអាយុ ៥ ឆ្នាំ ៤ ឆ្នាំ និង ២ ឆ្នាំនិយាយថា អ្នកស្រីបានមើលថែចៅទាំងអស់របស់លោកស្រីតាំងពីពេលដែលពួកគេមានអាយុ ៦ ខែមក។ រាល់ថ្ងៃអ្នកស្រីក្រោកពីម៉ោង ៥ ព្រឹកដើម្បីធ្វើម្ហូបសម្រាប់គ្រួសារ បញ្ចុកអាហារចៅ សម្អាតផ្ទះ លាងចាន បន្ទាប់មកបោកសម្លៀកបំពាក់ និងថែដំណាំ។ ស្ត្រីរូបនេះនិយាយទៀតថា៖ «ខ្ញុំក៏មានអារម្មណ៍ធុញថប់ នៅពេលខ្លះៗ អំឡុងពេលដែលកំពុងមើលថែចៅៗ ប៉ុន្តែប្រសិនបើខ្ញុំមិនមើលថែទាំចៅៗ កូនរបស់ខ្ញុំនឹងមិនអាចធ្វើការ និងរកចំណូលបាននោះទេ»។

ជាមួយគ្នានេះដែរ តាមការស្ទង់មតិរបស់អង្គការទស្សនៈពិភពលោកក៏បានរកឃើញថា ជីដូនចំនួន ៩៥% ជឿថា ការបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខ សម្រាប់រយៈពេល ៦ ខែដំបូង គឺមានប្រយោជន៍សម្រាប់ទារក។ ទោះជាយ៉ាងណាមានជីដូនតែ ១៤ ភាគរយប៉ុណ្ណោះ ដែលបានឱ្យចៅបៅទឹកដោះម្ដាយសុទ្ធរយៈពេល ៦ ខែ។អង្គ

ការទស្សនៈពិភពលោកក្នុងការអនុវត្តកម្មវិធីអាហារូបត្ថម្ភបញ្ជាក់ថា ជីដូនមានឥទ្ធិពលវិជ្ជមានទៅលើស្ថានភាពសុខភាព និងអាហារូបត្ថម្ភរបស់កុមារ ជាមួយនឹងចំណេះដឹងត្រឹមត្រូវអំពីមាតា ទារកទើបនឹងកើត និងការថែទាំកុមារ។

មន្រ្តីជំនាញផ្នែកអាហារូបត្ថម្ភនៅអង្គការទស្សនៈពិភពលោកនៅកម្ពុជា លោកស្រី Grana PuSelvi ឱ្យដឹងថា ការបំបៅកូនដោយទឹកដោះម្តាយតែ ១ មុខរយៈពេល ៦ ខែដំបូងរបស់ទារកអាចផ្តល់នូវសារជាតុចិញ្ចឹមសមស្របក្នុងបរិមាណត្រឹមត្រូវ និងការពារកុមារពីការឆ្លងជំងឺ។ កុមារដែលមិនទទួលបានការបំបៅដោយទឹកដោះម្តាយតែ ១ មុខអាចខ្វះអាហារូបត្ថម្ភ និងទទួលរងជំងឺឆ្លងញឹកញាប់។ លោកស្រីថ្លែងថា៖ «យើងចង់ឃើញកុមារទាំងអស់ ជាពិសេសកុមារងាយរងគ្រោះបំផុតមានសុខភាពល្អ និងមានអាហារូបត្ថម្ភល្អ។ ដោយសារតែជីដូនមានតួនាទីសំខាន់ ជាពិសេសក្នុងការចិញ្ចឹមកុមារ យើងត្រូវផ្តល់ជំបូន្មានដែលជួយបង្កើនចំណេះដឹងរបស់ក្រុមជីដូន និងលើកកម្ពស់ឥរិយាបថ និងការអនុវត្តល្អៗទាក់ទងនឹងសុខភាពរបស់កុមារតូច»។ អង្គការទស្សនៈពិភពលោកផ្តល់អត្ថប្រយោជន៍ដល់កុមារជាង ១៨០០ នាក់ដែលស្ថិតក្រោមការមើលថែរបស់ជីដូនតាមរយៈក្រុមជីដូនជំនួប ៥០ ក្រុម ដែលមានសមាជិកជាង ៥០០ នាក់ នៅស្រុកសំពៅងទង ស្រុកបសេដ្ឋ និងរាជធានីភ្នំពេញ។ អង្គការទស្សនៈពិភពលោក បានរៀបចំការប្រជុំជាប្រចាំខែដើម្បីលើកកម្ពស់ការយល់ដឹងអំពីវិធីសាស្រ្តថែទាំកុមារផ្សេងទៀតដែលល្អជាងមុន។ កម្មវិធីនេះក៏លើកទឹកចិត្តសមាជិកគ្រួសារដទៃទៀតឱ្យចែករំលែកទំនួលខុសត្រូវរបស់ជីដូន ដើម្បីសម្រាលតួនាទីរបស់គាត់តាមរយៈការប្រជុំរវាងសមាជិកក្នុងក្រុមគ្រួសារ៕

## ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១

## មេខ្យល់ម្នាក់ទៀត ត្រូវបានចាប់ខ្លួន និងចោទប្រកាន់ពីបទនាំមនុស្សឆ្លងដែនខុសច្បាប់

https://kohsantepheapdaily.com.kh/ ០១ ខែ មីនា ឆ្នាំ ២០២១ ម៉ោង ២០:០១

បន្ទាយមានជ័យ៖ ប៉ូលិសក្រុងប៉ោយប៉ែត បានឃាត់ខ្លួនជនសង្ស័យម្នាក់ ពីបទនាំមនុស្សឆ្លងដែនខុសច្បាប់ ហៅថា មេខ្យល់។ បុរសនោះ ត្រូវបានបញ្ជូនទៅសាលាដំបងខេត្តបន្ទាយមានជ័យ ចាត់ការតាមច្បាប់ នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១។

លោកវរៈសេនីយ៍ឯក សៅ សារឿន អធិការនគរបាលក្រុងប៉ោយប៉ែត បានអោយដឹងថា ជនសង្ស័យ មានឈ្មោះ លី លីន ភេទប្រុស អាយុ ៣៤ឆ្នាំ ស្នាក់នៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត។ លោកបានបញ្ជាក់ថា នៅពេលឃាត់ខ្លួនជនសង្ស័យ គឺកម្លាំងវរៈការពារព្រំដែនគោក លេខ៩១១ បានសហការជាមួយកម្លាំងកងពលតូចថ្មើរជើងលេខ៥១ ចេញល្បាតតាមបន្ទាត់ព្រំដែន ហើយឃាត់ខ្លួនជនសង្ស័យឈ្មោះ លី លីន បម្រុងនាំពលករឆ្លងពីប្រទេសថៃ ចូលមកកម្ពុជា ដោយគេចវេះពីធ្វើចត្តាឡីស័ក។ បុរសមេខ្យល់នេះ ត្រូវបានឃាត់ខ្លួន នៅវេលាម៉ោង ១១:៥០នាទី កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ នៅក្នុងភូមិសាស្រ្តក្រុងប៉ោយប៉ែត។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យបានប្រាប់ថា វិធានការឃាត់ខ្លួនមេខ្យល់នេះ បានធ្វើឡើង ក្រោយពីសារណែនាំពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចតេជោ ហ៊ុន សែន ដើម្បីពង្រឹងការទប់ស្កាត់ពលករចំណាកស្រុកខុសច្បាប់ ដែលត្រលប់ពីប្រទេសថៃ គេចវេះពីធ្វើចត្តាឡីស័ក។ ការធ្វើចត្តាឡីស័កនេះ ដើម្បីបង្ការ និងទប់ស្កាត់កូវីដ១៩។ លោកបានបញ្ជាក់ថា កងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន បានអវត្តតាមការណែនាំទប់ស្កាត់ពលករលួចឆ្លងជាច្រើនលើក ត្រូវបានធ្វើការណែនាំ បញ្ជូនទៅធ្វើចត្តាឡីស័ក ហើយស្រាវជ្រាវចាប់បានមេខ្យល់បាន ៤ ទៅ ៥ករណី ត្រូវបញ្ជូនទៅសាលាដំបូងខេត្ត ចាត់ការតាមច្បាប់៕ ដោយ៖ ប៊ុន ធឿន

## អាជ្ញាធរឃុំស្រែចារចុះផ្សព្វផ្សាយផលប៉ះពាល់នៃគ្រឿងញៀន និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ

http://cambodiapolice.com/policekh/ 4:10 pm 1 មីនា 2021

ក្រចេះ ៖ នៅព្រឹកថ្ងៃទី០១ ខែមីនា ឆ្នាំ២០២១ កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលស្រែចារ សហការជាមួយលោក សៅ សារុំ ក្រុមប្រឹក្សាឃុំ និងលោកមេភូមិ បានធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីផលប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន នៅចំណុចសាលាបុណ្យអញ្ចាញ ភូមិទ្រៀក ឃុំស្រែចារ ស្រុកស្នួល ខេត្តក្រចេះ ។ ក្នុងនោះកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបានធ្វើការផ្សព្វផ្សាយនិងចែកខិតប័ណ្ណរួមមាន ៖

-ផ្សព្វផ្សាយ សេចក្ដីចូលរួមអំពាវនាវចូលរួមគាំទ្រយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់នៅកម្ពុជា

-ចែកសារសម្រាប់អប់រំអំពីផល់ប៉ះពាល់គ្រោះថ្នាក់នៃគ្រឿងញៀន

-ផ្សព្វផ្សាយអនុក្រិត្យលេខ៣៩អនក្រ,បកចុះថ្ងៃទី១៧ ខែមីនាឆ្នាំ២០២០ ស្តីពីការពិន័យអន្តរកាលចំពោះអំពើល្មើសច្បាប់ចរាចរណ៍ផ្លូវគោកថ្មី

-ផ្សព្វផ្សាយរួមគ្នាបង្ការទប់ស្កាត់បទល្មើសបញ្ហាចោរកម្ម គ្រប់ប្រភេទ

-ផ្សព្វផ្សាយ រួមគ្នាបង្ការការប្រើអំពើហិង្សាទាក់ទង និងយេនឌ័រ អំពើជួញដូរស្ត្រី និងកុមារ ។

-ផ្សព្វផ្សាយគ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌគ្រាប់មិនទាន់ផ្ទុះ

-ផ្សព្វផ្សាយ អំពីការលេងល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ

-ផ្សព្វផ្សាយអំពីគ្រោះអគ្គីភ័យ និងផ្សព្វផ្សាយសេចក្ដីណែនាំរបស់ក្រសួងសុខាភិបាលស្តីពីវិធីការការពារទប់ស្កាត់នៃការរីករាលដាលអំពីជំងឺកូវីដ១៩ផងដែរ នៅក្នុងនោះ កម្លាំងយើងបានធ្វើការផ្សព្វផ្សាយនូវលក្ខណះសម្បត្តិទាំង០៧យ៉ាងរបស់គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពផងដែរ ៕

## នគរបាលប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនជនសង្ស័យជាមេខ្យល់ចំនួន០៧នាក់ ទៅសាលាដំបូងខេត្តចាត់ការតាមច្បាប់

http://cambodiapolice.com/policekh/ 4:21 pm 1 មីនា 2021

ខេត្តបន្ទាយមានជ័យ ៖ មុខសញ្ញាសង្ស័យជាមេខ្យល់ចំនួន០៧នាក់ ស្រី០១នាក់ កម្លាំងនគរបាលជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ កសាងសំណុំរឿងបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី០១ខែមីនា ឆ្នាំ២០២១ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យនគរបាលប្រឆាំងការជួញដូរមនុស្សនិងការ ពារអនីតិជន បានឲ្យដឹងថា៖ ដោយអនុវត្តតាមបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ ស្នងការ នគរបាលខេត្តបន្ទាយមានជ័យ កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា បានប្រតិបត្តិការតាមបន្ទាត់ព្រំដែន ដើម្បីទប់ស្កាត់ការលួចឆ្លងដែនដោយខុសច្បាប់ ។ក្នុងនោះកម្លាំងសមត្ថកិច្ចបានឃាត់ជនសង្ស័យជាមេខ្យល់នាំឆ្លងដែនដោយខុសច្បាប់ប្រុស ស្រីចំនួន០៧ ស្រុកម៉ាឡៃចំនួន០៤នាក់ ពាក់ព័ន្ធករណីដឹកជញ្ជូនពលករឆ្លងដែនទៅប្រទេសថៃនិងនាំផ្លូវពលករពីថៃមកខ្មែរគេចវះពីសមត្ថកិច្ចឈរជើងនៅតាមបន្ទាត់ព្រំដែន ត្រូវបានកម្លាំងនគរបាលអធិការដ្ឋាននគរបាលស្រុកម៉ាឡៃនិងកម្លាំងនគរបាលការពារព្រំដែនគោកលេខ៨១៥ ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន០៣នាក់ ស្រី០១នាក់ បាននាំពលករចំនួន០៩នាក់ឆ្លងដែនខុសច្បាប់ ក្នុងភូមិសាស្ត្រ ឃុំបឹងបេង មាន៖ ១/-ឈ្មោះ វង់ សារឿន ភេទស្រី អាយុ៥៣ឆ្នាំ រស់នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ។ ២/-ឈ្មោះ សារិន ចាន់ម៉ៅ ភេទ

ប្រុស អាយុ៣០ឆ្នាំ រស់នៅភូមិដំបូកវិល ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ។ ៣/-ឈ្មោះ ឃាត ខុន ភេទប្រុស អាយុ៣១ឆ្នាំ រស់នៅភូមិឈើទាល ឃុំអូរស្រឡៅ ស្រុកម៉ាឡៃ ។

ចំណែកឯស្រុកថ្មពួកចំនួន០៣នាក់ ជាមេខ្យល់ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨០៧សហការជាមួយកម្លាំងសិករងខេត្តបន្ទាយមានជ័យឃាត់ខ្លួន ចំណុចជើងភ្នំដងរ៉ែក ស្ថិតក្នុងភូមិដងរ៉ែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក ប្រគល់ឲ្យកម្លាំងនគរបាលអធិការស្រុកថ្មពួក មាន៖ ១/-ឈ្មោះ ស្រិន រី ភេទប្រុស អាយុ៥៩ឆ្នាំ នៅភូមិឆ្លក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក (នាំពលករ០១នាក់បំរុងឆ្លងដែនទៅថៃ) ។ ២/-ឈ្មោះ នាថ មនោ ភេទប្រុស អាយុ២០ឆ្នាំ ។ ៣/-ឈ្មោះ វ៉ាត សៃយ៉ាម ហៅឈី ភេទប្រុស អាយុ២៣ឆ្នាំ ទាំអ០២នាក់ នៅភូមិដងរ៉ែក ឃុំបន្ទាយឆ្មារ ស្រុកថ្មពួក (បាននាំពលករខ្មែរមកពីថៃចំនួន០៦នាក់ ក្នុងនោះក្មេង០២នាក់ គេចពីសមត្ថកិច្ចនៅតាមព្រំដែន ដើម្បីរួចផុតពីការធ្វើចត្តាឡីស័ក ) ។

នៅក្រុងប៉ោយប៉ែត ជនសង្ស័យជាមេខ្យល់០១នាក់ បាននាំពលករ០១នាក់ឆ្លងដែនទៅថៃ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៩១១ ឃាត់នៅចំណុចដើមស្នួល ប៉ុស្តិ៍បឹងសាគូ ភូមិទំនប់ក៥ សង្កាត់ប៉ោយប៉ែត ក្រុងប៉ោយប៉ែត ឈ្មោះ លី លីន ភេទប្រុស អាយុ៣៤ឆ្នាំ ស្នាក់នៅភូមិព្រៃគប់ សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរងទទួលផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានបញ្ជាក់ថា៖ ដោយផ្អែកលើចម្លើយបំភ្លឺរបស់ជនរងគ្រោះជាពលករ និងចម្លើយសារភាពរបស់ជនសង្ស័យជាមេខ្យល់ ។ ជនសង្ស័យប្រុស ស្រី ចំនួន០៧នាក់ ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បញ្ជូនខ្លួនទៅសាលាដំបូងខេត្តចាត់ការតាមផ្លូវច្បាប់ហើយដែរ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃចន្ទ ទី០១ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៦៦នាក់ ស្រី ២៩នាក់ ក្នុងនោះកុមារា ៨នាក់ កុមារី ៧នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៤នាក់ ស្រី ៦នាក់ កុមារា ២នាក់ កុមារី ២នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៨នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ១នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣៤នាក់ ស្រី ១៧នាក់ កុមារា ៥នាក់ កុមារី ៤នាក់។

៥- ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៣២នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ៣៤នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ដោយ៖ ធូ កុសល

# អាជ្ញាធរស្រុកមោងឫស្សី រកឃើញពលករលួចឆ្លងដែនខុសច្បាប់ជាង ១០០នាក់ គេចវេះ ការធ្វើចត្តាឡីស័ក

http://btv.com.kh/ 01/03/2021

បាត់ដំបង ៖ ពលករលួចឆ្លងដែនខុសច្បាប់ ភាគច្រើនចេញតាមច្រកព្រំដែនជាប់ខេត្តប៉ៃលិន ជាង ១០០ នាក់ បានគេចវេះធ្វើចត្តាឡីស័ក ធ្វើដំណើរមកដល់ទីកន្លែងកំណើត នៅស្រុកមោងឫស្សី ខេត្តបាត់ដំបង ប៉ុន្តែត្រូវបានអាជ្ញាធរដឹង និងនាំទៅធ្វើចត្តាឡីស័កវិញ ដើម្បីទប់ស្កាត់កាឆ្លងរាលដាលនៃជំងឺកូវីដ១៩ ចូលទៅក្នុងសហគមន៍កាន់តែខ្លាំង ។

លោក ទេព ហន អភិបាលស្រុកមោងឫស្សី បានប្រាប់តាមទូរស័ព្ទ នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ថា ចាប់ពីទី ២២ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២១ មានពលករលួចឆ្លងដែនមិនបានធ្វើចត្តាឡីស័ក ពីតំបន់ព្រំដែនមកដល់ស្រុកមោងឫស្សីចំនួន ៩២ នាក់ ភាគច្រើនឆ្លងដែនតាមច្រកព្រំដែន ខេត្តប៉ៃលិន ហើយគេចវេះមិនព្រមធ្វើចត្តាឡីស័កនៅទីនោះ ។ លោកអភិបាលស្រុក បន្ថែមថា ដោយឡែកកាលពីថ្ងៃទី២៨ ខែកុម្ភៈ អាជ្ញាធរស្រុក និងមន្ត្រីសុខាភិបាល ក៏បាននាំពលករចំនួន៩នាក់ទៀត ស្រី៦នាក់ រស់នៅភូមិអង្រ្គង ឃុំជ្រៃ ដែលបានធ្វើដំណើរតាមច្រកព្រំដែនជាប់ខេត្តប៉ៃលិន គេសវេះ ការធ្វើចត្តាឡីស័ក ដើម្បីនាំពួកគេឲ្យមកអនុវត្តតាមវិធានការសុខាភិបាល ក្នុងការទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ។

តាមការសាកសួរព័ត៌មាន ពលករបានឆ្លើយប្រាប់អាជ្ញាធរថា ពួកគេមិនមានមេខ្យល់ណានាំនោះទេ ដោយសារពួកគេធ្វើការចេញចូលតាមច្រករបៀងក្បែរច្រកអន្តរជាតិព្រំ ខេត្តប៉ៃលិន នោះយូរស្គាល់ផ្លូវច្បាស់ ទើបអាចគេចវេះពីភ្នែកសមត្ថកិច្ចដែលឈរជើងនៅតំបន់ព្រំដែននោះបាន និងអាចជិះឡានតាក់ស៊ី និងម៉ូតូឌុបមកដល់ស្រុកកំណើត ។

គួរបញ្ជាក់ថា ចាប់ពីមានការផ្ទុះឆ្លងរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ១៩ ក្នុងខេត្តសាមុទសាខន ប្រទេសថៃ មានពលករឆ្លងដែនពីថៃ តាមច្រកនានាជាប់ខេត្តបាត់ដំបង កើនដល់ជិត ១ម៉ឺននាក់ បានបញ្ចប់ចត្តាឡីស័ក និងអនុញ្ញាតឱ្យត្រឡប់ទៅផ្ទះជាង៦០៩៥នាក់ កំពុងនៅក្នុងមណ្ឌលចត្តាឡីស័ក ជាង៣៥០០នាក់ ខណៈកំណើតពលករឆ្លងដែនពីថៃ កាន់តែច្រើនឡើងនោះ អាជ្ញាធរខេត្តបាត់ដំបង កំពុងរៀបចំមណ្ឌលចត្តាឡីស័កបន្ថែមទៀតផងដែរ ៕

# ឆ្លងព្រំដែនតាមច្រកណាក៏ត្រូវតែធ្វើចត្តាឡីស័ក១៤ថ្ងៃសិន

https://kohsantepheapdaily.com.kh/ Banteay Meanchey ០២ ខែ មីនា ឆ្នាំ ២០២១ ម៉ោង ០៨:៥០

ខេត្តបន្ទាយមានជ័យ៖ យាយនិងចៅ២នាក់ត្រូវបានសមត្ថកិច្ចចម្រុះរួមមាននគរបាលការពារព្រំដែនគោក និងយោធាកងពលតូចលេខ៥១ ឈរជើងនៅបន្ទាត់ព្រំដែនក្នុងភូមិក្បាលស្ពាន១សង្កាត់ និងក្រុងប៉ោយប៉ែត ឃាត់យកទៅធ្វើចត្តាឡីស័កនៅព្រឹកថ្ងៃទី០១ មីនា ២០២១ ក្រោយពួកគាត់ទាំង២នាក់វិលត្រឡប់ពីទឹកដីថៃតាមច្រករបៀង។ ពួកគាត់ទាំង២នាក់ខាងលើ ម្នាក់ឈ្មោះស៊ូ ម៉េន អាយុ៥៨ឆ្នាំ និងម្នាក់ទៀតឈ្មោះរ៉ា រីអាយុ១៥ឆ្នាំ (ជាយាយនិងចៅ) រស់នៅភូមិព្រៃព្រិចសង្កាត់ប៉ោយប៉ែត។

លោកវរសេនីយ៍ត្រីរស់ពិសិដ្ឋនាយប៉ុស្តិ៍បឹងសាគូនៃនគរបាលការពារព្រំដែនគោកលេខ៩១១ប្រាប់ថា យោងការសាកសួរស្ត្រីចំណាស់ខាងលើ ប្រាប់ថាគាត់និងចៅទើបវិលមកពីធ្វើការនៅផ្សាររុងក្លឿ(រើសអេតចាយ)។ ក្រោយ

សាកសួរយាយនិងចៅទាំង២នាក់ត្រូវបានកម្លាំងចម្រុះប្រគល់ឲ្យជំនាញដឹកតាមរថយន្តយោធាយកទៅសាលាបឋមសិក្សាព្រហ្មនិមិត្ត ដើម្បីឲ្យធ្វើចត្តាឡីស័កតាមវិធានការរបស់ក្រសួងសុខាភិបាល១៤ថ្ងៃ ៕

## មានបងប្អូនពលករខ្មែរនិយាយប្រាប់ខ្ញុំថា ពួកគាត់ជាង៣០នាក់ត្រូវខាងរោងចក្រគេអត់ដំណើរការតវីសាអោយ

https://www.facebook.com/PheaktraFanClub/ 01-03-2021

មើលជាតួយ៉ាង៖ មានបងប្អូនពលករខ្មែរនិយាយប្រាប់ខ្ញុំថា ពួកគាត់ជាង៣០នាក់ត្រូវខាងរោងចក្រគេអត់ដំណើរការតវីសាអោយ ដោយលើកហេតុផលថាពួកគាត់ជាមេប៉ះបោរនាំពលករបាតុកម្មកាលពីឆ្នាំមុន ចុងក្រោយត្រូវគេបោះបង់ចោល ។

សំណួរសួរថា៖តើផលប្រយោជដែលពួកគាត់ជាង៣០នាក់នេះទាមទារអោយពលករដ៏ទៃទៀតរាប់ពាន់នាក់ដែលរងការគៀបសង្កត់កាលពីលើកមុននោះ ទទួលបានដំណោះស្រាយនោះជារឿងខុសឬ បានជាធ្វើបាបពួកគាត់ដូច្នេះ..? ហឹ! នេះហើយហេតុផលដែលពលករខ្មែរភាគច្រើនមិនចង់នាំរឿងដាក់ខ្លួន ធ្វើដើម្បីប្រយោជន៍រួមប៉ុន្តែត្រូវរងគ្រោះតែម្នាក់ឯង នេះហើយជីវិតស្រុកថៃបងប្អូនធ្វើល្អមិនសូវបានទទួលផលល្អទេ សុខចិត្តធ្វើឆ្កួតធ្វើឡប់ទើបនៅបានសុខ ។ ស៊ូស៊ូបងប្អូននៅថៃ ភក្ត្រា ពលករខ្មែរ

## ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១

### ឃាត់ពលរដ្ឋ១៦នាក់លួចឆ្លងដែនខុសច្បាប់ទៅកាប់ឈើក្រញូងក្នុងទឹកដីថៃ

https://www.rasmeinews.com/ 3 March, 2021

ដោយៈមុនីរ័ត្ន/ភ្នំពេញៈ អាជ្ញាធរមានសមត្ថកិច្ចខេត្តឧត្តរមានជ័យ បានឃាត់ប្រជាពលរដ្ឋចំនួន ១៦នាក់លួចឆ្លងដែនខុសច្បាប់ទៅកាប់ឈើក្រញូងក្នុងទឹកដីថៃ នៅថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១នេះ ។ ប្រជាពលរដ្ឋចំនួន ១៦នាក់ (ប្រុសទាំងអស់) លួចឆ្លងដែនខុសច្បាប់ទៅកាប់ឈើក្រញូងក្នុងទឹកដីថៃ មានដូចជា :

១~ឈ្មោះនឿន រដ្ឋា អាយុ២៦ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ បានឡើងកាប់ឈើចំនួន១ដង។

២~ឈ្មោះខុង ប៊ុន អាយុ៣៣ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៣~ឈ្មោះផា ភត់ អាយុ៣៣ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជុំ ឃុំត្រពាំងតាវចាស់ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៤~ឈ្មោះផា ផាន់នី អាយុ១៦ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជុំ ឃុំត្រពាំងតាវចាស់ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៥~ឈ្មោះរត្ន ថា អាយុ១៧ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិសាមគ្គី ឃុំត្រពាំងប្រិយ៍ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៦~ឈ្មោះយូ ឡោះ អាយុ៣៣ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៧~ឈ្មោះរើន សារឿន អាយុ៣៣ឆ្នាំ មុខរបរកសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៨~ឈ្មោះណុក ណាង អាយុ២៥ឆ្នាំ មុខរបរកសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

៩~ឈ្មោះវន សាន អាយុ២៨ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិសាមគ្គី ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១០~ឈ្មោះមាឃ វ៉ាក់ អាយុ៥៥ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១១~ឈ្មោះសាយ សុខ អាយុ២២ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១២~ឈ្មោះណាប់ ធឿម អាយុ៣៣ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិជើងភ្នំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១៣~ឈ្មោះវង្ស គុណ អាយុ៣៨ឆ្នាំ មុខរបរ កសិករ ទីលំនៅបច្ចុប្បន្នភូមិឈើក្រំ សង្កាត់កូនក្រៀល ក្រុងសំរោង ខេត្តឧត្តរមានជ័យ។

១៤~ឈ្មោះឈឿន បូឡា អាយុ ៣១ឆ្នាំ មុខរបរ កម្មករសំណង់ ទីលំនៅបច្ចុប្បន្នភូមិអភិវឌ្ឍន៍ ឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១៥~ឈ្មោះសយ ឡុញ អាយុ ៣១ឆ្នាំ មុខរបរ រត់ម៉ូតូឌុបទីលំនៅបច្ចុប្បន្នភូមិអូរជញ្ជៀនឃុំអន្លង់វែង ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។

១៦~ឈ្មោះហួត លាងវែង អាយុ ៤២ឆ្នាំ មុខរបរ រត់ម៉ូតូឌុបទីលំនៅបច្ចុប្បន្នភូមិទឹកជុំ ឃុំត្រពាំងប្រិយ៍ ស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ៕

## នគរបាលការពារព្រំដែនគោកលេខ៨១៧ ស្រុកសំពៅលូន ទទួលពលរដ្ឋខ្មែរ១០នាក់មកពីប្រទេសថៃ បញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២

http://cambodiapolice.com/policekh/ 8:20 pm 2 มีนา 2021

ខេត្តបាត់ដំបង ៖ ដោយតាមការចង្អុលបង្ហាញពី លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការពង្រឹងសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនគោក នៅអង្គារ ៤រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០២ ខែមីនា ឆ្នាំ២០២១ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនគោកគីឡូ៩ និងប៉ុស្តិ៍ព្រំដែនគោកកូនភ្នំ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ស្រុកសំពៅលូន បានសហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន និងកម្លាំងយោធាវរសេនាតូចលេខ១ បានទទួលប្រជាពលរដ្ឋត្រឡប់ពីប្រទេសថៃចូលមកប្រទេសកម្ពុជាវិញ ចំនួន១០នាក់ (ស្រី៦នាក់) ក្នុងនោះត្រង់ចំណុចភូមិសាស្ត្រភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន៣នាក់ ស្រី១នាក់ ត្រង់ចំណុចភូមិសាស្ត្រភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន១នាក់ (ស្រី) និងត្រង់ចំណុចភូមិសាស្ត្រភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន៦នាក់ (ស្រី៤នាក់) ។ បន្ទាប់ពីធ្វើការសាកសួរកត់ត្រា ឈ្មោះ និងធ្វើការអប់រំណែនាំរួចកម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ ៣២ ៕

## កម្លាំងស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង សហការជាមួយកម្លាំងយោធា ស្រុកសំពៅលូន ទទួលប្រជាពលរដ្ឋត្រឡប់ពីប្រទេសថៃមកប្រទេសកម្ពុជាវិញ ត្រង់ចំណុចភូមិសាស្ត្រពោធិ៍ជ្រៃ

http://cambodiapolice.com/policekh/ 9:27 am 2 มีนา 2021

ខេត្តបាត់ដំបង ៖ ដោយបានការអនុញ្ញាតពី លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង និងលោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨ ១៧ បានចាត់តាំង លោកអនុសេនីយ៍ទោ ម៉ឹង ម៉េត នាយប៉ុស្ថិ៍ស្តីទី ប៉ុស្ថិ៍នគរបាលព្រំដែនគោកលេខគីឡូ ១៣ ចំណុះឲ្យវរសេនាតូចនគរបាលព្រំដែនគោកលេខ ៨១៧ ដឹកនាំកម្លាំងសហការជាមួយកម្លាំងយោធាសឹករងស្រុកសំពៅលូន និងកម្លាំងយោធាវរសេនាតូច ៥៣៣ ទៅទទួលប្រជាពលរដ្ឋខ្មែរពីយោធាថៃអង្គភាពកងអនុសេនាធំ១៣០៥ ត្រឡប់មកប្រទេសកម្ពុជាវិញ ត្រង់ចំណុចភូមិសាស្ត្រពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ០៥នាក់ (ស្រី ០៣នាក់) ក្នុងនោះក្មេងស្រី ០១នាក់ ។ បន្ទាប់ពីធ្វើការសាកសួរកត់ត្រាឈ្មោះ និងធ្វើការអប់រំណែនាំរួចកម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ ៣២ ស្រុកសំពៅលូន ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី០២ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ១៩៤នាក់ ស្រី ៧៧នាក់ ក្នុងនោះកុមារ ១៥នាក់ កុមារី ៧នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៦១នាក់ ស្រី ២៦នាក់ កុមារ ៨នាក់ កុមារី ៣នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២២នាក់ ស្រី ៧នាក់ កុមារ ២នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១១១នាក់ ស្រី ៤៤នាក់ កុមារ ៥នាក់ កុមារី ៣នាក់។

៥-ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ សូមបញ្ជាក់៖ ពួកគាត់ទាំង ១៩៤នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៨៣នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន ១១១នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ដោយ៖ ធូ កុសល

# ក្រុមពលករមកពីប្រទេសថៃលើកឡើងថា អាជ្ញាធរបានយកចិត្តទុកដាក់យ៉ាងល្អ ពេលធ្វើចត្តាឡីស័ក

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០២១ វិទ្យុជាតិកម្ពុជា៖អត្ថបទ លោក ភី សុខ

បាត់ដំបង៖ ក្រុមពលករដែលកំពុងស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័ក តាមស្រុកជាប់ព្រំដែនជាច្រើន ដែលក្រុមការងារជួប សម្ភាសន៍ បានបង្ហាញពីស្ថានភាពនៃការស្នាក់នៅក្នុងមណ្ឌលចត្តាឡីស័កថា មានកន្លែងស្នាក់នៅសមរម្យ និង របបអាហារគ្រប់គ្រាន់ ហើយបងប្អូនបានសុំកុំឱ្យពលករដែលមកពីប្រទេសថៃ គេចវេះពីមណ្ឌលចត្តាឡីស័កដើម្បីសុវត្ថិភាព ទាំងអស់គ្នា។

លោក ថន ជាពលករម្នាក់ទើបត្រឡប់មកពីថៃមានស្រុកកំណើតនៅខេត្តពោធិ៍សាត់បានឱ្យដឹងថា លោកមាន បងប្អូន៥នាក់ កំពុងធ្វើចត្តាឡីស័ក ក្នុងមណ្ឌលវិទ្យាល័យ ស្រុកកំរៀង ១៣ ថ្ងៃមកហើយ នឹងបានទទួលការធ្វើតេស្តឈាម លើកទី១ គឺអវិជ្ជមានកូវីដ-១៩ទាំងអស់គ្នា។ លោកបន្តថា លោកបានធ្វើការបេះផ្លែឈើ នៅខេត្តចាន់បូរីប្រទេសថៃ ហើយដោយអស់ការងារនៅទីនោះ ក៏បានត្រឡប់មក ស្រុកវិញជុំគ្នាចំនួន៩៤នាក់ តម្រង់មកច្រកព្រំដែន គឺច្រកទ្បែម ក្នុងគោលបំណងឱ្យតម្រួតថៃនិងសមត្ថកិច្ចខ្មែរតាមព្រំដែន បញ្ជូនពួកខ្លួនមកធ្វើចត្តាឡីស័កដោយស្មគ្រ័ចិត្ត ។ លោកក៏ដូចជាអ្នកផ្សេងទៀត បានបង្ហាញពីមូលហេតុដែលខ្លួនស្ម័គ្រចិត្តដោយមិនគេចវេះពីការធ្វើចត្តាឡីស័កនេះ ដោយសារ តែមិនចង់ឱ្យមានការឆ្លងរាលដាលជំងឺកូវីដ-១៩ដល់គ្រួសារនិងបងប្អូនក្នុងភូមិណាមួយ និងខ្លាចមានទោសដែលត្រូវផាកពិន័យ ពី១លានរៀលទៅ៥លានរៀលផង ។ លោកបាននិយាយថា ការស្នាក់នៅធ្វើចត្តាឡីស័កក្នុងមណ្ឌលមានការហូបចុកសមរម្យ១ថ្ងៃអាហារបីពេល មានមុងខ្នើយកួយ សម្ភារប្រើប្រាស់អាជ្ញាធរបើកឱ្យ និងមានការពិនិត្យសុខភាពដោយមិនអស់ថវិកាជាដើម។

លោក ញ៉ែម ផល មានស្រុកកំណើតនៅខេត្តតាកែវ ទើបត្រឡប់មកពីថៃបានឱ្យដឹងដែរថា គ្រួសារគាត់មានគ្នា៥នាក់ ស្ម័គ្រចិត្តឱ្យតម្រួតថៃដឹកមកស្រុកខ្មែរ ដល់ច្រកអូរអន្លក់ និងសមត្ថកិច្ចខ្មែរដឹកបន្តមកផ្លូវ ចាន់គីរី ហើយបានមកធ្វើចត្តាឡីស័ក នៅមណ្ឌលវិទ្យាល័យកំរៀងដោយស្ម័គ្រចិត្ត។ ក្នុងអំឡុងធ្វើចត្តាឡីស័កក្នុងមណ្ឌល គឺមានភាពងាយស្រួលទាំងស្នាក់នៅ ហូបចុក ទោះបីមិនដូចនៅផ្ទះរបស់យើងក៏ដោយតែអាចទទួលយកបាន។ ពលកររូបនេះបានថ្លែងអំណរគុណដល់ប្រមុខរាជរដ្ឋាភិបាលដែលគិតគូរសុខទុក្ខដល់ពលករ ដែលស្នាក់នៅធ្វើចត្តាឡីស័ក ។

គួរបញ្ជាក់ថា ចាប់ពីមានការផ្ទុះឆ្លងរីករាលដាលក្នុងសហគមន៍នៃជំងឺកូវីដ-១៩ ក្នុងខេត្តសាមុតសាខនប្រទេសថៃ មានពលករឆ្លងដែនពីថៃ តាមច្រកនានាជាប់ខេត្តបាត់ដំបង កើនដល់ជិត១ម៉ឺននាក់ បានបញ្ចប់ចត្តាឡីស័ក និងអនុញ្ញាត ឱ្យត្រឡប់ទៅផ្ទះជាង៦០៩៥នាក់ និង កំពុងនៅក្នុងមណ្ឌលចត្តាឡីស័ក ជាង៣៥០០នាក់ ៕

## ថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១

# អាជ្ញាធរគ្រោងបង្កើតមណ្ឌលធ្វើចត្តាឡីស័កបន្ថែមទៀត ខណៈពលករសម្រុកចេញពីប្រទេសថៃកាន់តែច្រើន តាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ខេត្តឧត្តរមានជ័យ

http://www.freshnewsasia.com/ 2021-03-03 12:16pm

**(ឧត្តរមានជ័យ)៖** លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានថ្លែងប្រាប់ភ្នាក់ងារព័ត៌មាន Fresh News នៅព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ថា អាជ្ញាធរខេត្តឧត្តរមានជ័យគ្រោងបង្កើតមណ្ឌលធ្វើចត្តាឡីស័កបន្ថែមទៀត ខណៈបច្ចុប្បន្ននេះបងប្អូនពលករកំពុងសម្រុកចាកចេញពីប្រទេសថៃ តាមច្រកព្រំដែនអន្តរជាតិអូរស្មាច់ មានចំនួនកាន់តែច្រើនឡើងៗ។ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានថ្លែងទៀតថា នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១កន្លងទៅនេះ ពលករចូលមកតាមច្រកអន្តរជាតិអូរស្មាច់មានចំនួន ៤៥០នាក់ ដោយឡែកនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០២១ ពលករចូលមកតាមច្រកអន្តរជាតិអូរស្មាច់

មានចំនួន ៤៣០នាក់ និងនៅថ្ងៃទី២ ខែមីនា ពលករចូលមកមានចំនួន៥៣០នាក់បន្ថែមទៀត។ លោកថា កត្តាដែលនាំឲ្យពលករសម្រុកចូកមកច្រើនបែបនេះ ដោយសារកត្តាទី១ ពួកគាត់អត់មានការងារធ្វើក្នុងប្រទេសថៃ និងកត្តាទី២ បុណ្យចូលឆ្នាំប្រពៃណីជាតិជិតមកដល់ ដូច្នេះពួកគាត់ចង់មកជួបជុំក្រុមគ្រួសារផងដែរ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានថ្លែងយ៉ាងដូច្នេះទៀតថា «**ចាប់តាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ស្របពេលដែលប្រទេសថៃផ្ទុះជំងឺកូវីដ១៩ខ្លាំង រហូតមកដល់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១នេះ បងប្អូនពលករដែលចាកចេញ ពីប្រទេសថៃ និងបានធ្វើចត្តាឡីស័កនៅតាមមណ្ឌលនានាទូទាំងខេត្តមានចំនួនសរុប ១៣៩២៣នាក់ ក្នុងនោះបានធ្វើចត្តាឡីស័ករួចមានចំនួន ៩៥៨៤នាក់ និងកំពុងធ្វើចត្តាឡីស័កមានចំនួន៤៣៣៩នាក់ ចំពោះមណ្ឌលធ្វើចត្តាឡីស័ក ដែលបានរៀបចំគឺមានចំនួន២៣មណ្ឌល**»។ លោកប្រធានមន្ទីរបានថ្លែងទៀតថា ម្សិលមិញលោក ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ បានដឹកនាំក្រុមការងារចុះពិនិត្យមើលការរៀបចំមណ្ឌលធ្វើចត្តាឡីស័ក នៅក្នុងបរិវេណពហុកីឡដ្ឋានខេត្ត ដើម្បីដឹកជញ្ជូនបងប្អូន ពលករមកស្នាក់នៅធ្វើចត្តាឡីស័កនៅទីនេះ។ លោកថា មណ្ឌលចត្តាឡីស័កនៅពហុកីឡដ្ឋានខេត្ត មិនអាចដាក់បងប្អូនពលករអស់ដែរ ដោយមានការណែនាំពីលោកអភិបាលខេត្ត ពេលនេះក្រុមការងារកំពុងរៀបចំមណ្ឌលធ្វើចត្តាឡីស័កមួយកន្លែងទៀតនៅស្រុកអន្លង់វែង៕

## អាជ្ញាធរចុះប្រតិបត្តិការ ត្រួតពិនិត្យផ្ទៃសមុទ្រដើម្បីការពារកូវីដ១៩ ចូលក្នុងសហគមន៍ ទប់ស្កាត់ការលួចឆ្លងដែនមកពីថៃ

http://www.freshnewsasia.com/ 2021-03-03 12:32pm

**(កោះកុង)៖** ដើម្បីការពារការរីករាលដាលជំងឺឆ្លងកូវីដ១៩ កុំឲ្យមានការឆ្លងចូលក្នុងសហគមន៍នៅយប់ថ្ងៃទី២ ខែមីនា ឆ្នាំ២០២១ លោក សុវណ្ណ ប៊ុនធឿន ប្រធានទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិចាំយាមខេត្តកោះកុង និងជាសមាជិកគណៈបញ្ជាការឯកភាពខេត្ត បានដឹកនាំកងកម្លាំងសមត្ថកិច្ច ចុះប្រតិបត្តិការល្បាតលើផ្ទៃសមុទ្រ ដើម្បីត្រួតពិនិត្យទៅលើទូកប្រជានេសាទ ដែលធ្វើនេសាទលើផ្ទៃសមុទ្រជាប់គ្នារវាងខេត្តកោះកុង-ខេត្តត្រាត ដើម្បីពិនិត្យក្រែងមានពលករចំណាកស្រុកលួចឆ្លងដែនចូលស្រុកដោយខុសច្បាប់។ លោក សុវណ្ណ ប៊ុនធឿន បានឲ្យដឹងថា ការចុះប្រតិបត្តិការល្បាតលើផ្ទៃសមុទ្រ ដើម្បីកុំឲ្យមានការរីករាលដាលនៃជំងឺកូវីដ១៩ ឆ្លងចូលក្នុងសហគមន៍ និងអនុវត្តន៍ទៅតាមបទបញ្ជារបស់រាជរដ្ឋាភិបាល ឲ្យធ្វើការត្រួតពិនិត្យឲ្យបានតឹងរឹងទាំងផ្លូវទឹក និងផ្លូវគោក ដែលពលករចំណាកស្រុកលួចឆ្លងដែនខុសច្បាប់តាមច្រកធម្មជាតិ និងធ្វើដំណើរតាមផ្លូវទឹកវិលចូលស្រុកកំណើតវិញ ដែលគេចវេសពីការធ្វើចត្តាឡីស័ករបស់ក្រុមលោកគ្រូពេទ្យរយៈ ១៤ថ្ងៃ។

លោក សុវណ្ណ ប៊ុនធឿន បានឲ្យដឹងបន្តថា ដើម្បីសុខភាពប្រជាពលរដ្ឋយើងទាំងអស់ សមត្ថកិច្ចទាំងការពារផ្លូវទឹក ទាំងផ្លូវគោក ត្រូវរឹតបណ្តឹងត្រួតពិនិត្យឲ្យបានល្អ មិនត្រូវធ្វេសប្រហែសឡើយ ពីព្រោះជំងឺកូវីដ១៩ ពិបាកក្នុងគ្រប់គ្រងណាស់ ហេតុដូច្នេះយើងត្រូវរឹតបន្តឹងបន្ថែមទៀត ចំពោះពលករចំណាកស្រុកដែលគេចវេសពីការធ្វើចក្តាឡីស័ករយៈពេល១៤ថ្ងៃ។ លោកបានបន្ថែមថា ពលករចំណាកស្រុកមកពីប្រទេសថៃ វិលចូលស្រុកកំណើតវិញ រាជរដ្ឋាភិបាលមិនបានហាមឃាត់ទេ តែសូមឲ្យវិលត្រឡប់ចូលស្រុកដោយស្របច្បាប់ តាមច្រកទ្វារអន្តរជាតិចាំយាម ស្ថិតក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង ដើម្បីឲ្យក្រុមគ្រូពេទ្យធ្វើតេស្ត និងចត្តាឡីស័ករយៈ១៤សិន ដើម្បីសុវត្ថិភាពសុខភាពប្រជាពលរដ្ឋទាំងអស់គ្នា។ លោកសូមឲ្យប្រជានេសាទ ដែលមានមុខរបរធ្វើនេសាទចូលរួមសហការជាមួយសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន កុំដឹកពលករចំណាកស្រុកលួចឆ្លងដែនខុសច្បាប់ឲ្យសោះ ហើយបើឃើញមានទូកលួចដឹកពលករ ចំណាកស្រុកឆ្លងខុសច្បាប់ សូមចូលរួមផ្តល់ព័ត៌មានឲ្យបានលឿនជូនសមត្ថកិច្ច ឬអាជ្ញាធរមូលដ្ឋាន ដើម្បីការពារការរីករាលដាលចូលក្នុងសហគមន៍ ហើយសូមបងប្អូនប្រជាពលរដ្ឋ ត្រូវអនុវត្តន៍តាមការណែនាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល «៣កុំ និង៣ការពារ»៕

## មន្ត្រីៈ ពលករ សម្រុកចូលស្រុក នៅពេលអត់មានការងារធ្វើ និងបុណ្យចូលឆ្នាំខ្មែរ ជិតមកដល់

https://www.rasmeinews.com/ 3 March, 20210

**ដោយៈ អូរស្មាច់ / ឧត្តរមានជ័យៈ** *មន្ត្រីនៃមន្ទីរសុខាភិបាល ខេត្តឧត្តរមានជ័យ បានឲ្យ ដឹងថាៈ ពលករកម្ពុជា បានសម្រុកចូលស្រុក នៅប្រកព្រំដែន ក្នុងខេត្តឧត្តរមានជ័យ មានចំនួនកាន់តែច្រើន ។ ការសម្រុកចូលច្រើនបែបនេះ ដោយសារពួកគាត់មិនមាន ការងារធ្វើ នៅក្នុងប្រទេសថៃ និងជិតដល់ថ្ងៃបុណ្យ ចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរ។*

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ទីប្រឹក្សាក្រសួងសុខាភិបាល និងជាប្រធានមន្ទីរសុខភិបាល ខេត្តឧត្តរមានជ័យ បានឲ្យដឹង នៅថ្ងៃទី៤ ខែមីនានេះថា ពលករកម្ពុជាបានសម្រុកចេញ ពីប្រទេសថៃ ចូលមកស្រុកកំណើតវិញ នៅប្រកអូរស្មាច់ព្រំដែន ក្នុងខេត្តឧត្តរមានជ័យ មានចំនួនកាន់តែច្រើន។ ពលករ សម្រុកចូលមក ច្រើនបែបនេះ ដោយបច្ចុប្បន្ន ពួកគាត់ អត់មានការងារធ្វើ ក្នុងប្រទេសថៃ និងជិតដល់ថ្ងៃបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិ ក្នុងគោលបំណង បានជួបជុំក្រុមគ្រួសារ ផងដែរ។ លោកវេជ្ជបណ្ឌិត បានបន្តថាៈ បច្ចុប្បន្ន មានពលករកម្ពុជា បានចូលមក តាមប្រក អន្តរជាតិអូរស្មាច់ ពីចន្លោះជាងចំនួន ៤០០ ទៅជាង ៥០០ នាក់ ក្នុងមួយថ្ងៃ ហើយអាជ្ញាធរ ខេត្តឧត្តរមានជ័យ គ្រោងរៀបចំបង្កើត មណ្ឌលធ្វើចត្តាឡីស័ក បន្ថែមទៀត។ លោកវេជ្ជបណ្ឌិត ឃ្លោក ហួត បានបញ្ជាក់ថាៈ ចាប់តាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ស្របពេលដែលប្រទេសថៃ ផ្ទុះជំងឺកូវីដ.១៩ ខ្លាំង រហូតមកដល់ថ្ងៃនេះ ពលករប្រុស ស្រី ដែលបានចាកចេញ ពីប្រទេសថៃ និងបានធ្វើចត្តាឡីស័ក នៅតាមមណ្ឌលនានាទូទាំង ខេត្តមានចំនួនសរុប ១៣.៩២៣ នាក់ ក្នុងនោះ បានធ្វើចត្តាឡីស័ករួច មានចំនួន ៩.៥៨៤ នាក់ និងកំពុងធ្វើចត្តាឡីស័ក មានចំនួន ៤.៣៣៩ នាក់ លើទីតាំងមណ្ឌលធ្វើចត្តាឡីស័ក ដែលបានរៀបចំរួច មានចំនួន ២៣ មណ្ឌល ៕/V-PC

## មន្ត្រីសង្គមស៊ីវិលស្នើឱ្យសមត្ថកិច្ចចាត់វិធានការតាមផ្លូវច្បាប់ចំពោះមេខ្យល់នាំពលករឆ្លងដែនទៅក្រៅប្រទេស

https://www.rfa.org/ ហេង រស្មី 2021-03-03

មន្ត្រីសង្គមស៊ីវិលដែលឃ្លាំមើលពលករចំណាកស្រុក ស្វាគមន៍ចំពោះវិធានការណ៍របស់សមត្ថកិច្ចដែលមានគម្រោងចាប់បញ្ជូនមេខ្យល់នាំពលករខ្មែរចេញ និងចូលទៅប្រទេសវៀតណាម និងប្រទេសថៃ ទៅជំនុំជម្រះទោស។ តែពួកគេស្នើសុំឱ្យអាជ្ញាធររដ្ឋាភិបាលគួរតែមានវិធានការណ៍នេះជាប្រចាំ កុំចាំតែធ្វើឡើងក្រោយពីមានបញ្ជារបស់លោក ហ៊ុន សែន។

មន្ត្រីអង្គការសង់ត្រាល់(Central)ទទួលបន្ទុកសិទ្ធិការងារលោក ឌី ថេហូយ៉ា មានប្រសាសន៍ថា សកម្មភាពនៃការនាំមនុស្សទៅក្រៅប្រទេសមិនមែនកើតចេញពីប្រជាពលរដ្ឋធម្មតានោះទេ ភាគច្រើនគឺមេខ្យល់មានខ្នងបង្អែកដែលជាអ្នកមានអំណាចនៅពីក្រោយខ្នង។ លោកថា សមត្ថកិច្ចគួរតែមានសេចក្ដីក្លាហានក្នុងការចាប់បញ្ជូនខ្លួនមេខ្យល់ដែលមានខ្នងបង្អែកធំៗទាំងនោះទៅទទួលទោស ដើម្បីឱ្យមានភាពស្មើគ្នាចំពោះមុខច្បាប់។ លោកបន្តថា ការជួញដូរមនុស្សទៅកាន់ប្រទេសថៃ និង ទៅកាន់ប្រទេសចិនដោយឆ្លងកាត់ប្រទេសវៀតណាមនេះ សមត្ថកិច្ចត្រូវតែមានវិធានការណ៍ឱ្យបានតឹងរ៉ឹងទើបអាចលុបបំបាត់បាន៖«ការជួញដូរមនុស្សទៅថៃ ទៅម៉ាឡេស៊ី ទៅវៀតណាមនិងទៅចិនជាដើមនេះ ត្រូវរៀបចំលក្ខណៈឆ្លើយតបជាប្រព័ន្ធទើបអាចកាត់បន្ថយ និងលុបបំបាត់បាន ប៉ុន្តែប្រសិនជា គ្រាន់តែធ្វើផ្តើលម្តងម្កាលទេ។ ខ្ញុំគិតថា មិនមែនជាវិធានការណ៍ឆ្លើយតបឬលុបបំបាត់ទេ។ តែទោះជាយ៉ាងណាក៏ដោយប្រសិនបើមានការចាប់ផ្តើម យើងសារទរចំពោះវិធានការណ៍នោះ ហើយសង្ឃឹមថា វិធានការណ៍នេះ នឹងធ្វើជាបន្តបន្ទាប់ ហើយធ្វើឱ្យមានប្រសិទ្ធិភាពជាពិសេសឫសគល់ធំនៃការបង្កើតឱ្យមានអំពើជួញដូរហ្នឹងបាទ»។

សមត្ថកិច្ចកាលពីថ្ងៃទី ៣ មីនា គ្រោងចាប់បញ្ជូនមេខ្យល់នាំពលករខ្មែរឆ្លងដែនចំនួនជាង ១រយនាក់ទៅតុលាការខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប និងខេត្តឧត្តរមានជ័យ ក្រោយពីបាននាំពលករខ្មែរឆ្លងដែនដោយខុសច្បាប់ទៅធ្វើការនោះក្នុងប្រទេសថៃ ក្នុងពេលដែលកម្ពុជាកំពុងរាលដាលជំងឺកូវីដ ១៩។

អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិលោក ឆាយ គឹមឃឿន ប្រាប់អាស៊ីសេរីនៅថ្ងៃទី ៣ មីនា ថា សមត្ថកិច្ចចាប់មេខ្យល់សរុបចំនួន ១០៨ នាក់ គិតចាប់តាំងពីថ្ងៃទី១៣ ខែកុម្ភៈ រហូតមកដល់ដើមខែមីនានេះក្រោយពីបាននាំពលករឆ្លងដែនដោយខុសច្បាប់ចំនួន១៤០០ នាក់ទៅធ្វើការនៅក្នុងប្រទេសថៃ។ លោកថា សមត្ថកិច្ចមិនទាន់បញ្ជូនពួកគេទៅកាន់តុលាការភ្លាមៗទេ ដោយរង់ចាំការធ្វើចត្តាឡីស័ករយៈពេល ១៤ថ្ងៃជាមុនសិនៈ«ភាគច្រើនហ្នឹងគឺតុលាការខេត្តសាមី និងតុលាការនៅក្នុងខេត្តជាប់ព្រំដែនហ្នឹងតែម្តង។ភាគច្រើនជនសង្ស័យភាគច្រើននៅខេត្តជាប់ព្រំដែន បានគាត់ប្រកបមុខរបរល្មើសច្បាប់ហ្នឹងបានស្រួល ពីព្រោះគាត់ងាយស្រួលទាក់ទងទៅ មានមេខ្យល់ម្ខាងទៀតខាងភាគីថៃបណ្តាញរបស់គេ»។

ការចាប់ខ្លួនមេខ្យល់ជាបន្តបន្ទាប់នេះបានកើតមានឡើងក្រោយពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យកងកម្លាំងមានសមត្ថកិច្ចនៅជាប់ព្រំដែនកម្ពុជា-ថៃ និងប្រទេសវៀតណាម ទប់ស្កាត់ពលករខ្មែរដែលឆ្លងដែនដោយខុសច្បាប់ទៅក្រៅប្រទេស ឬពលករ វិលចូលស្រុកវិញដោយមិនបានធ្វើចត្តាឡីស័ក។

អនុប្រធានអង្គការលីកាដូទទួលបន្ទុកផ្នែកឃ្លាំមើលសិទ្ធិមនុស្សលោក អំ សំអាត មានប្រសាសន៍ថា សមត្ថកិច្ច កាលពីឆ្នាំមុនៗ មិនដែលឃើញចាប់ខ្លួនមេខ្យល់នាំពលករខ្មែរទៅក្រៅប្រទេសមកកាត់ទោសទេ ហើយទើបតែចាត់វិធានការក្រោយពីមានបទបញ្ជាលោក ហ៊ុន សែន។ លោកថា សមត្ថកិច្ចគួរតែអនុវត្តច្បាប់ជាប្រចាំដើម្បីទប់ស្កាត់ការនាំពលករខ្មែរចេញ និងចូលមកពីក្រៅប្រទេសៈ«អីចឹងករណីនេះយើងចង់ឱ្យទៅជាការអនុវត្តន៍ច្បាប់។ អ្នកដែលធ្វើខុសច្បាប់ត្រូវអនុវត្តន៍ទៅតាមផ្លូវច្បាប់ទៅ ដើម្បីកុំឱ្យមានការរិះគន់តទៅទៀត ហើយករណីនេះខ្ញុំមើលឃើញហើយថា ប្រសិនបើពុំមានករណីកូវីដ ហើយនិងការទប់ស្កាត់ការរីករាលដាលនៃការឆ្លងកូវីដ ១៩ទេគឺមន្ត្រីមួយចំនួននៅតាមព្រំដែនគឺអនុវត្តន៍ដូចពីមុនអីចឹង»។

របាយការណ៍ក្រសួងការងារថៃឱ្យដឹងថា គិតត្រឹមថ្ងៃទី៦ ខែកុម្ភៈ មានពលករខ្មែរជិត ១សែន ២ម៉ឺននាក់ហើយ (១១៩.៨១១) ដែលបានចុះឈ្មោះសុំសិទ្ធិធ្វើការស្របច្បាប់រួចរាល់។

មន្ត្រីសិទ្ធិការងារលោក ឌី ថេហូយ៉ា ឱ្យដឹងដែរថា ពលករខ្មែរធ្វើការងារនៅប្រទេសថៃមាន ១លាន ៨សែននាក់ ក្នុងនោះពលករធ្វើការខុសច្បាប់មានជាង ៤សែន(៤០០.០០០)នាក់។ មន្ត្រីសង្គមស៊ីវិលរូបនេះ ជឿថា ពលករខ្មែរជាង ២សែននាក់ នឹងក្លាយទៅជាពលករខុសច្បាប់ ហើយអាជ្ញាធរថៃ អាចនឹងចាប់បញ្ជូនពួកគាត់ត្រឡប់ទៅកម្ពុជាវិញ ឬចាប់ដាក់ពន្ធនាគារនៅពេលខាងមុខ។ លោកថា ដើម្បីដោះស្រាយបញ្ហានេះអាជ្ញាធរថៃគួរតែពន្យារពេលចុះឈ្មោះសុំសិទ្ធិធ្វើការទៅមុខមួយរយៈទៀត ហើយបញ្ចុះតម្លៃធ្វើប័ណ្ណការងារ ឱ្យបានទាបជាងពេលបច្ចុប្បន្ន។ បន្ថែមពីនេះ លោកជំរុញឲ្យរដ្ឋាភិបាលកម្ពុជានិងថៃចាត់វិធានលើក្រុមមេខ្យល់ ដែលរត់ការចុះឈ្មោះឱ្យពលករក្នុងតម្លៃថ្លៃលើសការកំណត់របស់អាជ្ញាធរថៃ៕

## COVID-19៖ ពលករពីថៃសះស្បើយអស់ហើយ ខណៈករណីសហគមន៍២០កុម្ភៈបន្តរាលដាល

https://thmeythmey.com/ 03, Mar 2021 , 11:39 am

គិតត្រឹមថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ នេះ របាយការណ៍ក្រសួងសុខាភិបាល បានបង្ហាញថា ពលករខ្មែរមកពីថៃទី៩០ បានជាសះស្បើយពីកូវីដ-១៩ ខណៈករណីពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ មាន២នាក់ដំបូងនៅខេត្តស្វាយរៀង ដែលសុទ្ធតែជាស្ត្រីជនជាតិវៀតណាម។

ចាប់តាំងពីចុងខែធ្នូ ឆ្នាំ២០២០ មក កម្ពុជាបានរកឃើញជាបន្តបន្ទាប់ករណីវិជ្ជមានកូវីដ-១៩ ក្នុងចំណោមពលករដែលត្រឡប់មកពីថៃ ពោលគឺក្នុងបណ្ដាខេត្តនៅតាមព្រំដែន រួមមានបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន និងឧត្ដរមានជ័យ។ ក្នុងចំណោមពលកររាប់ពាន់នាក់ ៩០នាក់ ត្រូវបានរកឃើញវិជ្ជមាន ហើយទទួលការព្យាបាលជាបន្តបន្ទាប់។ ករណីទី៩០ក្នុងចំណោមពលករដែលបានជាសះស្បើយនោះ គឺស្ត្រីអាយុ៥២ឆ្នាំ អាសយដ្ឋាននៅក្រុងតាខ្មៅ ខេត្តកណ្ដាល ដែលបានធ្វើដំណើរមកពីថៃ ហើយដល់កម្ពុជាកាលពីថ្ងៃទី៩ ខែកុម្ភៈ។ គាត់ត្រូវបានអនុញ្ញាតឲ្យចេញពីមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ក្រោយលទ្ធផលតេស្តអវិជ្ជមានកូវីដ-១៩ ចំនួន២លើក។

ផ្ទុយទៅវិញ ខណៈដែលករណីពលករមកពីថៃហាក់ដូចជាស្ងប់ស្ងាត់ ព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ បានផ្ទុះឡើង ដោយសម្ដេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ចេញមុខប្រកាស និងបញ្ជាឲ្យមានចំណាត់ការភ្លាមៗដើម្បីទប់ស្កាត់ការរាលដាលទ្រង់ទ្រាយធំ។ ករណីដែលកើតចេញពីការធ្វើចត្តាឡីស័កមិនបានត្រឹមត្រូវ បានធ្វើឲ្យចំនួនអ្នកឆ្លងមានរហូតដល់ទៅ៣៧៤នាក់ដោយគិតត្រឹមថ្ងៃទី៣ ខែមីនា នេះ។

ស្វាយរៀង បានក្លាយជាខេត្តទី៤ ដែលមានករណីសហគមន៍២០កុម្ភៈ។ ក្នុងសេចក្ដីជូនព័ត៌មានរបស់ខ្លួន ក្រសួងសុខាភិបាល មិនបានបញ្ជាក់លំអិតទាក់ទងនឹងស្ត្រីវៀតណាមទាំងពីរនោះឡើយ។ ក្រសួងបានបញ្ចូលទៅក្នុងតួលេខករណីសហគមន៍ ដោយបញ្ជាក់ថា ស្ត្រីទាំងពីរមានអាសយដ្ឋាននៅខណ្ឌចម្ការមន រាជធានីភ្នំពេញ ហើយតេស្តវិជ្ជមានពេលកំពុងចត្តាឡីស័កនៅសណ្ឋាគារមួយក្នុងខេត្តស្វាយរៀង។

អ្នកជំងឺពាក់ព័ន្ធព្រឹត្តិការណ៍សហគមន៍ ភាគច្រើនជាជនជាតិចិន បន្ទាប់មកមានវៀតណាម ខ្មែរ និងជាតិសាសន៍មួយចំនួនទៀត។ រាជធានីភ្នំពេញ និងខេត្តព្រះសីហនុ មានតួលេខកើនជាលំដាប់ រីឯខេត្តកណ្ដាល ក៏មានមួយចំនួនផងដែរ។ នៅភ្នំពេញ អ្នកជំងឺពាក់ព័ន្ធករណីសហគមន៍ភាគច្រើនត្រូវបានដាក់ឲ្យសម្រាកព្យាបាលនៅមណ្ឌលចត្តាឡីស័ករាជធានីភ្នំពេញ បន្ទាប់មកមាននៅមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន មណ្ឌលសុខភាពចាក់អង្រែ និងពេទ្យមិត្តភាពខ្មែរ-សូវៀត។ នៅមន្ទីរពេទ្យបង្អែកខេត្តព្រះសីហនុ មានអ្នកជំងឺ៦២នាក់ នៅមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្ដាលមាន២០នាក់ និងមន្ទីរពេទ្យខេត្តស្វាយរៀងមាន២នាក់។ ក្រៅពីនោះ អ្នកដំណើរចូលមកកម្ពុជាទាំងពលរដ្ឋខ្មែរ និងបរទេស មានវិជ្ជមាន៤១៤ករណី ហើយសះស្បើយ៣៩២នាក់។ នៅសាលារក្សាសន្តិភាពពហុសាស្ត្រកំពង់ស្ពឺ ក៏មានអ្នកជំងឺ៨នាក់ផងដែរកំពុងសម្រាកព្យាបាលដោយពួកគាត់ជាមន្ត្រីកងទ័ពមួកខៀវអង្គការសហប្រជាជាតិដែលទើបវិលត្រឡប់ពីបណ្ដាប្រទេសនៅអាហ្វ្រិក។

សរុបមកដល់បច្ចុប្បន្ន អ្នកកើតកូវីដ-១៩នៅកម្ពុជា ឡើងដល់៨៧៨នាក់ ក្នុងនោះ៤៨២នាក់បានជាសះស្បើយ។ ក្នុងចំណោមករណីវិជ្ជមានទាំងអស់ ជាង៤០០នាក់ជាជនជាតិខ្មែរ ជាង៣០០នាក់ជាជនជាតិចិន បន្ទាប់មកមានបារាំង វៀតណាម ឥណ្ឌូណេស៊ី ម៉ាឡេស៊ី និងអាមេរិក ដែលមានច្រើនជាង១០ករណី។ ក្រៅពីនេះ មានអ្នកជំងឺជាជនជាតិអង់គ្លេស ឥណ្ឌា បែលហ្ស៊ិក កាហ្សាក់ស្ថាន ប៉ូឡូញ ប៉ាគីស្ថាន ហុងគ្រី ណេប៉ាល់ ជប៉ុន ហ្សកដានី នីហ្សេរីយ៉ា ស្វីស ឆេក កូរ៉េខាងត្បូង និងសិង្ហបុរី៕

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ស្រុកសំពៅលូន សហការទទួលពលរដ្ឋត្រឡប់មកពីប្រទេសចំនួន៥នាក់ ប្រគល់ឲ្យគ្រូពេទ្យបញ្ជូនទៅមណ្ឌលធ្វើ ចត្តាឡីស័កនៅអនុវិទ្យាល័យភ្នំ៣២

https://cambodiapolice.com/policekh/ 5:37 pm 3 មីនា 2021

ខេត្តបាត់ដំបង ៖ លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង បានជំរុញឲ្យកម្លាំងនគរបាលវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ ស្ថិតក្នុងភូមិសាស្ត្រខេត្តបាត់ដំបង បន្តពង្រឹងសន្តិសុខតាមខ្សែបន្ទាត់ព្រំដែនគោកជាប្រចាំ ពិសេសត្រួតពិនិត្យមើលប្រជាពលរដ្ឋនិងមេខ្យល់ដឹកនាំពលរដ្ឋខុសច្បាប់។

ជាក់ស្តែងនៅថ្ងៃពុធ ៥រោច ខែផល្គុន ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៣ ខែ មីនា ឆ្នាំ២០២១ដែរ កម្លាំងនគរបាលប៉ុស្តិ៍ព្រំដែនគោកគីឡូ៩ និងប៉ុស្តិ៍ព្រំដែនគោកគីឡូ១៣ នៃវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ស្រុកសំពៅលូន បានសហការជាមួយកម្លាំងយោធាផ្នែកសឹករង ស្រុកសំពៅលូន និងកម្លាំងយោធាវរសេនាតូចលេខ៥៣៣ ទទួលប្រជាពលរដ្ឋខ្មែរត្រឡប់ពីប្រទេសថៃ មកប្រទេសកម្ពុជាវិញ ចំនួន៥នាក់ ស្រី ៣នាក់ (ក្មេងស្រីតូច១នាក់) ត្រង់ចំណុចភូមិសាស្រ្តភូមិគីឡូ៩ ឃុំជ្រៃសីមា ចំនួន២នាក់(ប្រុស)និងចំណុចភូមិសាស្រ្តភូមិពោធិ៍ ជ្រៃឃុំសិរីមានជ័យ ចំនួន៣នាក់ (ស្រី) ក្នុងនោះក្មេងស្រីតូច១នាក់ ស្រុកសំពៅលូន ។ បន្ទាប់ពីធ្វើការសាកសួរកត់ត្រាឈ្មោះ និងធ្វើការអប់រំណែនាំរួច កម្លាំងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី០៣ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ១២២នាក់ ស្រី ៣៦នាក់ ក្នុងនោះកុមារ ៧នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤៣នាក់ ស្រី ១៦នាក់ កុមារ ៤នាក់ កុមារី ៣នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២១នាក់ ស្រី ៣នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៥៨នាក់ ស្រី ១៧នាក់ កុមារ ០៣នាក់ កុមារី ១នាក់។

៥-ច្រកដូង ស្រុកកំរៀង÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៦៤នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យ ចំនួន ៥៨នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប ៖ ធូ កុសល

## ស្ថានទូតកម្ពុជា ប្រចាំម៉ាឡេស៊ី អំពាវនាវឲ្យពលករបញ្ឈប់ការ ធ្វើចំណាកស្រុក ដោយខុសច្បាប់ដែល អាចប្រឈមនឹងហានិភ័យខ្ពស់

https://dap-news.com/national/ ByKD102 Posted on March 4, 2021

**ភ្នំពេញ៖ ស្ថានឯកអគ្គរាជទូតកម្ពុជា ប្រចាំប្រទេសម៉ាឡេស៊ី បន្តជួយសម្របសម្រួល ជូនពលករ/ពលការិនីចំនួន៨នាក់ ដែលបានមករស់នៅ និងធ្វើការខុសច្បាប់នៅប្រទេសម៉ាឡេស៊ី បានវិលត្រឡប់ទៅកម្ពុជាវិញ ។ ពួកគាត់បានទៅដល់អាកាសយានដ្ឋាន អន្តរជាតិភ្នំពេញ តាមជើងយន្តហោះហើរ អាកាសចរណ៍សិង្ហបុរីលេខ SQ5008 កាលពីថ្ងៃទី៣ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ៥៖៣៥នាទី** ។ ជាមួយគ្នានោះស្ថានទូតកម្ពុជា ប្រចាំម៉ាឡេស៊ី អំពាវនាវឲ្យពលករបញ្ឈប់ការធ្វើចំណាកស្រុកដោយខុសច្បាប់ដែល អាចប្រឈមនឹងហានិភ័យខ្ពស់ ៕

# ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២១

## អាជ្ញាធរឃាត់ខ្លួនមេខ្យល់១០៨នាក់ ដែលនាំពលករឆ្លងដែនខុសច្បាប់ និងគេចវេះពីចត្តាឡីស័ក

https://thmeythmey.com/ 04, Mar 2021 , 8:29 pm

ភ្នំពេញ៖ លោក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិអះអាងថា មេខ្យល់១០៨នាក់ ត្រូវបានឃាត់ខ្លួន ដោយសារនាំពលករឆ្លងដែនខុសច្បាប់ និងគេចវេះពីការធ្វើចត្តាឡីស័ក។ បើតាមលោក ឆាយ គឹមខឿន ការឃាត់ខ្លួនមេខ្យល់១០៨នាក់ទាំងនេះ គឺគិតចាប់ពីថ្ងៃទី១៣កុម្ភៈ ដល់ថ្ងៃទី៣មីនា ឆ្នាំ២០២១នេះ។ លោកថា មេខ្យល់ទាំងនោះ គឺបាននាំពលករឆ្លងដែនខុសច្បាប់ រួមទាំងគេចពីចត្តាឡីស័ក ជាពិសេសចេញចូលប្រទេសថៃ។ អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិរូបនេះ ថ្លែងប្រាប់សារព័ត៌មានថ្មីៗនៅថ្ងៃទី៤ មីនាថា៖ «មេខ្យល់ជាង១០០នាក់នឹងត្រូវបញ្ជូនទៅតុលាការទាំងអស់ហ្នឹង គ្រាន់តែអ្នកមួយចំនួនបានបញ្ជូនទៅហើយ, អ្នកមួយចំនួនទៀតជាប់ធ្វើចត្តាឡីស័ក»។ ជាមួយគ្នានេះ លោក អំពាវនាវដល់ពលករទាំងអស់បញ្ឈប់ការឆ្លងដែនខុសច្បាប់ និងកុំព្យាយាមគេចវេះពីការធ្វើចត្តាឡីស័ក។

សូមជម្រាបថា អនុក្រឹត្យថ្មី បានចែងពីការពិន័យប្រាក់ពី១០លានរៀលដល់៥០លានរៀល លើអ្នកដែលនាំអ្នកដទៃ គេចវេះពីការធ្វើចត្តាឡីស័ក។ ចំពោះអ្នកដែលគេចវេះមិនចូលធ្វើចត្តាឡីស័ក និងអ្នកគេចចេញពីការធ្វើចត្តាឡីស័ក នឹងត្រូវពិន័យប្រាក់ពី១លានរៀលដល់៥លានរៀល។ គិតចាប់ពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២១ ពលរដ្ឋខ្មែរដែលវិលត្រឡប់ពីប្រទេសថៃវិញ មានជាង១,៨ ម៉ឺននាក់។ រយៈពេលដូចគ្នានេះ កម្ពុជាទទួលពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ពីអាជ្ញាធរថៃបានជាង១៣ពាន់នាក់។ នេះបើតាមរបាយការណ៍ដែលសារព័ត៌មានថ្មីៗ ( Thmey Thmey ) ទទួលបានពីលោក កែវ វណ្ណថន អគ្គនាយករងអន្តោប្រវេសន៍៕

## ក្មេងស្រីម្នាក់បានបង្ហោះសារសុំឱ្យជួយរំដោះចេញពីប្រទេសចិន

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2021-03-04

ជនរងគ្រោះ បានបញ្ជាក់នៅក្នុងវីដេអូឃ្លីប ដែលបានចែកចាយតៗ គ្នាតាមបណ្តាញសង្គមថា នាងត្រូវបានមេខ្យល់យកទៅលក់នៅកន្លែងរកស៊ីផ្លូវភេទមួយកន្លែងនៅក្នុងប្រទេសចិន តាំងពីអាយុ ១៥ឆ្នាំ ហើយត្រូវបានថៅកែបង្ខំឱ្យទទួលភ្ញៀវពីម្នាក់ទៅម្នាក់ជារៀងរាល់ថ្ងៃ។ នៅក្នុងវីដេអូឃ្លីបរយៈពេលជាងមួយនាទី ជនរងគ្រោះបានសុំអន្តរាគមន៍ពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីឱ្យបានវិលត្រឡប់ទៅជួបជុំក្រុមគ្រួសារនៅឯស្រុកត្បែងមានជ័យ ខេត្តព្រះវិហារវិញ៖ «ខ្ញុំសូមជម្រាបសួរអ្នកទាំងអស់គ្នា ខ្ញុំសូមលើកម្រាមដៃ១០ ឱ្យបងប្អូនខ្មែរជួយយកខ្ញុំទៅខ្មែរវិញផង។ ឱ្យអ្នកនៅខ្មែរឃើញវីដេអូហ្នឹងហើយជួយចែករំលែកឱ្យលោកជំទាវ ឱ្យសម្តេច ហ៊ុន សែន ឃើញ ឱ្យគាត់យកខ្ញុំទៅខ្មែរវិញផង។ ខ្ញុំចាញ់បោកមេខ្យល់យកមកលក់នៅប្រទេសចិន តាំងពីអាយុ១៥ឆ្នាំ ហើយអត់ឱ្យខ្ញុំទាក់ទងទៅអ្នកផ្ទះទេ»។

អាស៊ីសេរី បានព្យាយាមទាក់ទងទៅក្រុមគ្រួសារជនរងគ្រោះដើម្បីចង់ដឹងថា តើក្មេងស្រីរូបនោះ បានទៅរស់នៅក្នុងប្រទេសចិនប៉ុន្មានឆ្នាំហើយ ក្រោយពីនាងចាកចេញពីប្រទេសកម្ពុជាក្នុងវ័យ១៥ឆ្នាំនោះ ប៉ុន្តែនៅមិនទាន់អាចទាក់ទងក្រុមគ្រួសារនាងបាននៅឡើយ។

អ្នកនាំពាក្យក្រសួងការបរទេសលោក កុយ គួង បញ្ជាក់ថា លោកបានឃើញវីដេអូឃ្លីបនេះហើយៗ ក្រសួងការបរទេសទេសកំពុងចាត់វិធានការដើម្បីនាំយកក្មេងស្រីរងគ្រោះមកកាន់ប្រទេសកម្ពុជាវិញ៖ «ខ្ញុំបានបញ្ជូនវីដេអូឃ្លីបនេះទៅនាយកដ្ឋានពាក់ព័ន្ធទៅនាយកដ្ឋានក្រសួងការបរទេស ក៏ដូចជា ទៅស្ថានតំណាងក្រសួងការបរទេសចិន ដើម្បីធ្វើការស្រាវជ្រាវថា តើស្ថិតនៅក្នុងខេត្តណា ពីព្រោះនៅក្នុងវីដេអូនេះអត់មានបញ្ជាក់ទីកន្លែងច្បាស់

លាស់។ កាលណាអត់បញ្ជាក់អ៊ីចឹងការស្វែងរកមានការលំបាកខ្លះខ្លាំង ហើយប្រសិនបើបញ្ជាក់ទីកន្លែងច្បាស់លាស់នោះ គឺថា យើងអន្តរាគមន៍ជាមួយអាជ្ញាធរចិន នៅខេត្តដែលបានកំណត់នោះថា លឿន។ ប៉ុន្តែក្នុងវីដេអូនេះអត់មានការបញ្ជាក់ទីកន្លែងច្បាស់លាស់អ៊ីចឹងមានការលំបាក»។

អនុប្រធានអង្គការលីកាដូទទួលបន្ទុកសិទ្ធិមនុស្សលោក អំ សំអាត បញ្ជាក់ថា ស្ថានភាពនៃការជួញដូរមនុស្សពីកម្ពុជា ទៅកាន់ប្រទេសចិន នៅតែមន្តកើតមាន ហើយរដ្ឋាភិបាលក៏បានចូលរួមទប់ស្កាត់ផងដែរ។ ប៉ុន្តែនៅតែមានស្ត្រីខ្មែររងគ្រោះនៅតែបន្តជួញដូរទៅប្រទេសចិន៖ «រដ្ឋាភិបាល ជាពិសេស ក្រសួងដែលពាក់ព័ន្ធហ្នឹង ត្រូវតែចាត់វិធានការ ហើយដើម្បីធ្វើយ៉ាងណារំដោះក្មេងស្រី ដើម្បីយកកម្ពុជាវិញ ហើយស្វែងរកមេខ្យល់ អ្នកដែលពាក់ព័ន្ធនឹងការជួញដូរកុមារ ឬក៏ការជួញដូរស្ត្រីផ្សេងទៀត យកមកអនុវត្តតាមផ្លូវច្បាប់ ពីព្រោះឥឡូវយើងឃើញថា សូម្បីតែមេខ្យល់ដែលនាំពលករពីខ្មែរទៅថៃ ឬពីថៃមកខ្មែរ ក៏ត្រូវបានចាប់នឹងអនុវត្តបញ្ជូនទៅតុលាការ»។

ករណីស្ត្រីខ្មែរចាញ់បោក គេយកទៅជួញដូរផ្លូវភេទនៅចិនកំពុងកើនឡើង។ កាលពីថ្ងៃកាលពីថ្ងៃទី១១ កុម្ភៈ កន្លងទៅនេះបានរំដោះកុមារីអាយុ១៤ឆ្នាំម្នាក់ ដែលចាញ់បោកមេខ្យល់នាំយកទៅនៅប្រទេសចិនអស់រយៈពេលជាង ៤ខែ ដោយសារគេសន្យាថា នឹងរកការងារធ្វើនៅទីនោះ។ សមត្ថកិច្ចកម្ពុជា សហការជាមួយអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសចិន បានរំដោះកុមារីរងគ្រោះពីខេត្តហឺណាន (Hunan) ប្រទេសចិន។

សមត្ថកិច្ច កាលពីថ្ងៃទី២៩ ខែមករា ក៏បានរំដោះស្ត្រីខ្មែរអាយុ ២០ឆ្នាំម្នាក់ ពីប្រទេសចិន ក្រោយពីបានចាញ់បោកគេ និងត្រូវគេបង្ខំឱ្យរៀបការជាមួយជនជាតិចិន។ ជនរងគ្រោះអាយុ ២០ឆ្នាំ រស់នៅខេត្តក្រចេះ ត្រូវបានអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសចិនបញ្ជូនមកដល់ប្រទេសកម្ពុជាវិញ កាលពីថ្ងៃទី២៨ មករា។

កាលពីឆ្នាំ២០២០ កន្លងទៅនេះ ក្រសួងការបរទេសបានរំដោះស្ត្រីខ្មែរ ដែលចាញ់បោកមេខ្យល់ទៅរស់នៅប្រទេសចិន បានចំនួន ១៤៤នាក់ហើយនិងបុរសម្នាក់ផងដែរ៕

## ពលករចំណាកស្រុកបានសម្រុកចេញពីប្រទេសថៃកាន់តែច្រើន

https://www.kampucheathmey.com/ on March 3, 2021By KC Virak

ប្រជាពលរដ្ឋចំណាកស្រុកដែលទៅធ្វើការនៅក្នុងប្រទេសថៃបានសម្រុកចាកចេញមកកាន់ស្រុកភូមិកំណើតវិញកាន់តែច្រើនឡើង ខណៈពេលពិធីបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិនៅសល់ពេលប្រមាណជាង១ខែទៀត។ ជាក់ស្តែងគ្រាន់តែច្រកអូរស្មាច់ក្នុងខេត្តឧត្តរមានជ័យមួយមានពលករខ្មែរប្រមាណជាង៤០០ ទៅជាង ៥០០នាក់ ក្នុងមួយថ្ងៃបានវិលចូលមកក្នុងប្រទេសវិញ។

លោកវេជ្ជបណ្ឌិត ឃ្លោក ហួត ប្រធានមន្ទីរសុខាភិបាលខេត្តឧត្តរមានជ័យ បានឱ្យដឹងនៅថ្ងៃនេះថា ពលករខ្មែរបានសម្រុកចូកមកស្រុកកំណើតនៅច្រកអូរស្មាច់ ក្នុងខេត្តឧត្តរមានជ័យមានចំនួនកាន់តែច្រើនឡើងពីមួយថ្ងៃទៅមួយថ្ងៃ។ លោក ឃ្លោក ហួត បានឱ្យដឹងទៀតថា ការសម្រុកចូលមកស្រុកវិញនេះមានកត្តា២ យ៉ាង ទី១ ដោយសារការងារមួយចំនួននៅក្នុងប្រទេសថៃត្រូវបានផ្អាក ធ្វើឱ្យពលករអត់ការងារធ្វើ និងមួយទៀតដោយសារជិតដល់ថ្ងៃបុណ្យចូលឆ្នាំប្រពៃណីជាតិ ទើបបងប្អូនត្រូវការជួបជុំក្រុមគ្រួសារផងដែរ។ លោកវេជ្ជបណ្ឌិត មានប្រសាសន៍ថា៖ "បច្ចុប្បន្នមានពលករកម្ពុជាបានចូលមកតាមច្រកអន្តរជាតិអូរស្មាច់ចន្លោះពី៤០០ ទៅជាង ៥០០នាក់ ក្នុងមួយថ្ងៃ។ ហើយអាជ្ញាធរខេត្តឧត្តរមានជ័យគ្រោងរៀបចំបង្កើតមណ្ឌលចត្តាឡីស័កបន្ថែមទៀត"។

គួរបញ្ជាក់ថាចាប់តាំងពីថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២០ ស្របពេលដែលប្រទេសថៃផ្ទុះជំងឺកូវីដ១៩ខ្លាំងរហូតមកដល់ថ្ងៃនេះ ពលករខ្មែរដែលបានចាកចេញពីប្រទេសថៃតាមច្រក អូស្មាច់ និងបានធ្វើចត្តាឡីស័កនៅតាមមណ្ឌលនានាទូទាំងខេត្ត មានចំនួនសរុប ១៣,៩២៣នាក់ ក្នុងនោះបានធ្វើចត្តាឡីស័ករួចមានចំនួន ៩,៥៨៤នាក់ និង

កំពុងធ្វើចត្តាឡីស័កមានចំនួន ៤,៣៣៩នាក់ លើទីតាំងមណ្ឌលធ្វើចត្តាឡីស័កដែលបានរៀបចំរួចមានចំនួន២៣មណ្ឌល៕ អត្ថបទ៖ ណារី

# ចប្បធម៌នាយករដ្ឋមន្ត្រីបញ្ហាបានប្រឹងធ្វើឲ្យបញ្ចប់

https://kbn.news/ March 3, 2021

ប៉ុន្មានអាណត្តិចុងក្រោយនេះ រាជរដ្ឋាភិបាល ដឹកនាំដោយសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានខិតខំប្រែងខ្លាំងណាស់ក្នុងការកែទម្រង់គ្រប់វិស័យ ដើម្បីស្តារនិងអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិឲ្យមានការរីកចម្រើនមកដល់ពេលនេះ ។ ទន្ទឹមនឹងការខិតខំប្រឹងប្រែងរបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល និងមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀត មជ្ឈដ្ឋាន និងប្រជាពលរដ្ឋមួយចំនួនបានកត់សម្គាល់ឃើញថា មន្ត្រីថ្នាក់ក្រោមនៅស្ថាប័ន ឬអង្គភាពមួយចំនួនតូច បានអនុវត្តតួនាទី និងភារកិច្ចរបស់ខ្លួន នៅមានការចន្លោះប្រហោង មួយចំនួនតូចស្ពឹកស្រពន់ និងខ្លះជាមន្ត្រីជើង១០..ជាដើម ។

ជាក់ស្តែង ករណីរឹតបន្តឹងនៅតាមខ្សែបន្ទាត់ព្រំដែនជាមួយប្រទេសជិតខាង ដែលដាក់ចេញដោយរាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ការរីករាលដាលមេរោគកូវីដ១៩ អ្នកតាមដានសង្គម និងប្រជាពលរដ្ឋមួយចំនួនបានកត់សម្គាល់ឃើញថា អាជ្ញាធរនិងសមត្ថកិច្ចតាមព្រំដែនមួយចំនួនតូច មិនបានបំពេញតួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានគត់មត់ បណ្តាលឲ្យមានពលករមួយចំនួនលួចឆ្លងដែនដោយមិនបានធ្វើចត្តាឡីស័ក នាំដល់ការចម្លងកូវីដ១៩ផងដែរ ។ ប៉ុន្តែចាប់តាំងពីសម្ដេចតេជោនាយករដ្ឋមន្ត្រីដាក់ចេញបទបញ្ជា និងវិធានការក្តៅកាលពីដើមខែកុម្ភៈកន្លងមក និងអធិការស្រុកកំរៀង ខេត្តបាត់ដំបងរបូតតំណែង និងកំពុងជាប់ឃុំពីបទពុករលួយឃុបឃិតឲ្យមេខ្យល់នាំពលករចេញចូលឆ្លងដែននោះរួចមក គេឃើញមន្ត្រីអាជ្ញាធរ និងសមត្ថកិច្ចតាមព្រំដែនមួយចំនួនប្រឹងប្រឹងបំពេញកាតព្វកិច្ច ឬភាសាអ្នកស៊ីត្រាវថា"ត្រង់កន្ទុយ" ។

តាមរយៈការគោរព និងអនុវត្តបទបញ្ជារបស់សម្ដេចតេជោនោះរួចមក តាមរបាយការណ៍របស់អគ្គស្នងការដ្ឋាននគរបាលជាតិបានបង្ហាញថា មានមេខ្យល់នាំពលករចេញចូលឆ្លងដែនជាង១០០នាក់ហើយ គិតត្រឹមថ្ងៃត្រង់ថ្ងៃទី០៣ មីនា ២០២១ ត្រូវបានបញ្ជូនទៅសាលាដំបូងដើម្បីចាត់ការតាមច្បាប់ ។ ក្រុមអ្នកស៊ីត្រាវមួយចំនួនតូចបាននិយាយនៅតាមតៀមកាហ្វេក្បែរចិញ្ចើមថ្នល់ថា បើសិនសម្ដេចតេជោ ហ៊ុន សែន មិនដាក់ចេញវិធានការ ឬបទបញ្ជាក្តៅហូតធ្វើឲ្យមន្ត្រីខ្លះរបូតកៅអីទេ ទំនងជាមេខ្យល់ជាង១០០នាក់ ដែលនឹងឡើងវង់ក្រចកនាពេលខាងមុខ អាចបង្កព្យុះភ្លៀងតាមព្រំដែន ហើយការឆ្លងរីករាកដាលមេរោគកូវីដ១៩ ប្រហែលជាជៀសមិនផុត និងនាំដល់អន្តរាយដល់ជាតិទាំងមូលក៏ថាបាន ។

តាមរយៈសកម្មភាព និង លទ្ធផលខាងលើ មជ្ឈដ្ឋាននិងប្រជាពលរដ្ឋជាច្រើនបានទះដៃសាទរចំពោះស្នាដៃខិតខំប្រឹងប្រែងរបស់អាជ្ញាធរ និងសមត្ថកិច្ចពាក់ព័ន្ធទាំងអស់តាមព្រំដែន ក្នុងការស្រាវជ្រាវឈានទៅឃាត់ខ្លួនមេខ្យល់ជាង១០០នាក់ បញ្ជូនទៅតុលាការ ។ យ៉ាងណា ក្រុមអ្នកតាមដានសង្គមមួយចំនួនតូច ក៏បានសំណូមពរដល់មន្ត្រីចំណុះរាជរដ្ឋាភិបាលមួយចំនួនតូចដែលស្ពឹកស្រពន់ភ្ញាក់រឭក អនុវត្តន៍តួនាទី និងភារកិច្ចរបស់ខ្លួនឲ្យបានខ្ជាប់ខ្ជួន គោរពវិជ្ជាជីវៈ មានមនសិការការងារខ្ពស់ កុំចាំបាច់ទាល់តែនាយករដ្ឋមន្ត្រីស្រែកបានស្ទុះស្ទារ កុំធ្វើបាបសម្ដេចតេជោ ហ៊ុន សែន លោករវល់ និងលំបាកពេកហើយ។

## ដឹកជញ្ជូនប្រជាពលករខ្មែរ ចំនួន៩១នាក់ ដែលបានវិលត្រឡប់មកពីប្រទេសថៃ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក

http://www.arey-news.com/ (ថ្ងៃទី 05 March 2021 ម៉ោង 8:39 am)

ខេត្តសៀមរាប សៀមរាប៖ នៅថ្ងៃទី០៤ ខែមីនា ឆ្នាំ២០២១ នេះ មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង ។ សម្រាប់ខេត្តសៀមរាប សរុបចំនួនមក ៩១នាក់ ស្រី ៣៣នាក់ ក្នុងនោះកុមារា ៤នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៥២នាក់ ស្រី ១៥នាក់ កុមារា ៣នាក់ កុមារី ១នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ៣នាក់ កុមារា ១នាក់ កុមារី ១នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៣២នាក់ ស្រី ១៥នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៥- ច្រកដូង ស្រុកកំរៀង ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ សូមបញ្ជាក់៖ ពួកគាត់ទាំង ៩១នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៥៩នាក់, ខេត្តបាត់ដំបង ចំនួន ០០នាក់ និងឧត្តរមានជ័យចំនួន៣២នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕

---

## ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

## សម្តេចតេជោ ហ៊ុន សែន ដាក់បទបញ្ជាឱ្យរថយន្តកម្លាំងប្រដាប់អាវុធទាំងអស់ ដែលដឹកជញ្ជូនពលករចេញពីព្រំដែនកម្ពុជា-ថៃ និងមណ្ឌលចត្តាឡីស័ក ត្រូវមានសណ្តាប់ធ្នាប់ របៀបរៀបរយ និងមានសុវត្ថិភាព

https://information.gov.kh/ AKP ភ្នំពេញ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដាក់បទបញ្ជាឱ្យរថយន្តកម្លាំងប្រដាប់អាវុធទាំងអស់ ដែលដឹកជញ្ជូនពលករចេញពីព្រំដែនកម្ពុជា-ថៃ និងមណ្ឌលចត្តាឡីស័ក ត្រូវមានសណ្តាប់ធ្នាប់ របៀបរៀបរយ សុវត្ថិភាព និងគោរពតាមវិធានណែនាំរបស់ក្រសួងសុខាភិបាល។ ក្នុងសារជាសំឡេងនាថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ជូនឯកឧត្តម និងលោកជំទាវ ជាអភិបាលខេត្តតាមព្រំដែនកម្ពុជា-ថៃ ក៏ដូចជាបណ្តាខេត្តដែលនៅក្នុងផ្ទៃប្រទេស និងស្ថាប័នដែលមានការពាក់ព័ន្ធ សម្តេចតេជោបានបញ្ជាឱ្យអគ្គបញ្ជាការ ក៏ដូចជាបញ្ជាការជើងគោក និងក្រសួងការពារជាតិ បញ្ចេញរថយន្តដើម្បីទៅដឹកបងប្អូនទៅកាន់គោលដៅតាមខេត្ត។ សម្តេចតេជោបន្តថា អគ្គស្នងការនគរបាលជាតិ បើអាចធ្វើទៅបាន ក៏ត្រូវរួមចំណែកប្រើប្រាស់នៅកម្លាំង ដើម្បីជួយដឹកជញ្ជូនក្នុងមួយរយៈពេលខ្លី ព្រោះថាចំនួនមនុស្សនេះ នៅពេលដែលចប់ប្រតិបត្តិការ នៃការដឹកជញ្ជូននៅតាមមណ្ឌលចត្តាឡីស័ក យើងត្រូវដកកម្លាំងធំចេញ ហើយត្រៀមមួយចំនួនតូចសម្រាប់ការដឹកពួកគាត់បន្តទៀត។

សម្តេចតេជោគូសបញ្ជាក់ថា សម្រាប់ថ្ងៃនេះអ្នកដែលមកពីប្រទេសថៃ មិនចាំបាច់ដឹកចូលទៅក្នុងមណ្ឌលចត្តាឡីស័កនោះទេ រថយន្តកងទ័ពដែលនៅតាមព្រំដែនកម្ពុជា-ថៃស្រាប់ ត្រូវដឹកពួកគាត់ទៅកាន់ខេត្តខាងក្រោយតែម្តង។ សម្រាប់អ្នកដែលនៅក្នុងមណ្ឌលចត្តាឡីស័កត្រូវរង់ចាំដឹកនៅព្រឹកស្អែក។ សម្តេចតេជោលើកឡើងថា នៅក្នុងការធ្វើដំណើររបស់ពួកគាត់ ត្រូវតែធានាឱ្យបានថា ពួកគាត់បានទទួលទានអាហាររួចហើយ និងផ្គត់ផ្គង់ស្បៀងអាហារបន្ថែម ដូចជា មី និងទឹកសុទ្ធ ឬអ្វីផ្សេងទៀត ដើម្បីឱ្យពួកគាត់ធ្វើដំណើរមានអាហារតាមខ្លួន។ បានសេចក្តី

ថា ឱ្យពួកគាត់ទទួលទានអាហារពេលព្រឹក ឬក៏ទទួលទានអាហារពេលថ្ងៃត្រង់ មុននឹងពួកគាត់ចេញដំណើរ ព្រោះមិនអនុញ្ញាតឱ្យមានការដឹកជញ្ជូនក្នុងពេលយប់ទេ គឺសុំថាឱ្យដឹកពេលព្រឹក ឬពេលថ្ងៃត្រង់។ សម្តេចតេជោថ្លែងបន្ថែមថា ក្នុងការធ្វើដំណើរទៀតសោត កម្លាំងដឹកជញ្ជូនត្រូវតែយកចិត្តទុកដាក់ថែទាំសុខភាពរបស់ពួកគាត់ឱ្យបានហ្មត់ចត់ជាទីបំផុត ចៀសវាងការធ្វេសប្រហែសណាមួយ ដែលបង្កជាបញ្ហា ជាពិសេសគឺស្នើឱ្យរថយន្តនីមួយៗកុំដាក់មនុស្សច្រើនពេក ដើម្បីចៀសវាងនូវភាពកកកុញ ដែលវាមិនស្របទៅតាមគម្លាតសុវត្ថិភាព ដែលកំណត់ដោយក្រសួងសុខាភិបាលនោះទេ ក៏ប៉ុន្តែយើងក៏មិនមែនក្នុងមួយរថយន្តដឹកតែមនុស្ស ៤ ឬ៥នាក់នោះដែរ អាចដឹកច្រើនជាងនេះ ក៏ប៉ុន្តែមិនអាចប្រជ្រៀតគ្នាបាននោះដែរ។

ជុំវិញការដឹកជញ្ជូនពលករពីព្រំដែននេះដែរ សម្តេចតេជោថ្លែងសង្កត់ធ្ងន់ថា «យើងមិនបោះបង់ចោលការធ្វើចត្តាឡីស័កនោះទេ ក៏ប៉ុន្តែយើងប្រែពីការធ្វើចត្តាឡីស័កនៅតាមព្រំដែនទាំងអស់ ដែលទ្រង់ទ្រាយធំ មកធ្វើចត្តាឡីស័កនៅតាមភូមិ ឃុំ ស្រុក ខេត្តរបស់ពួកគាត់នៅខាងក្រោយវិញ ហើយនឹងបន្តធ្វើចត្តាឡីស័កសម្រាប់អ្នកដែលចូលមកដល់មានអាការៈមិនប្រក្រតី ត្រូវធ្វើចត្តាឡីស័កនៅតាមព្រំដែន»។ ដូច្នេះខេត្តដែលនៅតាមព្រំដែនទាំងអស់នៅតែមានការទទួលខុសត្រូវ ទទួលយកអ្នកដែលមានភាពមិនប្រក្រតី បន្តធ្វើចត្តាឡីស័កនៅទីនោះ ក្នុងពេលដែលយកសំណាករបស់ពួកគាត់មកធ្វើការពិនិត្យផងដែរ ពេលឃើញអវិជ្ជមានហើយចាំបញ្ជូនគាត់ត្រឡប់ក្រោយវិញ។

ឯសម្រាប់អ្នកដែលមានស្ថានភាពល្អប្រសើរ ទាំងអ្នកដែលនៅក្នុងមជ្ឈមណ្ឌលចត្តាឡីស័ក ទាំងអ្នកមកដល់ថ្មី គឺត្រូវបញ្ជូនពួកគាត់ចូលមកក្នុងផ្ទៃប្រទេសតាមរថយន្តកងទ័ព ឬរថយន្តនគរបាល គឺមិនអនុញ្ញាតឱ្យមានការធ្វើដំណើរដោយរថយន្តឯកជន ឬរថយន្តតាក់ស៊ីនោះទេ ហើយបណ្តាខេត្តខាងក្រោយប្រញាប់បញ្ជូនតំណាងរបស់ខ្លួនទៅកាន់មជ្ឈមណ្ឌលចត្តាឡីស័កនៅខេត្តខាងមុខ ដើម្បីពិនិត្យផ្ទៀងផ្ទាត់ទទួលយកពលរដ្ឋ ដែលស្ថិតនៅក្នុងក្របខណ្ឌទទួលខុសត្រូវរបស់ខ្លួនត្រឡប់មកខាងក្រោយវិញ ដើម្បីចៀសវាងការគេចវេះនៅតាមផ្លូវ។ សម្តេចតេជោគូសបញ្ជាក់ថា នេះជាការណែនាំបន្ថែម ដើម្បីផ្តោតការយកចិត្តទុកដាក់ ទៅលើសណ្តាប់ធ្នាប់ របៀបរៀបរយការរក្សាសុវត្ថិភាព សម្រាប់ប្រជាពលរដ្ឋរបស់យើង៕ ដោយ ជឹម ណារី សម្រួលផ្សាយដោយ៖ ធូ កុសល

## ឃាត់មេខ្យល់ម្នាក់បញ្ជូនទៅតុលាការនិងពលករ៦នាក់យកទៅធ្វើចត្តាឡីស័ក

http://nokorwatnews.com/ 06-03-2021

ខេត្តបន្ទាយមានជ័យ ៖ សមត្ថកិច្ចឈរជើងតាមបន្ទាត់ព្រំដែន បានឃាត់ខ្លួនមេខ្យល់ម្នាក់ដែលនាំពលករប្រុស-ស្រី៦នាក់ ឆ្លងដែនចូលទៅប្រទេសថៃដោយខុសច្បាប់នៅវេលាម៉ោង៥និង១០នាទី ថ្ងៃទី០៣ ខែមីនា ឆ្នាំ២០២១ នៅប្រមាណ៨០០ម៉ែត្រ ពីភូមិខ្វាវ ឃុំ/ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។

អធិការនគរបាលស្រុកស្វាយចេកលោកវរសេនីយ៍ឯក ជា ឈួញ បានប្រាប់ថា តាមការណែនាំពីលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ដើម្បីពង្រឹងការទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ ដែលកំពុងគេចវេសធ្វើចត្តាឡីស័កបង្ការទប់ស្កាត់កូវីដ១៩ មិនអោយឆ្លងរីករាលដាលកូវីដ១៩ ក្នុងសហគមន៍ កម្លាំងត្រូវពង្រឹងការចេញចូលតាមច្រកទ្វារព្រំដែនយ៉ាងចាំបាច់។ ដោយហេតុនេះហើយទើបកម្លាំងកម្លាំងនគរបាលមូលដ្ឋានបានសហការជាមួយកម្លាំងនគរបាលការពារព្រំដែនគោក បានចេញល្បាតតាមបន្ទាត់ព្រំដែនហើយបានប្រទះឃើញប្រជាពលរដ្ឋចំនួន៦នាក់ ស្រី៣នាក់ មានសាក់កាដូដាក់សម្លៀកបំពាក់កំពុងជិះគោយន្តកន្ត្រៃ១គ្រឿង ឆ្លងកាត់ព្រៃឆ្លងដែនចូលទៅប្រទេសថៃក៏ត្រូវបានឃាត់ខ្លួន រួមជាមួយមេខ្យល់ម្នាក់ផង។ លោកបញ្ជាក់ទៀតថា ក្រោយពេលឃាត់ខ្លួនពលករខ្មែរលួចឆ្លងដែនទៅរកការងារធ្វើនៅប្រទេសថៃ ដោយខុសច្បាប់តាមរយៈមេខ្យល់រួចមក កម្លាំងបានបញ្ជូនអ្នកទាំងអស់នេះទៅកាន់អធិការដ្ឋាននគរបាលស្រុកស្វាយចេក ដើម្បីសាកសាកសួរនិងធ្វើចត្តាឡីស័ក រយៈពេល១៤ថ្ងៃ។ ដោយឡែកមេខ្យល់ម្នាក់ឈ្មោះ ទឿង សុភាន់ ភេទប្រុស អាយុ២៨

ឆ្នាំ រស់នៅភូមិចំការគរ ឃុំ/ស្រុកស្វាយចេក ដែលចោទប្រកាន់ពីបទនាំមនុស្សឆ្លងដែនដោយខុសច្បាប់ ត្រូវបញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមច្បាប់ផងដែរ ៕

## តៃកុងរថយន្តដឹកពលករខ្មែរបម្រុងឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃចំនួន៦ ត្រូវសមត្ថកិច្ចចាប់ឃាត់

https://www.facebook.com/neakmeasnews/ ចេញផ្សាយថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ដោយ ជីវ័ន្ត

(ខេត្តបន្ទាយមានជ័យ)៖ យោងតាមរបាយការណ៍របស់កម្លាំងសមត្ថកិច្ចនគរបាលវីរៈការពារព្រំដែនគោកលេខ ៨១៥ កាលពីយប់ថ្ងៃទី៦,ខែកុម្ភៈ,ឆ្នាំ២០២១ បានអោយសារព័ត៌មានដឹងថា ពលករខ្មែរចំនួន ៦ នាក់និងតាកុងរថយន្តម្នាក់ផងដែរត្រូវបានកម្លាំងធ្វើការឃាត់ខ្លួនខណៈពេលបម្រុងលួចឆ្លងដែនដោយខុសច្បាប់។ សមត្ថកិច្ចបានបន្តឲ្យដឹងទៀតថា ក្នុងនោះមានស្រី៣នាក់រួមទាំងតៃកុងរថយន្តម្នាក់ផងដែរ ត្រូវបានកម្លាំងសមត្ថកិច្ចឈរជើងនៅតាមខ្សែបន្ទាត់ព្រំដែនរបស់នគរបាលការពារព្រំដែនលេខ៨១៥ធ្វើការឃាត់ខ្លួន។ តាមរបាយការណ៍របស់កម្លាំងនគរបាលវការពារព្រំដែន៨១៥ បានឲ្យដឹងថា ពលករខ្មែរទាំង ៦នាក់មាន៖

១-ឈ្មោះសុខជោគជ័យភេទប្រុសអាយុ២១ ឆ្នាំរស់នៅភូមិអូរជា,ឃុំបួរ ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

២,ឈ្មោះឡេង សោភា ភេទស្រីអាយុ ១៩ឆ្នាំនៅភូមិអូរជា,ឃុំបួរ,ស្រុកភ្នំព្រឹកខេត្តបាត់ដំបង

៣, ឈ្មោះឡេង មុី ភេទស្រីអាយុ១៨ឆ្នាំ ភូមិអូរជា,ឃុំបួរ,ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង

៤, ឈ្មោះអែន អន ភេទប្រុសអាយុ៣៧ ឆ្នាំរស់នៅភូមិពលី ឃុំព្រែកន្លៀង,ស្រុកពាមរខេត្តព្រៃវែង

៥,តាន ប៊ុនសុង ភេទប្រុសអាយុ៣៩ឆ្នាំរស់នៅផ្សារកណ្ដាល សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ

៦,ឈ្មោះយឿន សៃយ៉ា ភេទស្រីអាយុ ២១ឆ្នាំរស់នៅភូមិក្បាលស្ពាន សង្កាត់ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ។

៧, ឈ្មោះភោក គឹមសូត្រ ភេទប្រុសអាយុ៤១ឆ្នាំរស់នៅភូមិចាន់គីរី សង្កាត់ផ្សារកណ្ដាល ក្រុងប៉ោយប៉ែតខេត្តបន្ទាយមានជ័យ ជាតៃកុងឡានដែលដឹកពលរខ្មែរ រថយន្តម៉ាកឆ្លាមពណ៌ប្រផេះស្លាកលេខបន្ទាយមានជ័យ 2A- 6945 ក្រោយពីធ្វើការសាកសួរបញ្ជូនពលករទាំង ៦ នាក់បញ្ជូនទៅណ្ឌលចត្តាឡីស័កចំណែកតៃកុងក្នុងរថយន្តត្រូវបានប្រគល់ជូនកម្លាំងនគរបាលនៃអធិការដ្ឋានស្រុកម៉ាឡៃចាត់ការបន្តតាមនីតិវិធីច្បាប់។

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://www.information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី០៧ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១១០នាក់ ស្រី ៥០នាក់ ក្នុងនោះកុមារា ៣នាក់ កុមារី ៨នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤២នាក់ ស្រី ២០នាក់ កុមារា ៣នាក់ កុមារី ៧នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧នាក់ ស្រី ២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ៥៩នាក់ ស្រី ២៦នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៥- ច្រកដូង ស្រុកកំរៀង៖ ចំនួន ២នាក់ ស្រីចំនួន ០០នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ សូមបញ្ជាក់៖ ពួកគាត់ទាំង ៩៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក, នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តបន្ទាយមានជ័យចំនួន ៤៩នាក់, ខេត្តបាត់ដំបង ចំនួន ២នាក់ និងឧត្តរមានជ័យចំនួន ៥៩នាក់ ដើម្បីធ្វើការពិនិត្យសុខភាព និងយកសំណាក់៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## បញ្ចេញរថយន្តកងទ័ពជាង២០០ គ្រឿងដឹកពលករខ្មែរពីព្រំដែនប្រទេសថៃបន្ទាន់

https://www.kampucheathmey.com/ on March 8, 2021By deth leng

លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោក បានបញ្ជាឲ្យចេញរថយន្តរបស់កងទ័ពចំនួន២០៤ គ្រឿង ដើម្បីដឹកជញ្ជូនប្រជា ពលរដ្ឋខ្មែរ ដែលធ្វើដំណើរមកពីប្រទេសថៃ ទៅកាន់រាជធានី ខេត្ត ដែលជាគោលដៅរបស់ពួកគាត់។ ការចេញបញ្ជានេះ បានធ្វើឡើងបន្ទាបពីសម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចបិទការធ្វើ ចត្តាឡីស័កនៅតាមបណ្តាព្រំដែន សម្រាប់ពលករដែលមានសភាពធម្មតា លើកលែងតែពលករដែលមានអាការៈខុសប្រក្រតី។ លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត បានបញ្ជាក់ថា ដោយសារស្ថានភាពប្រជាពលរដ្ឋ ពេលនេះ បានសំរុកចាកចេញពីប្រទេសថៃកាន់តែច្រើន ដើម្បីចូលរួមពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីជាតិខ្មែរនាពេលខាងមុខ សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានតម្រូវឲ្យកងទ័ពជួយដឹកពលករខ្មែរ ដែលត្រឡប់មកពីប្រទេសថៃ ទៅកាន់គោលដៅ នៅតាមរាជធានី ខេត្ត ដើម្បីធ្វើចត្តាឡីស័កនៅខាងក្រោយ។

បើតាមលោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត "ជាជំហានដំបូងយើងត្រូវប្រើរថយន្តចំនួន២០៤ គ្រឿង ក្នុងនោះកងពលលេខ៩០ ចំនួន១០៤ គ្រឿង និងកងពល១០៩ ចំនួន១០០គ្រឿង"។ លោកបញ្ជាក់ថា កងពលធំ និងយោធភូមិភាគនៅតាមព្រំដែន ដែលមានយោធភូមិភាគទី០៣ យោធភូមិភាគទី០៤ ទៅខាងអូស្មាច់ និងយោធភូមិភាគទី០៥ ច្រកដូង និងប៉ៃលិន ហើយប្រែងកងទ័ពជើងគោកជាអ្នកធានា។ ជាមួយគ្នានោះលោក ហ៊ុន ម៉ាណែត បានដាក់បញ្ជាឲ្យមេបញ្ជាការកងពលធំលេខ ០២ លេខ០៣ និងយោធភូមិភាគទី០៤ ទី០៣ រាយការណ៍ពីប្រភេទរថយន្ត ដែលអាចដឹកជញ្ជូនបាន ហើយត្រូវយករថយន្តដែលមានខ្យល់ចេញចូលបាន ចៀសវាងរថយន្តបិទជិត ដែលអាចបង្កហានិភ័យ ប្រសិនបើនៅលើរថយន្តនោះមានអ្នកណាម្នាក់វិជ្ជមាន៕

## អភិបាលខេត្តកំពង់ស្ពឺ អញ្ជើញទទួលបងប្អូនពលករ៩៨នាក់ មកពីថៃ ដើម្បីឲ្យធ្វើចត្តាឡីស័ក

http://www.freshnewsasia.com/ 2021-03-08 09:19pm

**(កំពង់ស្ពឺ)៖** រសៀលថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ លោក វ៉ី សំណាង អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ មន្ទីរសុខាភិបាលខេត្ត មន្ត្រីពេទ្យ និងជំនាញពាក់ព័ន្ធ បានចុះពិនិត្យទីតាំងធ្វើចត្តាឡីស័ក នៅមណ្ឌលកម្ពុជា កូរ៉េ ស្ថិតនៅផ្លូវលេខ៤៤ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ។ លោក វ៉ី សំណាង អភិបាល ខេត្តកំពង់ស្ពឺ មានប្រសាសន៍ថា ក្រោយពីទទួលបានបទបញ្ជាដ៏ខ្ពង់ខ្ពស់ពី សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃកម្ពុជា ឱ្យទទួលយកពលករមកធ្វើចត្តាឡីស័ក នៅតាមបណ្តាខេត្ត របស់ខ្លួនវិញរួចមក នៅក្នុងថ្ងៃនេះមានរថយន្តកងយោធពលខេមរភូមិន្ទ បានធ្វើការដឹកជញ្ជូនបងប្អូនពលករមកពីបណ្តាខេត្ត ដែលមានព្រំដែនជាប់នឹងប្រទេសថៃ ប៉ៃលិន,បាត់ដំបង, បន្ទាយមានជ័យ,ឧត្តរមានជ័យ បញ្ជូនទៅតាមបណ្តាខេត្តនានាផងដែរ។ ដោយឡែកសម្រាប់ខេត្តកំពង់ស្ពឺ ថ្ងៃនេះក៏បានទទួលពលករចំនួន ៩៨ នាក់ ក្រោមការជួយជ្រោមជ្រែង និងដឹកជញ្ជូនបញ្ជាការដ្ឋានកងទ័ពជើងគោក។

អភិបាលខេត្តបន្តថា ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត កងកំលាំងប្រដាប់អាវុធទាំង បីប្រភេទ និងប្រជាពលរដ្ឋដែលទទួលបានទីតាំងធ្វើចត្តាឡីស័កដ៏សមរម្យ សូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ

សម្តេចតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានីហ៊ុនសែន ដែលសម្តេចទាំងទ្វេរ តែងតែយកចិត្តទុកដាក់គិតគូអំពីសុខទុក្ខ បងប្អូនប្រជាពលរដ្ឋមន្ត្រីរាជការគ្រប់ពេលវេលា គ្រប់ទីកន្លែង និងសូម ដឹងគុណចំពោះកងយោធពលខេមរភូមិន្ទ ដែលមិនត្រឹមតែជាកម្លាំងការពារជាតិប៉ុណ្ណោះទេ ប៉ុន្តែកងយោធពលខេមរភូមិន្ទគឺជាកម្លាំងជួរមុខនៅក្នុងការចូលរួមជួយកិច្ចការសង្គម ដូចជា៖គ្រោះរាំងស្ងួត ខ្យល់ព្យុះ ទឹកជំនន់ ជារៀងរហូតមក មិនតែប៉ុណ្ណោះ ថ្ងៃនេះទៀត ក៏បានចូលរួមដឹកជញ្ជូនពលករ ពីខេត្តផ្សេងៗមកកាន់ខេត្តកំពង់ស្ពឺរបស់យើងថែមទៀត។ លោកអភិបាលខេត្តបានសង្កត់ធ្ងន់ថា ដើម្បីសុខុមាលភាពក្រុមគ្រួសារ បងប្អូន ប្រជាជនទូទៅ បងប្អូនដាច់ខាតត្រូវធ្វើចត្តាឡីស័ក និងគោរពឲ្យបាននូវវិធានការរបស់ ក្រសួងសុខាភិបាល មិនត្រូវចាកចេញដោយគ្មានការអនុញ្ញាតដាច់ខាតទាំងនេះដើម្បីសុខដុមរម្យនាក្នុងសង្គមជាតិក្នុងគ្រួសារក្នុងបរិបទរីករាលដាលនៃជម្ងឺកូវីដ-១៩ ជាសកល៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃចន្ទ ទី០៨ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៤១នាក់ ស្រី ៦១នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ៧នាក់ មានដូចខាងក្រោម៖

១- សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២- សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២២នាក់ ស្រី ១៣នាក់ កុមារា ១នាក់ កុមារី ២នាក់។

៣- សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៣៩នាក់ ស្រី ១៩នាក់ កុមារា ១នាក់ កុមារី ២នាក់។

៤- សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៨០នាក់ ស្រី ២៩នាក់ កុមារា ០០នាក់ កុមារី ៣នាក់។

៥- ច្រកដូង ស្រុកកំរៀង ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៤១នាក់ សម្រាប់អ្នកចេញមកតាមច្រកព្រំដែននានាខេត្តបន្ទាយមានជ័យ ត្រូវបានក្រុមការងារបញ្ជូនមកដាក់មណ្ឌលចត្តាឡីស័ក នៅខេត្តសៀមរាប ចំនួន ៦១នាក់( បញ្ជូនមកទាំងអស់) ។ សម្រាប់អ្នកចេញមកតាមច្រកព្រំដែនអូស្មាច់ ខេត្តឧត្តរមានជ័យ ត្រូវបានក្រុមការងារ គ្រូពេទ្យដាក់មណ្ឌលចត្តាឡីស័ក នៅសាលារៀន និងវិទ្យាល័យនានា ក្នុងខេត្តឧត្តរមានជ័យចំនួន ៨០នាក់។

សូមជម្រាបជូនថា សម្រាប់រយៈពេលពីរថ្ងៃនេះ( ០៧ និង០៨ ខែមីនា) ការបញ្ជូនពលករដែលកន្លងមកដាក់ធ្វើចត្តាឡីស័កនៅមណ្ឌលចត្តាឡីស័កនានាក្នុងខេត្តបាត់ដំបង, ខេត្តបន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យមកមណ្ឌលចត្តាឡីស័កនៅខេត្តសៀមរាបវិញសរុបចំនួន ៣០១នាក់ ក្នុងនោះស្រី ១៦៣នាក់ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ប្រតិភូភូមិភាគ៥ចូលរួមប្រជុំពិភាក្សាជាមួយភាគីថៃបញ្ហាការងារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ និងការពង្រឹងកិច្ចសហប្រតិបត្តិការល្អ

http://nokorwatnews.com/ 06-03-2021

ថៃ÷នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២១ លោកឧត្តមសេនីយ៍ទោ សេង ធារិន មេបញ្ជាការរងនាយសេនាធិការយោធភូមិភាគទី៥ បានអញ្ជើញចូលរួមប្រជុំពិភាក្សាការងារទប់ស្កាត់ការរីករាលដាលជំងឺកូវីដ-១៩ និងការ

ពង្រឹងកិច្ចសហប្រតិបត្តិការល្អរវាងខេត្តបាត់ដំបងនៃព្រះរាជាណាចក្រកម្ពុជា ជាមួយនឹងខេត្តច័ន្ទបូរីនៃព្រះរាជាណាចក្រថៃ នៅស្រុកពោងណាមរ៉ន ខេត្តច័ន្ទបូរីនៃព្រះរាជាណាចក្រថៃ ក្រោមអធិបតីភាពលោក ងួន រតនៈ អភិបាលនៃគណៈអភិបាលខេត្តបាត់ដំបង ។ ក្នុងកិច្ចប្រជុំនោះលោកឧត្តមសេនីយ៍ទោ សេង ផារិន បានស្នើឲ្យភាគីថៃជួយផ្សព្វផ្សាយជូនពលករកម្ពុជាដែលធ្វើការនៅប្រទេសថៃ សូមកុំចាញ់បោកមេខ្យល់ហើយបើចង់មកប្រទេសខ្មែរសូមមកផ្លូវត្រង់ ដើម្បីងាយស្រួលគ្រប់គ្រងបញ្ជូនពួកគាត់ទៅធ្វើចត្តាឡីស័កស្របតាមគោលការណ៍របស់ក្រសួងសុខាភិបាលដើម្បីការពារទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ-១៩ ។ លោកឧត្តមសេនីយ៍ទោ បានបន្តទៀតថា សម្រាប់ពលករដែលបានធ្វើចត្តាឡីស័កនៅកម្ពុជា ទាំងការហូបចុកទាំងការពិនិត្យសុខភាពព្រមទាំងការដឹកជញ្ជូនដល់ភូមិឋានផ្ទាល់គឺប្រមុខរាជរដ្ឋាភិបាលជាអ្នកចេញថ្លៃទាំងអស់ ដូច្នេះសូមឲ្យពួកគាត់កុំចាញ់បោកមេខ្យល់ដើម្បីងាយស្រួលដល់កម្លាំងយើងគ្រប់គ្រងនិងបញ្ជូនគាត់ធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវ ៕

## ពលករខ្មែរជិត ១ពាន់នាក់នៅថៃ តវ៉ាករណីថៅកែរោងចក្របណ្ដេញពួកគេពីការងារ

https://www.rfa.org/khmer/ ដោយ អាស៊ីសេរី 2021-03-08

ពលករខ្មែរប្រមាណជិត ១ពាន់នាក់ ធ្វើការនៅរោងចក្រសាច់មាន់ ក្នុងខេត្តឈុនបុរី ប្រទេសថៃ ផ្ទុះការតវ៉ាករណីថៅកែកាត់ប្រាក់ខែ និងបណ្ដេញពលករ ចំនួន៣២នាក់ ចេញពីការងារ នៅល្ងាចថ្ងៃទី៧ មីនា។

តំណាងពលករខ្មែរនៅប្រទេសថៃដែលត្រូវថៅកែបណ្ដេញចេញ លោក យ៉ែម យ៉ត ថ្លែងថា ថៅកែបានកាត់ប្រាក់ខែពួកគាត់ប្រមាណជិត ៥០ភាគរយនៃប្រាក់ខែកន្លងទៅ នៅប៉ុន្មានខែចុងក្រោយនេះ ដោយយកលេសថាពួកគេកាប់សាច់យឺត និងខូចខាតច្រើន។ លោកបន្តថា នេះ ជារឿងអយុត្តិធម៌បំផុតសម្រាប់ពលករខ្មែរទាំងនោះ ដោយលោកអះអាងថា ករណីកាប់សាច់ខូចនេះ គឺដោយសារសាច់ដែលថៅកែយកមកឱ្យពលករកាប់នោះ ពុំមានគុណភាពល្អស្រាប់ ទើបធ្វើឱ្យខូចខាតច្រើនបែបនេះ។ លោកត្អូញត្អែរថា ពលករទាំងនោះ ធ្វើការច្រើនម៉ោងជាងមុន ពោលគឺពី១០ ទៅ១១ម៉ោងក្នុងមួយថ្ងៃ ប៉ុន្តែប្រាក់ខែរបស់ពួកគេបែរជាធ្លាក់ចុះក្នុងកម្រិតខ្ពស់មួយ។ លោក យ៉ែម យ៉ត លើកឡើងថា ក្រៅពីការកាត់ប្រាក់ខែថៅកែបានបញ្ឈប់បុគ្គលិក ៣២នាក់ចេញពីការងារ ដោយលើកហេតុផលថា សុពលភាពសៀវភៅការងាររបស់ពួកគេផុតកំណត់។ លោកថា ថៅកែបកស្រាយថា ការបញ្ឈប់បុគ្គលិកទាំង ៣២នាក់នេះ គឺដោយសារពួកគេមិនបានគិតពីផលប្រយោជន៍ក្រុមហ៊ុនសកម្មក្នុងការតវ៉ា និងបកប្រែភាសាមានលក្ខណៈលំអៀងជួយដល់ពលករខ្មែរ ជាដើម៖ «បុគ្គលិកគាត់ចូលរួមច្រើន មានបងប្អូនខ្លះគាត់មិនមានឈ្មោះដែលគេមិនតឯកសារឱ្យទេ គឺគាត់មានឈ្មោះតជម្មតា តែដោយគាត់ឃើញទី១ គឺភាពអយុត្តិធម៌ចំពោះពលរដ្ឋខ្មែរ ទី២ សូម្បីតែខ្លួនគាត់ជិតអស់អាយុ Passport ជិតអស់អាយុលិខិតធ្វើការហ្នឹងក៏គាត់កំពុងតែមានការភ័យខ្លាច លដល់ពេលគាត់ ខាងក្រុមហ៊ុន គាត់នឹងមានការចោទប្រកាន់ក្នុងករណីដូចគ្នាអ៊ីចឹងដែរ»។

ការតវ៉ារបស់ពលករខ្មែរនេះ ពុំមែនជាលើកទីមួយទេ គឺធ្វើឡើងច្រើនលើកច្រើនសាមកហើយ ដោយសារថៅកែក្រុមហ៊ុនរោងចក្រសាច់មាន់មួយនេះ បានកាត់ប្រាក់ខែ និងមានបំណងចង់បញ្ឈប់ការងាររបស់ពួកគេ។ លទ្ធផលនៃការតវ៉ានៅថ្ងៃអាទិត្យម្សិលមិញនេះ ថៅកែបានកោះហៅបុគ្គលិកតវ៉ាទាំងអស់ឱ្យទៅជួបនៅថ្ងៃចន្ទនេះ ដើម្បីជជែករកដំណោះស្រាយ។ ទោះជាយ៉ាងណា ពួកគេទទូចស្នើសុំឱ្យរដ្ឋាភិបាលខ្មែរជួយអន្តរាគមន៍នៅក្នុងរឿងនេះ ដោយជួយឱ្យថៅកែទទួលពួកគេចូលធ្វើការវិញ បន្តសុពលភាពសៀវភៅការងារ និងទូទាត់ប្រាក់ឱ្យពួកគេត្រឹមត្រូវឡើងវិញ៕

# ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១

## ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ សម្តែងការសោកស្តាយជាខ្លាំង ដែលអធិការស្រុកសៀមប៉ាងព្រមានស្ត្រីជាមន្ត្រីនគរបាលបំបៅដោះកូន

https://www.postkhmer.com/ ឡាយ សាមាន | Publication date 10 March 2021 | 14:45 ICT

**ស្ទឹងត្រែង៖** ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និងគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស នៅថ្ងៃទី ១០ ខែមីនានេះ បានចេញលិខិតមួយផ្ញើជូនគណៈអភិបាលខេត្តស្ទឹងត្រែង ដោយសម្តែងការសោកស្តាយជាខ្លាំង ដែលអធិការស្រុកសៀមប៉ាង បានធ្វើការព្រមានលោកស្រី អនុសេនីយ៍ទោម្នាក់ដែលបំបៅកូននៅក្នុងពេលបំពេញបេសកកម្មតាមផ្លូវ។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ និងក៏ជាអនុប្រធានអចិន្ត្រៃយ៍ នៃគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងការជួញដូរ មនុស្សបានលើកឡើងនៅក្នុងលិខិតថា ការប្រើឥរិយាបថ ដោយកោះហៅលោកស្រីនគរបាលម្នាក់ ដែលគាត់បំបៅដោះកូននៅតុការងារតាមផ្លូវ ដើម្បីទៅព្រមាន និងឲ្យធ្វើកិច្ចសន្យាបញ្ឈប់បំបៅដោះកូនបែបនេះ ដោយមិនបានវែកញែក ឱ្យច្បាស់ពីកំហុស និងគុណសម្បត្តិ ពីសំណាក់លោកអធិការស្រុកសៀមប៉ាង គឺជារឿងសោកស្តាយយ៉ាងខ្លាំង។ លោកស្រីថ្លែងថា៖«ក្នុងស្ថានភាពជាស្ត្រីដែលមានភារកិច្ចទទួលខុសត្រូវទ្វេដងលើសពីបុរស គឺបំពេញការងារស្នូល ក្នុងអង្គភាពស្ថាប័នផង និងត្រូវចិញ្ចឹមបីបាច់ថែទាំកូន តាំងពីក្នុងផ្ទៃរហូតដល់កើត....។ នេះជាទង្វើដែលខ្ញុំជាស្ត្រីម្នាក់ សូមកោតសរសើរនូវឆន្ទៈដ៏មោះមុតក្នុងការបំពេញភារកិច្ចរបស់មន្ត្រីជាស្ត្រី ទោះជាប្រឈមនឹងការលំបាកយ៉ាងណាក៏ដោយ»។ លោកស្រីបានគូសបញ្ជាក់ថា៖«លោកអធិការ គួរតែសម្តែងនូវការកោតសរសើរ លើកទឹកចិត្ត និងរិះរកមធ្យោបាយឱ្យមន្ត្រីស្ត្រីបែបនេះ ទទួលបាននូវការយកចិត្តទុកដាក់ និងឱ្យគាត់មានឱកាសគ្រប់គ្រាន់ថែទាំកូន ដូចម្តាយលោកថែទាំលោកកាលពីនៅទារក និងភរិយាលោកថែទាំកូនលោកដូចគ្នាដែរ»។ លោកស្រីបន្ថែមថា ទង្វើរបស់លោកស្រីនគរបាល មិនបានសម្តែងការបញ្ចេញភាពសិចស៊ី ដើម្បីថតបង្ហាញសាធារណជន ដើម្បីទាក់ទាញដូចអ្នករកស៊ីលក់ភាពសិចស៊ី ដែលលោកអធិការត្រូវមានចំណាត់ការនោះទេ។ លោកស្រី ជូ ប៊ុនអេង បានស្នើឲ្យអភិបាលខេត្ត និងស្នងការខេត្តស្ទឹងត្រែង ព្រមទាំងមន្ត្រីក្នុងខេត្តនេះ រិះរកវិធីលើកទឹកចិត្ត ស្ត្រីដែលជាមន្ត្រីនគរបាលបំបៅដោះកូននេះ និងស្ត្រីជាមន្ត្រីរាជការដទៃទៀត តាមដែលអាចធ្វើទៅបាន ដើម្បីកុំឲ្យបាក់ទឹកចិត្ត ជាពិសេសក្នុងទិវាអន្តរជាតិនារីខួបលើកទី១១០ ឆ្នាំ២០២១ នេះ។

លោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា បានថ្លែងប្រាប់ ភ្នំពេញប៉ុស្តិ៍ នៅថ្ងៃទី១០ មីនានេះថា ការដែលលោកស្រីបង្ហោះរូបភាពបំបៅដោះកូន គឺពុំមានចេតនាធ្វើឱ្យប៉ះពាល់ដល់អង្គភាព និងកិត្តិយសរបស់ស្ត្រីខ្មែរនោះទេ គឺលោកស្រីគ្រាន់ចង់បង្ហាញពីទឹកចិត្តរបស់ម្តាយប៉ុណ្ណោះ។ លោកស្រីបញ្ជាក់ថា៖ «បច្ចុប្បន្នខ្ញុំមានកូន ២ នាក់ កូនដែលខ្ញុំបំបៅដោះនោះ មានអាយុ ១ ខួប ២ ខែ តែមិនទាន់ផ្តាច់ដោះទេ គឺត្រូវបំបៅដោះរាល់ថ្ងៃ។ និយាយរួម ខ្ញុំយកទៅតាមធ្វើការរាល់ថ្ងៃ លើកលែងតែខ្ញុំមកប្រជុំនៅខេត្ត ខ្ញុំផ្ញើនៅជាមួយបងស្រីខ្ញុំ»។ លោកស្រីលើកឡើងថា៖ «ខ្ញុំផុស (លើហ្វេសប៊ុក) ខ្ញុំអត់មានចេតនា គោលបំណងអីធ្វើឱ្យប៉ះពាល់ដល់អង្គភាព ឬប៉ះពាល់ដល់ស្ត្រីខ្មែរទេ ខ្ញុំផុសគ្រាន់តែចង់ឆ្លុះបញ្ចាំងទឹកចិត្តម្តាយជាមួយកូនថា ស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ក៏ម្តាយមិនចោលកូនដែរ»៕

# អ្នកការពារសិទ្ធិមនុស្សសោកស្ដាយ ដែលក្រសួងកិច្ចការនារីថា ស្ត្រីបំបៅដោះកូនត្រូវ ប្រយ័ត្នចៀសវាងការរិះគន់ថាធ្វើអោយប៉ះពាល់សេចក្ដីថ្លៃថ្នូរបស់ស្ត្រី

https://www.rfa.org/khmer/news/ ដោយ សុជីវី 2021-03-10

ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាខកចិត្តនៅពេលដែលក្រសួងកិច្ចការនារីមិនបានទាមទារឱ្យអធិការស្រុកសៀមប៉ាងសុំទោសមន្ត្រីនគរបាលក្រោមបង្គាប់ខ្លួន តែបែរជាដាស់តឿនឱ្យស្ត្រីជាម្ដាយត្រូវបិទបាំងពេលបំបៅដោះកូនដើម្បីការពារសេចក្ដីថ្លៃថ្នូរបស់ស្ត្រីខ្មែរទៅវិញ។

ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាអ្នកស្រី ចក់ សុភាព ថ្លែងថា ក្រសួងកិច្ចការនារីគួរតែជំរុញថា ការបំបៅដោះកូនដោយទឹកដោះម្ដាយ គឺជារឿងអស្ចារ្យ ជារឿងកោតសរសើរ ព្រោះទឹកដោះដែលម្ដាយផ្ដល់ឱ្យកូនបានទ្រទ្រង់ជីវិតកូន។ អ្នកស្រីថា គ្មានអ្វីដែលត្រូវខ្មាស់ ឬប៉ះពាល់ដល់កិត្តិយសស្ត្រីនោះទេ៖ «*យើងឃើញហើយការបំបៅដោះកូននៅតាមភូមិនៅតាមអីហ្នឹងតែគាត់ត្រូវបំបៅគាត់បំបៅហើយ អត់ចាំបាច់ទៅគិតគូរឿងទីតាំងរឿងអីទេ។ ខ្ញុំមិនយល់ថាតើខាងក្រសួង ឬខាងតួអង្គដែលគាត់លើកថា ការបំបៅដោះកូននៅទីសាធារណៈ ហើយការបង្ហាញដោះនៅពេលបំបៅកូនហ្នឹងវាទៅជារឿងដែលសង្គមវាយតម្លៃថា មិនសមរម្យ តើយើងយោងតាមអី? ខ្ញុំថាអំណះអំណាងនេះ គឺតែងតែត្រូវយកមកប្រើប្រាស់ចំពោះស្ត្រី ដាក់បន្ទុកស្ត្រី ហើយដាក់ជាចំណោទបន្ទោសបង្អាប់ស្ត្រីថែមទៀត ហើយដែលខ្ញុំគិតថាយើងគួរតែធ្វើការផ្លាស់ប្ដូរ ហើយការផ្លាស់ប្ដូរនេះគួរតែចាប់ផ្ដើមចេញពីក្រសួងពាក់ព័ន្ធ ជាពិសេសក្រសួងកិច្ចការនារី*»។

ក្រសួងកិច្ចការនារី កាលពីថ្ងៃទី១០ ខែមីនាបានចេញមុខកោតសរសើរមន្ត្រីនគរបាលអ្នកស្រី ស៊ីថុង សុខា ដែលបានបំពេញតួនាទីដោយការទទួលខុសត្រូវទាំងក្នុងពេលបំពេញការងារ និងតួនាទីជាម្ដាយដ៏ល្អ។ ក្រសួងកិច្ចការនារីក៏បានណែនាំទៅស្ថាប័ន អង្គភាព ដែលមានស្ត្រីជាមន្ត្រីក្រោមឱវាទ ឬជាបុគ្គលិក គួរបង្កើតបរិស្ថានការងារអំណោយផលដូចជា ទីកន្លែងបំបៅដោះកូនជាដើម។ តែទោះជាយ៉ាងណា ក្រសួងកិច្ចការនារី បានក្រើនរំឭកថា ករណីស្ថាប័នមិនទាន់មានទីកន្លែងសមរម្យស្ត្រីជាម្ដាយគួរមានក្រម៉ា ឬកន្សែង ដើម្បីឱ្យការបំបៅដោះកូននោះបានសមរម្យ ចៀសផុតពីការរិះគន់ពីមហាជនមួយចំនួន ដែលថាបង្កឱ្យមានរូបភាពមិនសមរម្យប៉ះពាល់ដល់តម្លៃ និងកិត្តិយសរបស់ស្ត្រីខ្មែរ។

ប្រតិកម្មរបស់ក្រសួងកិច្ចការនារីនេះ គឺបន្ទាប់ពីអធិការស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង លោក ជឹម អេង បានបង្ខំឱ្យនគរបាលក្រោមបង្គាប់ គឺអ្នកស្រី ស៊ីថុង សុខា ធ្វើកិច្ចសន្យាឈប់បង្ហោះរូបភាព បំបៅដោះកូនពេលធ្វើការក្រោមហេតុផលប៉ះពាល់កិត្តិយសនគរបាល និងស្ត្រីខ្មែរ។

ក្រុមអ្នកសិទ្ធិមនុស្សរិះគន់ថា ការបំបៅដោះកូនពេលកំពុងបំពេញការងារនោះ មិនមានអ្វីខុសឆ្គងឡើយ ហើយការបង្ហោះរូបភាពបំបៅដោះកូនតាមបណ្ដាញសង្គមនោះទៀតសោត ក៏ជាសិទ្ធិសេរីភាពបញ្ចេញមតិរបស់គាត់។ អ្នកសិទ្ធិមនុស្សថា ចំណាត់ការបែបនេះជាការបំបាក់ទឹកចិត្ត គំរាមកំហែង និងជាការរើសអើងស្ត្រីធ្ងន់ធ្ងរ។ លើសពីនេះក៏មានការទាមទារអោយអធិការស្រុកសុំទោសចំពោះទង្វើរបស់ខ្លួន។

អធិការស្រុកសៀមប៉ាង លោក ជឹម អេង បដិសេធការសុំទោសជាសាធារណៈ។ លោកបកស្រាយថា ការណែនាំ និងការបង្គាប់ឱ្យធ្វើកិច្ចសន្យានេះ គឺដោយសារមន្ត្រីរបស់លោករូបនេះ យករូបភាពបំពេញការងារទៅបង្ហោះជាសាធារណៈ៖ «*ខ្លួនគាត់បង្ហោះខ្លួនឯង ហើយកិច្ចសន្យាគាត់ធ្វើខ្លួនឯងបង្ហោះខ្លួនឯង អ៊ីចឹងមិនពាក់ព័ន្ធខាងខ្ញុំទៅសូមទោសអីទេ បានន័យថា មិនមែនខាងខ្ញុំតម្រូវឱ្យគាត់បង្ហោះទេ ខ្ញុំមានតែហាមឃាត់ កុំឱ្យគាត់បង្ហោះ* »។

ចំណែកស្នងការខេត្តស្ទឹងត្រែងលោក អូត ស៊ីវុត្ថា វិញ លោកថ្លែងការពារមន្ត្រីក្រោមបង្គាប់របស់លោកថា ថ្នាក់លើពុំបានដាក់ពិន័យចំពោះស្ត្រីជានគរបាលនេះនោះទេ ដោយគ្រាន់តែអប់រំណែនាំឱ្យរកកន្លែងសមរម្យបំបៅដោះកូន៖ «*ខាងអធិការអត់មានដាក់ពិន័យទេ ក្នុងនាមខ្ញុំស្នងការក៏អត់មានដាក់ពិន័យគាត់ដែរ គ្រាន់តែហៅគាត់ យើងបំបៅដោះទៅកន្លែងជញ្ជាំង និងគ្រលុកគ្រលៀតផ្ទះពលរដ្ឋជាប់ហ្នឹងទៅ កុំបំបៅកណ្ដាលវាលអ៊ីចឹង។ អធិការក៏លើកទឹកចិត្តគាត់ដែរ តាមរយៈខ្ញុំថ្ងៃទី ០៨ មិនា ហ្នឹង* »។

អនុប្រធានផ្នែកស្ត្រីនៃសមាគមអាដហុក (ADHOC) អ្នកស្រី មាស សារ៉ឹម យល់ថា ទង្វើរបស់អធិការស្រុកសៀមប៉ាងមិនត្រឹមតែប៉ះពាល់សិទ្ធិស្ត្រីនោះទេ គឺប៉ះពាល់ដល់សិទ្ធិកុមារ នឹងជះឥទ្ធិពលមិនល្អដល់សង្គម៖ «*ការមិនគោរពសិទ្ធិកុមារ និងការមិនគោរពសិទ្ធិស្ត្រីវាប៉ះពាល់ ហើយក្នុងនាមគាត់ជាបុរសមួយរូប ដែលគាត់កើត បានរស់រានមានជីវិតដោយសារម្ដាយ ដោយសារស្ត្រីហ្នឹងដែល ជះឥទ្ធិពលអាក្រក់ ដែលកម្ពុជាយើង មានរដ្ឋធម្មនុញ្ញក៏គាំទ្រ មានច្បាប់ពាក់ព័ន្ធក៏គាំទ្រទៀត បើសិនជាបង្កើតបទបញ្ជាផ្ទៃក្នុង វាផ្ទុយហ្នឹងរដ្ឋធម្មនុញ្ញ វាផ្ទុយហ្នឹង កតិកាសញ្ញាអន្តរជាតិ វាត្រូវលុបចោល ត្រូវដកចេញ* »។

រដ្ឋលេខាធិការ និងជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ អ្នកស្រី ជូ ប៊ុនអេង បានចេញលិខិតមួយច្បាប់កាលពីថ្ងៃទី១០ មីនា ដោយសម្ដែងការសោកស្ដាយយ៉ាងខ្លាំងចំពោះទង្វើរបស់អធិការស្រុកសៀមប៉ាង លោក ជឹម អេង។ អ្នកស្រីថា នេះជាការមិនបានវែកញែកឱ្យច្បាស់អំពីកំហុស និងគុណសម្បត្តិ។ អ្នកស្រីបន្តថាស្ត្រីមានកាពត្វកិច្ចទទួលខុសត្រូវទ្វេដង ដោយបំពេញការងារស្នូលក្នុងស្ថាប័នផង និងចិញ្ចឹមកូនផង ហេតុនេះអាជ្ញាធរគួរតែលើកទឹកចិត្ត និងរកមធ្យោបាយផ្ដល់លទ្ធភាពឱ្យគាត់ថែទាំកូនរបស់គាត់បាន។ មន្ត្រីជាន់ខ្ពស់ក្រសួងមហាផ្ទៃរូបនេះ ទូន្មានអធិការស្រុកសៀមប៉ាង លោក ជឹម អេង ឱ្យកោតសរសើរ លើកទឹកចិត្ត និងអនុញ្ញាតឱ្យស្ត្រីនគរបាលក្រោមបង្គាប់មានឱកាសថែទាំកូនបានគ្រប់គ្រាន់ ដូចអ្វីដែល «ម្ដាយលោកបានថែទាំលោកកាលពីនៅទារក» យ៉ាងដូច្នេះដែរ៕

## អភិបាលរងខេត្ត ដឹកនាំក្រុមការងារខេត្តកំពង់ចាម ដើម្បីទៅទទួល និងដឹកជញ្ជូនបងប្អូនពលករមកពីបណ្ដាខេត្តនៅតាមព្រំដែនកម្ពុជា-ថៃ

http://nokorwatnews.com/ 10-03-2021

ខេត្តកំពង់ចាម៖ តាមប្រភព ពីរដ្ឋបាលខេត្តកំពង់ចាមបានអោយដឹងថា៖ ក្រោយពីទទួលបានបទបញ្ជាដ៏ខ្ពង់ខ្ពស់ពីសម្ដេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ឱ្យទទួលយកពលករមកធ្វើចត្តាឡីស័ក នៅតាមបណ្ដាខេត្តរបស់ខ្លួនវិញលោក អ៊ុន ចាន់ដា អភិបាលនៃគណៈអភិបាលខេត្ត និងជាប្រធានកម្មការខេត្ត ប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ–១៩ បានចាត់ឲ្យ លោក កែវ នាឫទ្ធិ អភិបាលរងខេត្ត ដឹកនាំក្រុមការងារខេត្តកំពង់ចាមដើម្បីទៅទទួល និងដឹកជញ្ជូនបងប្អូនពលករ មកពីបណ្ដាខេត្តនៅតាមព្រំដែន កម្ពុជា–ថៃ ក្នុងនោះមាន៖ ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ ប៉ៃលិន និងខេត្តឧត្តរមានជ័យ ។ លោក កែវ នាឫទ្ធិ អភិបាលរងខេត្ត បានបញ្ជាក់ថា ក្នុងបេសកកម្មនាថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១នេះ ក្រុមការងារ ជាពិសេសក្រោមការជួយជ្រោមជ្រែង និងដឹកជញ្ជូន របស់បញ្ជាការដ្ឋានកងទ័ពជើងគោក កងយោធពលខេមរភូមិន្ទ បានដឹកជញ្ជូនបងប្អូនពលករ មកពីបណ្ដាខេត្តជាប់ព្រំដែនមកកាន់ខេត្តកំពង់ចាម បានចំនួន ៦៩នាក់។ លោកមានប្រសាសន៍ថា ប្រជាពលរដ្ឋខ្មែរទាំង ៦៩នាក់ ត្រូវបានអាជ្ញាធរថៃ បញ្ជូនមក កាន់ប្រទេសកម្ពុជា តាមច្រកជាប់ទល់ដែនថៃ ។

លោក លើកឡើងថា នាពេលថ្មីៗកន្លងទៅនេះ លោក អ៊ុន ចាន់ដា អភិបាលខេត្ត និងជាប្រធានគណៈកម្មការប្រយុទ្ធជម្ងឺកូវីដ–១៩ បានដឹកនាំប្រជុំ ដាក់ចេញយន្តការ ដើម្បីទទួលពលករត្រឡប់មកពីប្រទេសថៃ តាមច្រកព្រំដែន មកធ្វើចត្តាឡីស័ក ដែលរៀបចំឡើង ដោយរដ្ឋបាលខេត្តកំពង់ចាម ។

សូមបញ្ជាក់ថា៖ រដ្ឋបាលខេត្តកំពង់ចាម បានរៀបចំមណ្ឌលចត្តាឡីស័កចំនួន ០២កន្លែង គឺ ៖ នៅសណ្ឋាគារមេគង្គ និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគកំពង់ចាម និងកន្លែងសម្រាកព្យាបាល អ្នកផ្ទុកវីរុសកូវីដ-១៩ ចំនួន ១កន្លែង ស្ថិតនៅក្នុងមន្ទីរពេទ្យ ខេត្តកំពង់ចាម។ គិតត្រឹមថ្ងៃទី០៩ ខែមីនាឆ្នាំ២០២១នេះ មានបងប្អូនពលករ មកពីប្រទេសថៃ និងអ្នកពាក់ពន្ធ័ព្រឹត្តិការណ៍២០ កុម្ភៈ កំពុងធ្វើចត្តឡីសក័ ក្នុងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកំពង់ចាម ចំនួន៩៨នាក់ និងនៅសណ្ឋាគារមេគង្គចំនួន ៨៥នាក់៕

## អាជ្ញាធរបានត្រៀមខ្លួនរួចជាស្រេច ដើម្បីទទួលបងប្អូនពលករជាង ៤០០នាក់ មកពីខេត្តបន្ទាយមានជ័យ មកបន្តចត្តាឡីស័កនៅខេត្តកំពង់ធំ

http://www.freshnewsasia.com/ 2021-03-10 01:12pm

(កំពង់ធំ)៖ លោក សុខ លូ អភិបាលខេត្តកំពង់ធំនៅព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ បានត្រៀមខ្លួនរួចជាស្រេច ដើម្បីត្រៀមទទួលបងប្អូនពលករជាង ៤០០នាក់ មកពីខេត្តបន្ទាយមានជ័យ មកបន្តចត្តាឡីស័កនៅខេត្តកំពង់ធំ ដែលនឹងត្រូវមកដល់នៅយប់នេះ។ បន្ថែមលើសពីនេះទៀត លោក សុខ លូ ក៏បានជំរុញឲ្យលោកអភិបាលក្រុងស្រុក និងប្រធានមន្ទីរអង្គភាព ត្រូវចាត់ឲ្យមានមន្ត្រីប្រចាំការ ដើម្បីត្រៀមទទួលបងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃ និងតំបន់ផ្សេងៗ ត្រូវបន្តធ្វើចត្តាឡីស័កនៅក្នុងខេត្តកំពង់ធំ និងត្រៀមមធ្យោបាយ សម្រាប់ដឹកជញ្ជូននិងត្រៀមសម្ភារដើម្បីបងប្អូនពលករ យកទៅបន្តធ្វើចត្តាឡីស័កតាមក្រុងស្រុកបន្ថែមទៀត ព្រមទាំងត្រៀមរៀបចំអាហារសម្រាប់ពួកគាត់ផងដែរ។

ក្នុងនោះលោក សុខ លូ អភិបាលខេត្តកំពង់ធំ បានណែនាំដល់អាជ្ញាធរក្រុងស្រុក ត្រូវខិតខំពន្យល់ណែនាំ និងធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានរបស់ខ្លួន អោយរក្សាអនាម័យ អនុវត្តនូវវិធានការការពារ កូវីត ១៩ ៣ការពារ និង ៣កុំ របស់រាជរដ្ឋាភិបាល និងអនុវត្តតាមការណែនាំរបស់ក្រសួងសុខាភិបាល ជាពិសេសមិនត្រូវមានការជួបជុំគ្នា រាំលេងកំសាន្ត ចាក់ធុងបាសតាមភូមិ ការរៀបអាពាហ៍ពិពាហ៍ត្រូវកាត់បន្ថយអ្នកចូលរួម និងកាត់បន្ថយនូវកម្មវិធីណាដែលមិនចាំបាច់៕

## រយៈពេលបីថ្ងៃ មានពលករខ្មែរជិតពាក់កណ្តាលបានចាកចេញពីមណ្ឌលចត្តាឡីស័កពីខេត្តបន្ទាយមានជ័យទៅខេត្តសាមី

https://www.rasmeinews.com/ 10 March, 2021

ដោយ ៖ ភ្នំស្វាយ / បន្ទាយមានជ័យៈក្នុងរយៈពេល៣ថ្ងៃកន្លងមកនេះ (ថ្ងៃទី៨,៩និង១០ មីនា)ឆ្នាំ២០២១ មានពលករខ្មែរជិតពាក់កណ្តាល ឬជាង២.០០០ នាក់ បានចាកចេញពីមណ្ឌលចត្តាឡីស័កនានានិងមួយភាគតូចក៏មានពលករមកត្រង់ពីប្រទេសថៃ(ដោយមិនបាច់ចូលមណ្ឌលចត្តាឡីស័កនៅខេត្តខាងមុខ) គឺពីខេត្តបន្ទាយមានជ័យទៅខេត្តសាមីដែលជាលំនៅឋានរបស់បងប្អូនពលករ ។

លោក អ៊ុំ រាត្រី អភិបាលខេត្ត លោកស្រី ប៉ុក ណាឌី លោកស្រីរស់ សុផានី អភិបាលរងនៃខេត្តបន្ទាយមានជ័យ និងក្រុមការងារកាលពីថ្ងៃទី១០ ខែមីនា បានជូនដំណើរពលករខ្មែរ៨០២នាក់ ដែលត្រូវជញ្ជូនរថយន្តងទ័ពជើងគោកចំនួន៤៧គ្រឿង ចេញពីមណ្ឌលចត្តាឡីស័កវិទ្យាល័យសម្តេចឪ ;មណ្ឌលកងរ៉ា,,,និងមណ្ឌលឯទៀតក្នុងស្រុក /ក្រុង៨ទៀត ទៅកាន់មណ្ឌលនៃខេត្តសាមីលំនៅឋានពលករ ៖កំពង់ធំ ព្រៃវែង និងស្វាយរៀង ។

បើគិតពីថ្ងៃទី៨ ខែមីនា មានការបញ្ជូនពលករ(ប្រជាពលរដ្ឋ)ដែលកំពុងធ្វើចត្តាឡីស័កទៅចត្តាឡីស័កបន្តនៅខេត្ត រាជធានីនានាតាមរថយន្ត៣៧គ្រឿង មានចំនួន៦៨៧នាក់ ទៅខេត្តបាត់ដំបងនិងកំពង់ស្ពឺ។ ថ្ងៃទី៩ខែមីនា បានបញ្ជូនតាមរថយន្ត៣៦គ្រឿងនូវពលរដ្ឋចំនួន៦៤៦នាក់ ទៅខេត្តសៀមរាប កំពង់ចាម ត្បូងឃ្មុំនិងពោធិសាត់ ។ សរុប៣ថ្ងៃមានពលរដ្ឋចំនួន២.១៣៥នាក់ ឬស្មើជិតពាក់កណ្តាលនៃពលរដ្ឋ(ពលករខ្មែរ ) ដែលវិលត្រឡប់ពីប្រទេសមកមាតុប្រទេស ហើយស្នាក់នៅធ្វើចត្តាឡីស័កនៅខេត្តបន្ទាយមានជ័យ នៅសល់មានជិត៥.០០០នាក់ ។

លោកអភិបាលខេត្តបន្ទាយមានជ័យមានប្រសាន៍ថា៖ ពលករដែលជិះរថយន្តដឹកចេញពីមណ្ឌលចត្តាឡីស័កក្នុងខេត្តបន្ទាយមានជ័យនោះ មានសុខភាពល្អជាធម្មតាទេ ។ដោយក្នុងមណ្ឌលចត្តាឡីស័កនោះ រដ្ឋបាលខេត្តនុងក្រុមគ្រូពេទ្យបានយកចិត្តទុកដាក់ថែរក្សា និងផ្គត់ផ្គង់ស្បៀងអាហាអំណោយសម្តេចតេជោហ៊ុន សែន នាយករដ្ឋ

មន្ត្រីនិងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត ចំនួន៣ពេលក្នុង១ថ្ងៃៗ ។ពេលធ្វើដំណើរតាមរថយន្តទាំងនេះ ក៏ត្រូវផ្តល់ដល់ពលករនូវ មី និងទឹកសុទ្ធ ក្នុងការធ្វើដំណើរតាមផ្លូវផងទៀត ។

សូមរំលឹកដែរថា លោកឧត្តមសេនីយ៍ឯក ហ៊ុន ម៉ាណែត អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ មេបញ្ជាការកងទ័ពជើងគោកបានបញ្ជាឱ្យចេញរថយន្តរបស់កងទ័ពជើងគោកចំនួន ២០៤គ្រឿង ដើម្បីទៅជួយដឹកជញ្ជូនពលរដ្ឋខ្មែរ( ពលករ ) ដែលវិលមកពីប្រទេសថៃ មកកាន់ខេត្តនៅជាប់ព្រំដែនកម្ពុជា ថៃ។

សូមរំលឹកថា បន្ទាប់ពីសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីកម្ពុជា ដាក់បទបញ្ជាសម្រេចបិទការធ្វើចត្តាឡីស័កពលករនៅតាមបណ្តោយព្រំដែនកម្ពុជា ថៃឬខេត្តជួរមុខពីថ្ងៃទី៨ ខែមីនា ឆ្នាំ២០២១ ។ពោលគឺ ត្រូវដឹកទៅធ្វើចត្តាឡីស័កបន្តនៅខេត្តសាមីលំនៅឋានរបស់ពួកគាត ៕សរន

## ក្រុមការងារ ត្រូវទៅទទួលពលករ នៅបណ្តាខេត្ត ជាប់ព្រំដែនថៃ មកខេត្តសាមី ឱ្យបានឆាប់បំផុត

https://www.rasmeinews.com/ 10 March, 2021

**ដោយៈ បូកគោ / កំពតៈ** *ក្នុងកិច្ចប្រជុំ កាលពីរសៀល ថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ អភិបាល ខេត្តកំពត បានបង្កើតក្រុមការងារ រួចតម្រូវឱ្យប្រញាប់ប្រញាល់ ចេញទៅទទួលពលករ ពីបណ្តាខេត្តជាប់ព្រំដែនថៃ មកបន្តធ្វើចត្តាឡីស័ក មុននឹងវិលចូលស្រុកកំណើតវិញ។*

លោក ជាវ តាយ អភិបាលខេត្តកំពត បានមានប្រសាសន៍ថាៈ ទោះបីមកដល់ថ្ងៃនេះ រដ្ឋបាលខេត្តកំពត បានគ្រប់គ្រង ស្ថានការណ៍ ក៏ដូចជា បង្ការការឆ្លងរាលដាល ជំងឺកូវីដ១៩ បានល្អក្តី ថ្នាក់ដឹកនាំ នៅតែមានការព្រួយបារម្ភ និងប្រុងប្រយ័ត្នខ្ពស់ ចំពោះករណី ប្រកបដោយ ភាពប្រឈមនោះ។ បន្ថែមលើនេះ សម្តេចប្រមុខរាជរដ្ឋាភិបាល បានដាក់បទបញ្ជាបន្ទាន់ ក្នុងការតម្រូវឱ្យរដ្ឋបាលខេត្តនីមួយៗ ទៅទទួលយកពលករ វិលពីប្រទេសថៃ និងកំពុងស្នាក់នៅ បណ្តាខេត្ត ជាប់ព្រំដែន មកបន្តធ្វើចត្តាឡីស័ក ក្នុងខេត្តសាមីវិញ។ លោកអភិបាលខេត្ត បានបន្តថាៈ ផ្អែកតាមចំណាត់ការ ដ៏មឺុងម៉ាត់នោះ ក្រុមការងារ ក្នុងដែនសមត្ថកិច្ច ត្រូវតែប្រញាប់ប្រញាល់ អនុវត្តប្រកបដោយប្រសិទ្ធភាពបំផុត។ កិច្ចការនេះ នឹងជួយដល់បងប្អូនពលករទាំងអស់ទទួលបាននូវសុវត្ថិភាព ទាំងការមកកាន់មណ្ឌលចត្តាឡីស័ក ទាំងដំណើរបន្ត ទៅស្រុកកំណើតវិញ។ លោក ជាវ តាយ បានបញ្ជាក់ថាៈ ក្នុងករណីរថយន្តដឹកជញ្ជូន របស់កងទ័ពមិនមានទំនេរ រដ្ឋបាលខេត្ត ត្រូវជួលរថយន្តឯកជន ទៅទទួលឱ្យបានគ្រប់ចំនួន ព្រោះពលករ ជាអ្នកកំពត ដែលបានត្រឡប់មក ពីប្រទេសថៃ មានរហូតជាង ២០០ នាក់ឯណោះ។

សូមបញ្ជាក់ថា ចាប់ពីព្រឹកថ្ងៃទី៩ ខែមីនា រហូតដល់រសៀល ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ក្រុមការងាររបស់រដ្ឋបាលខេត្តកំពត បានទៅទទួលពលករ ពីបណ្តាខេត្តជាប់ព្រំដែនថៃ មកបន្តធ្វើចត្តាឡីស័ក នៅមណ្ឌលវិទ្យាល័យចំណេះទូទៅ និងបច្ចេកទេស ព្រះរាជសម្ភារ បាន ១០៣នាក់។ ការមកដល់របស់បងប្អូន ជាអ្នកចំណាកស្រុកអាចនឹងមានបន្ត បន្ទាប់ទៀត៕/V-PC

## ក្រោយធ្វើចត្តាឡីស័ក១៤ថ្ងៃ ពលករខ្មែរមកពីថៃ ជិត ៧០០ត្រូវអនុញ្ញាតឲ្យវិលទៅផ្ទះវិញ

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 09/03/2021

អាជ្ញាធរខេត្តបន្ទាយមានជ័យ បានសម្រេចឲ្យពលករខ្មែរមកពី ប្រទេសថៃ ចំនួន៦៨៧នាក់ ក្នុងនោះស្រី ៣៥៦ នាក់វិលត្រឡប់ ទៅផ្ទះវិញ បន្ទាប់ពីធ្វើចត្តាឡីស័ករយៈពេល ១៤ ថ្ងៃ។ ពលករទាំងនោះត្រូវជិះតាមរថយន្ត

របស់កងទ័ពមានចំនួន៣៦គ្រឿង កាលពីម្សិលមិញដោយមានអ្នកចូលរួមពិនិត្យ លោកអភិបាលក្រុងសិរីសោភ័ណ លោកមេបញ្ជាការកងរាជអាវុធហត្ថខេត្ត លោកអធិការនគរបាលខេត្តនិងមន្ត្រីពាក់ព័ន្ធជាច្រើននាក់ទៀត ។

លោក ហ៊ឹល រ៉ាយ៉ា អភិបាលក្រុងសិរីសោភ័ណ មានប្រសាសន៍ថា ពលករដែលជិះឡានដឹកចេញពីមណ្ឌលចត្តាឡីស័កចំរុះ ក្នុងខេត្តបន្ទាយមានជ័យនោះមាន សុខភាពល្អធម្មតាក្នុងមណ្ឌលចត្តាឡីស័កនោះក្រុមគ្រូពេទ្យបានយកចិត្ត ទុកដាក់ថែរក្សាផ្គត់ផ្គង់ ស្បៀងអាហារ ព្រឹកល្ងាច។ លោកបានឲ្យដឹងបន្តទៀតថា ឡាននិមួយៗដាក់មនុស្សតិចមិនប្រជ្រៀតគ្នា នោះទេស្របតាម វិធានសុខាភិបាលពេល ដឹកទៅដល់ខេត្ត នីមួយៗត្រូវដឹកបន្តបញ្ជូនទៅតាម មូលដ្ឋានក្នុង ករណី មានការ សង្ស័យ ត្រូវត្រួតពិនិត្យ សំណាក និងព្យាបាលបន្តទៀត ៕

## រយៈពេល៣ថ្ងៃ រដ្ឋបាលខេត្តសៀមរាបដឹកពលករ មកពីថៃជាង៧០០នាក់

https://thmeythmey.com/ 10, Mar 2021 ,  2:42 pm

សៀមរាប៖ រយៈពេល៣ថ្ងៃ ចាប់ពីថ្ងៃទី៧ ដល់ថ្ងៃទី៩ មីនា អាជ្ញាធរខេត្តសៀមរាប បានដឹកជញ្ជូនពលករខ្មែរពីថៃសរុបប្រមាណជាង៧០០នាក់ ដែលក្នុងនោះ អ្នកខ្លះ ធ្វើដំណើរទៅកាន់ខេត្តរៀងៗខ្លួន ហើយអ្នកខ្លះ ត្រូវទុកឲ្យធ្វើចត្តាឡីស័កនៅតាមខេត្តជាប់ព្រំដែន។

ក្បួនរថយន្តខេមរភូមិន្ទជាច្រើនគ្រឿង ដែលដឹកពលករតាមច្រកព្រំដែនកម្ពុជា-ថៃជាបន្តបន្ទាប់នារយៈពេលប៉ុន្មានថ្ងៃចុងក្រោយនេះ ទៅកាន់មណ្ឌលចត្តាឡីស័កក្នុងខេត្តសៀមរាប បន្ទាប់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជាសម្រេចឱ្យពលករទាំងនោះ ទៅធ្វើចត្តាឡីស័កតាមខេត្តគោលដៅរបស់ខ្លួន។ ត្រឹមរយៈពេល៣ថ្ងៃ ពីថ្ងៃទី៧ ដល់ទី៩ មីនា រដ្ឋបាលខេត្តសៀមរាបបានដឹកជញ្ជូនពលករសរុប៧២៥នាក់។

អភិបាលរងខេត្តសៀមរាប លោកស្រី យូ សុភា មានប្រសាសន៍ថា គិតត្រឹមថ្ងៃទី៩ មីនា គឺមានពលរកសរុប ៧២៥នាក់ហើយ ដែលត្រូវបានដឹកជញ្ជូនចេញពីច្រកព្រំដែននានានៃប្រទេសកម្ពុជា-ថៃ ចូលទៅខេត្តសៀមរាប។ លោកស្រីបន្ថែមថា គ្រាន់តែច្រកព្រំដែនប៉ោយប៉ែតមួយ គឺមានពលករសរុប៣២៤នាក់ ក្នុងនោះមានស្ត្រី ១៣៨ នាក់ កុមារ៣០នាក់ ដែលត្រូវបានដឹកទៅកាន់ខេត្តសៀមរាប។ បើតាមការបញ្ជាក់ពីលោកស្រីអភិបាលរង ពលករមួយចំនួនធំដែលដឹកជញ្ជូនមកពេលនេះ គឺបានធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័កក្នុងខេត្តជាប់ព្រំដែនរួចហើយ ហើយពួកគេនឹងត្រូវបានពិនិត្យសុខភាពម្តងទៀត បើករណីសង្ស័យនឹងតម្រូវឱ្យធ្វើចត្តាឡីស័កនៅមណ្ឌលគុរុកោសល្យខេត្ត ខណៈពលករដែលមានសុខភាពធម្មតា នឹងត្រូវដឹកជញ្ជូនបន្តដើម្បីទៅធ្វើចត្តាឡីស័កតាមស្រុកគោលដៅ។

គួរបញ្ជាក់ថាប្រមុខរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃទី៧ ខែមីនា បានប្រកាសឱ្យពលករខ្មែរ ដែលមានសុខភាពធម្មតា វិលចូលមកកម្ពុជាវិញតាមច្រកព្រំដែន មិនចាំបាច់ធ្វើចត្តាឡីស័កនៅតាមព្រំដែនដូចមុនទេ ហើយសម្រាប់អ្នកមានអាការឬសញ្ញាសង្ស័យ ត្រូវធ្វើចត្តាឡីស័កនៅតាមព្រំដែនដដែល។ ចំពោះអ្នកមានសុខភាពធម្មតា ត្រូវដឹកជញ្ជូនទៅតាមខេត្តរបស់ពួកគេរៀងៗខ្លួន តែត្រូវបន្តធ្វើចត្តាឡីស័កក្នុងខេត្តរបស់ពួកគេ៕

## កម្លាំងនគរបាលសហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋត្រឡប់ពីប្រទេសថៃមកប្រទេសកម្ពុជាវិញ យកទៅកាន់មណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 4:31 pm   10 មីនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃពុធ ទី១០ ខែមីនា ឆ្នាំ២០២១ តាមការណែនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯកប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ បានចាត់តាំងកម្លាំងជាមួយកម្លាំងអនុសេនាធំទី២, កម្លាំងវរសេនាតូចលេខ១ ,

កម្លាំងវរសេនាតូច៩៣៣, កម្លាំងសឹករងស្រុកសំពៅលូន, កម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបារាំងធ្លាក់នៃអធិការដ្ឋាននគរបាលស្រុកភ្នំព្រឹក និងកម្លាំងប្រជាការពារ បានទៅទទួលប្រជាពលរដ្ឋត្រឡប់មកប្រទេសកម្ពុជាវិញ ចំនួន ២០ នាក់ , ស្រី ៥នាក់ ក្នុងនោះ ក្មេងស្រី ២នាក់ និងក្មេងប្រុស ៤ នាក់ ពីចំណុចភូមិចំការត្រប់ ឃុំបារាំងធ្លាក់ស្រុកភ្នំព្រឹក ចំនួន ៥នាក់ , ស្រី ២នាក់ ក្នុងនោះក្មេងប្រុស ១នាក់ និងពីចំណុចភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ១៥ នាក់, ស្រី ៣ នាក់ ក្នុងនោះក្មេងប្រុស ៣ នាក់ , ក្មេងស្រី ២នាក់ ។ បន្ទាប់ពីធ្វើការសាកសួររួចក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យ ដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កវិទ្យាល័យពេជ្រចិន្តា ចំនួន៥នាក់, ស្រី ២នាក់ ក្នុងនោះក្មេងប្រុស១ នាក់ នឹងទៅមណ្ឌលចត្តាឡីស័កអនុវិទ្យាល័យកូនភ្នំ៣២ ចំនួន ១៥ នាក់, ស្រី ៣ នាក់ ក្នុងនោះក្មេងស្រី ២នាក់ និងក្មេងប្រុស ៣ នាក់ ៕

## កិច្ចប្រជុំពង្រឹងការងារសន្តិសុខ សណ្តាប់ធ្នាប់តាមបន្ទាត់ព្រំដែន ក្នុងស្រុកម៉ាឡៃ

http://cambodiapolice.com/policekh/ 11:47 am 10 មីនា 2021

ខេត្តបន្ទាយមានជ័យ ៖ នៅរសៀលថ្ងៃទី០៩ខែមីនា ឆ្នាំ២០២១ នៅសាលាស្រុកម៉ាឡៃ បានរៀបចំកិច្ចប្រជុំទាក់ទងនឹងការ ងារពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់ នៅតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រនៃស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ក្រោមវត្តមានចូលរទមរបស់លោកឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋាន សន្តិសុខផ្ទៃក្នុង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ពិធីនេះមានការចូលរួមពីលោកឧត្តមសេនីយ៍ទោសិទ្ធិ ឡោះ ស្នងការនគរ បាលខេត្តបន្ទាយមានជ័យ លោកឡៅ ឈួន អភិបាលស្រុកម៉ាឡៃ និងបណ្តាថ្នាក់ដឹកនាំអង្គភាពពាក់ព័ន្ធ ជាច្រើនរូប ។ បន្ទាប់ពីបានស្តាប់នូវរបាយសង្ខេប របស់បណ្តាថ្នាក់ដឹកនាំអង្គភាពពីចំណុចឈរជើងតាមបន្ទាត់ព្រំដែន ក្នុងភូមិសាស្ត្រនៃស្រុកម៉ាឡៃ ដែលមានកិច្ចសហការទប់ស្កាត់ការលួចឆ្លងដែនរបស់ពលករ ដើម្បីប្រយុទ្ធប្រឆាំងការរាតត្បាតមេរោគកូវីដ-១៩ ។

លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ ស្នងការដ្ឋាននគរបាលខេត្តមានកម្លាំងនគរបាលវរសេនាតូចការពារព្រំដសែនគោកចំនួន០៤ ឈរជើងតាមបន្ទាត់ព្រំដែន ក្រោយពីមានការផ្ទុះជម្ងឺកូវី១៩ នៅខេត្តសមុទ្រសាខនប្រទេសថៃនោះមក ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំង ជម្ងឺកូវីដ១៩ ពីសេសត្រួតពិនិត្យទប់ស្កាត់រាល់ការលួចឆ្លងដែនទៅមក របស់ពលករខ្មែរពីថៃចូលមកខ្មែរពីខ្មែរទៅថៃ ដើម្បីធានាបានសន្តិសុខ ស្នងការដ្ឋានបានបន្ថែមកម្លាំងនគរបាលស្រុក ក្រុងដែលមានភូមិ សាស្ត្រជាប់ព្រំដែន ក្នុងនោះក៏មានការសហការជាមួយកម្លាំងយោធា ដើម្បីរួមគ្នាទទួលខុសត្រូវក្នុងភូមិសាស្ត្រឈរជើង ។ ជាមួយគ្នានោះដែរ កម្លាំងសមត្ថកិច្ចយើងបង្ក្រាបបទល្មើសនាំឆ្លងដែនដោយមិនស្របច្បាប់បាន៣០ករណីឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ប្រុស ស្រីចំនួន៤៤នាក់ បញ្ជូនទៅសាលាដំបូងខេត្ត។ ជាមួយគ្នានោះដែរ ក៏បានចាត់តាំងកម្លាំងជំនាញចំនួន១៤០ នាក់ សហការជាមួយកម្លាំងសមត្ថកិច្ចចូលរួមការពារសន្តិសុខសណ្តាប់ធ្នាប់ តាមមណ្ឌលចត្តាឡីស័ក ទាំង១៦ ក្នុងខេត្ត។ ជាមួយគ្នានោះដែរ ស្នងការដ្ឋាន បានប្រើប្រាស់នូវវិធានការសុប មធ្យោបាយសរុបនិងកម្លាំងសរុប ដើម្បីឃ្លាំចាំមើលមុខសញ្ញាដែលជាក្រុមឧទ្ទាមក្រៅច្បាប់ ក្រែងមានបន្លំខ្លួនជាមួយពលរដ្ឋវិលមកស្រុកកំណើតនោះផងដែរ ។

មានមតិនាឱកាសនោះលោកឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋាន សន្តិសុខផ្ទៃក្នុង បានលើកឡើងថា៖ អនុវត្តតាមបទបញ្ជារបស់ឯកឧត្តម នាយឧត្តមសេនីយ៍សន្តិបណ្ឌិត នេត សាវឿន អគ្គ ស្នងការនគរបាលជាតិ ក្នុងការស្រាវជ្រាវរកមុខសញ្ញាមេខ្យល់នាំមនុស្សទៅថៃ ម្យ៉ាងវិញទៀតចូលឆ្នាំប្រពៃណីខ្មែរជិតឈានចូលមកដល់ដូច្នេះលំហូរពលករនឹងវិលមកលេងស្រុកកំណើតច្រើន ក្នុងនោះក៏អាចនឹងមានការឆ្លងនូវជម្ងឺកូវីដ១៩ ដល់ប្រជាពលរដ្ឋក្នុងស្រុក។ តាមបទបញ្ជាការអគ្គស្នងការនគរបាលជាតិ អគ្គស្នងការរង ទទួលការងារសន្តិសុខ គឺឲ្យចាប់ឃាត់មេខ្យល់ដែលនាំមនុស្សឆ្លងដែនដោយខុសច្បាប់ឲ្យខាងតែបាន ក្នុងនោះអ្វីដែលសំខាន់ ពួកក្រុមឧទ្ទាម

ក្រៅច្បាប់ដែលមានបំណងប៉ុនប៉ងបំផ្លិចបំផ្លាញប្រទេសជាតិ ។ លោកប្រធាននាយកដ្ឋាន ឧត្តមសេនីយ៍ សម វណ្ណវីរៈ បានបញ្ជាក់ថា៖ ដើម្បីទប់ស្កាត់ការរីករាលដាលជម្ងឺកូវីដនេះ សូមឲ្យកងកម្លាំងមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់បន្តសហការជាមួយកម្លាំងនគរបាល និងទប់ស្កាត់ឲ្យបានផងដែរពួកក្រុមឧទ្ទាមក្រៅច្បាប់ សហការឲ្យបានល្អជាមួយភាគីថៃ ដើម្បីរួមគ្នាទប់ស្កាត់នូវជម្ងឺកូវីដ១៩ និងបង្ក្រាបឲ្យខាងតែបានចំពោះមេខ្យល់ដែលនាំឆ្លងដែនមិនស្របច្បាប់ ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី១០ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១១៧នាក់ ស្រី ៤២នាក់ ក្នុងនោះកុមារា ៩នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣១នាក់ ស្រី ១២នាក់ កុមារា ៣នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៥នាក់ ស្រី ៧នាក់ កុមារា ១នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៥៧នាក់ ស្រី ២១នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៥-ច្រកដូង និងសំពៅលូន ស្រុកកំរៀង÷ ចំនួន ៤នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១១៧នាក់ ស្រី ៤២នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបនៅក្នុងថ្ងៃនេះ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករខ្មែរជាង១ពាន់នាក់ សម្រុកចេញពីថៃក្នុង១ថ្ងៃៗតាមច្រកព្រំដែនកម្ពុជា-ថៃ

https://www.kampucheathmey.com/ on March 10, 2021By Kang Tola

ពលករខ្មែរប្រមាណជាង១ពាន់នាក់ បានសម្រុកចេញពីប្រទេសថៃក្នុង១ថ្ងៃៗ តាមច្រកព្រំដែនខេត្តបន្ទាយមានជ័យនិងឧត្តរមានជ័យ ខណៈពិធីបុណ្យចូលឆ្នាំខ្មែរនឹងឈានចូលមកដល់នាពេលខាងមុខនេះ។

លោក លី សារី អភិបាលរង និងជាអ្នកនាំពាក្យសាលាខេត្តបន្ទាយមានជ័យបានឲ្យដឹងនៅថ្ងៃទី១០ មីនានេះថាមួយរយៈចុងក្រោយនេះ ចំនួនពលករខ្មែរត្រឡប់មកពីប្រទេសថៃ មានការកើនឡើងច្រើន ខុសពីប្រក្រតីដោយគ្រាន់តែច្រកទ្វារ ខេត្តបន្ទាយមានជ័យមួយប៉ុណ្ណោះ មានពលករខ្មែរប្រមាណពី ៥០០ ទៅ៧០០នាក់ ក្នុងមួយថ្ងៃៗ សម្រុកមកពីប្រទេសថៃ។ លោក លី សារី បានមានប្រសាសន៍បន្តថា ការដែលពលករសម្រុកត្រឡប់មកស្រុកវិញយ៉ាងគំហុកដូច្នេះ គឺដោយសារតែនៅថៃត្រូវសម្រាកត្រៀមបុណ្យចូលឆ្នាំថ្មី ដែលធ្វើឲ្យរោងចក្រ សហគ្រាសនៅថៃត្រូវឈប់សម្រាករយៈពេលយូរ ទើបធ្វើឲ្យពលករខ្មែរគ្មានការងារធ្វើហើយម្យ៉ាងទៀតគាប់ជួនគ្នានឹងជិតដល់ពិធីបុណ្យចូលឆ្នាំខ្មែរផងដែរ។

មិនខុសពីខេត្តបន្ទាយមានជ័យ លោក ឌី រ៉ាដូ អភិបាលរង និងអ្នកនាំពាក្យសាលាខេត្តឧត្តរមានជ័យបានមានប្រសាសន៍ថាចំ ណែកខេត្តឧត្តរមានជ័យក៏មានពលករខ្មែរប្រមាណពី៣០០ទៅ៤០០នាក់ក្នុង១ថ្ងៃៗបានចេញពីប្រទេសថៃឆ្លងកាត់តាមច្រកព្រំដែនអូរស្មាច់ ខណៈកាលពីមុនមានត្រឹមតែជាង១០០នាក់ប៉ុណ្ណោះ។

ផ្ទុយពីខេត្តទាំងពីរខាងលើ លោក សៀម ប៊ុនរិទ្ធិ អភិបាលរង និងជាអ្នកនាំពាក្យសាលាខេត្តបាត់ដំបងបានឲ្យដឹងដែរថា មួយរយៈចុងក្រោយនេះ មានពលករខ្មែរចេញមកពីប្រទេសថៃតាមច្រកព្រំដែនខេត្តបាត់ដំបងបែរជាមានចំនួនតិចជាងមុនទៅវិញ គឺមានប្រមាណតែ២០ទៅ៣០នាក់ប៉ុណ្ណោះ ខណៈកាលពីមុនមានរហូតដល់ខ្ទង់រយនាក់ឯណោះ។ លោកអភិបាលរងខេត្តបានពន្យល់ថា ការថយចុះចំនួនពលករតាមច្រកព្រំដែនខេត្តបាត់ដំបងនេះដោយសាររដ្ឋបាលខេត្តបានសហការជាមួយអាជ្ញាធរថៃក្នុងការទប់ស្កាត់មេខ្យល់ ដែលតែងតែនាំពលករខ្មែរឆ្លងដែនដោយខុសច្បាប់បានទាន់ពេលវេលា។ លោកបានបន្តថា ម្យ៉ាងទៀតអាចបណ្តាលមកពីអាជ្ញាធរថៃនាំពលករទៅតាមច្រកព្រំដែនខេត្តផ្សេងទៀតដូចជាខេត្តបន្ទាយមានជ័យ ឬ ខេត្តឧត្តរមានជ័យព្រោះថា អាជ្ញាធរថៃតែងតែប្រមូលផ្តុំពលករខ្មែរឲ្យបានច្រើនជាមុនសិនទើបបញ្ជូនចេញពីប្រទេសថៃ។

យ៉ាងណាក៏ដោយ អ្នកនាំពាក្យសាលាខេត្តទាំងបីខាងលើបានអះអាងដូចៗគ្នាថា ពលករដែលឆ្លងកាត់តាមព្រំដែនចូលមកកម្ពុជាត្រូវបានក្រុមការងារចម្រុះដែលរួមមានតំណាងក្រសួងសុខាភិបាល អាជ្ញាធរពាក់ព័ន្ធត្រួតពិនិត្យសុខភាពយ៉ាងម៉ត់ចត់។ បើពលករណាមានសុខភាពល្អទុកមួយកន្លែង ដើម្បីធ្វើការទំនាក់ទំនងជាមួយខេត្តផ្សេងៗឲ្យមកយកទៅធ្វើចត្តាឡីស័កនៅតាមស្រុកកំណើតគេរៀងៗខ្លួន។ ក្នុងករណីពលករណាមានបញ្ហាសុខភាពដែលមានអាការៈសង្ស័យថា មានឆ្លងជំងឺកូវីដ១៩ត្រូវឃាត់ខ្លួនគាត់សិនត្រូវបញ្ជូនគាត់ធ្វើចត្តាឡីស័ក និង យកសំណាកទៅពិនិត្យរកជំងឺកូវីដ១៩។ នៅពេលលទ្ធផលតេស្តអវិជ្ជមានពីរដងនោះ ទើបត្រូវបញ្ជូនទៅកាន់ស្រុកកំណើតវិញដោយធ្វើចត្តាឡីស័កបន្តនៅមូលដ្ឋានរបស់គាត់វិញ៕ *ដោយ ៖ សំអឿន*

## ពលករខ្មែរមួយចំនួនជួបការលំបាកបន្ទាប់ ពីថៅកែមិនបន្តទិដ្ឋាការដល់ពួកគាត់

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2021-03-10

ពលករខ្មែរធ្វើការក្នុងរោងចក្រសាច់មាន់នៅខេត្តឈុនបូរី (Chonburi) ប្រទេសថៃ ព្រួយបារម្ភអំពីជីវភាពរស់នៅប្រចាំថ្ងៃ ដោយសារថៅកែជនជាតិថៃមិនធ្វើឯកសារបន្តសុពលភាពទិដ្ឋាការឱ្យពួកគេ ក្រោយពីពួកគេតវ៉ាទាមទារលក្ខខណ្ឌការងារសមរម្យ។ មន្ត្រីអង្គការសង្គមស៊ីវិល ចាត់ទុករឿងនេះជាការរំលោភបំពានសិទ្ធិពលករ។

ពលករខ្មែរចំនួន ៣២នាក់ឱ្យដឹងថា ថៅកែថៃមិនចេញឯកសារដើម្បីបន្តទិដ្ឋាការឱ្យពួកគាត់បានធ្វើការងារស្របច្បាប់នោះទេ ក្រោមហេតុផលថា ពួកគេបាននាំគ្នាតវ៉ាឱ្យខូចផលប្រយោជន៍របស់ក្រុមហ៊ុន។ ពលករមួយចំនួនបានចាកចេញពីរោងចក្រ ដោយពុំទាន់រកការងារធ្វើបាននៅឡើយទេ។ ក្រុមពលករខ្មែរធ្វើការរោងចក្រសាច់មាន់នៅខេត្តឈុនបូរី (Chonburi) ប្រាប់អាស៊ីសេរីនៅព្រឹកថ្ងៃទី១០ មីនាថា ពួកលោកបានតវ៉ាទាមទារឱ្យថៅកែថៃជួយតសុពលភាពទិដ្ឋាការ ដើម្បីបានធ្វើការងារឡើងវិញ ប៉ុន្តែត្រូវបានថៅកែបដិសេធ។ ក្រុមពលករទាំងនេះ បញ្ជាក់ថាពួកលោកពិបាករកការងារធ្វើ ហើយត្រូវចំណាយប្រាក់ច្រើន ដើម្បីធ្វើទិដ្ឋាការជាមួយថៅកែថ្មី៖ «គឺយើងចង់ឱ្យខាងក្រុមហ៊ុន តវីសាឱ្យអ្នកទាំង ៣២នាក់វិញ ព្រោះអីតាមការយល់ឃើញរបស់ពលករទាំងអស់គ្នា គាត់មិនខុសអ្វីទេ គឺគាត់គ្រាន់តែនិយាយដើម្បីការពារផលប្រយោជន៍ពលករទាំងអស់គ្នា។ បច្ចុប្បន្ន បើសិនជាពួកខ្ញុំទៅកម្ពុជាក៏មិនបានព្រោះមានការធ្វើចត្តាឡីស័ក ១៤ថ្ងៃ ហើយមិនសិនជាមិនត្រឡប់ទៅកម្ពុជា ទោរកការងារផ្សេងក៏វា ខាតពេលវេលានិងត្រូវចំណាយប្រាក់ជាច្រើនទៀត ដើម្បីរកចាំការងារថ្មី»។

កាលពីថ្ងៃទី៧ មីនា ពលករខ្មែរប្រមាណ ១.០០០នាក់ ធ្វើការនៅរោងចក្រសាច់មាន់ ក្នុងខេត្តឈុនបុរី បាននាំគ្នាតវ៉ា ដោយសារតែថៅកែកាត់ប្រាក់ខែពួកគាត់ និងមិនផ្តល់ទិដ្ឋាការជូនពលករចំនួន ៣២នាក់។ រឿងនេះ

ដោយសារថៅកែមិនពេញចិត្តតំណាងពលករទាំងនោះ ដែលដឹកនាំពលករតវ៉ាទាមទារលក្ខខណ្ឌការងារសមរម្យ កាលពីខែតុលាឆ្នាំ២០២០ កន្លងទៅ។ ក្រុមពលករបន្តថា កន្លងមកពួកលោកបានទាក់ទងទៅមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីឱ្យជួយធ្វើអន្តរាគមន៍ជាច្រើនលើករួចមកហើយ ប៉ុន្តែរហូតមកទល់នេះ ពុំមានមន្ត្រីណាចុះទៅដោះស្រាយជូនពួកលោកឡើយ។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយពីក្ដីកង្វល់របស់ពលករនេះបានទេនៅថ្ងៃទី១០ មីនា។ អាស៊ីសេរីក៏មិនអាចទាក់ទងអ្នកនាំពាក្យក្រសួងការងារ លោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយអំពីបញ្ហានេះបានដែរដោយទូរស័ព្ទចូលជាច្រើនដង តែពុំមានអ្នកទទួល។

ទោះជាយ៉ាងណាក្តី មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា ថ្លែងថា នេះជាទង្វើអមនុស្សធម៌ ពីព្រោះអំឡុងពេលនេះពលករពិបាករកការងារធ្វើ ដោយសារការរាតត្បាតជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលរូបនេះបន្ថែមថា មន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃគួរតែអន្តរាគមន៍ដល់ពលករជាបន្ទាន់ ដើម្បីឱ្យពួកគាត់បានចូលធ្វើការឡើងវិញ។លោក ឌី ថេហូយ៉ា ជឿថា រឿងនេះប្រសិនបើអាជ្ញាធរខ្មែរមិនជួយអន្តរាគមន៍ដល់ពលករទេនោះ នឹងធ្វើឱ្យថៅកែថៃបានចិត្ត ហើយចេះតែធ្វើបាបពលករខ្មែរជាបន្តបន្ទាប់ទៀត៖ «បើយើងនិយាយពីតួនាទីរបស់រដ្ឋយើងគឺអត់ឆ្លើយតាមកាតព្វកិច្ច ក្នុងការឆ្លើយតបចំពោះពលរដ្ឋខ្លួនឯង។ ទី២ ក្រុមហ៊ុនពាក់ព័ន្ធដែលបញ្ជូនពលករទៅហ្នឹងក៏មិនឃើញចេញមុខដោះស្រាយ ហើយបើតាមដែលខ្ញុំដឹងពួកហ្នឹងដូចជាមានការឃុបឃិតគ្នាយកអង្គហេតុផ្សេងៗ ហ្នឹងស្ដាប់តែពីខាងនិយោជកទេ។ នៅពេលនិយោជកធ្វើរបាយការណ៍មកថា មានកំហុសឆ្គងអី វាមានការសម្រេចទៅតាមរបាយការណ៍នោះ អាហ្នឹងគឺថា វាអត់ត្រឹមត្រូវទេ និងវាអសីលធម៌»។

រោងចក្រសាច់មាន់នៅខេត្តឈុនបូរី មានពលករខ្មែរប្រមាណ ៣.០០០នាក់ធ្វើការ។ ពលករភាគច្រើនចូលធ្វើការងារនៅទីនោះប្រមាណពី ៣ ទៅ ៦ឆ្នាំហើយ ដោយបានប្រាក់ឈ្នួលចន្លោះពី ១.២០០ ទៅ ១៥.០០០ បាត ឬស្មើនឹងពី ៤០០ ទៅ ៥០០ដុល្លារក្នុងមួយខែ។ របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា មានពលករខ្មែរធ្វើការស្របច្បាប់ និងមិនស្របច្បាប់ប្រមាណ ១លាន ៨សែននាក់ធ្វើការងារនៅប្រទេសថៃ៕

## ថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១

### លោកជំទាវ ជូ ប៊ុនអេង បានជួបសំណេះសំណាលជាមួយ លោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា អធិការរង នៃអធិការដ្ឋានស្រុកសៀមប៉ាង

https://cen-news.com/ ByPen Srey Neat March 11, 2021

ភ្នំពេញ ៖ នៅរសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) អនុប្រធានក្រុមប្រឹក្សាជាតិដើម្បីស្ត្រី អនុប្រធានសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍ និងជាប្រធានក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ បាននាំយកថវិកាមួយចំនួន ជាថវិកាផ្ទាល់ខ្លួន និងមន្ត្រីក្រោមឱវាទរបស់អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ព្រមទាំងសប្បុរសជនរួមមាន លោកជំទាវឧកញ៉ាបណ្ឌិត សៀង ចាន់ហេង នាយិកាក្រុមហ៊ុនហេងអភិវឌ្ឍន៍និងជាស្ថាបនិករមណីយដ្ឋានរាជិនីលង្វែក ចំនួន៥០០ដុល្លា និងលោកជំទាវ សុខ វិល័យ រដ្ឋលេខាធិការក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភានិងអធិការកិច្ច ចំនួន១០០ដុល្លា សរុបចំនួន៧០០០០០រៀល និង៧០០ដុល្លាអាមេរិក ជូនចំពោះលោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា ជាអធិការរងទទួលការងារចរាចរណ៍ នៃអធិការដ្ឋាននគរបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង។ មានវត្តមាននៅក្នុងជំនួបនេះផងដែរ មានលោកជំទាវ ឧ.ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន គជបជ លោកជំទាវ ឧ.ទោ រ៉ែន សិរីលក្ខិណា អគ្គលេខាធិការរង លោកស្រី ផាន់ ណារ៉ា អភិបាលរងស្រុកសៀមប៉ាង ដែលបានរួមដំណើរមកជាមួយពីខេត្តស្ទឹងត្រែង ។

គួរបញ្ជាក់ផងដែរថា កាលពីថ្ងៃទី៩ ខែមីនា ឆ្នាំ២០២១ លោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា ត្រូវបានលោកអធិការស្រុកសៀមប៉ាង ព្រមានឱ្យសុំទោសជាសាធារណៈ ព្រមទាំងហៅទៅធ្វើកិច្ចសន្យាមួយដែលត្រូវបានលោកពន្យល់ថា "ការបំបៅកូនក្នុងឯកសណ្ឋានជារឿងមិនសមរម្យ ធ្វើឱ្យប៉ះពាល់កិត្តិយសអង្គភាពនគរបាល និងប៉ះពាល់កិត្តិយសស្ត្រីខ្មែរ" ក្រោយពីបានឃើញលោកស្រីបង្ហោះរូបភាពកំពុងបំបៅកូនអាយុ១ខួប២ខែ នៅក្នុងឯកសណ្ឋានការងារ និងនៅកន្លែងការងារផ្ទាល់តាមដងផ្លូវកំពុងបំពេញភារកិច្ច។

ភ្លាមៗនោះ ដោយបានមើលឃើញពីការមិនផ្តល់តម្លៃ ប្រាស់ចាកអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក៏ដូចជាការលើកទឹកចិត្តស្ត្រីក្នុងការចិញ្ចឹមទារកដោយទឹកដោះម្តាយរបស់ក្រសួងសុខាភិបាល លោកជំទាវ ជូ ប៊ុនអេងបានចេញសារលិខិតជូនចំពោះឯកឧត្តមអភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែងក្នុងន័យថា "ខ្ញុំមានការសោកស្តាយជាខ្លាំង ដែលលោកអធិការបានប្រើឥរិយាបថបែបនេះ និងមិនបានរែកញែកឱ្យច្បាស់ពីកំហុស និងគុណសម្បត្តិ។ក្នុងស្ថានភាពជាស្ត្រីដែលមានភារកិច្ចទទួលខុសត្រូវទ្វេរដងលើសពីបុរសគឺបំពេញការងារស្នូលក្នុងអង្គភាព ស្ថាប័នផង និងត្រូវចិញ្ចឹមបីបាច់ថែរទាំកូន តាំងពីក្នុងផ្ទៃរហូត កើតមក និងបន្តទៅទៀតដល់ពេញវ័យ បើទោះជាបុរសជាស្វាមី ឬអ្នកដែលជាថ្នាក់ដឹកនាំមិនបានយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនាង ទទួលបាន នូវឱកាសថែរទាំកូនបានងាយស្រួលយ៉ាងណាក៏ដោយ ក៏នាងមិនបោះបង់កូន និងការងារស្នូលរបស់នាងដែរ។ លោកអធិការគួរតែសម្តែងនូវការកោតសរសើ លើកទឹកចិត្ត និងរិះរកមធ្យោបាយឱ្យមន្ត្រីស្ត្រីបែបនេះ ទទួលបាននូវការយកចិត្តទុកដាក់និងឱ្យគាត់មានឱកាសគ្រប់គ្រាន់ថែរទាំកូនដូចម្តាយលោកថែរទាំលោកកាលពីនៅទារក និងភរិយាលោកថែរទាំកូនលោកដូចគ្នាដែរ។

"បន្ថែមទៅទៀត ក្រសួងកិច្ចការនារីក៏បានចេញនូវសេចក្តីថ្លែងការណ៍ ដែលមានអត្ថន័យថា " ក្រសួងកិច្ចការនារីសូមសម្តែងនូវការកោតសរសើចំពោះលោកស្រី អនុសេនីយ៍ទោ ស៊ីថុង សុខា ដែលបានបង្ហាញពីការទទួលខុសត្រូវខ្ពស់ ទាំងក្នុងការបំពេញភារកិច្ចជូនស្ថាប័ន និងតួនាទី ជាម្តាយដ៏ល្អក្នុងការចិញ្ចឹមបីបាច់និងផ្តល់ភាពកក់ក្តៅដល់កូន។ ក្នុងន័យនេះ ស្ថាប័នអង្គភាពដែលមានស្ត្រី ជាមន្ត្រីក្រោមឱវាទឬជាបុគ្គលិកបំពេញការងារគួរបង្កើតបរិស្ថានការងារអំណោយផល ដូចជាទីកន្លែងបំបៅដោះកូន និងអនុញ្ញាតឱ្យស្ត្រីដែលមានកូនតូចអាចបំពេញការងារផង និងបំពេញតួនាទីជាម្តាយផង។ ក្រោយពីមានលិខិតអន្តរាគមន៍របស់លោកជំទាវ ជូ ប៊ុនអេង និងក្រសួងកិច្ចការនារី យើងឃើញមានការសាទរពីសំណាក់សាធារណៈជន និងមានការចូលរួមចំណែកលើកទឹកចិត្តដោយពាក្យសំដីថវិកា និងសម្ភារៈជាច្រើន ជូនដល់លោកស្រី ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## ពលករខ្មែរ២០នាក់ត្រូវបានអាជ្ញាធរឃាត់ខ្លួនក្រោយត្រឡប់ពីថៃតាមច្រករបៀង និង បានគេចវេះការធ្វើចត្តាឡីស័ក

https://www.facebook.com/CHNChannelNews/ ថ្ងៃទី១១ ខែមិនា ឆ្នាំ២០២១ ម៉ោង ១០:៣៣:២៥

ភ្នំពេញ៖ ពលករខ្មែរចំនួន២០នាក់ ដែលបានត្រឡប់មកពីថៃតាមច្រករបៀង ប៉ុន្តែព្យាយាមគេចវេះ ពីការធ្វើចត្តាឡីស័ក ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន រួចប្រគល់ឱ្យគ្រូពេទ្យអនុវត្តវិធានការសុខាភិបាល, យោងតាមសេចក្តីរាយការណ៍ចុះថ្ងៃទី១០ ខែមិនា។ សេចក្តីរាយការណ៍បានឱ្យដឹងថា ពលករខ្មែរទាំង ២០នាក់នោះ បានធ្វើដំណើរដោយថ្មើរជើងតាមផ្លូវកាត់ តាមច្រករបៀងនៅ ចំណុច៖ ភូមិចម្ការគ្រប់ ឃុំបារាំងធ្លាក់ ស្រុកភ្នំព្រឹក និង ភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ដោយពួកគេគេចវេះមិនព្រមចូលធ្វើចត្តាឡី តាមការណែនាំ របស់ក្រសួងសុខាភិបាល ក៏ដូចជាវិធានការរបស់រាជរដ្ឋាភិបាល។

មន្ត្រីនគរបាលបានបញ្ជាក់ដែរថា កងកម្លាំងបានប្រគល់ពលករខ្មែរ២០នាក់នេះ ទៅមណ្ឌលចត្តាឡីស័ក អនុវិទ្យាល័យកូនភ្នំ ៣២ ដើម្បីពិនិត្យសុខភាព និងយកវត្ថុសំណាក។ ដោយក្នុងនោះ គឺតម្រូវឱ្យសម្រាកតាមដាន រយៈពេល១៤ថ្ងៃ ដើម្បីបញ្ចៀសការរីករាលដាល ជំងឺកូវីដ-១៩ ឆ្លងចូលក្នុងសហគមន៍។

## ពលករខ្មែរប្រមាណជាង៦០០នាក់ត្រូវបានអាជ្ញាធរខេត្តបន្ទាយមានជ័យបញ្ជូនមកកាន់ខេត្តកំពង់ធំ ដើម្បីធ្វើចត្តាឡីស័កបន្ត

https://khmernote.com.kh/ ព័ត៌មានជាតិ March 11, 2021 srey nuch

ខេត្តកំពង់ធំ៖ យោងតាមការចុះផ្សាយរបស់រដ្ឋបាលខេត្តកំពង់ធំ បានឲ្យដឹងថា ឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ និងក្រុមការងារទទួលពលករមកពីប្រទេសថៃប្រមាណជាង ៦០០នាក់ ត្រូវបានអាជ្ញាធរខេត្តបន្ទាយមានជ័យ បញ្ជូនមកកាន់ខេត្តកំពង់ធំ ដើម្បីធ្វើចត្តាឡីស័កបន្តទៀត នាល្ងាចថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដើម្បីទប់ស្កាត់ និងការរីករាលដាលមេរោគកូវិដ១៩។ ជាមួយគ្នានោះដែរឯកឧត្តម សុខ លូ អភិបាលខេត្តកំពង់ធំ មានប្រសាសន៍លើកឡើងថា ពលករប្រុសស្រី ប្រមាណជាង ៦០០នាក់ ដែលមានស្រុកកំណើតនៅក្នុងខេត្តកំពង់ធំ ត្រូវបានអាជ្ញាធរខេត្តបន្ទាយមានជ័យបញ្ជូនមកនៅពេលនេះ គឺដើម្បីយកមកធ្វើចត្តាឡីស័កបន្តទៀត អោយបានគ្រប់ចំនួន១៤ថ្ងៃ ទើបអនុញ្ញាតិអោយពួកគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋានរៀងៗខ្លួន ។

ឯកឧត្តម សុខ លូ បន្តថា ពលករទាំងអស់នេះ គឺយើងបានបែងចែកអោយទៅតាមក្រុងស្រុកនីមួយៗ មិនទុកអោយនៅក្នុងមណ្ឌលចត្តាឡីស័ក វិទ្យាល័យកំពង់ធំទាំងអស់ទេ គឺអោយពួកគាត់ទៅធ្វើចត្តាឡីស័កតាមស្រុករបស់ពួកគាត់ គឺមានន័យថា តាមមណ្ឌលចត្តាឡីស័ករបស់ស្រុកនីមួយៗ ។ ទន្ទឹមនោះដែរ ឯកឧត្តមអភិបាលខេត្តកំពង់ធំបានអំពាវនាវដល់ពលករគ្រប់ សូមកុំគេចវេះពីការធ្វើចត្តាឡីស័កអោយសោះ ។ បើមិនស្រឡាញ់ខ្លួនឯងទេ សូមកុំបំផ្លាញក្តីសុខអ្នកដទៃអោយសោះ។ ឯកឧត្តមបានបញ្ជាក់ទៀតថា បងប្អូនពលករបានមកធ្វើចត្តាឡីស័កនាពេលនេះ មានក្រុមគ្រូពេទ្យជំនាញ អាជ្ញាធរ មន្ទីរគ្រប់ស្ថាប័ន សមត្ថកិច្ចទាំង៣ គឺ កម្លាំងនគរបាលខេត្ត កម្លាំងអាវុធហត្ថខេត្ត កម្លាំងយោធា បានរង់ចាំទទួល ការពារសុខ សន្តិសុខជូនបងប្អូនពលករគ្រប់រូប នឹងចែកបាយ ចែកទឹកដល់ពួកគាត់ផងដែរ ៕

## ពលករ៧៩៥នាក់ ដែលត្រឡប់មកពីថៃ ត្រូវបានអាជ្ញាធរដឹកដល់ខេត្តព្រៃវែង ដើម្បីយកទៅធ្វើចត្តាឡីស័ក

http://www.freshnewsasia.com/ 2021-03-11 04:32pm

(ព្រៃវែង)៖ ពលករចំណាកស្រុកចំនួន៧៩៥នាក់ ត្រូវបានអាជ្ញាធរដឹកតាមរថយន្តចំនួន ៣០គ្រឿង មកកាន់ខេត្តព្រៃវែង ដើម្បីនាំធ្វើចត្តាឡីស័កនៅតាមបណ្តាស្រុកក្រុងនានាក្នុងខេត្ត។ នេះបើយោងតាមរបាយការណ៍របស់រដ្ឋបាលក្រុងព្រៃវែង ដែលអង្គភាព Fresh News ទទួលបាននៅព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១នេះ។

សូមបញ្ជាក់ថា ខេត្តព្រៃវែង គិតត្រឹមល្ងាចថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ មានមនុស្សចំនួន២៣នាក់ បានឆ្លងជំងឺកូវីដ១៩ ពីលោកគ្រូពេទ្យពេទ្យម្នាក់ នៅសម្ភពព្យាបាលមួយស្ថិតនៅក្នុងស្រុកពាមរក៍ ខេត្តព្រៃវែង។ ក្នុងនោះរដ្ឋបាលខេត្តព្រៃវែង បានចេញសេចក្តីជូនដល់ប្រជាពលរដ្ឋ ដែលពាក់ព័ន្ធនឹងម្ចាស់មន្ទីរសម្រាកព្យាបាល និងសម្ភពគិតចាប់ពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ រហូតដល់ពេលនេះ សូមសហការជាមួយសមត្ថកិច្ច និងមន្ទីរជំនាញដោយត្រូវទៅពិនិត្យសុខភាព និងយកសំណាកនៅ មន្ទីរពេទ្យបង្អែកអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែង។

ដោយឡែកចំពោះបងប្អូន ដែលមិនស្ថិតនៅក្នុងព្រឹត្តិការណ៍នេះ ប្រសិនបើមានរោគសញ្ញាដូចជា៖ ផ្តាសាយ ក្តៅខ្លួន ក្អក ហៀរសំបោរ ឈឺបំពង់ក ឬមានរោគសញ្ញាស្រដៀង សូមអញ្ជើញទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យ ឬ

មណ្ឌលសុខភាព ដែលស្ថិតនៅជិតកន្លែងបងប្អូនរស់នៅ ឬវាយការណ៍ទៅអាជ្ញាធរមូលដ្ឋានជាបន្ទាន់។ ទន្ទឹមនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានសម្រេចផ្អាកដំណើរការគ្រឹះស្ថានសិក្សាសាធារណៈ និងឯកជនទូទាំងខេត្តព្រៃវែងផងដែរ៕

## ពលករខ្មែរ ៩នាក់ និងកុមារ ៤នាក់ ដែលរស់នៅ ធ្វើការខុសច្បាប់នៅម៉ាឡេស៊ី និងមកដល់កម្ពុជាល្ងាចថ្ងៃនេះ

https://dap-news.com/national/ ByKD102 Posted on March 11, 2021

**ភ្នំពេញ៖ ដោយមានការជួយសម្របសម្រួល របស់ស្ថានទូតកម្ពុជាប្រចាំប្រទេសម៉ាឡេស៊ី ពលករ ពលការិនីខ្មែរចំនួន ៩នាក់ និងកុមារ ៤នាក់ ដែលបានមករស់នៅ និងធ្វើការខុសច្បាប់ នៅប្រទេសម៉ាឡេស៊ី នឹងមកដល់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ តាមជើងយន្តហោះ អាកាសចរណ៍សិង្ហបូរីលេខ SQ5008 នៅម៉ោង ៥៖៣៥នាទីល្ងាច ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១នេះ ។** តាមរយៈបណ្តាញសង្គមតេឡេក្រាម នៅមុននេះបន្តិច លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសខ្មែរ បានឲ្យដឹងបន្តថា ស្ថានទូតបានចេញលិខិត ធ្វើដំណើរបណ្តោះអាសន្ន ចំពោះអ្នកដែលគ្មានលិខិតឆ្លងដែន និង រៀបចំឯកសារទៅអគ្គនាយកដ្ឋាន អន្តោប្រវេសន៍ម៉ាឡេស៊ី ជូនទៅធ្វើតេស្ត កូវីដ១៩ ព្រមទាំងបានចាត់ មន្ត្រីជូនពលករ ពលការិនីខាងលើ ទៅអាកាសយានដ្ឋានអន្តរជាតិ KLIA ផងដែរ ៕

## ក្រុមអង្គការសង្គមស៊ីវិល៣៩ស្ថាប័នស្នើឱ្យលើកកម្ពស់សិទ្ធិស្ត្រីនៅកន្លែងការងារ

https://www.rfa.org/khmer/ ដោយ មាន ឫទ្ធិ 2021-03-11

ក្រុមអង្គការ សមាគមនិងសហជីព ចំនួន ៣៩ស្ថាប័ន ដែលភាគច្រើនធ្វើការផ្នែកលើកស្ទួយសិទ្ធិស្ត្រី និងសិទ្ធិមនុស្ស ខកចិត្តជាខ្លាំងចំពោះករណីមន្ត្រីនគរបាលជាស្ត្រីម្នាក់ នៅខេត្តស្ទឹងត្រែង ប្រឈមនឹងវិធានការវិន័យ ដោយសារការបង្ហោះរូបភាពបំបៅដោះកូនក្នុងសំលៀកបំពាក់ឯកសណ្ឋាននគរបាលក្នុងទំព័រហ្វេសប៊ុករបស់ខ្លួន។ ក្រុមអង្គការសង្គមស៊ីវិលទាំងនេះចាត់ទុកករណីនេះជាឧទាហរណ៍ស្រាប់បង្ហាញថា រដ្ឋាភិបាលខកខានការពារសិទ្ធិស្ត្រីនៅកន្លែងធ្វើការងារ បើទោះបីជាប្រទេសកម្ពុជាបានផ្តល់សច្ចាប័ណ្ណលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទនិងការពារសិទ្ធិធ្វើការងារដោយពុំមានការរើសអើងក្តី។ ក្រុមអង្គការដែលចេញសេចក្តីថ្លែងការណ៍រួមមាន អង្គការសីលកា មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(CCHR)អង្គការក្លាហាន អង្គការលីកាដូ និងសមាគមអាដហុកជាដើម។ ក្រុមអង្គការទាំងនេះលើកឡើងថា ស្ថាប័នការងារជាច្រើនពុំបានផ្តល់ហេដ្ឋារចនាសម្ព័ន្ធ និងបរិក្ខារមើលថែទាំទារកឱ្យបានគ្រប់គ្រាន់សម្រាប់បុគ្គលិក ឬកម្មករនិយោជិតជាម្តាយនៅឡើយទេ ហើយប្រការនេះគឺជាឧបសគ្គដ៏ធំ រារាំងស្ត្រីក្នុងការឡើងដំណែងជាថ្នាក់ដឹកនាំ។ ក្រុមអង្គការសង្គមស៊ីវិលបន្ថែមថា ដើម្បីឱ្យស្ត្រីទទួលបានសិទ្ធិនៅកន្លែងធ្វើការ អង្គភាពត្រូវផ្តល់ហេដ្ឋារចនាសម្ព័ន្ធនិងបរិក្ខារមើលថែទារក និងពេលវេលាសម្រាកបំបៅដោះកូន ដោយទទួលបានប្រាក់ឈ្នួល ព្រមទាំងបង្កភាពងាយស្រួលដល់អាជីពការងាររបស់ពួកគេ។ ការចេញសេចក្តីថ្លែងការណ៍រួមគ្នារបស់ក្រុមអង្គការសង្គមស៊ីវិលនេះ ធ្វើឡើងបន្ទាប់ពីអធិការស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែងលោក ជឹម អេង បានបង្ខំឱ្យស្ត្រីជានគរបាលម្នាក់ឈ្មោះ ស៊ីថុង សុខា ឱ្យធ្វើកិច្ចសន្យាឈប់បង្ហោះរូបភាពបំបៅដោះកូនពេលធ្វើការក្រោមហេតុផលប៉ះពាល់កិត្តិយសនគរបាល និងស្ត្រីខ្មែរ។ ក្រុមអង្គការសង្គមស៊ីវិលគូសបញ្ជាក់ថា ជារឿងគួរឱ្យអាម៉ាស់ចំពោះការតម្រូវឱ្យស្ត្រីជានគរបាលនោះសូមទោសក្រោមហេតុផលធ្វើឱ្យប៉ះពាល់កិត្តិយសរបស់អង្គភាពនិងស្ត្រីខ្មែរ ហើយតម្រូវឱ្យចុះកិច្ចសន្យាបញ្ឈប់។

នាយិកាអង្គការសីលកា (SILAKA) អ្នកស្រី សេង រាសី មានប្រសាសន៍ថា ទង្វើរបស់អធិការស្រុកសៀមប៉ាងជះឥទ្ធិពលមិនល្អដល់អារម្មណ៍របស់ស្ត្រីផ្សេងទៀត ដោយពួកគេនឹងខ្លាចញញើតក្នុងការសម្តែងមតិតាមបណ្តាញ

សង្គម និងបង្ហោះរូបភាពបំបៅដោះកូននៅកន្លែងការងារ។ អ្នកស្រីជឿថា សេចក្ដីថ្លែងការណ៍នេះ ភ្ជាប់ជាមួយការរិះគន់របស់មហាជន នឹងធ្វើឱ្យកន្លែងការងាររបស់នគរបាលស្រុកសៀមប៉ាងត្រូវបានកែប្រែឱ្យល្អប្រសើរវិញ៖ *«ការលើកឡើងរបស់ភាគីពាក់ព័ន្ធទាំងអស់នឹងអាចធ្វើឱ្យកន្លែងការងាររបស់បងស្រី សុខា មានការកែប្រែឥរិយាបថ និងគំនិត។ យើងសង្ឃឹមថា ការចេញសេចក្ដីថ្លែងការណ៍ហ្នឹងជាការក្រើងរំឭកឱ្យគ្នាទៅវិញទៅមកហើយកែប្រែស្ថានភាពឱ្យកាន់តែប្រសើរឡើង»។* ក្រុមអង្គការសង្គមស៊ីវិលបានជំរុញឱ្យអគ្គស្នងការនគរបាលជាតិ គួរមានវិធានការកែតម្រូវដើម្បីធានាថា ករណីបែបនេះនឹងពុំកើតឡើងជាថ្មីទៀតឡើយ។

អាស៊ីសេរីមិនអាចទាក់ទងប្រធានអង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលលោក ផៃ ស៊ីផាន និងអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិលោក ឆាយ គឹមខឿន ដើម្បីសុំការឆ្លើយតបចំពោះសេចក្ដីថ្លែងការណ៍របស់ក្រុមអង្គការសង្គមស៊ីវិលនេះទេនៅថ្ងៃទី១១ ខែមីនា។ រីឯស្ត្រីជានគរបាលអ្នកស្រី ស៊ីថុង សុខា វិញក៏អាស៊ីសេរីមិនទាន់អាចទាក់ទងបានដែរ។

ក្រុមអង្គការសង្គមស៊ីវិលនៅតែទាមទារឱ្យអធិការស្រុកសៀមប៉ាងចេញមុខសុំទោសជាសាធារណៈចំពោះទង្វើឆ្គាំឆ្គងរបស់ខ្លួន ដែលពួកគេហៅថា ជាការធ្វើឱ្យប៉ះពាល់ដល់កិត្តិយសនិងសេចក្ដីថ្លៃថ្នូររបស់មន្ត្រីក្រោមបង្គាប់។ ប៉ុន្តែអធិការស្រុកសៀមប៉ាងលោក ជឹម អេង បានប្រាប់អាស៊ីសេរីថា លោកនឹងមិនសុំទោសជាសាធារណៈឡើយ៖ *«ខ្លួនគាត់បង្ហោះខ្លួនឯង ហើយកិច្ចសន្យាគាត់ធ្វើខ្លួនឯងបង្ហោះខ្លួនឯង អ៊ីចឹងមិនពាក់ព័ន្ធខាងខ្ញុំទៅសូមទោសអីទេ បានន័យថាមិនមែនខាងខ្ញុំតម្រូវឱ្យគាត់បង្ហោះទេខ្ញុំមានតែហាមឃាត់កុំឱ្យគាត់បង្ហោះ»។*

ក្រុមអង្គការសង្គមស៊ីវិលទាំង ៣៩ស្ថាប័នស្នើឱ្យរដ្ឋាភិបាលចាត់វិធានការសមស្របដើម្បីធានាថា ឪពុកម្ដាយគ្រប់រូបបំពេញការងារដោយទទួលបានការគាំទ្រនៅកន្លែងការងារ និងចាត់វិធានការដាក់លាក់ដើម្បីធានាថា សិទ្ធិរបស់ស្ត្រីត្រូវបានគោរពនិងលើកកម្ពស់។ ជាពិសេសពួកគេទទូចដល់រដ្ឋាភិបាលអនុវត្តអនុសាសន៍ទាំងឡាយទាក់ទងនឹងការបង្កើនកិច្ចប្រឹងប្រែងលុបបំបាត់ការរើសអើងស្ត្រីភេទនិងបញ្ឈប់ការរឹតត្បិតលើសេរីភាពបញ្ចេញមតិ៕

## ទស្សនៈនានា លើបណ្ដាញសង្គម ជុំវិញស្ត្រីនគរបាល ដែលបំបៅកូនពេលម៉ោងធ្វើការ

https://www.rfa.org/khmer/ ដោយ សេក បណ្ឌិត 2021-03-11

ការសរសេរលិខិតសុំទោសមេកើយ ពីស្ត្រីនគរបាលម្នាក់ មានឋានៈជាអនុសេនីយ៍ទោ ឈ្មោះ ស៊ីថុង សុខា នៃស្នងការនគរបាលស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដែលបំបៅកូនពេលម៉ោងធ្វើការនោះ បានធ្វើឲ្យអ្នកប្រើប្រាស់បណ្ដាញសង្គមហ្វេសប៊ុកចាប់អារម្មណ៍ និងបញ្ចេញទស្សនៈព្រោងព្រាតជុំវិញរឿងនេះ ចាប់តាំងពីថ្ងៃទី៩ មីនាមក។ តើទស្សនមតិទាំងនោះ វិជ្ជមាន ឬអវិជ្ជមាន ចំពោះរឿងនេះ? រឿងរ៉ាវនេះ ពីដំបូងផ្ដើមចេញពីគណនីហ្វេសប៊ុកឈ្មោះ កូនកាត់ឡាវ (Sokha Konkatlao) ដែលបានផុសរូបថតស្ត្រីស្លៀកពាក់ឯកសណ្ឋានជាមន្ត្រី ប៉ូលិសចរាចរណ៍ អង្គុយលើកៅអីជ័រ ក្បែរតុដែកមួយតាមដងផ្លូវនៅជនបទ ដើម្បីបំបៅកូន។

ទីតាំងទំនងជាទីកន្លែងប៉ុស្តិ៍ត្រួតពិនិត្យអ្វីមួយ។ នៅពីលើរូបថតនោះ មានសរសេរឃ្លាមួយ បែបស៊ីអារម្មណ៍គ្រាន់បើថា៖ ព្រោះតែពាក្យថាម្ដាយ មិនថាក្នុងកាលៈទេសៈណាទេ ដើម្បីកូនភ្លេចអស់ហើយការអៀនខ្មាស នេះហើយជីវិតពិត។ រូបភាពនេះ ត្រូវបានអ្នកប្រើប្រាស់បណ្ដាញសង្គម ចែករំលែកតគ្នា ឬហៅ Share ពីមួយទៅមួយ។ ក្រោយមក ម្ចាស់គណនីហ្វេសប៊ុកដដែលនេះ ក៏បានផុសម្ដងទៀត នូវរូបដដែលនេះ ដោយភ្ជាប់មកជាមួយលិខិតសរសេរដោយដៃផ្ទាល់ផង និងអក្សរពុម្ពផង ដែលមានន័យស្រដៀងគ្នា។ លិខិតនោះសរសេរថា នាងខ្ញុំអនុសេនីយ៍ទោ ស៊ីថុង សុខា អត្តលេខ271655 សូមចេញមុខសុំទោសជាសាធារណៈក្នុង FACEBOOK ចំពោះការផុសរូបភាពបំបៅដោះកូននៅកន្លែងធ្វើការ និងស្លៀកឈុតឯកសណ្ឋានកាលពីថ្ងៃទី២ មីនាកន្លងមកនេះ។ ការផុសទៅនេះ នាងខ្ញុំពុំមានគោលបំណងធ្វើឱ្យប៉ះពាល់ដល់កិត្តិយសអង្គភាពនគរបាល ព្រមទាំងប៉ះពាល់ដល់កិត្តិយសស្ត្រីខ្មែរ

ទេ។ អាស្រ័យដូចនេះសូមអង្គភាព និងថ្នាក់ដឹកនាំគ្រប់ជាន់ថ្នាក់មេត្តាដោយក្តីអនុគ្រោះ។ លិខិតមួយទៀតសរសេរដោយដៃ ស្រដៀងគ្នាប៉ុន្តែ មានបន្ថែមនូវកិច្ចសន្យា ២ចំណុចៈ ១/ នាងខ្ញុំគ្មានបំណងផុស Facebook ដែលមិនសមរម្យ ធ្វើឲ្យប៉ះពាល់ដល់កិត្តិយស អង្គភាពនគរបាល ព្រមទាំងប៉ះពាល់ដល់កិត្តិយសស្ត្រីខ្មែរទេ។ ២/ ប្រសិនបើនាងខ្ញុំមិនគោរពពាក្យសន្យា ខាងលើនាងខ្ញុំសូមទទួលខុសត្រូវ ចំពោះច្បាប់ជាធរមាន។ លិខិតនេះ ធ្វើនៅថ្ងៃទី៩ មីនា មួយថ្ងៃក្រោយទិវាសិទ្ធិនារី ៨មីនា ឆ្នាំ២០២១ ដោយមានផ្តិតមេដៃសាមីខ្លួន ឈ្មោះ ស៊ីថុង សុខា ផង។

អ្នកប្រើប្រាស់បណ្តាញសង្គម ហាក់មិនចង់ឃើញការសូមទោសមេកើយ ដោយធ្វើកិច្ចសន្យាទទួលកំហុសរបស់នគរបាលជាស្ត្រីនោះជាសាធារណៈ ដោយហេតុបំបៅកូន ពេលម៉ោងធ្វើការនោះឡើយ។ ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ Mao Chandara បានផុសរូប ស្ត្រីជាសមាជិកព្រឹទ្ធសភាអូស្ត្រាលី ដែលបំបៅកូនពេលប្រជុំ។ ហើយសរសេរ Comment ថា រៀនមើលគេ មើលឯងផង! ស្អីទៅហៅថា យេនឌ័រ? ១ឆ្នាំៗ ចាយលុយលើកម្មវិធីនេះអស់ប៉ុន្មាន ដើម្បីលើកកម្ពស់សិទ្ធិស្ត្រី? ចំណែកម្ចាស់គណនីហ្វេសប៊ុកឈ្មោះChantha Muth ក៏បានផុសរូបស្ត្រី ស៊ីថុង សុខា បំបៅកូន អមជាមួយកិច្ចសន្យាសរសេរដោយដៃ និងរូបស្ត្រីជាសមាជិកព្រឹទ្ធសភាអូស្ត្រាលី ដែលបំបៅកូនពេលប្រជុំ ដែលទំនងជាចង់ឲ្យប្រៀបធៀបគ្នា។ Chantha Muth ក៏បានសរសេរ Comment ជាសំណួរថា តើការបំបៅដោះកូនក្នុងម៉ោងធ្វើការ ឬកំពុងបំពេញតួនាទីសាធារណៈ រំលោភក្រមសីលធម៌របស់នគរបាលជាតិ ឬបញ្ញត្តិច្បាប់ណាដែរ? ក្រសួងកិច្ចការនារី ឬ អង្គការមិនមែនរដ្ឋាភិបាល-សមាគមធ្វើការលើការលើកកម្ពស់សិទ្ធិស្ត្រី និងសមភាពយេនឌ័រ គួរតែបង្ហាញជំហរចំពោះរឿងនេះ។ **ដោយឡែក ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ** Ly DA RA ក៏បានផុសរូបស្ត្រី ស៊ីថុង សុខា បំបៅកូន និងComment តប ចំពោះរឿងនេះដែរ ដោយលើកពីទិដ្ឋភាពច្បាប់ថា ទាំងច្បាប់ក៏មិនខុស និងទាំងសីលធម៌ក៏មិនខុស!

1/ បើជានិយោជិត (កម្មករ) វិញ ច្បាប់ការងារតម្រូវឲ្យនីយោជក (ថៅកែ) ត្រូវតែធ្វើបន្ទប់សម្រាប់មាតាបំបៅដោះកូនក្នុងម៉ោងការងារ (បើនិយោជកមិនគោរពតាមវិធាននេះ និយោជកត្រូវទទួលពិន័យ)។

2/ រីឯព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកនៃមន្ត្រីនគរបាល គឺអត់មានចែងអំពីការរៀបចំបន្ទប់សម្រាប់មាតាបំបៅដោះកូនក្នុងម៉ោងការងារទេ ដូច្នេះបើចង់ចាប់កំហុស គឺខុសមេអង្គភាពទៅវិញទេ!

3/ ចំពោះសីលធម៌ គឺមិនខុសទាល់តែសោះ ព្រោះការបញ្ចេញដើមទ្រូងប៉ុនពីរធ្នាប់ ដើម្បីកូនបៅដោះ មិនមែនជាការបញ្ចេញកេរខ្មាសស៊ិចស៊ីឯណា បើប្រៀបធៀបទៅនឹងទ្រូងអ្នកលក់តាមអនឡាញវិញ មិនបាច់ថ្លែង តាំងពីបំពង់កហូតដល់គល់ផ្ចិត វាលធេញហ្មង។

4/ រូបភាពនេះបង្ហាញពីព្រហ្មវិហារធម៌របស់ម្តាយ។

គ្រូ ហៀង សូមគោរពវីរៈភាពរបស់ប្អូនស្រី ស៊ីថុង សុខា Sokha Konkatlao។

ដោយឡែក **ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ** ម៉ែន ណាត ក៏បានលើរឿងនេះ និងបានសរសេរ Comment លើទឹកចិត្ត ដល់ស្ត្រីនគរបាល ស៊ីថុង សុខា ថា ស៊ីថុងសុខា គាប្បី ត្រូវបានលើកទឹកចិត្ត មិនមែនជាទណ្ឌកម្មទេ។ លោកសូមអំពាវនាវដល់ក្រសួងមហាផ្ទៃឲ្យពិនិត្យមើលរឿងនេះ។ លោកសរសេរបន្តថា អ្នកស្រី ស៊ីថុង សុខា គ្មានកំហុសអីទេ គាត់បំបៅដោះកូនបានគ្រប់ពេល ទោះបីក្នុងពេលម៉ោងធ្វើការក៏ដោយ។ គ្មានច្បាប់ណាដាក់ទណ្ឌកម្មទៅកាតព្វកិច្ចរបស់ម្តាយ ដែលមានកូនង៉ាបៀបនេះឡើយ។ អ្នកស្រីគប្បីទទួលបានការលើកទឹកចិត្តបន្ថែមទៀត ពីក្រុមការងារ និងថ្នាក់លើរបស់គាត់ នូវអ្វីដែលគាត់ខំបម្រើការងារជូនស្ថាប័ន។ ថ្នាក់លើរបស់អ្នកស្រី ស៊ីថុង សុខា គួរចេះខ្មាសអៀនខ្លួនឯងផងទៅ ដែលបង្ខំឲ្យអ្នកស្រី សរសេរកិច្ចសន្យា ជាទណ្ឌកម្មរបស់អាជ្ញាធរ និងជាការបំបាក់ទឹកចិត្តដល់ស្ត្រីដទៃទៀត ដែលបំពេញការងារ ដូចអ្នកស្រី ស៊ីថុង ដែរនោះ។ លោកសូមអំពាវនាវដល់ស្ថាប័នពាក់ព័ន្ធអាជ្ញាធរខេត្តស្ទឹងត្រែង និងក្រសួងមហាផ្ទៃ ពិនិត្យលើទង្វើរបស់មន្ត្រីថ្នាក់លើខ្លះ ឲ្យលប់ចោលកិច្ចសន្យានោះចោល រួចផ្តល់រង្វាន់លើកទឹកចិត្តដល់អ្នកស្រីធ្វើជាគំរូល្អសម្រាប់ស្ត្រីឯទៀត នៅក្នុងស្ថាប័នមន្ត្រីរាជការ និងស្ថាប័នឯទៀត។

**ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ** Phorn Phana បានសរសេរខឹងឯង ចំពោះរឿងនេះដែរថា ប្លែកៗ ស្រុករំជួល! នាំគ្នាឈប់ថ្ងៃ ៨ មីនា រាល់ឆ្នាំ ស្រែកតាមគ្នាទិវាសិទ្ធិនារីៗ។ ដល់តែនារីជាម៉ែថតបង្ហោះរូបបំបៅដោះកូននៅកន្លែងធ្វើការហៅគ្នាអប់រំ។ តើបទវិន័យប៉ូលិស ហាមបំបៅដោះកូន នៅកន្លែងធ្វើការឬ? តើស្ត្រីបំបៅដោះកូនវាអាក្រក់កន្លែងណា? ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ **Sea Seakleng សៀ សៀកឡេង ថា «គ្រាន់តែអ៊ីចឹង ដល់ថ្នាក់ត្រូវធ្វើកិច្ចសន្យាទៀត?» ការបំបៅដោះកូនខុសត្រង់ណា? តើគួរទុកឲ្យកូនស្រេកឃ្លាន ឬយ៉ាងណា? ម្ចាស់គណនីហ្វេសប៊ុក ឈ្មោះ** Chandara Samban បន្ទរចុងក្រោយថា ស្រុកអច្ឆរិយ ពេលគេធ្វើចំណាត់ការអីក៏អច្ឆរិយ ច្បាប់គ្មានមនុស្សធម៌ ជាច្បាប់របស់ពួកបិសាច៕

## ការបំបៅកូនរបស់ស្ត្រីប៉ូលិសទទួលការកោតសរសើរ រិះគន់ និងព្រមាន

https://khmer.voanews.com/ 12 មិនា 2021 ហ៊ុល រស្មី

ភ្នំពេញៈ ការបង្ហោះរូបថតបំបៅកូនដោយស្ត្រីជាមន្ត្រីនគរបាលម្នាក់ ក្នុងស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង បានបន្តទាញប្រតិកម្មជាបន្តបន្ទាប់ ទាំងការគាំទ្រ ការកោតសរសើរ និងការរិះគន់។ កាលពីថ្ងៃទី២ ខែមីនា ដោយបានប្រើគណនីហ្វេសប៊ុកឈ្មោះ Sokha Konkatlao ក្នុងពេលបំពេញការងារ លោកស្រី ស៊ីថុង សុខា បានថតបង្ហោះរូបដែលលោកស្រីក្នុងឯកសណ្ឋានជាប៉ូលិសចរាចរណ៍ កំពុងបំបៅកូន នៅលើកៅអីមុខតុ ដែលដាក់នៅតាមដងផ្លូវ។ លោកស្រីសរសេរសារអមជាមួយរូបថតនៅលើហ្វេសប៊ុកថា៖ «ព្រោះតែជាពាក្យថាម្តាយ មិនថាក្នុងកាលៈទេសៈណាទេ ដើម្បីកូន ភ្លេចអស់ភាពអៀនខ្មាស់ (នេះហើយជីវិតពិត)»។

ក្នុងសេចក្តីថ្លែងការណ៍មួយចុះថ្ងៃទី ១០ ខែមីនា ក្រសួងកិច្ចការនារីបានកោតសរសើរចំពោះលោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា ដែលបានបង្ហាញអំពីការទទួលខុសត្រូវខ្ពស់ ទាំងក្នុងការបំពេញភារកិច្ចជូនស្ថាប័ននិងតួនាទីជាម្តាយដ៏ល្អ ក្នុងការចិញ្ចឹមបីបាច់និងផ្តល់ភាពកក់ក្តៅដល់កូន នៅពេលដែលស្ថាប័នដែលស្ត្រីរូបនោះបម្រើការមិនទាន់បានបង្កើតបរិស្ថានការងារអំណោយផល ដូចជាទីកន្លែងបំបៅកូន។ បន្ថែមលើការសរសើរនោះ ក្រសួងបានលើកឡើងថា៖ «ក្នុងករណីស្ថាប័នមិនទាន់មានទីកន្លែងសមរម្យ ស្ត្រីសាមីគួរមានឧបករណ៍ដូចជាក្រម៉ា ឬកន្សែងដើម្បីអនុញ្ញាតឲ្យការបំបៅកូននេះអាចប្រព្រឹត្តទៅដោយភាពសមរម្យ និងរលូន ជៀសផុតពីការរិះគន់ពីមហាជនមួយចំនួន ដែលថា ជារូបភាពមិនសមរម្យប៉ះពាល់ដល់តម្លៃនិងកិត្តិយសរបស់ស្ត្រីខ្មែរ»។

ក្រុមមន្ត្រីសិទ្ធិមនុស្សបង្ហាញការស្រងាកចិត្តជាមួយសេចក្តីថ្លែងការណ៍របស់ក្រសួងកិច្ចការនារី។ ពួកគេនិយាយថា ការបំបៅកូនទោះនៅទីណាក៏ដោយ គួរតែត្រូវបានលើកទឹកចិត្ត និងមិនគួរបានការស្តីបន្ទោស នៅពេលស្ត្រីបំបៅកូនក្នុងម៉ោងធ្វើការទេ។ លោកស្រី ចក់ សុភាព នាយិកាមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ប្រាប់វីអូអេនៅថ្ងៃព្រហស្បតិ៍យ៉ាងដូច្នេះថា៖ «ការបំបៅដោះ ទោះបីនៅទីឯកជនក្តី ទីសាធារណៈក្តី វាមិនមែនជារឿងអីត្រូវ ឬក៏ប៉ះពាល់កិត្តិយសស្ត្រីទេ ប៉ុន្តែវាបែរជាលើកកម្ពស់នូវកិត្តិយសស្ត្រីទៅវិញ ដែលៗពួកគាត់ទន្ទឹមនឹងការបំពេញភារកិច្ចការងារផ្លូវការ ហើយគាត់នូវតែបំពេញតួនាទីជាមាតា ក្នុងពេលតែមួយ ដែលមិនមានអ្នកដទៃឧទាហរណ៍ជាបុរសអីជាដើមហ្នឹង អាចធ្វើបាន»។ លោកស្រីនិយាយថា លោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា មិនគួរទទួលបានការរិះគន់ពីក្រុមមន្ត្រីរដ្ឋាភិបាល ចំពោះកាយវិការជាម្តាយដែលបំបៅកូន ក្នុងពេលចុះបំពេញការងារទេ។ មេដឹកនាំអង្គការសិទ្ធិមនុស្សរូបនេះយល់ថា ការទិតៀនរបស់ក្រសួងកិច្ចការនារីមកលើលោកស្រី ស៊ីថុង សុខា ថាជាការរើសអើង និងអាចបង្អាក់សម្រេចបាននូវសមភាពយេនឌ័ររវាងស្ត្រីនិងបុរស។ «ការណ៍ដែលយើងនាំគ្នាដាក់បន្ទុក ហើយរិះគន់ដូចតួយ៉ាងថ្នាក់លើរបស់ស្ត្រីជានគរបាល ហៅគាត់ឲ្យធ្វើការសុំទោស ហើយធ្វើកិច្ចសន្យាអីបែបនោះ គឺថ្នាក់លើគាត់នោះទេ ដែលត្រូវធ្វើការសុំទោសទៅស្ត្រីហ្នឹងវិញ ហើយត្រូវបង្ហាញវិធានការដាក់លាក់ចំពោះសមភាពយេនឌ័រ ហើយ

និងការភាពអំណោយផលការបង្កភាពអំណោយផលសម្រាប់ស្ថាប័នខ្លួន ក្នុងការគាំទ្រដល់ស្ត្រីដែលគាត់ជាម្តាយទាំងឡាយ ដែលគាត់កំពុងបំពេញភារកិច្ចនៅក្នុងស្ថាប័នគាត់ហ្នឹង»។

លោកស្រី ម៉ាន ចិន្តា រដ្ឋលេខាធិការក្រសួងកិច្ចការនារី បដិសេធមិនផ្តល់ការអធិប្បាយទេ នៅថ្ងៃព្រហស្បតិ៍នេះ។ មួយសប្តាហ៍ក្រោយការបង្ហោះរូបថតនោះ លោកស្រី ស៊ីថុង សុខា ត្រូវបានថ្នាក់លើរបស់គាត់ ហៅឲ្យចូលខ្លួនធ្វើកិច្ចសន្យាបញ្ឈប់ការបង្ហោះរូបបំបៅកូន ក្នុងទីសាធារណៈ ទាំងមានពាក់ឯកសណ្ឋាន។ លោកស្រី សុខា ក៏បានធ្វើកិច្ចសន្យាថា ឈប់បង្ហោះរូបភាពរបៀបនេះតទៅទៀត ហើយថា លោកស្រីគ្មានចេតនាធ្វើឲ្យប៉ះពាល់កិត្តិយសអង្គភាព និងស្ត្រីខ្មែរទូទៅទេ។

ក្រោយមក លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃទទួលបន្ទុកប្រឆាំងអំពើជួញដូរមនុស្ស បានសម្តែងការសោកស្តាយជាខ្លាំង ក្រោយលោកស្រីឃើញសេចក្តីរាយការណ៍សារព័ត៌មួយថា លោកអធិការស្រុកសៀមប៉ាងបានហៅលោកស្រីនគរបាលម្នាក់ ដែលគាត់បំបៅកូននៅគុការងារ តាមផ្លូវប្រហែលជានគរបាលចរាចរណ៍ ដើម្បីទៅព្រមាននិងឲ្យធ្វើកិច្ចសន្យាបញ្ឈប់ការបំបៅកូនបែបនេះ។ ក្នុងលិខិតមួយធ្វើជូនអភិបាលខេត្តស្ទឹងត្រែង កាលពីថ្ងៃទី ១០ ខែមីនា លោកស្រី ជូ ប៊ុនអេង បានសរសេរថា៖ «បានអានអត្ថបទនេះ ខ្ញុំមានការសោកស្តាយជាខ្លាំង ដែលលោកអធិការបានប្រើឥរិយាបថបែបនេះ និងមិនបានវែកញែកឲ្យច្បាស់ពីកំហុសនិងគុណសម្បត្តិ។ លោកស្រីបានកោតសរសើរលោកស្រី សុខា ថាបានខិតខំថែទាំកូន និងបំពេញការងារក្នុងពេលដំណាលគ្នាដែលជាភារកិច្ចទទួលខុសត្រូវទ្វេដងលើសពីបុរស។

ក៏ប៉ុន្តែ ថ្នាក់ដឹកនាំរបស់លោកស្រី សុខា បានប្រាប់សារព័ត៌មានក្នុងស្រុកថា ពួកគាត់មិនបានដាក់ពិន័យលើកូន ចៅគាត់ ហើយគ្រាន់តែបានហៅមកអប់រំតែប៉ុណ្ណោះ។

លោកស្រី ស៊ីថុង សុខា គឺជាអធិការរងនៃអធិការដ្ឋាននគរបាលស្រុកសៀមប៉ាង ទទួលបន្ទុកសណ្តាប់ធ្នាប់និងចរាចរណ៍។ លោកស្រី សុខា សុំមិនធ្វើការអធិប្បាយច្រើនទេ ដោយថាចង់ឲ្យករណីនេះស្ងប់ស្ងាត់។ លោកស្រីនិយាយថា៖ «ខ្ញុំ post ហ្នឹង ខ្ញុំមិនមែន post ដើម្បីនិយាយបញ្ឆាក់ ដើម្បីខូចដល់កន្លែងដែលខ្ញុំធ្វើការទេគឺ post ហ្នឹងគឺ post ពីទឹកចិត្តម្តាយ ឆ្លុះបញ្ចាំងពីទឹកចិត្តម្តាយចំពោះកូនទេ»។

នៅថ្ងៃព្រហស្បតិ៍នេះ ក្រុមអ្នកការពារសិទ្ធិស្ត្រី អង្គការសមាគមចំនួន ៣៩ បានចេញសេចក្តីថ្លែងការណ៍រួមគ្នាថា នេះជារឿងគួរឲ្យអាម៉ាស់ដែលលោកស្រី ស៊ីថុង សុខា ត្រូវថ្នាក់លើស្នើឲ្យធ្វើកិច្ចសន្យា ឈប់បង្ហោះរូបភាពបំបៅកូនតទៅទៀត ហើយអ្វីដែលគួរឲ្យខកចិត្តទៅទៀតនោះ គឺការធ្វើកិច្ចសន្យានោះបានកើតឡើងតែមួយថ្ងៃប៉ុណ្ណោះ បន្ទាប់ពីទិវានារីអន្តរជាតិ ៨ មីនា។ ពួកគេឡើងថា៖ «នោះគឺជារឿងគួរឲ្យអាម៉ាស់ចំពោះការតម្រូវឲ្យមន្ត្រីនគរបាល ត្រូវសុំទោសក្រោមហេតុផលថាបានធ្វើឲ្យប៉ះពាល់ដល់កិត្តិយសរបស់អង្គភាព និងស្ត្រីខ្មែរ ហើយតម្រូវឲ្យនាងចុះកិច្ចសន្យាមិនបន្តអកប្បកិរិយាបែបនេះទៅទៀត»។ ពួកគេបន្ថែមថា៖ «ក្រោយមកបន្ទាប់ពីមានការរិះគន់ពីសាធារណជន មន្ត្រីនគរបាលជាថ្នាក់ដឹកនាំនោះបានចេញមុខបកស្រាយ ដោយយោងលើហេតុផលថា អ្នកស្រីនគរបាលរូបនោះ ពុំបានសុំការអនុញ្ញាតជាមុនក្នុងការបង្ហោះរូបភាពនៃការបំបៅកូននៅលើទំព័រហ្វេសប៊ុក ដែលការពន្យល់នេះបង្កើនការព្រួយបារម្ភថែមទៀត អំពីសេរីភាពក្នុងការបញ្ចេញមតិ»។

វីអូអេមិនទាន់អាចទាក់ទងសុំការអធិប្បាយពីលោក អូត ស៊ីវុត្ថា ស្នងការនគរបាលខេត្តស្ទឹងត្រែង បានទេនៅ រសៀលថ្ងៃព្រហស្បតិ៍នេះ។

អ្នកនាំពាក្យអគ្គស្នងការនគរបាលជាតិលោក ឆាយ គឹមខឿន បានប្រាប់សារព័ត៌មានក្នុងស្រុក Freshnews នៅថ្ងៃព្រហស្បតិ៍នេះថា លោកស្រីអនុសេនីយ៍ទោ ស៊ីថុង សុខា អធិការរងទទួលផែនសណ្តាប់ធ្នាប់នៃអធិការដ្ឋាននគរបាលស្រុកសៀមប៉ាង ត្រូវបានផ្តល់រង្វាន់លើកទឹកចិត្ត ក្នុងពេលបំពេញការងារហើយឆ្លៀតបំបៅកូន។ លោកមានប្រសាសន៍ថា ការបំបៅកូនដូចនេះ មិនមានកំហុសធំដុំទេ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ទី១១ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១១៩នាក់ ស្រី ៥០នាក់ ក្នុងនោះកុមារ ៩នាក់ កុមារី ៧នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤៣នាក់ ស្រី ១៨នាក់ កុមារ ៣នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២១នាក់ ស្រី ៩នាក់ កុមារ ៦នាក់ កុមារី ៤នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់៖ ចំនួន ៥០នាក់ ស្រី ២១នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៥-ច្រកដូង ស្រុកកំរៀង៖ ចំនួន ៥នាក់ ស្រីចំនួន ២នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១១៩នាក់ ស្រី ៥០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាបនៅក្នុងថ្ងៃនេះ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ពលករនៅតែបន្តមកពីច្រកព្រំដែនកម្ពុជា-ថៃ

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០២១

(កំពង់ធំ)៖ នៅយប់ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១នេះ ពលករមកពីច្រកព្រំដែនកម្ពុជា-ថៃ នៅតែបន្តមកស្រុកកំណើតរបស់គាត់ជាបន្តបន្ទាប់ ដាក់ស្តែងនៅខេត្តកំពង់ធំ នាយប់នេះមានពលករដែលដឹកតាមរថយន្តចំនួន ០៩គ្រឿង ដែលមានពលករសរុបចំនួនជិត១៣០នាក់។ ក្នុងពេលនោះផងដែរឯកឧត្តម សុខ លូ អភិបាលខេត្តបានយកចិត្តទុកដាក់ទទួលបាយ ទឹកហើយក្រុមគ្រូពេទ្យបានពិនិត្យយ៉ាងយកចិត្តទុកដាក់បំផុត។ ឯកឧត្តមក៏បានសំណូមពរ សូមឲ្យបងប្អូនប្រជាពលរដ្ឋអនុវត្តការអនាម័យជាប្រចាំ ពិសេសអនុវត្តឲ្យបាននូវវិធានការ ៣ការពារ និង ៣កុំ ការពារខ្លួនយើងនិងការពារអ្នកនៅជុំវិញយើង។ ក្រុង ស្រុក ក៏បានដឹកជញ្ជូនពួកគាត់យកទៅធ្វើចត្តាឡីស័កបន្តទៀត៕ ដោយ៖ មន្ទីរព័ត៌មានខេត្តកំពង់ធំ

# ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១

## សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន កោតសរសើរ និងលើកទឹកចិត្ត ដល់ស្ត្រីនគរបាលចរាចរណ៍នៅស្រុកសៀមប៉ាង ខេត្តស្ទឹងត្រែង ដែលលះបង់គ្រប់បែបយ៉ាង ដើម្បីកូន និងការងារ

http://freshnewsasia.com/ 2021-03-12 10:02pm

**(ភ្នំពេញ)៖** ក្នុងនាមម្តាយមួយរូប សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ភរិយានាយករដ្ឋមន្ត្រីនៃ កម្ពុជា បានសម្តែងនូវការកោតសរសើរយ៉ាងក្រៃលែង ចំពោះស្ត្រីជាមាតាគ្រប់រូប ដែលបានលះបង់គ្រប់បែបយ៉ាង ដែល

ក្នុងស្ថានភាពជាស្ត្រី មានភារកិច្ចទទួលខុសត្រូវទ្វេដងលើសពីបុរស គឺបំពេញការងារស្នូលក្នុងអង្គភាព-ស្ថាប័នផង និងត្រូវចិញ្ចឹមបីបាច់ថែទាំកូនតាំងពីនៅក្នុងផ្ទៃរហូតកើតមក និងបន្តដល់ពេលពេញវ័យផង ដោយមិនដែលបោះបង់កូនទោះស្ថិតក្នុងស្ថានភាពណាក៏ដោយ។

ជាក់ស្តែង លោកស្រី អនុសេនីយ៍ ទោ ស៊ីថុង សុខា បានបំបៅកូននៅតុការងារតាមផ្លូវ ក្នុងពេលបំពេញការងារផងកាលពីថ្មីៗនេះ, សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន នៅថ្ងៃសុក្រ ទី១២ ខែមីនា ឆ្នាំ២០២១នេះ បានចាត់លោក ម៉ុម សារឿន អភិបាលនៃគណៈអភិបាលខេត្តស្ទឹងត្រែង ចុះសួរសុខទុក្ខ និងនាំយកថវិកា ១០លានរៀល ផ្តល់ជូនដើម្បីជាការលើកទឹកចិត្ត និងជួយសម្រាលការលំបាកក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ លោកស្រី អនុសេនីយ៍ ទោ ស៊ីថុង សុខា បានសម្តែងនូវក្តីរំភើបរីករាយឥតឧបមា បន្ទាប់ពីបានដឹងថា ករណីរបស់លោកស្រីបានជ្រាបទៅដល់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ហើយថែមទាំងទទួលបានការគិតគូរ យកចិត្តទុកដាក់យ៉ាងកក់ក្តៅ ដែលនេះជាការលើកទឹកចិត្ត និងផ្តល់តម្លៃយ៉ាងធំធេង ចំពោះស្ត្រីជាមាតាគ្រប់រូប។

ជាមួយគ្នានេះ លោកស្រី បានបួងសួងគោរពជូនពរដល់ សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ដែលជាមាតាមនុស្សធម៌ និងសម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី សូមសម្តេចទាំងទ្វេ មានសុខភាពល្អ រឹងមាំ អាយុយឺនយូរ ដើម្បីជាម្លប់ ផ្តល់ភាពកក់ក្តៅដល់ប្រជាពលរដ្ឋកម្ពុជា ក្រោមម្លប់នៃសន្តិភាព៕

## អ្នករត់ម៉ូតូឌុប ២នាក់ ដឹកជនជាតិចិនទាំង៥នាក់ លួចឆ្លងដែនពីវៀតណាមចូលកម្ពុជានៅខេត្តតាកែវ ពេលនេះសមត្ថកិច្ចឃាត់ខ្លួន និងតាមរកមេខ្យល់

https://www.khmer-press.com/ Khmer pressMarch 12, 2021 at 4:33 pm

(តាកែវ)៖ កម្លាំងតំបន់ប្រតិបត្តិការសឹករងតាកែវ នៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១នេះ បានធ្វើការឃាត់ខ្លួនជនជាតិចិន៥នាក់ និងអ្នករត់ម៉ូតូឌុបចំនួន២នាក់ ដែលលួចឆ្លងដែនពីប្រទេសវៀតណាម ចូលមកប្រទេសកម្ពុជា តាមច្រកស្រុកបូរីជលសា ក្នុងខេត្តតាកែវ។ លោកឧត្តមសេនីយ៍ត្រី នាង សុភារ៉ា មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្តតាកែវ បានឲ្យដឹងថា ប្រតិបត្តិការចាប់ជនជាតិចិនលួចឆ្លងដែននេះ គឺសហការជាមួយកម្លាំងអធិការនគរបាលស្រុកបូរីជលសារ ហើយក្រោយពីបានធ្វើការឃាត់ខ្លួន ពួកគេត្រូវបានប្រគល់ជូនកម្លាំងនគរបាលដើម្បីធ្វើការសួរនាំបន្ត និងនាំយកទៅធ្វើចត្តាឡីស័ក នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។

លោកឧត្តមសេនីយ៍ត្រី នាង សុភារ៉ា បានបន្ថែមថា ក្រោយសមត្ថកិច្ចជំនាញបានធ្វើការសាកសួរអ្នករត់ម៉ូតូឌុប ដឹកជនជាតិចិនទាំង៥នាក់រួចមក សមត្ថកិច្ចបានកំណត់មុខសញ្ញា អ្នកនាំជនជាតិចិនឆ្លងដែនរួចរាល់អស់ហើយ ហើយមុខសញ្ញាទាំងអស់នោះកំពុងតែរត់គេចខ្លួន។ ពាក់ព័ន្ធនឹងសកម្មភាពឆ្លងដែនខុសច្បាប់តាមច្រកស្រុកបូរីជលសារជាញឹកញាប់នោះ លោក ទុយ សុភ័ក្រ អភិបាលស្រុកបូរីជលសារ បានថ្លែងថា សមត្ថកិច្ចកំពុងតែធ្វើការស្រាវជ្រាវរកមេខ្យល់ ហើយចំពោះពាក្យចចាមអ៉ារ៉ាមថា មានការពាក់ព័ន្ធនឹងសមត្ថកិច្ចស្រុកនោះ ត្រូវបានលោកអភិបាលស្រុកច្រានចោល។

គួរបញ្ជាក់ថា ក្នុងរយៈពេលប៉ុន្មានថ្ងៃមកនេះមានជនជាតិចិនជាច្រើននាក់ ដែលលួចឆ្លងដែនពីប្រទេសវៀតណាម ចូលមកកម្ពុជា តាមច្រកខេត្តតាកែវ ត្រូវបានសមត្ថកិច្ចចាប់បានជាបន្តបន្ទាប់ ដែលការលួចឆ្លងដែនដោយខុសច្បាប់នេះ កំពុងតែនាំឲ្យមានការព្រួយបារម្ភពីការរីករាលដាលជំងឺកូវីដ-១៩៕ ផ្តល់សិទ្ធិដោយ៖ freshnews

## ជនជាតិចិន៦នាក់ លួចឆ្លងដែនពីប្រទេសវៀតណាម ចូលមកប្រទេសកម្ពុជា តាមរយៈមេខ្យល់ មកដល់ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ

https://www.khmer-press.com/ Khmer pressMarch 12, 2021 at 3:52 pm

(កំពង់ស្ពឺ)៖ ប្រជាពលរដ្ឋបានប្រទះឃើញជនជាតិចិនចំនួន៦នាក់ ដើរក្នុងអូរត្រង់ចំណុច ភូមិថ្មីខាងត្បូង ឃុំទួលអំពិល ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ ហើយបានរាយការណ៍ទៅកាន់សមត្ថកិច្ច ដើម្បីឃាត់ខ្លួនយកទៅសួរនាំភ្លាមៗនៅព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១នេះ និងបានបញ្ជូនទៅពិនិត្យសំណាកព្រមទាំងធ្វើចត្តាឡីស័កផងដែរ។

លោកឧត្តមសេនីយ៍ទោ សម សាមួន ស្នងការនគរបាលខេត្តកំពង់ស្ពឺ បានថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News ឲ្យដឹងថា តាមការសួរនាំជំហ៊ានដំបូងរបស់សមត្ថកិច្ច ជនជាតិចិនទាំង៦នាក់នេះ បានសារភាពថាពួកគេលួចឆ្លងដែនពីប្រទេសវៀតណាម ចូលមកប្រទេសកម្ពុជា តាមរយៈមេខ្យល់។ លោកឧត្តមសេនីយ៍ទោ សម សាមួន បានបន្ថែមទៀតថា ផ្អែកតាមចម្លើយសារភាពនោះ ពួកគេបានចេញពីប្រទេសវៀតណាម នៅថ្ងៃទី០៨ ខែមីនា ហើយមកដល់រាជធានីភ្នំពេញ នៅថ្ងៃទី១០ ខែមីនា ដោយស្នាក់សណ្ឋាគារមួយកន្លែងឈ្មោះ «ស៊ិនជិន»។ ក្រោយមកនៅព្រឹកថ្ងៃទី១២ ខែមីនា ពួកគេបានជិះរថយន្តមួយគ្រឿង ក្នុងគោលដៅទៅខេត្តកំពត ប៉ុន្តែដោយសាររថយន្តខូចពួកគេបានចុះដើរតែម្តង។ នៅពេលដើរកាត់តាមភូមិក៏ត្រូវបានប្រជាពលរដ្ឋ និងប្រជាការពារប្រទះឃើញរាយការណ៍ជូនសមត្ថកិច្ចមូលដ្ឋាន ធ្វើការឃាត់ខ្លួនភ្លាមៗតែម្តង ដើម្បីធ្វើការសួរនាំ និងចាត់ការតាមនីតិវិធី។

អភិបាលខេត្តកំពង់ស្ពឺ លោក វ៉ី សំណាង ក៏បានអះអាងស្រដៀងគ្នាដែរ ជនជាតិចិនទាំង៦នាក់ គឺមានមេខ្យល់នាំឆ្លងដែនពីប្រទេសវៀតណាម ចូលមកកម្ពុជា ដោយមេខ្យល់នោះ បានដកយកនូវលិខិតឆ្លងដែន និងទូរស័ព្ទជាដើម។ នេះបើតាមអ្វីដែលលោកបានបញ្ជាក់នៅលើបណ្តាញសង្គម Facebook។

យ៉ាងណាមិញ លោកឧត្តមសេនីយ៍ស្នងការ បានលើកឡើងថា ចម្លើយសារភាពរបស់ពួកគេហាក់មានការលាក់លាមនៅឡើយ ហើយរហូតមកដល់ពេលនេះ សមត្ថកិច្ចខេត្តកំពង់ស្ពឺ កំពុងសហការជាមួយកម្លាំងសមត្ថកិច្ចរាជធានីភ្នំពេញ ដើម្បីធ្វើការស្រាវជ្រាវរកទីតាំងដែលពួកគេស្នាក់នៅរាជធានីភ្នំពេញ នាពេលកន្លងទៅក្រោយឆ្លងដែនមកពីប្រទេសវៀតណាម។ បើតាមអ្វីដែលជាការបញ្ជាក់របស់លោកឧត្តមសេនីយ៍ទោ សម សាមួន ក្រោយបញ្ចប់ការសួរនាំជនជាតិចិនទាំង៦នាក់នេះ ត្រូវបានបញ្ជូនទៅពិនិត្យសំណាក និងធ្វើចត្តាឡីស័កនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទ កម្ពុជា-កូរ៉េ ដែលមានទីតាំងនៅក្រុងច្បារមន ខេត្តកំពង់ស្ពឺជាបណ្តោះអាសន្នសិន រង់ចាំលទ្ធផលពីខាងសុខាភិបាល៕ ផ្តល់សិទ្ធិដោយ៖ freshnews

## អាជ្ញាធរខេត្តសៀមរាប បន្តដឹកពលករតាមព្រំដែនថៃជាង៣០០នាក់ទៀតមកធ្វើចត្តាឡីស័កក្នុងខេត្ត

http://freshnewsasia.com/ 2021-03-12 10:08pm

**(សៀមរាប)៖** ពលករខ្មែរជាង៣០០នាក់បន្ថែមទៀតនៅថ្ងៃទី១២ ខែមីនា ត្រូវបានអាជ្ញាធរខេត្តសៀមរាបទៅទទួល និងដឹកជញ្ជូនតាមរថយន្តទាហាន ដើម្បីមកធ្វើចត្តាឡីស័កនៅតាមស្រុកគោលដៅនានាក្នុងខេត្តសៀមរាប។ ការដឹកជញ្ជូននេះ បន្ទាប់ពីប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសបិទការធ្វើចត្តាឡីស័កនៅតាមខេត្តជាប់ព្រំដែនថៃសម្រាប់អ្នកដែលមានសុខភាពធម្មតា។

នារសៀលថ្ងៃទី១២ ខែ មីនា ក្បួនរថយន្តចំនួន១៧គ្រឿង បានដឹកពលករខ្មែរចំនួន ៣៣២នាក់ ក្នុងនោះមានស្រី ១២៩នាក់ មកពីតាមបណ្តាខេត្តជាប់ព្រំដែនកម្ពុជា-ថៃ រួមមានខេត្តបន្ទាយមានជ័យ បាត់ដំបង ប៉ៃលិន និងខេត្តឧត្តរមានជ័យ។ ពលករទាំងនោះ គឺជាអ្នកដែលបានវិលត្រឡប់ពីប្រទេសថៃ ហើយបាននិងកំពុងធ្វើចត្តាឡីស័កនៅតាមមណ្ឌលចត្តាឡីស័កតាមខេត្តជាប់ព្រំដែន។ ក្រុមពលករខាងលើ ត្រូវបានយកមកពិនិត្យសុខភាពនៅ

តាមមណ្ឌលចត្តាឡីស័កចំនួន២ គឺមណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាគរុកោសល្យខេត្ត និងសាលាបឋមសិក្សាវត្តស្វាយ។ ដោយសារពលករមានចំនួនច្រើន អាជ្ញាធរខេត្តសៀមរាប បានបង្កើនមណ្ឌលចត្តាឡីស័កចំនួន១បន្ថែមទៀត គឺសាលាបឋមសិក្សាវត្តស្វាយ។

អភិបាលខេត្តសៀមរាប លោក ទៀ សីហា បានទទូចដល់ប្រជាពលរដ្ឋគ្រប់រូប ត្រូវតែចូលរួមអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវវិធានការ ៣ការពារ, ៣កុំ ចូលរួម និងធ្វើការស្កេន QR Code ឲ្យបានខ្ជាប់ខ្ជួន និងចូលរួមស្ម័គ្រចិត្តយកសំណាក ក្នុងករណីបងប្អូនទើបតែមក ឬពាក់ព័ន្ធនឹងកន្លែងដែលមានហានិភ័យ ដែលក្រសួងសុខាភិបាលបានប្រកាសកន្លងមក។ ក្នុងនោះសូមម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ហាងទំនិញ ផ្សារ សូមចុះឈ្មោះស្នើសុំ QR Code ដើម្បីចូលរួមចំណែកបង្ការ ទប់ស្កាត់ និងងាយស្រួលស្រាវរកអ្នកមានពាក់ព័ន្ធនឹងជម្ងឺកូវីដ១៩ ពីព្រោះថា យើងអាចភ្លេចកូវីដបាន តែកូវីដមិនភ្លេចយើងឡើយ។

បើតាមការបញ្ជាក់របស់លោកស្រី យូ សុភា បានឲ្យដឹងថា ពលករដែលបានមកក្រៅប្រទេស ហើយបានធ្វើចត្តាឡីស័កនៅតាមបណ្ដាខេត្តជាប់ព្រំដែន បានចូលមកកាន់មណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាអនុវត្តគរុកោសល្យខេត្ត គឺចំពោះពលករដែលមិនទាន់បានធ្វើចត្តាឡីស័កនៅតាមព្រំដែន តែចំពោះបងប្អូនពលករ ដែលបានចូលទៅមណ្ឌលចត្តាឡីស័កនៅសាលាបឋមសិក្សាវត្តស្វាយ គឺមានបងប្អូនខ្លះបានធ្វើចត្តាឡីស័កគ្រប់ តាមគោលការណ៍របស់ក្រសួងសុខាភិបាល ខ្លះមិនទាន់គ្រប់ថ្ងៃត្រូវតែបន្តផងដែរ ។ លោកស្រីបន្ថែមថា បងប្អូនដែលបានចូលមកដល់មណ្ឌលចត្តាឡីស័កមួយចំនួនបានធ្វើការយកសំណាកបានម្ដងមកហើយ និង មួយចំនួនបានបំពេញទៅតាមការកំណត់របស់ក្រសួងសុខាភិបាលរយៈពេល១៤ថ្ងៃ មួយចំនួនដែលមិនទាន់គ្រប់ គឺត្រូវបន្តធ្វើចត្តាឡីស័កនៅតាមបណ្ដាក្រុង ស្រុក ក្រោយពេលយកសំណាកបានគ្រប់ចំនួន។ ជាក់ស្ដែងផងដែរ បងប្អូនដែលបានធ្វើចត្តាឡីស័កបានគ្រប់ចំនួន និង អ្នកបានយកសំណាកបានគ្រប់ តាមការកំណត់ក៏ត្រូវបានបញ្ជូនឲ្យទៅបន្តធ្វើចត្តាឡីស័កនៅតាមក្រុង ស្រុករបស់ពួកគេរៀងៗខ្លួន។

គួបញ្ជាក់ថា នៅថ្ងៃទី៩ មីនាកន្លងទៅ អាជ្ញាធរខេត្តសៀមរាប ក៏បបានដឹកជញ្ជូនពលករពីថៃជាទ្រុងទ្រាយធំផងដែរដែលសរុបប្រមាណជាង៧០០នាក់ដែលសរុបមកដល់ពេលនេះគឺមានពលករខ្មែរជាងមួយពាន់នាក់ហើយ៕

## ទាល់តែក្រឡាប់ឡានទើបដឹងនិងឆ្នាក់ថា អ្នកជិះសុទ្ធតែចិន១៣នាក់

https://kohsantepheapdaily.com.kh/ ១៣ ខែ មីនា ឆ្នាំ ២០២១ ម៉ោង ០៨:៥២

ខេត្តស្វាយរៀង ៖ មានករណីជនជាតិចិនចំនួន១៣នាក់ ជិះរថយន្ត១គ្រឿងម៉ាក LEXUS RX300 ពណ៌ទឹកមាស ពាក់ស្លាកលេខភ្នំពេញ 2G-9521 បានក្រឡាប់ផ្ងារជើងឡើងលើមិនដឹងថា ពួកជនជាតិចិនទាំងនេះ មកពីណានោះទេ កើតឡើងនៅវេលាម៉ោង៤និង២៥នាទីព្រឹកនៅចំណុចភូមិស្វាយតឿ សង្កាត់ស្វាយតឿ ក្រុងស្វាយរៀង។

បើតាមសមត្ថកិច្ចបានឲ្យដឹងថា មុនពេលកើតហេតុ គេឃើញរថយន្ត១គ្រឿងបើកពីទិសខាងលិចទៅកើតយ៉ាងលឿននៅលើកំណាត់ផ្លូវជាតិលេខ១។ លុះមកដល់ចំណុចខាងកើតហេតុ ស្ពានទន្លៀងទី២ ចំម្ងាយ២០០ម៉ែត្រស្រាប់តែរេចង្កូតទៅខាងស្ដាំធ្លាក់ចិញ្ចើមថ្នល់ បានជ្រុលទៅបុកដើមអាកាស្យានៅខាមុខផ្ទះអ្នកស្រុកក្រឡាប់ផ្ងារជើងឡើងលើតែម្ដង ខណៈនោះគេឃើញមនុស្សលូនចេញពីខាងក្នុងរថយន្តបន្តបន្ទាប់រហូតទៅ១៤នាក់។ ហើយភ្លាមៗនោះ អ្នកបើកបររថយន្តបានរត់គេចខ្លួនពីកន្លែងកើតហេតុបាត់ស្រមោល ហើយមនុស្ស៥នាក់ បានរត់ទៅពួនតាមផ្ទះអ្នកស្រុកនៅសល់៨នាក់នៅកន្លែងរថយន្តកើតហេតុ។ ប្រភពបន្តទៀតថា ក្រោយមកសមត្ថកិច្ចនគបាលអធិការដ្ឋាននគបាលក្រុងស្វាយរៀង និងស្នងការដ្ឋាននគបាលខេត្តបានមកដល់បានឃើញមនុស្សទាំង៨នាក់ គឺជនជាតិចិនទើបឃាត់ខ្លួនបញ្ជូនទៅការិយាល័យអន្តោប្រវេសន៍នៃស្នងការដ្ឋាននគបាលខេត្ត ដើម្បីសាកសួរនិងបន្តតាមចាប់ខ្លួនជនជាតិចិនបាន៥នាក់ទៀតយកមកសាកសួរសរុប១៣នាក់ ។ ចំណែកអ្នកបើកបររថយន្តសង្ស័យថា ជាជនជាតិខ្មែរសមត្ថ

កិច្ចកំពុងស្រាវជ្រាវរក ដើម្បីទទួលខុសត្រូវ និងសួរព័ត៌មានថា តើគេដឹកជនជាតិចិននេះមកពីណា ។ ប្រភពមិនច្បាស់ការ គឺជនជាតិចិនទាំងនេះមិនព្រមឆ្លើយប្រាប់ឈ្មោះ ហើយមកពីណាទៅណា គ្រាន់តែឆ្លើយថា ពួកគេមកពីប្រទេសចិន មានគេយកមកឲ្យធ្វើការនៅស្រុកខ្មែរ ក៏មិនដឹងថា ទៅធ្វើការនៅកន្លែងណាទេ គេមិនស្គាល់ទេ ក៏ប៉ុន្តែបើតាមការសន្និដ្ឋានរបស់សមត្ថកិច្ចថា ជនជាតិចិន១៣នាក់នេះគឺរថយន្តដឹកទៅក្រុងបាវិត។

បើតាមលោកតូច ប៉ូលីវ៉ា អភិបាលរងខេត្តនិងជាអនុប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងការឆ្លងមេរោគកូវីដ១៩ខេត្តស្វាយរៀងបានឲ្យដឹងថា ជនជាតិចិន១៣នាក់នេះសមត្ថកិច្ចបានបញ្ជូនទៅធ្វើចត្តាឡីសក័នៅក្នុងមណ្ឌលធ្វើចត្តាឡីសក័ផ្ទះសំណាក់គ្រូបង្រៀន នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តស្ថិតនៅភូមិស្រះវង្ស សង្កាត់ស្វាយរៀង ក្រុងស្វាយរៀង និងក្រុមគ្រូពេទ្យបានយកសំណាកទៅពិនិត្យធ្វើតេស្តកូវីដ១៩នៅរាជធានីភ្នំពេញរួចហើយដែរ។ ហើយចំពោះព័ត៌មានជនជាតិចិនមកពីណានោះ គឺរង់ចាំការស្វែងរកអ្នកបើកបររថយន្តឲ្យឃើញមកបំភ្លឺទើបដឹងការពិតដោយជនជាតិចិនទាំង១៣នាក់ មិនព្រមឆ្លើយ ពីសាវតា និងអត្តសញ្ញាណ ឲ្យសមត្ថកិច្ចបានដឹងនៅឡើយ ។

## សមត្ថកិច្ចចម្រុះពួនស្ទាក់ចាប់ជនជាតិចិនចំនួន១៣នាក់លួចឆ្លងដែន និងមេខ្យល់ខ្មែរ៥នាក់

https://cen-news.com/ By Pen Srey Neat March 12, 2021

ខេត្តព្រៃវែង ៖ កម្លាំងសមត្ថកិច្ចចម្រុះពួនស្ទាក់ចាប់ជនជាតិចិន លួចឆ្លងដែនតាមច្រកល្បៀងអូរស៊េរ ចំនួន១៣នាក់ ក្នុងនោះមានស្ត្រីម្នាក់ និងប្តីប្រពន្ធតាកុងឡាន២នាក់ខ្មែរ និង ៣នាក់ខ្មែរបន្ថែមទៀតមេខ្យល់ និងរថយន្តពណ៌សពាក់ផ្លាកលេខ ភ្នំពេញ 2BI 75 39 ក្នុងចន្លោះបង្គោលលេខ ២៣០លើ៥ ២៣០លើ៦ ក្នុងចន្លោះបង្គោលព្រំដែនកម្ពុជាស្រពពេលប្រទេសកំពុងមានវិបិត្តកូវីដ១៩ នៅច្រកស្វាយអាង៉ោង ឃុំចាម ស្រុកកំពង់ត្របែក ខេត្តព្រៃវែង នាយប់រំលងអធ្រាត្រវេលាម៉ោង ៣និង២០នាទីថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១។

កម្លាំងសមត្ថកិច្ច បានបញ្ជាក់ថា ក្នុងប្រតិបត្តិការនេះនោះ មានមេខ្យល់ប្តីប្រពន្ធ២នាក់ ជាតាកុងឡាន ឈ្មោះ វ៉ន សុឃុន ភេទប្រុសអាយុ៤១ ឆ្នាំ និងប្រពន្ធ ឈ្មោះ ផៃ គន្ធា អាយុ ៣៣ឆ្នាំ រស់នៅភូមិកំពង់ពោធិ ឃុំកំពង់ភ្នំ ស្រុកលើដែក ខេត្តកណ្តាល ។ មេខ្យល់៣នាក់ គឺ១ ឈ្មោះ ចេង ពុធ ភេទប្រុស រស់នៅភូមិរោង ឃុំចាម ស្រុកកំពង់ត្របែកខេត្តព្រៃវែង ២ ឈ្មោះ ដែន ភេទប្រុស រស់ភូមិតាប៉ុល ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង ៣ ឈ្មោះ ខ្មៅ ហៅង៉ងភេទប្រុស រស់នៅភូមិតាប៉ុល ឃុំជាងដែក ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ បច្ចុប្បន្នកម្លាំងសមត្ថកិច្ចចម្រុះជំនាញពាក់ព័ន្ធ កំពុងរៀបចំឯកសារកំណត់ហេតុទៅតាមនីតិវិធីច្បាប់ ៕ រក្សាសិទ្ធិដោយៈបញ្ញាស័ក្តិ

## បន្ទាប់មេខ្យល់នាំជនជាតិវៀតណាមឆ្លងដែនចូលកម្ពុជា ឃាត់ខ្លួន២នាក់ ខណៈជនជាតិវៀតណាម៤នាក់ ត្រូវបានបណ្តេញចេញ

http://www.freshnewsasia.com/ 2021-03-15 07:35am

(កំពត)៖ លោកឧត្តមសេនីយ៍ទោ ម៉ៅ ច័ន្ទមធុរិទ្ធ ស្នងការនគរបាលខេត្តកំពត បានថ្លែងប្រាប់បណ្តាញព័ត៌មាន Fresh News នៅព្រឹកថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១នេះថា នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២១ កម្លាំងនគរបាលនៃស្នងការដ្ឋាននគរបាលខេត្តកំពត បានឃាត់ខ្លួនមេខ្យល់ និងបក្ខពួកនាំមនុស្សឆ្លងដែនខុសច្បាប់ចូលកម្ពុជា ចំនួន២នាក់។ លោកបន្តថា មេខ្យល់ម្នាក់ ត្រូវបាននាំយកពីសមត្ថកិច្ចខេត្តតាកែវ ជាមួយជនជាតិវៀតណាមចំនួន៤នាក់។ ចំណែកឯកអ្នកជាប់ពាក់ព័ន្ធមេខ្យល់ម្នាក់ទៀត ត្រូវបានឃាត់ខ្លួន នៅស្រុកកំពង់ត្រាច។ លោកឧត្តមសេនីយ៍បន្តថា មេខ្យល់នាំមនុស្សឆ្លងដែនពីវៀតណាមចូលកម្ពុជានេះ ឈ្មោះ ជា សុវណ្ណារី ភេទប្រុស អាយុ៣០ឆ្នាំ ហៅចិន ជនជាតិខ្មែរ មុខរបររត់ឡានតាក់ស៊ី ដឹកភ្ញៀវទៅកាសស៊ីណូព្រែកចាក មានទីលំនៅភូមិក្រសាំង ឃុំឈូក ស្រុកឈូក ខេត្តកំពត និងឈ្មោះ នាង ខេង ភេទស្រីអាយុ៥៨ ឆ្នាំ ហៅ បីហ៊ាន់ មុខរបរដឹកបារីហ៊ារ៉ូទៅប្រទេសវៀតណាម មានទីលំនៅភូមិ ព្រែក

គ្រើស ឃុំព្រែកគ្រើស ស្រុកកំពង់ត្រាច ខេត្តកំពត។ លោកបន្តថា ចំពោះជនជាតិវៀតណាមចំនួន៤នាក់ បានប្រគល់ឲ្យទៅភាគីវៀតណាមវិញ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃសៅរ៍ ទី១៣ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៦៦នាក់ ស្រី ២៦នាក់ ក្នុងនោះកុមារា ២នាក់ កុមារី ២នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣៤នាក់ ស្រី ១៥នាក់ កុមារា ២នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២២នាក់ ស្រី ៨នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។6- ខេត្តប៉ៃលិន ÷ ចំនួន ៧នាក់ ស្រីចំនួន ២នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៦៦នាក់ ស្រី ២៦នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាបនៅក្នុងថ្ងៃនេះ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១

## នាយឧត្តមសេនីយ៍ នេត សាវឿន ណែនាំឱ្យបិទច្រកទ្វារព្រំដែនមិនឲ្យពលរដ្ឋខ្មែរ ចេញក្រៅប្រទេស និងត្រៀមទទួលពលរដ្ឋត្រឡប់មកវិញ

https://dap-news.com/national/ BySS107 Posted on March 15, 2021

ភ្នំពេញ ៖ នាយឧត្តមសេនីយ៍ នេត សាវឿន អគ្គស្នងការនគរបាលជាតិ បានធ្វើការណែនាំកម្លាំងសមត្ថកិច្ចនៅតាមបណ្ដាខេត្តជាប់ព្រំដែនត្រូវសហការជាមួយអាជ្ញាធរ ដើម្បីបិទច្រកទ្វារមិនឲ្យប្រជាពលរដ្ឋខ្មែរចេញទៅក្រៅប្រទេស និងត្រៀមទទួលប្រជាពលរដ្ឋត្រលប់មកវិញ ដើម្បីបញ្ជូនទៅធ្វើចត្តាឡីស័កត្រឹមត្រូវ។ នេះបើយោងតាមការចេញផ្សាយ អគ្គស្នងការនគរបាលជាតិ។

ក្នុងកិច្ចប្រជុំជាមួយបណ្ដាស្នងការនគរបាលរាជធានី-ខេត្ត តាមប្រព័ន្ធអេឡិចត្រូនិច ស្ដីពីការចូលរួមបង្ការទប់ស្កាត់ការរីករាលដាលជំងឺឆ្លងកូវីដ-១៩ នៅតាមសហគមន៍ ក្នុងដែនសមត្ថកិច្ចរបស់ស្នងការដ្ឋាននគរបាលរាជធានី-ខេត្តនីមួយៗ នៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នាយឧត្តមសេនីយ៍ នេត សាវឿន បានថ្លែងថា «ចំពោះបណ្ដាខេត្តជាប់ព្រំដែន ត្រូវសហការជាមួយអាជ្ញាធរខេត្តជាប់ព្រំដែន បិទច្រកទ្វារទប់ស្កាត់មិនឲ្យពលរដ្ឋខ្មែរចេញទៅក្រៅប្រទេស និងត្រៀមទទួលប្រជាពលរដ្ឋដែលត្រលប់មកវិញ ដើម្បីបញ្ជូនទៅធ្វើចត្តាឡីស័កតាមវិធានសុខាភិបាល»។ នាយឧត្តមសេនីយ៍ បន្តថា ដោយឡែក ជនបរទេសដែលលួចជ្រៀតចូលដោយខុសច្បាប់គឺ ទី១-បើចូលតាមច្រកណា ត្រូវបញ្ជូនចេញតាមច្រកនោះ, ទី២-បើលួចចូលតាមរបៀងមកដល់ទឹកដីកម្ពុជា ត្រូវបញ្ជូនទៅធ្វើចត្តាឡីស័ក

រួចត្រូវសហការជាមួយអគ្គនាយកដ្ឋានអន្តោប្រវេសន៍ ធ្វើបែបបទបញ្ជូនចេញពីប្រទេសវិញតាមនីតិវិធី និងទី៣-ត្រូវបន្តស្រាវជ្រាវ ស្វែងរកចាប់ខ្លួនរកមេខ្យល់ មេក្លោង និងបណ្តាញពាក់ព័ន្ធ ដើម្បីផ្តន្ទាទោសតាមច្បាប់។

ចំពោះខាងផ្ទៃក្នុងប្រទេសវិញ អគ្គស្នងការនគរបាលជាតិ ក៏បានលើកឡើងថា ទី១-បើមានជនសង្ស័យ ត្រូវឃុំគ្រង និងរាយការណ៍ សហការជាមួយសុខាភិបាល បញ្ជូនទៅធ្វើចត្តាឡីស័កឲ្យបានត្រឹមត្រូវ និងស្រាវជ្រាវជាបន្ទាន់រកអ្នកពាក់ព័ន្ធដោយផ្ទាល់ និងប្រយោល និងទី២-បើនៅតាមអង្គភាពមានសញ្ញាសង្ស័យ ត្រូវឃុំគ្រងគោលដៅ ឬអង្គភាពនោះ ដោយចាត់វិធានសុខាភិបាលឲ្យបានត្រឹមត្រូវ និងបញ្ជូនជនសង្ស័យទៅយកសំណាក ឬធ្វើចត្តាឡីស័ក ព្រមទាំងផ្តល់ដំណឹងដល់ក្រុមគ្រួសារ ដើម្បីកាត់ផ្តាច់ទំនាក់ទំនង៕

## កូរ៉េផ្តល់កូតាដល់ពលករកម្ពុជាជាង៣ពាន់នាក់សម្រាប់ឆមាសទី១

https://www.kampucheathmey.com/ on March 15, 2021By Kang Tola

ភ្នំពេញ ៖ ក្រសួងការងារ និងមុខរបរ នៃសាធារណរដ្ឋកូរ៉េបានផ្តល់កូតាដល់ពលករកម្ពុជាសម្រាប់ឆមាសទី១ ឆ្នាំ២០២១ចំនួន ៣,៤០៤នាក់ ទៅលើវិស័យឧស្សាហកម្ម ហើយបានសន្យាថា នឹងបន្តផ្តល់កូតាបន្ថែមទៀតនៅឆមាសទី២ ប្រសិនបើស្ថានភាពជំងឺកូវីដ១៩ មានភាពធូរស្រាល។

យោងតាមសេចក្តីជូនដំណឹងរបស់ក្រសួងការងារ និងមុខរបរ នៃសាធារណរដ្ឋកូរ៉េ បានឲ្យដឹងថា បើទោះបីស្ថានភាពនៃការរាតត្បាតជំងឺកូវីដ-១៩ មិនទាន់មានការថមថយក៏ដោយ ក៏រដ្ឋាភិបាលកូរ៉េនៅតែបន្តផ្តល់កូតាចំនួន៥០ភាគរយ សម្រាប់ឆមាសទី១ ឆ្នាំ២០២១ទៅលើវិស័យឧស្សាហកម្មចំនួន ៣,៤០៤នាក់ ហើយ សម្រាប់ឆមាសទី២ឆ្នាំ២០២១ កម្ពុជា នឹងទទួលបានកូតាបន្ថែមទៀត បន្ទាប់ពីស្ថានភាពជំងឺកូវីដ-១៩ មានភាពធូរស្បើយ។ ក្រសួងបានបន្តថា ដោយឡែក ចំនួនពលករដែលត្រូវបានអនុញ្ញាតដាក់ចូលក្នុងបញ្ជីសុំស្វែងរកការងារធ្វើក្នុងឆ្នាំ២០២១ មានចំនួនសរុប ២២,៦៩៧ ក្នុងនោះ វិស័យឧស្សាហកម្ម ចំនួន ១៦,២៦១នាក់; វិស័យកសិកម្ម&ចិញ្ចឹមសត្វ ចំនួន ៥,៧៧៨នាក់ និង វិស័យសំណង់ ចំនួន ៦៥៨នាក់។

ចំណែកក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈសង្ឃឹមថា នឹងទទួលបានកូតាបន្ថែមទៀត បន្ទាប់ពីស្ថានភាពជំងឺកូវីដ-១៩ មានភាពល្អប្រសើរឡើង។ ក្នុងចំណោមពលករបរទេសធ្វើការនៅកូរ៉េខាងត្បូងចំនួន១៦ប្រទេស ពលករខ្មែរត្រូវបាននិយោជកកូរ៉េមានការកោតសរសើរថា មានចរិតស្លូតបូត រួសរាយរាក់ទាក់ឧស្សាហ៍ព្យាយាមក្នុងបំពេញការងារដែលធ្វើឲ្យនិយោជកកូរ៉េទទួលយកពលករខ្មែរជាបន្តបន្ទាប់ទៀត។

គួរបញ្ជាក់ថា បច្ចុប្បន្ននេះកម្ពុជាមានពលករខ្មែរធ្វើការនៅប្រទេសកូរ៉េខាងត្បូងប្រមាណជាង៤ម៉ឺន៥ពាន់នាក់ដោយធ្វើការទៅលើវិស័យឧស្សាហកម្ម កសិកម្មនិងសំណង់ដែលបានជួយលើកស្ទួយដល់ជីវភាពគ្រួសារក៏ដូចជាសេដ្ឋកិច្ចជាតិឲ្យកាន់តែប្រសើរផងដែរ៕ *ដោយ ៖ សំអឿន*

## អភិបាលខេត្ត ៖ ពលករជាង១ពាន់នាក់ត្រូវបានបញ្ជូនទៅ កាន់រាជធានីខេត្តផ្សេង

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 16/03/2021

ខេត្តបាត់ដំបង ៖ លោក ងួន រតនៈ អភិបាលខេត្តបាត់ដំបងបានថ្លែងថា គិតចាប់ពីថ្ងៃទី៧ ខែមីនា ឆ្នាំ២០២១ រហូតមកដល់ បច្ចុប្បន្ននេះ អាជ្ញាធរខេត្តបាត់ដំបងបានបញ្ជូនពលករជាង ១,០០០នាក់ ទៅរាជធានី-ខេត្តផ្សេងៗ ។ ទន្ទឹមនោះក៏មានពលករជាង ២,០០០នាក់ ដែលមានលំនៅដ្ឋានក្នុងខេត្តបាត់ដំបង ត្រូវបានបញ្ជូនពីបណ្តាខេត្តជាប់ព្រំដែន ខណៈបច្ចុប្បន្នមានពលករ កំពុងធ្វើចត្តាឡីស័កក្នុងខេត្តមានចំនួន ២,៣១៥នាក់។ ផ្តើមពីនោះលោកអភិបាលខេត្តក៏បានស្នើឲ្យរដ្ឋបាលស្រុក ចំនួន២ថ្មគោល និងស្រុកបវេលត្រូវរៀបចំបន្ថែមមណ្ឌលចត្តាឡី

ស័ក សម្រាប់ពលករខ្មែរ ដែលទើបត្រឡប់ពីប្រទេសថៃផងដែរ។ ការថ្លែងបែបនោះរបស់លោកអភិបាលខេត្តធ្វើឡើងក្នុងឱកាសចុះពិនិត្យស្ថានភាពទូទៅ និងគ្រប់គ្រងពលករតាមមណ្ឌលចត្តាឡីស័ក នៅតាមបណ្ដាស្រុកមួយចំនួននៅរសៀលម្សិលមិញ លោកបន្តថា ការស្នើឲ្យស្រុកទាំងពីរខាងលើរៀបចំ មណ្ឌលចត្តាឡីស័កបន្ថែមទៀតនេះដោយសង្កេតឃើញថាចំនួនពលករច្រើនមកពីប្រទេសថៃមានចំនួនច្រើន។

ដូចនេះស្រុកទាំងពីរខាងលើត្រូវរៀបចំមណ្ឌលចត្តាឡីស័កបន្ថែមទៀត ដើម្បីត្រៀមសម្រាប់ពលករវិលត្រឡប់ពី ប្រទេសថៃវិញ។ លោក ងួន រតនៈ បានបញ្ជាក់បន្ថែមថា ការរៀបចំមណ្ឌលចត្តាឡីស័ក ក៏ត្រូវមានរៀបចំនូវបង្គន់អនាម័យឲ្យបានត្រឹមត្រូវ ក៏ដូចជាកន្លែងងូតទឹក ភ្លើងអគ្គីសនី និងផ្ដល់របបអាហារឲ្យបានគ្រប់គ្នា រួមទាំងត្រូវរឹតបន្តឹងការធ្វើចត្តាឡីស័ករបស់ពលករ និងផ្សព្វផ្សាយអប់រំពីវិធានទប់ស្កាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ១៩ ដល់ពួកគេឲ្យបានយល់ដឹងច្បាស់ ព្រមទាំងច្បាប់ស្ដីពីកូវីដ១៩ និងអនុក្រឹតរបស់រាជរដ្ឋាភិបាល។ លោកថា ស្រុកជាប់ជាយដែន រួមមានស្រុកកំរៀង ភ្នំព្រឹក និងស្រុកសំពៅលូន ចាប់ផ្ដើមមានសភាពធូរស្រាល ប៉ុន្តែស្រុកមួយចំនួននៅខាងក្នុង មានកំណើនពលករច្រើន ពិសេសនៅមុនរដូវបុណ្យចូលឆ្នាំនេះ៕

## NGO **រកឃើញករណីរំលោភសេពសន្ថវៈក្នុងឆ្នាំ ២០២០ មានការកើនឡើងតិចតួច**

https://www.postkhmer.com/ គឹម សារុំ | Publication date 16 March 2021 | 16:20 ICT

**ភ្នំពេញៈ** មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុកបានអះអាងថា នៅឆ្នាំ ២០២០ អាដហុកបានរកឃើញអំពើរំលោភសេពសន្ថវៈ ១៤៥ ករណី ដែលកើនឡើងតិចតួច បើប្រៀបនឹងឆ្នាំ ២០១៩ ក្នុងនោះជនរងគ្រោះភាគច្រើនគឺជាក្មេងស្រី អាយុក្រោម ១៨ ឆ្នាំ ដែលប្រព្រឹត្តដោយសាច់ញាតិផ្ទាល់ ឬបុគ្គលក្រៅរង្វង់គ្រួសារ ហើយមានជនរងគ្រោះខ្លះត្រូវបានសម្លាប់ផងដែរ។

លោកស្រី ម៉ៅ ម៉ាប់ មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុកទទួលបន្ទុកស្ត្រី និងកុមារបានឱ្យដឹងពីថ្ងៃទី១២ មីនាថា អំពើរំលោភសេពសន្ថវៈក្នុងឆ្នាំ ២០២០ គឺអាដហុកបានអង្កេត និងប្រមូលទិន្នន័យបានពីតាមបណ្ដាខេត្តក្នុងប្រទេសកម្ពុជាដោយបង្ហាញថា មាន ១៤៥ ករណី ដែលជាចំនួនច្រើនជាងឆ្នាំ ២០១៩ បន្តិចបន្តួច ក៏ប៉ុន្តែលោកស្រីមិនបានបញ្ជាក់ពីតួលេខក្នុងឆ្នាំ ២០១៩ ថា មានចំនួនប៉ុន្មានករណីនោះទេ។ លោកស្រីបន្តថា សមាគមអាដហុកភាគច្រើនធ្វើការផ្ដោតលើកុមារីដែលមានអាយុក្រោម ១៨ ឆ្នាំ ហើយបានរកឃើញថាពួកគេត្រូវរងនូវអំពើរំលោភសេពសន្ថវៈពីសំណាក់ជនល្មើសក្នុងនោះមានសាច់ញាតិផ្ទាល់ក្នុងគ្រួសារក្មេងស្រីរងគ្រោះ ឬបុគ្គលនៅក្រៅរង្វង់គ្រួសារពួកគេ (អ្នកដទៃ)។ បើតាមលោកស្រី ម៉ៅ ម៉ាប់ កត្តាសំខាន់ដែលនាំឱ្យមានបទល្មើសនេះគឺមកពីស្ថានភាពសេដ្ឋកិច្ចក្រីក្រក្នុងគ្រួសាររបស់ក្មេងតែម្ដង។ ករណីនេះគឺឪពុកម្ដាយក្មេងធ្វើចំណាកស្រុកទៅធ្វើការនៅក្រៅប្រទេសហើយទុកកូនតូចៗឱ្យនៅជាមួយជីដូនជីតាដែលមានវ័យចំណាស់ គ្មានកម្លាំងគ្រប់គ្រាន់ក្នុងការមើលថែរក្សាចៅ។ ហេតុនេះក្មេងៗទាំងនេះមិនទទួលបានការការពារខ្លួនពេញលេញទេ។ ម្យ៉ាងទៀតជម្រកកុមារីរងគ្រោះដែលស្នាក់នៅជាមួយជីដូនជីតានោះគឺមានខ្លះជាខ្ទមដែលជាឱកាសល្អសម្រាប់ជនខិលខូចធ្វើបាបលើកុមារី។

លោកស្រីបានបញ្ជាក់ថា៖ «ករណីភាគច្រើនលុះត្រាណាតែក្មេងមានបញ្ហាដូចជា មានរបួសស្នាមឈឺអ៊ីចឹងទៅ ទើបឪពុកម្ដាយ ឬសាច់ញាតិបានដឹងថាក្មេងនោះរងគ្រោះ។ ករណីនេះភាគច្រើនកើតនៅតំបន់ដាច់ស្រយាលឆ្ងាយៗជាបញ្ហាមួយដែលយើងមើលឃើញក្នុងពេលបច្ចុប្បន្ន»។ លោក ស្រី ម៉ៅ ម៉ាប់ បន្ថែមថាករណីរំលោភសេពសន្ថវៈនេះគឺកុមារីរងគ្រោះភាគច្រើនកម្រហ៊ានប្រាប់ដល់គ្រួសារ ឬឪពុកម្ដាយណាស់។ មូលហេតុដោយសារជនល្មើសតែងតែគំរាមក្មេងរងគ្រោះថា ប្រសិនបើពួកគេហ៊ាននិយាយចេញឱ្យសាច់ញាតិដឹងគឺអាចត្រូវគេសម្លាប់ចោល ១ គ្រួសារ ឬអាចសម្លាប់កុមារីនោះចោល។ អ៊ីចឹងហើយទើបក្មេងរងគ្រោះភ័យខ្លាចការសំឡុតគំរាមនោះ។ យ៉ាងណាក្ដី លោកស្រីថា បញ្ហានេះក៏ព្រោះតែការយល់ដឹងពីច្បាប់របស់ពលរដ្ឋតាមមូលដ្ឋាននៅមានកម្រិតផងដែរ។

ម្យ៉ាងដោយសារពួកគាត់ហាក់មិនសូវមានជំនឿលើប្រព័ន្ធតុលាការ ព្រោះការដោះស្រាយបណ្ដឹងតែងប្រើពេលយូរ ទើបពេលខ្លះពួកគាត់សម្រេចចិត្តទទួលយកសំណងរដ្ឋប្បវេណីពីជនល្មើសក្រៅប្រព័ន្ធតុលាការ។

លោកស្រីថា៖ «ភាគច្រើនគ្រួសារក្មេងរងគ្រោះយកសំណងហើយពួកគាត់គិតថា បញ្ចប់រឿងត្រឹមយកសំណងហើយនោះពួកគាត់មិនចូលរួមនៅតុលាការទៀតទេ។ ក្នុងរឿងព្រហ្មទណ្ឌគឺជនរងគ្រោះគាត់មានសិទ្ធិយកសំណងរដ្ឋប្បវេណីតែបណ្ដឹងអាជ្ញារបស់ពួកគាត់គឺនៅតែដំណើរការទេ។ នេះហើយជាបញ្ហាធ្វើឱ្យនិទណ្ឌភាពនៅតែកើតមានហើយករណីខ្លះមានការសម្របសម្រួលក្រៅប្រព័ន្ធតុលាការផង»។ ទោះជាយ៉ាងណា ទាក់ទងនឹងដំណើរការនីតិវិធីប្ដឹងវិញឃើញថា រដ្ឋាភិបាលកម្ពុជាក៏ដូចជាអាជ្ញាធរពាក់ព័ន្ធបានខិតខំប្រឹងប្រែងខ្លាំង។ ភាគច្រើនពេលមានបណ្ដឹងគឺសមត្ថកិច្ចតែងចាប់ជនល្មើសផ្ដន្ទាទោស។ នេះបើតាមការបញ្ជាក់បន្ថែមពីលោកស្រី ម៉ៅ ម៉ាប់។ បើតាមលោកស្រី ម៉ៅ ម៉ាប់ ករណីបទល្មើសរំលោភសេពសន្ថវៈកើតច្រើនជាងគេគឺមានដូចជា ខេត្តបាត់ដំបង ខេត្តកំពត និងកំពង់ធំ។ ចំណែកករណីឪពុកម្ដាយក្មេងដែលចេញទៅធ្វើការនៅក្រៅប្រទេសវិញក៏ខេត្តទាំង ៣ នេះមានតួលេខច្រើនជាងខេត្តផ្សេងៗផងដែរ។

ទាក់ទងនឹងបញ្ហានេះ លោកឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានថ្លែងពីម្សិលមិញថា ប្រសិនបើពលរដ្ឋដឹងថា មានបទល្មើសរំលោភសេពសន្ថវៈកើតឡើងសូមប្រញាប់ប្ដឹងសមត្ថកិច្ចនគរបាលភ្លាមៗពិសេសគឺអង្គភាពដែលនៅជិតកន្លែងកើតហេតុបំផុត។ លោក ផល្លី បានបញ្ជាក់ថា៖ «យើងមើលឃើញថា កន្លងមកទោះជាមានបទល្មើសអីកើតឡើងក៏ដោយ គឺនៅពេលទទួលបានព័ត៌មានសមត្ថកិច្ចយើងតែងខ្នះខ្នែងធ្វើសកម្មភាពចាត់ចែងភ្លាម។ យើងឆ្លើយតបដើម្បីពលរដ្ឋក្នុងនាមជាកងកម្លាំងយើងត្រូវតែការពារជូនពលរដ្ឋ។ កន្លងទៅក៏ដូចបច្ចុប្បន្នយើងកំពុងធ្វើការយ៉ាងសកម្មនៅពេលទទួលបានបណ្ដឹងគឺយើងមានចំណាត់ការភ្លាមៗ»។

ករណីបទល្មើសរំលោភសេពសន្ថវៈនេះកាលពីដើមខែមីនាឆ្នាំនេះ មានស្ត្រីម្នាក់ ឈ្មោះ ហួន ស្រី អាយុ ២៣ ឆ្នាំ បម្រើការនៅកាស៊ីណូមួយក្នុងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យត្រូវជនល្មើសឈ្មោះ រឿន ជារិន អាយុ ៣៨ ឆ្នាំចាប់រំលោភរួចចាក់សម្លាប់ក្នុងបន្ទប់ជួលរបស់នាង។ ប៉ុន្តែក្រោយមកត្រូវសមត្ថកិច្ចតាមចាប់ខ្លួនដល់ខេត្តសៀមរាប ហើយត្រូវបានតុលាការខេត្តបន្ទាយមានជ័យសម្រេចឃុំខ្លួនកាលពីថ្ងៃទី ៦ មីនា ពាក់ព័ន្ធនឹងបទល្មើសមនុស្សឃាតដោយចេតនា៕

## ពលករខ្មែរជាច្រើននាក់បន្តវិលត្រឡប់នៅកម្ពុជាវិញ ដោយសារនៅថៃអត់ការងារធ្វើ

https://www.rfa.org/khmer/ ដោយ ឡេង ម៉ាលី 2021-03-16

ពលករខ្មែរជាច្រើននាក់ នៅតែនាំគ្នាឆ្លងដែនត្រឡប់ទៅកម្ពុជាវិញ ដោយសារតែនៅក្នុងប្រទេសថៃអត់ការងារធ្វើជាច្រើនខែ បណ្ដាលមកពីវិបត្តិជំងឺកូវីដ១៩។ មន្ត្រីសង្គមស៊ីវិលយល់ថា រឿងនេះអាចនឹងក្លាយទៅជាវិបត្តិសង្គមនៅពេលខាងមុខ ដែលអាជ្ញាធរពាក់ព័ន្ធគួរតែមានវិធានការជួយដល់ពួកគាត់ជាបន្ទាន់។ ពលករខ្មែរភាគច្រើនឆ្លងដែនចូលទៅកម្ពុជាតាមច្រករបៀងព្រំដែនក្នុងខេត្តបាត់ដំបង បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ។

ពលករមានស្រុកកំណើតនៅព្រះវិហារ លោក រិន វិសាល ប្រាប់អាស៊ីសេរីនៅរសៀលថ្ងៃទី១៥ មីនាថា លោកបានធ្វើដំណើរពីទីក្រុងបាងកក ហើយបានឆ្លងដែនចូលទៅកម្ពុជាតាមច្រកទ្វារព្រំដែនអូរស្មាច់ ក្រុងសំរោង ខេត្តឧត្តរមានជ័យកាលពីថ្ងៃទី១១ មីនា ដោយចំណាយអស់ថវិកាប្រមាណ២ពាន់បាត ឬស្មើនឹងជាង ៦០ដុល្លារ។ ពលកររូបនេះ បញ្ជាក់ថា ក្នុងថ្ងៃដែលលោកធ្វើដំណើរនោះមានពលករខ្មែរប្រមាណ ២០០នាក់ បានត្រឡប់ទៅកម្ពុជាវិញ ដោយសារនៅប្រទេសថៃអត់ការងារធ្វើ៖ «គឺគេឱ្យយើងចូលប៉ូលិសថៃ ហើយគេបញ្ជូនទៅប៉ូលិសខ្មែរ ហើយគេបញ្ជូនខ្ញុំមកខ្មែរបណ្ដោយ និយាយទៅល្អងាយស្រួល។ខ្ញុំត្រឡប់មកវិញនេះ គឺស្រុកថៃអស់ការងារធ្វើ ហើយធ្វើប៉ា

សស្ត័រវាថ្លៃពេក ធ្វើលិខិតឆ្លងដែនគេគិតលុយរហូតវាអត់សល់លុយ បើនៅខ្មែរបានបងប្អូនផ្ញើអង្ករមកឱ្យយើងចេះតែនៅរស់បាន ខ្ញុំនិយាយការពិត»។

ស្រដៀងគ្នានេះដែរពលករមានស្រុកកំណើតនៅខេត្តកំពង់ចាម លោក ហន ណារុង ថ្លែងថា លោកបានឆ្លងដែនចូលមកដល់កម្ពុជានៅរសៀលថ្ងៃទី៧ មីនា បន្ទាប់ពីធ្វើការងារនៅប្រទេសថៃជាង ២ឆ្នាំ។ ពលករវ័យ ៣០ឆ្នាំរូបនេះថា លោកកំពុងធ្វើចត្តាឡីស័កនៅក្នុងខេត្តព្រះវិហារ ហើយលោកនឹងចេញទៅស្រុកកំណើតនៅសប្តាហ៍ក្រោយ។ ពលកររូបនេះនិយាយថា លោកមិនត្រឡប់ទៅធ្វើការនៅប្រទេសថៃវិញទេ ដោយចង់រកការងារធ្វើនៅក្នុងស្រុកដើម្បីបានរស់នៅជួបជុំគ្រួសារ៖ «ខ្ញុំធ្វើការនៅថៃយូរហើយដល់ពេលខ្ញុំដល់ពេលត្រូវត្រឡប់មកផ្ទះវិញ ខ្ញុំដាច់វីសា។ ខ្ញុំចង់មករកបរខ្លួនឯងនៅផ្ទះវិញ និយាយនឹកប្រពន្ធកូន ណាមួយចង់មកនៅផ្ទះបណ្តោយណាមួយក៏ពិបាករឿងកូវីដ ហើយគេតម្រូវឱ្យខ្ញុំបន្តសុពលភាពទិដ្ឋាការដល់ពេលអីចឹងខ្ញុំត្រូវនៅរយៈពេល ២ឆ្នាំទៀត។ អីចឹងខ្ញុំនឹកផ្ទះដែរ បើថាអត់មានកូវីដ១៩ ខ្ញុំអត់ទាន់មកទេ ដល់ពេលមានជំងឺកូវីដអីចឹងទៅខ្ញុំសុំគេមកផ្ទះបណ្តោយ»។

ទាក់ទិននឹងការវិលត្រឡប់របស់ក្រុមពលករនេះ ស្នងការរងនគរបាលខេត្តបន្ទាយមានជ័យទទួលបន្ទុកផ្នែកការពារព្រំដែន លោក អ៊ុំ សុផល ប្រាប់អាស៊ីសេរីថា អាជ្ញាធរថៃបានចាប់បញ្ជូនពលករខ្មែរប្រមាណ២០០នាក់ប្រគល់ឱ្យអាជ្ញាធរកម្ពុជាវិញតាមច្រករបៀងព្រំដែនក្នុងខេត្តបន្ទាយមានជ័យនៅព្រឹកថ្ងៃទី១៥មីនា។ លោកបញ្ជាក់ថា ពលករមួយចំនួនត្រូវបានអាជ្ញាធរថៃចាប់ខ្លួន ក្នុងពេលដែលពួកគេធ្វើដំណើរត្រឡប់មកកម្ពុជា ដោយសារនៅប្រទេសថៃអត់ការងារធ្វើ៖ «គេចាប់បញ្ជូនមក ទាហានថៃគេដឹកមកទម្លាក់បាទ គេចាប់តាមផ្លូវមក គឺដឹកមកទម្លាក់តាមច្រករបៀងមករួចហើយគាត់ដើរមក។ ខ្លះទៅគាត់មកខ្លួនឯង ខ្លះទៅគាត់ថានៅឯណោះអត់មានការងារធ្វើ គេបិទរោងចក្របិទអ៊ីអីចឹងទៅគាត់អត់មានអីធ្វើ ដល់នៅទីនោះគាត់ដើរអត់កើតផង ដោយសារខ្លាចឆ្លងកូវីដទៅគាត់សម្រេចចិត្តត្រឡប់មកខ្មែរវិញ»។

ទោះជាយ៉ាងណាមន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុលផ្នែកពលករ លោក ឌី ថេហូយ៉ា យល់ថារឿងនេះអាចនឹងក្លាយទៅជាបញ្ហាសង្គមនៅពេលខាងមុខ ដោយសារតែពួកគេអត់ការងារធ្វើ ហើយគ្មានប្រាក់សងធនាគារ។ មន្ត្រីសង្គមស៊ីវិលរូបនេះ បញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហានេះរដ្ឋាភិបាលគួរតែបញ្ជូនមន្ត្រីជំនាញចុះបង្រៀនដល់ក្រុមពលករទាំងនោះឱ្យចេះដាំដុះ និងជួយរកទីផ្សារលក់កសិផលក្នុងតម្លៃសមរម្យ ដើម្បីពួកគាត់បានប្រាក់ដោះស្រាយជីវភាពគ្រួសារ៖ «បើយើងមើលអំពីស្ថានភាពសព្វថ្ងៃនេះរោងចក្រផ្សេងៗ អីគេអាចបញ្ឈប់ គេអាចបិទ ក៏ប៉ុន្តែអាពាក់ព័ន្ធដំណើរផលិតការហូបចុកនេះ ខ្ញុំគិតថា វាអត់សូវជាប៉ះពាល់ទេ បើសិនជាយើងជំរុញផ្នែកដាំដុះផ្នែកអីហ្នឹងអាចជួយគាត់បានច្រើន។ អាហ្នឹងវាអាស្រ័យទៅលើរដ្ឋាភិបាលថាតើរៀបចំគោលនយោបាយបែបម៉េច ពាក់ព័ន្ធហ្នឹងកសិកម្មដើម្បីឱ្យគាត់បានដាំដុះចិញ្ចឹមជីវភាពក៏ដូចជាលក់ដូរចិញ្ចឹមជីវភាពរបស់គាត់ហ្នឹង»។

ចាប់តាំងពីចុងឆ្នាំ២០២០ រហូតមកដល់ពេលនេះមានពលករខ្មែរជាង៤ម៉ឺននាក់(៤០.០០០)ហើយ ដែលបានត្រឡប់មកកម្ពុជាវិញ ដោយសារការរាតត្បាតជំងឺកូវីដ១៩ ឆ្លងចូលក្នុងសហគមន៍នៅប្រទេសថៃជាលើកទី២។ របាយការណ៍អង្គការសង់ត្រាល់ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការងារស្របច្បាប់និងមិនស្របច្បាប់ប្រមាណ ១លាន ៨សែននាក់ (១.៨០០.០០០) ធ្វើការនៅប្រទេសថៃ៕

## កម្លាំងនគរបាលនិងកម្លាំងយោធា ទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ១៤នាក់រួចបញ្ជូនមកកាន់មណ្ឌលចត្តាឡីស័ក

http://nokorwatnews.com/ 16/03/2021

ខេត្តបាត់ដំបង៖ នៅថ្ងៃអង្គារ ទី១៦ ខែមីនា ឆ្នាំ២០២១ តាមការណែនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គីមសាន ស្នងការនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាល

ការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយ កម្លាំងយោធាវរសេនាតូច៥៣៣, កម្លាំងសឹករងស្រុកសំពៅលូន និងកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រៃសីមានៃអធិការដ្ឋាននគរបាលស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន១៤ នាក់ ,ស្រី៤នាក់ ក្នុងនោះក្មេងស្រី១នាក់ និងក្មេងប្រុស២នាក់ ពីចំណុចភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ បន្ទាប់ពីសាកសួររួចក៏បានអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៦ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី១៦ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២២នាក់ ស្រី ៤៨នាក់ ក្នុងនោះកុមារ ៣នាក់ កុមារី ៣នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២៦នាក់ ស្រី ១៣នាក់ កុមារ ៣នាក់ កុមារី ២នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ២៤នាក់ ស្រី ១០នាក់ កុមារ ០០នាក់ កុមារី ១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៥៦នាក់ ស្រី ២០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ១១នាក់ ស្រីចំនួន ៥នាក់ កុមារចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ៥នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២២នាក់ ស្រី ៤៨នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបនៅក្នុងថ្ងៃនេះ ចំនួន ១១៦នាក់ ស្រី ៤១នាក់ ត្រូវបានបញ្ជូនទៅខេត្តសៀមរាបរួចហើយ។ ចំណែកនៅខេត្តបាត់ដំបង ចំនួន ១១នាក់ ស្រី ៥នាក់ និងខេត្តប៉ៃលិនចំនួន ៥នាក់ ស្រី ០០នាក់ មិនទាន់បានធ្វើការបញ្ជូនទៅខេត្តសៀមរាបទេ ៕ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃចន្ទ ទី១៥ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២៤នាក់ ស្រី ៤៧នាក់ ក្នុងនោះកុមារ ៨នាក់ កុមារី ៧នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារ ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៥នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤៩នាក់ ស្រី ២០នាក់ កុមារា ៧នាក់ កុមារី ៦នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៥៦នាក់ ស្រី ២២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ៤នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២៤នាក់ ស្រី ៤៧នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបនៅក្នុងថ្ងៃនេះ ចំនួន ១២០នាក់ ស្រី ៤៦នាក់ ចំណែកខាងខេត្តបាត់ដំបងចំនួន ៤នាក់ ស្រី ១នាក់មិនទាន់បានបញ្ជូនទៅខេត្តសៀមរាបឡើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## កម្លាំងនគរបាល និងកម្លាំងកងរាជអាវុធហត្ថ បង្រ្កាបមេខ្យល់ចំនួន២នាក់ នាំពលករឆ្លងដែនខុសច្បាប់១៤នាក់ទៅប្រទេសថៃ

https://www.kampucheathmey.com/ on March 16, 2021By Kang Tola

បន្ទាយមានជ័យ ៖ កម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយមន្រ្តីជំនាញនាយកដ្ឋានសន្តិសុខផ្ទៃក្នុង កំលាំងអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ និងកងរាជអាវុធហត្ថស្រុកម៉ាឡៃ ក្រោមការដឹកនាំរបស់ ឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុង បានចុះស្រាវជ្រាវបង្ក្រាបករណីនាំមនុស្សឆ្លងដែនខុសច្បាប់នៅក្នុងភូមិសាស្រ្តស្រុកម៉ាឡៃ នៅវេលាម៉ោង៧យប់ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ បានធ្វើការឃាត់ខ្លួនមេខ្យល់២នាក់លួចនាំពលករចំនួន១៤នាក់ ស្រី៩នាក់ ឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ក្នុងភូមិសាស្រ្ត ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។

លោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាល ស្រុកម៉ាឡៃ បានឲ្យដឹងថា ជនសង្ស័យជាមេខ្យល់ទាំង២នាក់១ឈ្មោះ ចក់ រី ហៅ ០៩ ភេទប្រុស អាយុ ៤១ឆ្នាំ រស់នៅ ភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យជាមេក្លោង ២ឈ្មោះ យ៉ាត ប៊ុននី ភេទប្រុស អាយុ ៣៨ឆ្នាំ រស់នៅភូមិត្រពាំងជរ ឃុំចំណាលើ ស្រុកស្ទោង ខេត្តកំពង់ធំ ជាមេខ្យល់ទាំង២នាក់នេះ បាននាំពលករប្រុស ស្រីចំនួន១៤នាក់ យកមកលាក់ខ្លួននៅក្នុងផ្ទះសំណាក់ ម៉ី ម៉ី ស្ថិតនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីត្រៀមលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ នៅយប់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ចំណែកឈ្មោះអោម ចាន់រ៉ា ភេទប្រុសអាយុ៦៣ឆ្នាំ ជាម្ចាស់ផ្ទះសំណាក់ ម៉ី ម៉ី មិនសហការជាមួយសមត្ថកិច្ចបានផ្តល់ទីតាំងឲ្យមេខ្យល់លាក់ពលករ។

លោកអធិការបានបញ្ជាក់ថា ជនសង្ស័យជាមេខ្យល់ទាំង២នាក់និងម្ចាស់ផ្ទះសំណាក់ កំពុងធ្វើការសាកសួរនៅអធិការដ្ឋាននគរបាលស្រុក ដើម្បីរៀបចំសំណុំរឿងបញ្ជូនមកស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។ ដោយឡែកពលករទាំង១៤នាក់កំពុងធ្វើការសាកសួរនៅអធិការដ្ឋាន៕ *ដោយ ៖ វ៉ាន់ណាង*

## ប្តីប្រពន្ធ ត្រូវបានចោទប្រកាន់ពីនាំបុរសវៀតណាម ៤ នាក់ឆ្លងដែនចូលកម្ពុជា

https://www.khmertimeskh.com/ បុត វស្មីគង្គា / Khmer Times

ស្នងការនគរបាលខេត្តកំពតលោកឧត្តមសេនីយ៍ទោ ម៉ៅច័ន្ទ មធុរិទ្ធ បានបញ្ជាក់ថាជនជាប់ចោទទាំង ២ នាក់មានឈ្មោះជា សុវណ្ណារីអាយុ ៣០ ឆ្នាំមុខរបរតាក់ស៊ី មានទីលំនៅភូមិក្រសាំងឃុំឈូកស្រុកឈូកខេត្តកំពត និងស្ត្រីឈ្មោះនាង ខេង អាយុ ៥៨ ឆ្នាំជាអាជីវករលក់បារីដែលរស់នៅភូមិព្រៃកគ្រួសឃុំព្រៃកគ្រួសក្នុងស្រុកកំពង់ត្រាចខេត្តកំពត។ មេខ្យល់ទាំងពីរនាក់ដែលត្រូវបានចាប់ខ្លួនកាលពីថ្ងៃអាទិត្យនៅខេត្តកំពតត្រូវបានចោទប្រកាន់ពី«

បទនាំមនុស្សឆ្លងដែនខុសច្បាប់» តាមមាត្រា ១១ នៃច្បាប់ស្តីពីការបង្រ្កាបការជួញដូរមនុស្សនិងការធ្វើអាជីវកម្មផ្លូវភេទ។ លោកបន្តថា ប្រសិនបើត្រូវផ្តន្ទាទោស ពួកគេម្នាក់ៗនឹងត្រូវជាប់ពន្ធនាគារពី ៧ ទៅ ១៥ ឆ្នាំ។ លោកបានប្រាប់កាសែតខ្មែរថាមស៍ថា៖« ពួកគេត្រូវបានចាប់ខ្លួនដោយប៉ូលីសខេត្តរបស់យើងបន្ទាប់ពីពួកគេបានលួចនាំជាតិវៀតណាមចំនួន ៤ នាក់នៅតាមព្រំដែនកម្ពុជា – វៀតណាមអំឡុងពេលមានការផ្ទុះកូវីត១៩ នៅពេលដែលរដ្ឋាភិបាលបានបិទព្រំដែនដើម្បីការពារការរីករាលដាលនៃជំងឺនេះ» ។

លោកបាននិយាយថា ប៉ូលីសក៏បានចាប់ខ្លួនបុរសជនជាតិវៀតណាមទាំងនោះ ប៉ុន្តែពួកគេត្រូវបានគេនិរទេសទៅប្រទេសវៀតណាមបន្ទាប់ពីគេបានរកឃើញថាពួកគេមិនបានឆ្លងជំងឺកូវីដ-១៩ នោះទេ។ លោកឧត្តមសេនីយ៍ឯកច័ន្ទ មធុរិទ្ធបានមានប្រសាសន៍ថា មេខ្យល់កំពុងត្រូវបានឃុំខ្លួនក្នុងពន្ធនាគាររង់ចាំការជំនុំជម្រះ។ លោកបានបន្ថែមថា៖« ជាមួយនឹងការបិទព្រំដែនយើងនឹងមិនអនុញ្ញាតឱ្យអ្នកណាម្នាក់ចូលក្នុងប្រទេសដោយខុសច្បាប់ឡើយពីព្រោះអាទិភាពរបស់យើងគឺការពារការរីករាលដាលនៃជំងឺនេះទៅក្នុងប្រទេស» ៕

## ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២១

### គិតត្រឹមថ្ងៃទី១៦មីនា សមត្ថកិច្ចបានឃាត់ខ្លួនពលករខ្មែររត់គេចពីការធ្វើចត្តាឡីស័កជាង ៤០០០នាក់

https://www.kampucheathmey.com/ on March 17, 2021By vin vatdara

ចាប់ពីថ្ងៃទី១៣ រហូតដល់ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១នេះ សមត្ថកិច្ចបានធ្វើការឃាត់ខ្លួនពលករខ្មែរដែលគេចវេសពីការធ្វើចត្តាឡីស័កបានជាង៤០០០នាក់ និងបានបញ្ជូនទៅធ្វើចត្តាឡីស័កវិញនៅទូទាំងប្រទេស។ នេះបើតាមការឱ្យដឹងពីលោក ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាល នៅព្រឹកថ្ងៃទី១៧ មីនា ឆ្នាំ២០២១។ លោក ឧត្តមសេនីយ៍ឯក បានបន្តថា ក្នុងចំណោមពលករគេចវេសពីការធ្វើចត្តាឡីស័កជាង៤០០០នាក់ ភាគច្រើនជាបុរសដោយមួយចំនួនត្រូវអាជ្ញាធរធ្វើការឃាត់ខ្លួននៅតាមព្រំដែនពេលពួកគេលួចឆ្លងដែនខុសច្បាប់ និងមួយចំនួនទៀតឃាត់ខ្លួននៅតាមភូមិកំណើតរបស់ពួកគេ ហើយបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅតាមមណ្ឌលធ្វើចត្តាឡីស័ករយៈពេល១៤ វិញ។ លោក ឧត្តមសេនីយ៍ឯក បានអំពាវនាវដល់ពលករដែលកំពុងធ្វើការ និងស្នាក់នៅក្រៅប្រទេសសូមកុំទាន់វិញត្រឡប់មកស្រុកវិញនៅដំណាក់កាលនេះអី សូមបន្តស្នាក់នៅ និងធ្វើការនៅស្រុកគេសិនទៅ ព្រោះថាបើបងប្អូនត្រឡប់មកវិញក៏ត្រូវធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃដែរ ហើយអាចនាំជំងឺកូវីដ១៩មកចម្លងក្នុងស្រុកទៀតផង។

លោក ឧត្តមសេនីយ៍ឯក បានអំពាវនាវទៀតថា ចំណែកពលករដែលបានចូលមកដល់ស្រុកវិញហើយត្រូវអនុវត្តទៅតាមការណែនាំរបស់ក្រសួងសុខាភិបាលមិនត្រូវធ្វើការរត់គេចវេះពីការធ្វើចត្តាឡីស័កនោះទេ ដើម្បីចៀសវាងទទួលនូវការផាកពិន័យ ឬទោសទណ្ឌតាមផ្លូវច្បាប់ ពិសេសអាចចម្លងមេរោគកូវីដ១៩ទៅក្រុមគ្រួសារ និងសហគមន៍ជុំវិញខ្លួនដែលធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សង្គមជាតិនិងធ្វើឲ្យមានវិប្បដិសារីទៅថ្ងៃក្រោយ។ លោក ឧត្តមសេនីយ៍ឯក បានបញ្ជាក់ថា«ខ្ញុំសូមអង្វរករហើយអង្វរករទៀតដល់បងប្អូនពលករយើង ដែលនៅក្រៅប្រទេសសូមកុំទាន់វិលត្រឡប់មកវិញអី សូមបន្តស្នាក់នៅឬធ្វើការនៅទីនោះសិនទៅ។ ចំណែកពលករដែលវិលត្រឡប់មកដល់កម្ពុជាហើយគួរតែគោរពនិងអនុវត្តទៅតាមវិធានការណែនាំរបស់រាជរដ្ឋាភិបាលទាំងអស់គ្នាដើម្បីការពារអាយុជីវិតប្រជាពលរដ្ឋឲ្យចៀសផុតពីជំងឺកូវីដ១៩ដែលជាជំងឺដ៏កាចសាហាវនេះ»។

គួរបញ្ជាក់ថា ច្បាប់ថ្មីស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត ទើបប្រកាសដាក់ឲ្យប្រើប្រាស់ថ្មីៗនេះបានឲ្យដឹងថា បើបុគ្គលណាអ្នកគេចវេះពីការធ្វើចត្តាឡីស័ក ឬគេចចេញពីទីកន្លែងចត្តាឡីស័ក ត្រូវផ្តន្ទាទោសត្រូវដាក់ពន្ធនាគារពី៦ខែទៅ៣ឆ្នាំ និង

ពិន័យជាប្រាក់ពី ២លានរៀលទៅ១០លានរៀល កាលបើអំពើខាងលើនេះបណ្តាលឱ្យមានការចម្លងជំងឺកូវីដ-១៩ ដល់អ្នកដទៃ៕ អត្ថបទ៖ សំអឿន

## អំពាវនាវដល់បងប្អូនពលករទៅដល់កំពង់ធំ សូមចូលរួមទប់ស្កាត់ជម្ងឺរាតត្បាត តាមរយៈ "៣ការពារ ៣កុំ ២ចូលរួម "

https://www.rasmeinews.com/ 17 March, 2021

**ដោយ: ភ្នំស្វាយ / កំពង់ធំ:** *រដ្ឋបាលកំពង់ធំ បានអំពាវនាវដល់បងប្អូនពលករទាំងអស់ សូមចូលរួមទប់ស្កាត់ជំងឺកូវីដ១៩ តាមរយ: "៣ការពារ ៣កុំ ២ចូលរួម" ។*

លោក សុខ លូ អភិបាលខេត្តកំពង់ធំ បានថ្លែងដូច្នេះនៅក្នុងពិធីសំណេះសំណាលជាមួយបងប្អូនពលករដែលទើបវិលត្រឡប់មកពីប្រទេសថៃនៅយប់ថ្ងៃទី ១៦ ខែមីនា ចំនួន ១០៤នាក់ នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យកំពង់ធំ។ លោកបានអំពាវនាវអោយអនុវត្តនូវទិសស្លោក ថា ៖ ៣ ការពារ៖ គឺ ១. ពាក់ម៉ាស់នៅគ្រប់ទីសាធារណៈ ។ ២. លាងដៃជាមួយសាប៊ូ អាល់កុល ឬជែល ។ ៣. រក្សាគម្លាតសុវត្ថិភាពសង្គម និងបុគ្គល ចាប់ពី មួយម៉ែត្រកន្លះឡើងទៅ។ ឯ ៣ កុំ៖ ១. កុំចូលទៅកន្លែងបិទជិតគ្មានខ្យល់ចេញចូល ។ ២. កុំចូលទៅកន្លែងមានមនុស្សច្រើនកុះករ ។ ៣. កុំប៉ះពាល់គ្នា។ លើសពីនេះទៀត លោកក៏បានពន្យល់ពីសារៈសំខាន់នៃការធ្វើចត្តាឡីស័ក និងច្បាប់ស្តីពីការផាកពិន័យជាសាច់ប្រាក់កំឡុងពេលកូវីដ ១៩។

សូមរំលឹកថា រៀងរាល់ព្រឹក ថ្នាក់ដឹកនាំខេត្តកំពង់ធំ តែងជួបសំណេះសំណាលជាមួយបងប្អូនពលករដែលវិលត្រឡប់មកពីប្រទេសថៃ ទើបមកថ្មី ហើយសម្រាកមួយយប់ នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យកំពង់ធំ ឬមណ្ឌលតាមស្រុក ឯទៀត ៕

## កូរ៉េនៅបន្តទទួលយកពលករកម្ពុជាចំនួន ៣ ៤០៤ នាក់ សម្រាប់ឆមាសទី១ ឆ្នាំនេះ

https://www.postkhmer.com/ ឡុង គីមម៉ារីតា | Publication date 17 March 2021 | 15:00 ICT

**ភ្នំពេញ:** បើទោះបីជាស្ថានភាពនៃការរាតត្បាតជំងឺកូវីដ ១៩ នៅមិនទាន់ថមថយក៏ដោយ ក៏រដ្ឋាភិបាលកូរ៉េនៅតែបន្តផ្តល់កូតាក្នុងការនាំពលករកម្ពុជា ទៅធ្វើការនៅប្រទេសនេះចំនួន ៥០ ភាគរយ សម្រាប់ឆមាសទី១ ឆ្នាំ២០២១ ខណៈពលករដែលត្រូវបានអនុញ្ញាតឱ្យដាក់ឈ្មោះចូលក្នុងបញ្ជីសុំស្វែងរកការងារធ្វើក្នុងឆ្នាំនេះ មានចំនួនសរុប ២២ ៦៩៧ នាក់។

លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានសរសេរបង្ហោះនៅលើទំព័រហ្វេសប៊ុករបស់លោកកាលពីថ្ងៃទី ១៥ មីនា ថា ក្រសួងការងារ និងមុខរបរនៃសាធារណរដ្ឋកូរ៉េបានជូនដំណឹងពីការបែងចែកកូតាសម្រាប់ពលករកម្ពុជាទៅធ្វើការនៅសាធារណរដ្ឋកូរ៉េតាមរយៈប្រព័ន្ធអនុញ្ញាតមុខរបរ (EPS)។ បើទោះបីស្ថានភាពនៃការរាតត្បាតជំងឺកូវីដ ១៩ មិនទាន់មានការថមថយក៏ដោយ ក៏រដ្ឋាភិបាលកូរ៉េនៅតែបន្តផ្តល់កូតាចំនួន ៥០ ភាគរយ គឺមានវិស័យឧស្សាហកម្មចំនួន ៣ ៤០៤ នាក់។ សម្រាប់ឆមាសទី២ ឆ្នាំ ២០២១ កម្ពុជានឹងទទួលបានកូតាបន្ថែមទៀត បន្ទាប់ពីស្ថានភាពជំងឺកូវីដ ១៩ មានភាពធូរស្បើយ។ លោកបន្ថែមថា៖ «ដោយឡែក ចំនួនពលករដែលត្រូវបានអនុញ្ញាតដាក់ចូលក្នុងបញ្ជីសុំស្វែងរកការងារធ្វើក្នុងឆ្នាំ ២០២១ មានចំនួនសរុប ២២ ៦៩៧ នាក់ ក្នុងនោះវិស័យឧស្សាហកម្មចំនួន ១៦ ២៦១ នាក់ វិស័យកសិកម្ម និងចិញ្ចឹមសត្វចំនួន ៥ ៧៧៨ នាក់ និងវិស័យសំណង់ចំនួន ៦៥៨ នាក់»។ លោក សំហេង សង្ឃឹមថានឹងទទួលបានកូតាបន្ថែមទៀត បន្ទាប់ពីស្ថានភាពជំងឺកូវីដ ១៩ មានភាពល្អប្រសើរឡើង។ បើតាមក្រសួងការងារក្នុង១ឆ្នាំៗ ពលករកម្ពុជាដែលបានទៅធ្វើការនៅប្រទេសកូរ៉េមានប្រមាណ ៦ ០០០ នាក់។ កាលពីខែកុម្ភៈ កម្ពុជា និងសាធារណរដ្ឋកូរ៉េបន្តចុះហត្ថលេខាលើអនុស្សរណៈនៃ

ការយោគយល់គ្នា ស្តីពីការបញ្ជូនពលករទៅបម្រើការងារនៅសាធារណរដ្ឋកូរ៉េក្រោមប្រព័ន្ធអនុញ្ញាតមុខរបរ (EPS) ជាលើកទី៦ ខណៈរយៈពេលជាង ១០ ឆ្នាំកន្លងមកនេះ ប្រព័ន្ធ EPS បានបញ្ជូនពលករកម្ពុជាជិត ៧ ម៉ឺននាក់ទៅបំពេញការងារនៅក្នុងប្រទេសនេះ។

លោក ឌី ថេហូយ៉ា មន្ត្រីកម្មវិធីការពារសិទ្ធិពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ធ្លាប់បានលើកឡើងថា ដំណើរការនៃការបញ្ជូនពលករទៅកាន់ប្រទេសកូរ៉េនេះ គឺជាដំណើរការល្អមួយដែលអាចផ្តល់ឱកាសដល់ពលរដ្ឋខ្មែរបានច្រើនបើប្រៀបធៀបនឹងការបញ្ជូនពលករចេញទៅប្រទេសដទៃ។ ក៏ប៉ុន្តែលោកថា បើទោះជាដំណើរការបញ្ជូនពលករទៅប្រទេសនេះមានភាពល្អប្រសើរហើយក្តី ក៏លោករំពឹងថា រដ្ឋាភិបាលនៃប្រទេសទាំង ២ គួរតែយកចិត្តទុកដាក់បន្ថែមទៀត។ លោកបញ្ជាក់ថា៖ «ពាក់ព័ន្ធនឹងប្រព័ន្ធនៃការការពារទៅលើសិទ្ធិពលករ និងលក្ខខណ្ឌការងារ និងប្រាក់ឈ្នួល ឬកន្លែងរស់នៅមានមួយចំនួនហាក់នៅខ្វះចន្លោះ ព្រោះយើងឃើញមានករណីស្លាប់ មានអី អ៊ីចឹងហើយ ប្រព័ន្ធលក្ខខណ្ឌកន្លែងរស់នៅនេះគឺត្រូវតែយកចិត្តទុកដាក់ត្រូវតែការពារពួកគាត់ឱ្យមានសុវត្ថិភាពនៅកន្លែងការងារ និងកន្លែងរស់នៅ»។ ក្រៅពីនេះលោក ឌី ថេហូយ៉ា ចង់ឱ្យរដ្ឋាភិបាលកម្ពុជាពិនិត្យមើលលទ្ធភាពនៃការចំណាយរបស់ពលករម្នាក់ៗ ដែលទម្រាំទទួលបានឱកាសការងារនៅប្រទេសកូរ៉េ គឺត្រូវចំណាយប្រាក់ជាច្រើន។

លោក ហេង សួរ អ្នកនាំពាក្យក្រសួងការងារប្រាប់ភ្នំពេញ-ប៉ុស្តិ៍កាលពីម្សិលមិញថា ក្រៅពីទទួលបានកូតាពីរដ្ឋាភិបាលកូរ៉េនេះ កម្ពុជាក៏បានស្នើសុំទៅភាគីថៃ ដើម្បីសម្រួលថ្លៃសេវានានាដល់ពលករខ្មែរដែលកំពុងធ្វើការនៅប្រទេសនោះផងដែរ។ លោកបន្តថា កន្លងទៅការស្នើសុំបន្តទិដ្ឋាការដើម្បីបន្តការរស់នៅ និងធ្វើការនៅប្រទេសនេះគឺមានការលើកឡើងថា មានតម្លៃថ្លៃ ប៉ុន្តែសំណើរបស់កម្ពុជាគឺអាស្រ័យទៅលើការសម្រេចរបស់រដ្ឋាភិបាលថៃក្នុងការបញ្ចុះតម្លៃថ្លៃសេវានេះ។ លោកបញ្ជាក់ថា៖ «យើងបានស្នើសុំទៅភាគីថៃដើម្បីសម្រួលថ្លៃសេវានានា។ ប៉ុន្តែនោះគឺជាអធិបតេយ្យភាពរបស់សមភាគីយើង»។ ចាប់ពីថ្ងៃទី ១៥ ខែមករា ដល់ថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ ២០២១ ពលករបរទេសដែលបានចុះឈ្មោះជាមួយក្រសួងការងារថៃមានចំនួន ៦៥៤ ៨៦៤ នាក់ ក្នុងនោះមានពលករកម្ពុជាចំនួន ២០៣ ៦៧៩ នាក់។ ក្នុងចំណោមពលករខ្មែរទាំងនេះ គឺមានពលករមាននិយោជកចំនួន ១៨០ ៤៧៦ នាក់ និងមានពលករមិនមាននិយោជកចំនួន ២៣ ២០៣ នាក់ទទួលបានការបន្តទិដ្ឋាការដើម្បីបន្តការងារ និងរស់នៅក្នុងប្រទេសថៃស្របច្បាប់។

លោក លឹង សុផុន ក្រុមការងារនៃអង្គការសង់ត្រាល់ប្រចាំប្រទេសថៃបានលើកឡើងថា បើសិនជារដ្ឋាភិបាលស្វែងរកការចរចា ដើម្បីឱ្យពលករនៅប្រទេសថៃទទួលបានលក្ខខណ្ឌល្អដូចពលករខ្មែរ ដែលទៅធ្វើការនៅប្រទេសកូរ៉េនោះគឺជារឿងមួយដែលប្រសើរ។ លោកបន្តថា ពលករខ្មែរនៅប្រទេសមួយចំនួនកំពុងប្រឈមនឹងការអត់ការងារធ្វើ ហើយមួយចំនួនទៀតទិដ្ឋាការរបស់ពួកគាត់ ក៏ត្រូវបានហួសសុពលភាពដែលមិនមានលទ្ធភាពបន្តបានព្រោះតម្លៃនៃការបន្តនេះត្រូវចំណាយច្រើន។ លោកបញ្ជាក់ថា៖ «ក្នុងអំឡុងពេលពាក់កណ្តាលឆ្នាំ ២០២០ មានពលករ គាត់បានដាច់ទិដ្ឋាការធ្វើឱ្យពួកគាត់ដំណើរការតទិដ្ឋាការនេះ មានភាពស្មុគស្មាញ និងចំណាយច្រើនមិនតិចជាង ១៤ ០០០ បាត ទៅ ១៥ ០០០ បាត ហើយពលករយើងខ្លះក៏បាត់បង់ប្រាក់ចំណូលមិនមានលុយទិដ្ឋាការនេះ ហើយក៏បានសម្រេចចិត្តវិលត្រឡប់មកកម្ពុជាវិញ»៕

## នគរបាលខេត្តបាត់ដំបងទទួលពលករខ្មែរប្រុស-ស្រីចំនួន៣៦នាក់ ត្រឡប់មកពីប្រទេសថៃ នាំមកធ្វើចត្តាឡីស័ក នៅអនុវិទ្យាល័យភូនភ្នំ៣២

http://cambodiapolice.com/policekh/ 8:08 pm 17 មីនា 2021

បាត់ដំបង ៖ នៅរសៀលថ្ងៃពុធ ទី១៧ ខែមីនា ឆ្នាំ២០២១ តាមការណែនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក ពៅ ថាវុធ ស្នងការរង ទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ និង លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូច

នគរបាលការពារព្រំដែនគោកលេខ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយ កម្លាំងយោធាវរសេនាតូច៥៣៣, កម្លាំងសឹករងស្រុកសំពៅលូន និងកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលជ្រៃសីមា នៃអធិការដ្ឋាននគរបាលស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន៣៦នាក់ (ស្រី១៤នាក់ ក្នុងនោះក្មេងប្រុស៦នាក់ និងក្មេងស្រី៤នាក់) ពីចំណុចភូមិស្ពានយោល ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ។ បន្ទាប់ពីធ្វើការសាកសួររួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំង បានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## នគរបាលប្រឆាំងការជួញដូរនិងការពារអនីតិជន បញ្ជូនជនសង្ស័យ០៣នាក់ ទៅសាលាដំបូងខេត្ត

http://cambodiapolice.com/policekh/ 5:48 pm 17 មីនា 2021

បន្ទាយមានជ័យ ៖ ជនសង្ស័យចំនួន០៣នាក់ ក្នុងនោះ០២នាក់ ជាមេខ្យល់នាំពលករឆ្លងដែនដោយខុសច្បាប់និង០១នាក់ទៀត ជាអ្នកផ្តល់ទីតាំងលាក់ពលករសម្រាប់ឆ្លងដែន ត្រូវបានកម្លាំងនគរបាលការិយាល័យប្រឆាំងការជួញដូរនិងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ រៀបចំសំណុំរឿងបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ នៅថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ។

លោកស្រីឧត្តមសេនីយ៍ត្រី ឌី សុជាតិ ស្នងការរង ផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនបានឲ្យដឹងថា ជនសង្ស័យទាំង០៣នាក់នេះ ត្រូវបានកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយមន្ត្រីជំនាញនាយកដ្ឋានសន្តិសុខផ្ទៃក្នុង កម្លាំងអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ និងកងរាជអាវុធហត្ថស្រុកម៉ាឡៃ ដែលដឹកនាំផ្ទាល់របស់ ឯកឧត្តម ឧត្តមសេនីយ៍ឯក សម វណ្ណវីរៈ ប្រធាននាយកដ្ឋានសន្តិសុខផ្ទៃក្នុងនៃអគ្គស្នងការដ្ឋាននគរបាលជាតិ បានចុះស្រាវជ្រាវបង្ក្រាបករណីនាំមនុស្សឆ្លងដែនខុសច្បាប់នៅក្នុងភូមិសាស្ត្រស្រុកម៉ាឡៃ ហើយត្រូវបានធ្វើការឃាត់ខ្លួននៅវេលាម៉ោង០៧យប់ ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ នៅចំណុចផ្ទះសំណាក់ ម៉ី ម៉ី ស្ថិតនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ក្នុងនោះជនសង្ស័យពាក់ព័ន្ធនាំពលករឆ្លងដែនខុសច្បាប់ចំនួន ០២នាក់ ដែលលួចនាំពលករចំនួន១៤នាក់ ស្រី ០៩នាក់ ឆ្លងដែនទៅប្រទេសថៃដោយខុសច្បាប់ ក្នុងភូមិសាស្ត្រ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

លោកស្រីឧត្តមសេនីយ៍ស្នងការរងបានបញ្ជាក់ថា៖ ជនសង្ស័យជាមេខ្យល់ ចំនួន០២នាក់ មាន៖១/-ឈ្មោះ ចក់ វី ហៅ ០៩ ភេទប្រុស អាយុ៤១ឆ្នាំ បច្ចុប្បន្នស្នាក់នៅ ភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ជនសង្ស័យជាមេក្លោង។២-ឈ្មោះធន វាសនា ភេទប្រុសអាយុ២១ឆ្នាំ នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ជនសង្ស័យជាមេខ្យល់ ។ ជនទាំង០២នាក់នេះ ពាក់ព័ន្ធករណីនាំពលករប្រុស ស្រីចំនួន១៤នាក់ យកមកលាក់ខ្លួននៅក្នុងផ្ទះសំណាក់ ម៉ី ម៉ី ស្ថិតនៅភូមិដូង ឃុំម៉ាឡៃ ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ដើម្បីត្រៀមលួចឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ នាយប់ថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២១ ។៣/-ឈ្មោះអោម ចាន់រ៉ា ភេទប្រុសអាយុ៦៣ឆ្នាំ ជាម្ចាស់ផ្ទះសំណាក់ ម៉ី ម៉ី ដែលមិនសហការជាមួយសមត្ថកិច្ចសង្ស័យផ្តល់ទីតាំងឲ្យមេខ្យល់ លាក់ពលករបំរុងឆ្លងដែនទៅប្រទេសថៃ។ លោកស្រីឧត្តមសេនីយ៍ស្នងការរងក៏បានបញ្ជាក់ទៀតថា៖ជនសង្ស័យជាមេខ្យល់ទាំង០២នាក់និងម្ចាស់ផ្ទះសំណាក់សង្ស័យផ្តល់ទីតាំងនោះ ត្រូវបានកម្លាំងនគរបាលជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនខ្លួនទៅសលាលាដំបូងខេត្ត ដើម្បីចាត់ការបន្តតាមនិតិវិធីច្បាប់ ។ដោយឡែកពលករទាំង១៤នាក់ កម្លាំងនគរបាលអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ បានធ្វើកិច្ចសន្យាអប់រំពួកគាត់រួចហើយ បានឲ្យពួកគាត់វិលត្រឡប់ទៅលំនៅដ្ឋានវិញ ៕

# ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០២១

សៀមរាបៈ នៅថ្ងៃពុធ ទី១៧ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១២៤នាក់ ស្រី ៥០នាក់ ក្នុងនោះកុមារ ០០នាក់ កុមារី ១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៤៩នាក់ ស្រី ២៣នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៨នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៦៧នាក់ ស្រី ២៦នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១២៤នាក់ ស្រី ៥០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបនៅក្នុងថ្ងៃនេះ ចំនួន ១២៤នាក់ ស្រី ៥០នាក់ ត្រូវបានបញ្ជូនទៅខេត្តសៀមរាបរួចហើយ។ ចំណែកនៅខេត្តបាត់ដំបង ចំនួន ០០នាក់ ស្រី ០០នាក់ និងខេត្តប៉ៃលិនចំនួន ០០នាក់ ស្រី ០០នាក់ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

# មេខ្យល់នាំពលករខ្មែរឆ្លងដែនខុសច្បាប់ជាង១៤០នាក់ ត្រូវបានសមត្ថកិច្ចចាប់បញ្ជូនទៅតុលាការកាត់ទោស

https://www.kampucheathmey.com/ on March 17, 2021By Kang Tola

ភ្នំពេញ ៖ ចាប់ពីថ្ងៃទី១៣ កុម្ភៈ រហូតមកដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២១នេះ សមត្ថកិច្ចបានចាប់មេខ្យល់ដែលនាំពលករខ្មែរឆ្លងដែនខុសច្បាប់ចេញ-ចូលប្រទេសកម្ពុជាចំនួន១៤៤នាក់ ស្រី១១នាក់ ទៅតុលាការដើម្បីធ្វើការផ្តន្ទាទោសទៅតាមផ្លូវច្បាប់។

លោក ឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អគ្គស្នងការរង និងជាអ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិ បានប្រសាសន៍នៅថ្ងៃទី១៧ មីនានេះថា ការចាប់មេខ្យល់ទាំងនោះភាគច្រើននាំពលករចេញចូលប្រទេសកម្ពុជានិងថៃ។ ចំណែកមេខ្យល់នាំពលករចេញចូលកម្ពុជា និងវៀតណាមវិញមានតិចតួចប៉ុណ្ណោះ។ មេខ្យល់ទាំងនោះ ត្រូវបានសមត្ថកិច្ចបញ្ជូនទៅតុលាការដើម្បីចាត់ការតាមផ្លូវច្បាប់ផងដែរ។ យ៉ាងណាក៏ដោយ លោក ឧត្តមសេនីយ៍ឯក ឆាយគឹមខឿនបានបញ្ជាក់ថា បន្ទាប់ពីរាជរដ្ឋាភិបាលចាត់វិធានការក្តៅទៅលើពួកមេខ្យល់រួចមកឃើញថា ការនាំពលករចូលមកកម្ពុជាតាមព្រំដែនកម្ពុជាថៃហាក់មានការថមថយច្រើនហើយអាចនឹងឈានទៅលប់បំបាត់បញ្ហានេះនាពេលខាងមុខទៀតផង។

លោក ឧត្តមសេនីយ៍ឯក ឆាយគឹមខឿន បានបញ្ជាក់ថា ចាប់ពីថ្ងៃទី១៣រហូតមកដល់ថ្ងៃទី១៦ ខែមីនា ឆ្នាំ ២០២១នេះដែរ សមត្ថកិច្ចក៏បានធ្វើការឃាត់ខ្លួនពលករខ្មែរដែលគេចវេះពីការធ្វើចត្តាឡីស័កបានជាង៤០០០នាក់ និងបានបញ្ជូនទៅធ្វើចត្តាឡីស័កវិញនៅទូទាំងប្រទេស។ លោក ឧត្តមសេនីយ៍ឯកបានបន្តថា ក្នុងចំណោមពលករ

គេចវេះពីការធ្វើចត្តាឡីស័កជាង ៤០០០នាក់ ភាគច្រើនជាបុរសដោយមួយចំនួនត្រូវអាជ្ញាធរធ្វើការឃាត់ខ្លួននៅតាមព្រំដែនពេលពួកគេលួចឆ្លងដែនខុសច្បាប់ និងមួយចំនួនទៀតឃាត់ខ្លួននៅតាមភូមិកំណើតរបស់ពួកគេហើយបានបញ្ជូនទៅធ្វើចត្តាឡីស័កនៅតាមមណ្ឌលធ្វើចត្តាឡីស័ករយៈ១៤វិញ។ លោក ឧត្តមសេនីយ៍ឯក ឆាយគឹមខឿន បានអំពាវនាវដល់ពលករទាំងអស់សូមបញ្ឈប់ការឆ្លងដែនខុសច្បាប់ និងកុំព្យាយាមគេចវេះពីការធ្វើចត្តាឡីស័ក ដើម្បីចៀសវាងការទទួលការផាកពិន័យនិងទោសទណ្ឌតាមផ្លូវច្បាប់៕ *ដោយ ៖ សំអឿន*

## គណៈមេធាវី ចុះ MoU ជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីស្តីពី «កិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់»

http://freshnewsasia.com/ 2021-03-18 10:03am

**(ភ្នំពេញ)៖** គណៈមេធាវីកម្ពុជា បានចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្តីពី **«កិច្ចសហប្រតិបត្តិការផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងការអប់រំច្បាប់»**។ នេះបើយោងតាមសេចក្តីប្រកាសព័ត៌មាន ដែលអង្គភាពព័ត៌មាន Fresh News ទទួលបាននៅព្រឹកថ្ងៃទី១៨ ខែមីនានេះ។

ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់គ្នានេះ បានធ្វើឡើងនាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២១ ម្សិលមិញ ក្រោមវត្តមាន លោក លី ច័ន្ទតុលា ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់នៃស្ថាប័នទាំងពីរ មានគោលបំណងពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការអនុវត្តគម្រោងផ្តល់សេវាការពារក្តីតាមផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រីក្រីក្រ ដែលរងគ្រោះដោយអំពើហិង្សា និងបណ្តុះបណ្តាលចំណេះដឹងលើវិស័យច្បាប់ដល់មន្ត្រីអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី និងមន្ត្រី/ភ្នាក់ងារនគរបាលយុត្តិធម៌ នៃក្រសួងកិច្ចការនារី និងមន្ទីរកិច្ចការនារីរាជធានី-ខេត្ត។ អនុស្សរណៈនៃការយោគយល់នេះ មានរយៈពេល ៣(បី)ឆ្នាំ គិតចាប់ពីខែមករា ឆ្នាំ២០២១ ដល់ខែធ្នូ ឆ្នាំ២០២៣។

យោងតាមខ្លឹមសារនៃអនុស្សរណៈនេះ គណៈមេធាវីកម្ពុជា មានកាតព្វកិច្ចផ្តល់សេវាការពារក្តីដល់ស្ត្រី និងក្មេងស្រីក្រីក្រដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ រងគ្រោះក្នុងករណីរំលោភបំពានផ្លូវភេទ រងគ្រោះក្នុងករណីធ្វើអាជីវកម្មផ្លូវភេទ និងរងគ្រោះក្នុងករណីពិសេសពាក់ព័ន្ធការបំពានសិទ្ធិ កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ស្ត្រីឬផ្តល់មេធាវីតំណាងដោយអាណត្តិដល់ស្ត្រីដែលលែងបណ្តាលមកពីអំពើហិង្សា។ លើសពីនេះ គណៈមេធាវីអាចចូលរួមបណ្តុះបណ្តាលចំណេះដឹងលើវិស័យច្បាប់ដល់មន្ត្រីអនុវត្តច្បាប់ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី របស់ក្រសួងកិច្ចការនារី និងរបស់មន្ទីរកិច្ចការនារីរាជធានី-ខេត្ត។ ដោយឡែកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រីមានកាតព្វកិច្ចផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុចំនួន ១,២០០,០០០រៀល ក្នុងមួយសំណុំរឿងដល់មេធាវី ដែលបានការពារក្តី ឬតំណាងដោយអាណត្តិឱ្យជនរងគ្រោះ៕

# ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១

## សមត្ថកិច្ចឃាត់ខ្លួនមេខ្យល់នាំមនុស្សមកពីវៀតណាម២នាក់នៅចំណុចឃុំកំពង់ក្រសាំង ស្រុកបុរីជលសារ

http://nokorwatnews.com/ 18-03-2021

ខេត្តតាកែវ៖ កងកម្លាំងមានសមត្ថកិច្ចនៅមូលដ្ឋានស្រុកបុរីជលសារ បានធ្វើការឃាត់ខ្លួនមុខសញ្ញាមេខ្យល់នាំមនុស្សជនជាតិវៀតណាម៣នាក់ ដោយខុសច្បាប់មកពីប្រទេសវៀតណាមបានចំនួន២នាក់ ដែលជាជនជាតិខ្មែរ ចូលមកតាមភូមិសាស្ត្រឃុំកំពង់ក្រសាំង ស្រុកបុរីជលសារ ខេត្តតាកែវ។

លោកវរសេនីយ៍ឯក ផាន ផល អធិការនគរបាលស្រុកបុរីជលសារ បានឱ្យដឹងថា នៅវេលាម៉ោង៩ និង៤០នាទីព្រឹក ថ្ងៃព្រហស្បតិ៍ ទី១៨ ខែមីនា ឆ្នាំ២០២១ ដោយអនុវត្តតាមបទបញ្ជាយ៉ាងម៉ឺងម៉ាត់របស់លោកឧត្តមសេនីយ៍ទោ សុខ សំណាង ស្នងការនៃស្នងការដ្ឋាននគរបាលខេត្តតាកែវ បានសហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលបូរីជលសារ បានចុះល្បាតមូលដ្ឋានស្រុកបុរីជលសារ ហើយបានឃាត់រថយន្តមួយគ្រឿងម៉ាកស៊ីណា ពណ៌ស ពាក់ស្លាកលេខ តាកែវ 2B -7875 ដែលជាមុខសញ្ញានាំជនជាតិវៀតណាមខុសច្បាប់មកកម្ពុជា មានមនុស្សសរុបចំនួន៦នាក់ ស្រី០នាក់ ក្នុងនោះជនជាតិវៀតណាមចំនួន៣នាក់ (មិនស្គាល់អត្តសញ្ញាណ ដោយមិនមានអ្នកបកប្រែ) ។

ដោយឡែកជនជាតិខ្មែរមានចំនួន៣នាក់ ក្នុងនោះអ្នកបើកបរម្នាក់ឈ្មោះ អម អាន ភេទប្រុស អាយុ៣៨ឆ្នាំ រស់នៅភូមិត្រពាំងប្រិយ ឃុំអង្គខ្នុរ ស្រុកទ្រាំង ខេត្តតាកែវ និងមេខ្យល់នាំផ្លូវចំនួន២នាក់ ទី១-ឈ្មោះ សុខ រ៉ាវុធ ភេទប្រុស អាយុ ២៥ឆ្នាំ រស់នៅភូមិសង្គមមានជ័យ ឃុំកំពង់ក្រសាំង ស្រុកបុរីជលសារ ខេត្តតាកែវ និងទី២-ឈ្មោះ ភូ ហេងសេង ភេទប្រុស អាយុ២០ឆ្នាំ រស់នៅភូមិសង្គមមានជ័យ ឃុំកំពង់ក្រសាំង ស្រុកបុរីជលសារ ខេត្តតាកែវ ឃាត់ខ្លួនបាននៅចំណុច ភូមិស្នាចដួច ឃុំបុរីជលសារ ស្រុកបុរីជលសារ ខេត្តតាកែវ ។ លោកអធិការបានបន្ថែមថា បន្ទាប់ពីបានឃាត់ខ្លួន បច្ចុប្បន្នកម្លាំងជំនាញកំពុងសាកសួរដើម្បីកំណត់មុខសញ្ញាបន្ថែមទៀត ដែលជាមុខសញ្ញានាំមនុស្សដោយខុសច្បាប់ចូលមកប្រទេសកម្ពុជា ដោយមិនបានធ្វើចត្តាឡីស័កត្រឹមត្រូវ ៕

## កម្លាំងនគរបាល សហការជាមួយកម្លាំងយោធា ទទួលប្រជាពលរដ្ឋត្រឡប់ពីប្រទេសថៃ ចូលប្រទេសកម្ពុជាវិញចំនួន ១២នាក់ បញ្ជូនទៅកាន់មណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 9:35 am 18 មីនា 2021

ខេត្តកំពង់ឆ្នាំង ៖ នៅរសៀលថ្ងៃពុធ ទី១៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង០៥ និង៣០នាទី កម្លាំងអធិការដ្ឋាននគរបាលស្រុកបរិបូណ៌ សហការជាមួយកម្លាំងសឹករងស្រុក កម្លាំងមូលដ្ឋានកងរាជអាវុធហត្ថស្រុក កម្លាំងមន្ទីរពេទ្យបង្អែកស្រុក និងកម្លាំងរដ្ឋបាលស្រុក ដឹកនាំដោយលោក ថែម ភក្តិ អភិបាលរងស្រុកបរិបូណ៌ បានទទួលពលករខ្មែរចំណូលស្រុកមកពីប្រទេសថៃ តាមច្រក បន្ទាយមានជ័យ ចំនួន ១២នាក់ ស្រី ០២នាក់ ក្នុងនោះ ស្រុកកំពង់ត្រឡាច ០២នាក់ ប្រុស និងស្រុកសាមគ្គីមានជ័យចំនួន ១០នាក់ ស្រី ០២នាក់ ដើម្បីធ្វើចត្តាឡីស័កនៅមណ្ឌលវិទ្យាល័យហ៊ុនសែនបរិបូណ៌ ៕

# ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃព្រហស្បតិ៍ ទី១៨ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១១២នាក់ ស្រី ៥០នាក់ ក្នុងនោះកុមារា ៨នាក់ កុមារី ៨នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៣នាក់ ស្រី ៧នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤៣នាក់ ស្រី ២២នាក់ កុមារា ៨នាក់ កុមារី ៨នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៥៥នាក់ ស្រី ២១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ១នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១១២នាក់ ស្រី ៥០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាបនៅក្នុងថ្ងៃនេះ ចំនួន ១១១នាក់ ស្រី ៥០នាក់ ត្រូវបានបញ្ជូនទៅខេត្តសៀមរាបរួចហើយ។ ចំណែកនៅខេត្តបាត់ដំបង ចំនួន ១នាក់ ស្រី ០០នាក់ និងខេត្តប៉ៃលិនចំនួន ០០នាក់ ស្រី ០០នាក់ បានបញ្ជូនទៅខេត្តសៀមរាបរួចហើយដែរ ៕ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ជូ កុសល

## ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១

## ចាប់មេខ្យល់ម្នាក់ទៀតពេលដឹកមនុស្សឆ្លងដែនដោយខុសច្បាប់ទៅថៃ

https://www.rasmeinews.com/ 21 March, 20210

**ដោយ:ប.ជ័យ / បន្ទាយមានជ័យ:** *មេខ្យល់ម្នាក់ ដែលដឹកមនុស្សឆ្លងដែន ខុសច្បាប់ទៅប្រទេសថៃ ត្រូវបានកម្លាំងនគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជននៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ ឃាត់ខ្លួនរួចកសាងបញ្ជូនទៅសាលាដំបូងខេត្តនាថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១។* លោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃ បានឲ្យដឹងថាជនសង្ស័យឈ្មោះ មឿន សារឿន ភេទ ប្រុសអាយុ ៤១ឆ្នាំ នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។

សូមរំលឹកថា នៅវេលាម៉ោង៧ព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ កម្លាំងនគរបាលស្រុកម៉ាឡៃ និងកម្លាំងនគរបាលវរសេនាតូចការបារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាវរសេនាតូចការពារព្រំដែនគោកលេខ៥១១នៃកងពលតូចជម្រើសជើងលេខ៥១ បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ចំនួន១៥នាក់ (ស្រី៦នាក់) ។ ក្នុងនោះមកពី៣ខេត្ត បន្ទាយមានជ័យ ចំនួន១១នាក់, សៀមរាបចំនួន៣នាក់ និងខេត្តបាត់ដំបងចំនួន១នាក់៕

# យល់ដឹងផ្នែកច្បាប់៖ អំពើលក់-ដូរមនុស្ស

http://plus.freshnewsasia.com/ 2021-03-21 03:23pm

**(ភ្នំពេញ)៖** ប្រជាពលរដ្ឋគ្រប់រូបមានសិទ្ធិរស់រានមានជីវិតប្រកបដោយសេរីភាព កិត្តិយស សេចក្តីថ្លៃថ្នូរ និងត្រូវបានធានារ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយណាមួយឡើយ ស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ច្បាប់កំពូលនេះ ក៏បានហាមឃាត់យ៉ាងដាច់ខាតចំពោះអំពើលក់-ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម ឬអំពើអាសអាភាស ដែលធ្វើប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ស្ត្រី និងកុមារ។ យ៉ាងណាមិញ ក្រុមមនុស្សដែលងាយរងគ្រោះនឹងបញ្ហាលក់-ដូរមនុស្សដោយខុសច្បាប់នេះ ភាគច្រើនកើតចេញពីកត្តាសេដ្ឋកិច្ច កង្វះការអប់រំ និងកង្វះការយកចិត្តទុកដាក់ពីក្រុមគ្រួសារជាដើម។ ដូច្នេះហើយ ទើបព្រះរាជាណាចក្រកម្ពុជាបានបង្កើតឱ្យមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្នុងឆ្នាំ២០០៨ និងចូលជាសមាជិកក្នុងអនុសញ្ញាអន្តរជាតិដែលពាក់ព័ន្ធនានា ក៏ដូចជាបានបង្កើតគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដើម្បីចាត់វិធានការទប់ស្កាត់អំពើទុច្ចរិតនេះយ៉ាងមុតមាំ។ តើអំពើ និងសកម្មភាពបែបណាដែលត្រូវបានចាត់ទុកថាជាអំពើលក់-ដូរមនុស្ស? ហើយជនដែលប្រព្រឹត្តអំពើនេះ ត្រូវទទួលទោសតាមច្បាប់កម្រិតណា?

**កម្មវិធីយល់ដឹងផ្នែកច្បាប់របស់អង្គភាពព័ត៌មាន Fresh News សហការជាមួយ ក្រុមមេធាវីកម្ពុជាសហប្រតិបត្តិការអន្តរជាតិ សូមលើកយកប្រធានបទស្តីអំពី «អំពើលក់-ដូរមនុស្ស» មកចែករំលែក ជូនបងប្អូនប្រជាពលរដ្ឋ សិស្ស និស្សិត ទាំងអស់ ដូចខាងក្រោម៖**

យោងមាត្រា១៣ កថាខណ្ឌ១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨ «អំពើលក់-ដូរមនុស្ស» ជាការប្រគល់ការគ្រប់គ្រងលើជនណាម្នាក់ទៅអ្នកដទៃដោយខុសច្បាប់ ឬ ការទទួលយកការគ្រប់គ្រងលើជនណាម្នាក់ពីអ្នកដទៃដោយខុសច្បាប់ ដោយផ្លាស់ប្តូរនឹងវត្ថុមានតម្លៃអ្វីមួយ ដោយរាប់បញ្ចូលទាំងសេវា និងមនុស្សផង។ ស្រដៀងគ្នានេះដែរ អនុសញ្ញាអាស៊ានស្តីពីការប្រឆាំងនឹងការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលមានប្រទេសកម្ពុជាជារដ្ឋភាគីផងនោះ ក៏ពុំបានគាំទ្រលើជនខិលខូចដែលប្រព្រឹត្តបទល្មើសដែលមានសកម្មភាពដូចជា ការផ្ទេរ ឬទទួលជនណាម្នាក់ តាមរយៈការគំរាមកំហែង ឬបោកបញ្ឆោត ឬផ្តល់ប្រយោជន៍នានា ដើម្បីសម្រេចបានការយល់ព្រមនៃមនុស្សម្នាក់ដែលមានអំណាចត្រួតត្រាលើមនុស្សណាម្នាក់ទៀត ក្នុងគោលបំណងកេងប្រវ័ញ្ចលើរូបរាងកាយ ផ្លូវភេទ ពលកម្ម សេវាដោយបង្ខំ ឬ ការដកហូតសរីរាង្គជាដើម។

ជាក់ស្តែងយើងសង្កេតឃើញថា អំពើលក់-ដូរមនុស្សបានធ្វើឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរចំពោះសិទ្ធិសេរីភាពរបស់បុគ្គលដែលត្រូវបានគេយកទៅលក់ ក៏ដូចជាប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈផងដែរ។ ដូចនេះហើយ សកម្មភាពខាងលើត្រូវបានចាត់ទុកថាជាបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ៥ (ប្រាំ) ឆ្នាំ តាមមាត្រា១៤ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ឆ្នាំ២០០៨។ មាត្រា១៣ ត្រង់កថាខណ្ឌ២ នៃច្បាប់នេះដដែល ក៏បានបញ្ជាក់ផងដែរថា ជនណាដែលធ្វើជាភ្នាក់ងារកណ្តាលនៃការលក់-ដូរមនុស្ស ត្រូវផ្តន្ទាទោសដូចគ្នាទៅនឹងជនដែលប្រព្រឹត្តអំពើលក់-ដូរមនុស្សដោយផ្ទាល់ដែរ។ បន្ថែមពីលើនេះទៅទៀត ក្នុងករណីដែលការលក់-ដូរមនុស្សនេះ ធ្វើឡើងក្នុងគោលបំណងស្វែងរកប្រយោជន៍ឈ្លានពានខាងផ្លូវភេទ ផលិតរូបភាពអាសអាភាស រៀបអាពាហ៍ពិពាហ៍ដែលផ្ទុយពីឆន្ទៈរបស់ជនរងគ្រោះ សុំកូនប្រគល់ ឬនាំយកទៅក្រៅព្រះរាជាណាចក្រកម្ពុជា ឬ ទម្រង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀត នោះស្ថានទម្ងន់ទោសនឹងកើនឡើងទៅជាការដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ។

**ការផ្តន្ទាទោសខាងលើនេះនឹងកើនឡើងរហូតដល់ ១៥ (ដប់ប្រាំ) ឆ្នាំ ទៅ ២០ (ម្ភៃ) ឆ្នាំ ក្នុងករណីដែល៖**

* ជនរងគ្រោះជាអនីតិជន។

* អំពើល្មើសប្រព្រឹត្តឡើង ដោយមន្ត្រីសាធារណៈ ដែលបំពានដោយអំណាចរបស់ខ្លួនមកលើជនរងគ្រោះ។
* អំពើល្មើសប្រព្រឹត្តឡើង ដោយក្រុមមានការចាត់តាំង។

សរុបមកវិញ ប្រសិនបើជនណាម្នាក់បានប្រព្រឹត្តអំពើល្មើសដូចខាងលើនេះ ត្រូវចាត់ទុកថាជាអំពើលក់-ដូរមនុស្ស និងត្រូវទទួលការផ្តន្ទាទោសយ៉ាងធ្ងន់ធ្ងរតាមច្បាប់ជាធរមាន។ ទន្ទឹមនឹងនេះ ដើម្បីចូលរួមក្នុងការទប់ស្កាត់អំពើខុសច្បាប់ខាងលើ ប្រជាពលរដ្ឋម្នាក់ៗជួយផ្សព្វផ្សាយចំណេះដឹងអំពីបញ្ហានេះទៅកាន់អ្នកដទៃ ជាពិសេសទៅកាន់ប្រជាពលរដ្ឋដែលរស់នៅតាមទីជនបទ។ អាចណែនាំកុមារ និងអាណាព្យាបាល អំពីសកម្មភាពនានាអំពីការលក់-ដូរមនុស្ស ដើម្បីឱ្យពួកគាត់មានការប្រុងប្រយ័ត្នខ្ពស់ និងជៀសវាងពីការបោកប្រាស់របស់ជនខិលខូចដែលឆ្លៀតឱកាស។ ជាពិសេសអាចពន្យល់ណែនាំទៅកាន់ឪពុកម្តាយ ឬអាណាព្យាបាល អំពីបទល្មើសនៃការលក់-ដូរកុមារ ដើម្បីឱ្យពួកគាត់មានការភ័យខ្លាច មិនហ៊ានប្រព្រឹត្ត និងបង្កើនការប្រុងប្រយ័ត្នចំពោះជនដែលងាយទទួលរងគ្រោះទោះបីជាក្នុងកាលៈទេសៈណាមួយក៏ដោយ៕

## សមត្ថកិច្ចបញ្ជូនខ្លួនបុរសម្នាក់ ដែលលួចនាំពលករឆ្លងដែនចូលប្រទេសថៃ មកកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមច្បាប់

http://plus.freshnewsasia.com/ 2021-03-21 04:07pm

**(បន្ទាយមានជ័យ)៖** កម្លាំងនគរបាលជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនបុរសម្នាក់ដែលលួចដឹកជញ្ជូនពលករខ្មែរចំនួន ១៥នាក់ ឆ្លងដែនទៅប្រទេសថៃ មកកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ ចាត់ការតាមផ្លូវច្បាប់ នៅព្រឹកថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១នេះ។

បើតាមលោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃ បានឱ្យដឹងថា ជនសង្ស័យឈ្មោះ មឿន សារឿន ភេទ ប្រុស អាយុ៤១ឆ្នាំ នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ លោកវរសេនីយ៍ឯកបានថ្លែងថា កាលពីវេលាម៉ោង៧ព្រឹកថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ កម្លាំងនគរបាលស្រុកម៉ាឡៃ និងកម្លាំងនគរបាលវរសេនាតូចការពារព្រំដែនគោកលេខ៨១៥ សហការជាមួយកម្លាំងយោធាវរសេនាតូចការពារព្រំដែនគោកលេខ៥១១ នៃកងពលតូចជម្រើសជើងលេខ៥១ បានធ្វើការទប់ស្កាត់ពលករចំណាកស្រុកដោយខុសច្បាប់ចំនួន ១៥នាក់ ក្នុងនោះមានស្រី៦នាក់ មកពីខេត្តចំនួន៣ រួមមាន៖ ខេត្តបន្ទាយមានជ័យ ចំនួន១១នាក់ ខេត្តសៀមរាប ចំនួន៣នាក់ និងខេត្តបាត់ដំបងចំនួន ១នាក់ នៅចំណុចដីរបស់ឈ្មោះទ្រី ភាព ស្ថិតក្នុងភូមិសង្កែ ឃុំបឹងបេង ស្រុកម៉ាឡៃ ដើម្បីធ្វើការសួរនាំ។

ក្នុងនោះពលករទាំង១៥នាក់ បានឆ្លើយប្រាប់សមត្ថកិច្ចថា ពួកគាត់ត្រូវបានឈ្មោះ ទូច ភេទប្រុស អាយុប្រហែល២០ឆ្នាំ នៅធ្វើការប្រទេសថៃ ឱ្យទំនាក់ទំនងជាមួយឈ្មោះ មឿក សុភា ភេទប្រុស អាយុប្រហែល២៩ឆ្នាំ នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ពេលពួកគាត់មកដល់ស្រុកម៉ាឡៃ មានឈ្មោះ មឿន សារឿន បានឱបពួកគាត់មកដាក់នៅចំណុចដីឈ្មោះ ទ្រី ភាព ដើម្បីឆ្លងដែន។

នៅចំពោះមុខសមត្ថកិច្ចឈ្មោះ មឿន សារឿន ជាអ្នកដឹកជញ្ជូនពលករបានសារភាពថា ខ្លួនពិតជាបានដឹកពលករទាំងនោះមែនឱ្យឈ្មោះ មឿក សុភា ដោយពលករម្នាក់ឈ្មោះ មឿក សុភា ឱ្យតម្លៃ ១០,០០០រៀល។

ដោយឡែកលោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការបារអនីតិជន បានឱ្យដឹងថា ដោយផ្អែកលើការបំភ្លឺរបស់ពលករទាំង ១៥នាក់ និងចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ មឿន សារឿន ត្រូវបានកម្លាំងជំនាញបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនីតិវិធីច្បាប់ ចំពោះមេខ្យល់ឈ្មោះ មឿក សុភា កម្លាំងនគរបាលមូលដ្ឋានកំពុងស្រាវជ្រាវ ដើម្បីឃាត់ខ្លួនកសាងសំណុំរឿងតាមនីតិវិធីច្បាប់៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី២១ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៦៨នាក់ ស្រី ៦៨នាក់ ក្នុងនោះកុមារា ៩នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៣២នាក់ ស្រី ១២នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៤៦នាក់ ស្រី ២១នាក់ កុមារា ៩នាក់ កុមារី ៤នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៨៤នាក់ ស្រី ៣៤នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ៤នាក់ ស្រីចំនួន ១នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៦៨នាក់ ស្រី ៥០នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាប ក្នុងថ្ងៃនេះ ចំនួន ១៦៤នាក់ ស្រី ៦៧នាក់ ត្រូវបានបញ្ជូនទៅខេត្តសៀមរាបរួចហើយ។ ចំណែកនៅខេត្តបាត់ដំបង ចំនួន ០០នាក់ ស្រី ០០នាក់ និងខេត្តប៉ៃលិនចំនួន ៤នាក់ ស្រី ១នាក់ មិនទាន់បានបញ្ជូនទៅខេត្តសៀមរាបឡើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល

## ឯកឧត្តម ម៉ៅ ធនិន៖ ទីផ្សារពលកម្មក្នុងខេត្ត កំពុងតែត្រូវការ ដូច្នេះសូមបងប្អូនយកចំណេះជំនាញ មកធ្វើការតាមបណ្តាក្រុមហ៊ុន សហគ្រាស និងរោងចក្រ ជៀសវៀងការធ្វើចំណាកស្រុក

https://information.gov.kh/ AKP ពោធិ៍សាត់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២១

ឯកឧត្តម ម៉ៅ ធនិន អភិបាលនៃគណៈអភិបាលខេត្តពោធិ៍សាត់ និងជាប្រធានគណៈកម្មការខេត្ត ប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ នាព្រលប់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២១ បានលើកឡើងថា បច្ចុប្បន្នដោយស្ថានភាពកូវីដកំពុងតែផ្ទុះឡើងក៏ពិតមែន ក៏ប៉ុន្តែទីផ្សារពលកម្មកំពុងតែត្រូវការ បងប្អូនយើងដែលមានចំណេះជំនាញ ដើម្បីមកធ្វើការនៅតាមបណ្តាក្រុមហ៊ុន សហគ្រាស និងរោងចក្រនានា ជៀសវៀងបន្តការធ្វើចំណាកស្រុក។ ឯកឧត្តមបានលើកឡើងបែបនេះ ក្នុងឱកាសចុះជួបសំណេះសំណាល និងសួរសុខទុក្ខ បងប្អូនប្រជាពលរដ្ឋ ដែលទើបតែវិលត្រឡប់មកពីប្រទេសថៃ ហើយត្រូវបាននឹងកំពុង ដាក់ឱ្យនៅដាច់ដោយឡែកចំនួន១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កសាលាបឋមសិក្សាទួលគ្រួស ស្ថិតក្នុងភូមិទួលគ្រួស សង្កាត់ចំរើនផល ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ថ្លែងក្នុងឱកាសនោះ ឯកឧត្តម ម៉ៅ ធនិន បានឱ្យដឹងថា ការចុះមកនាពេលនេះ គឺដើម្បីចង់ដឹងពីសុខទុក្ខរបស់បងប្អូនយើង ដែលទើបវិលត្រឡប់មកពីប្រទេសថៃ និងកំពុងតែដាក់ឱ្យធ្វើចត្តាឡីស័ក ថាតើមានបញ្ហាប្រឈម ក៏ដូចជាសំណូមពរអ្វីខ្លះ យកមកធ្វើការដោះស្រាយរួមគ្នា។

ឯកឧត្តមបានធ្វើការណែនាំ ទៅដល់បងប្អូនពលករទាំងអស់ សូមប្រកាន់ភ្ជាប់ និងចូលរួមអនុវត្តឱ្យបានត្រឹមត្រូវបំផុត តាមការណែនាំរបស់ក្រសួងសុខាភិបាល ក៏ដូចជាវិធានការ «៣កុំ និង៣ការពារ» របស់សម្ដេចប្រមុខនៃរាជរដ្ឋាភិបាលកម្ពុជា ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងជំងឺកូវីដ១៩ ដែលកំពុងតែឆ្លងចូលសហគមន៍របស់យើង។ ឯកឧត្តមអភិបាលខេត្តពោធិ៍សាត់ បានជម្រាបជូនពីការរីកចម្រើនលើគ្រប់វិស័យ និងសមិទ្ធផល សម្រេចបាននៅក្នុងខេត្ត ក្រោមការដឹកនាំរបស់សម្ដេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃកម្ពុជា ដែលបានលះបង់កម្លាំងកាយចិត្ត តស៊ូរហូតទទួលបានសុខសន្តិភាពមកទល់បច្ចុប្បន្ន។ ជាមួយគ្នានោះ ឯកឧត្តមក៏បានជម្រាបជូនបន្ថែម អំពីការតម្រូវការទីផ្សារពលកម្ម នៅតាមក្រុមហ៊ុន សហគ្រាស និងរោងចក្រ ដែលមាននៅក្នុងខេត្ត ជាពិសេសក្រោយពីស្ថានភាពជំងឺកូវីដបានធូរស្បើយ។

ឯកឧត្តមក៏បានចាត់ឱ្យថ្នាក់ដឹកនាំមន្ទីរការងារ បណ្ដុះបណ្ដាល និងវិជ្ជាជីវៈខេត្តពោធិ៍សាត់ ត្រូវធ្វើការជាមួយបងប្អូនយើង ដើម្បីឱ្យពួកគេមានឱកាស យកចំណេះជំនាញដែលពួកគេមាន អាចមកធ្វើការនៅតាមបណ្ដាក្រុមហ៊ុន សហគ្រាស និងរោងចក្រនានា ក្នុងខេត្តយើងបាន ជៀសវៀងការធ្វើចំណាកស្រុកទៅក្រៅប្រទេសបន្តទៀត និងសូមកុំឱ្យមានការផ្លាស់ប្ដូរលេខទូរស័ព្ទដែល កំពុងតែប្រើនេះ។ ឯកឧត្តមក៏បានសន្យាថា នឹងរួមសុខរួមទុក្ខជាមួយបងប្អូនយើងគ្រប់ពេលវេលា ហើយនៅថ្ងៃបន្តបន្ទាប់ឯកឧត្តមនឹងបន្តចុះជួបសំណេះសំណាល សួរសុខទុក្ខបងប្អូនយើង នៅគ្រប់មណ្ឌលចត្តាឡីស័កនីមួយៗក្នុងខេត្ត ហើយដែលនឹងអាចវិលត្រឡប់មកទីនេះម្ដងទៀតផងដែរ។ ក្នុងឱកាសនោះ ឯកឧត្តម ម៉ៅ ធនិន ក៏បាននាំយកវត្ថុកំដរដៃ ផ្ដល់ជូនបងប្អូនប្រជាពលរដ្ឋ ដែលកំពុងដាក់ឱ្យធ្វើចត្តាឡីស័ក ចំនួន៨៦នាក់ ដោយក្នុងម្នាក់ៗ ទទួលបាន មី១កេស ទឹកសុទ្ធ៥ដប ត្រីខ១យួរ និងនំមួយកញ្ចប់ស្មើ ២គីឡូក្រាម៕

## បានប្រាក់រាប់ពាន់បាត លួចដឹកពលករឆ្លងទៅថៃ ទាំងប្រថុយប្រថាន

https://www.kampucheathmey.com/ on March 22, 2021By deth leng

កម្លាំងការិយាល័យប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានឃាត់ខ្លួនមេខ្យល់ម្នាក់ និងគោយន្តកន្ត្រៃ១គ្រឿងលួចដឹកពលករ ឆ្លងដែនទៅប្រទេសថៃ។ ការឃាត់ខ្លួនបានធ្វើឡើងនៅថ្ងៃទី២១ ខែមីនា ត្រង់ចំណុចចំការស្វាយចន្ទី ជិតភូមិចក់ពួក ឃុំស្លក្រាម ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ។ បុរសជនសង្ស័យជាមេខ្យល់មានឈ្មោះ តេង តុញ អាយុ២៤ឆ្នាំ មានស្រុកកំណើតនៅខេត្តបន្ទាយមានជ័យ។ នៅវេលាម៉ោង១១និង៣០នាទីយប់កម្លាំងចម្រុះបានដើរល្បាតនៅតាមព្រំដែន ហើយបានឃាត់គោយន្តកន្ត្រៃ ដឹកពលករលួចឆ្លងដែនទៅប្រទេសថៃចំនួន១៦នាក់ ស្រីចំនួន៦នាក់ ក្នុងនោះកុមារ១នាក់ មកពីខេត្តព្រៃវែង៥នាក់ ខេត្តឧត្តរមានជ័យ៧នាក់ ក្នុងខេត្តបន្ទាយមានជ័យ៤នាក់ កុមារ១នាក់ រួចនាំមកសួនាំនៅអធិការដ្ឋាននគរបាលស្រុកស្វាយចេក។

លោកវរសេនីយ៍ឯក ជា ស្លួញ អធិការស្រុកស្វាយចេកបានប្រាប់ថាតាមចម្លើសារភាពរបស់ឈ្មោះ តេង តុញ ថាខ្លួនបានដឹកពលករឲ្យទៅឈ្មោះ ពីន ពេត ជាមេខ្យល់លួចនាំឆ្លងដែនទៅប្រទេសថៃចំនួន១០លើក មកហើយដែលមានពលករសរុបចំនួន១៣៤នាក់ ហើយដឹកក្នុង១លើក ឈ្មោះ ពីន ពេត ឲ្យតម្លៃ១លើក ពី៥០០បាត ទៅ ១,០០០បាត តាមមនុស្សតិចឬច្រើន ហើយលើកទី១០នេះ ខ្លួនដឹកពលករចំនួន១៦នាក់ កុមារម្នាក់ តម្លៃ១,០០០បាត ចំណែកពលករម្នាក់ត្រូវ ឈ្មោះ ពីន ពេត មេខ្យល់នោះយកតម្លៃ ៤,០០០បាត ទៅដល់ដីថៃ។ បច្ចុប្បន្នជនសង្ស័យឈ្មោះ តេង តុញ ត្រូវបានកម្លាំងនគរបាលជំនាញ បញ្ជូនខ្លួនទៅសាលាដំបូងខេត្ត ចាត់ការតាមច្បាប់។ ចំពោះជនសង្ស័យជាមេខ្យល់ឈ្មោះ ពីន ពេត នគរបាលស្រុកស្វាយចេកកំពុងតាមប្រម៉ាញ់ ដើម្បីចាប់ខ្លួនយកទៅផ្ដន្ទាទោសតាមច្បាប់៕ អត្ថបទ៖វ៉ាន់ ណាង

## ពលករខ្មែរ១០នាក់ឆ្លងកូវីដនៅថៃ ក្នុងការផ្ទុះចង្កោមចម្លងថ្មី

https://www.kampucheathmey.com/ on March 22, 2021By Sok Sovann

ពលរដ្ឋខ្មែរ១០នាក់ ស្ថិតក្នុងចំណោមកម្មករចំណាកស្រុក ដែលត្រូវបានរកឃើញថា ឆ្លងជំងឺកូវីដ១៩នៅក្នុងប្រទេសថៃ។ នេះបើយោងតាមការចុះផ្សាយដោយកាសែត បាងកកប៉ុស្តិ៍ នៅព្រឹកថ្ងៃចន្ទទី២២ខែមីនា។ នាយកដ្ឋានប្រយុទ្ធប្រឆាំងជំងឺឆ្លង (DDC) បាននិយាយកាលពីថ្ងៃអាទិត្យថា ខេត្ត សាមុត ប្រាកាន បានលេចចេញជាចំណុចផ្ទុះជំងឺកូវីដ១៩ បន្ទាប់ពីការឆ្លងចង្កោមថ្មី ត្រូវបានរកឃើញក្នុងចំណោមកម្មករចំណាកស្រុករបស់ខេត្តនេះ។ អគ្គនាយក DDC លោក Opas Karnkawinpong បាននិយាយកាលពីម្សិលមិញថា សរុបទៅ មនុស្សចំនួន៥៨៤នាក់ ត្រូវបានដាក់នៅក្រោមការឃ្លាំមើលយ៉ាងជិតដល់ បន្ទាប់ពីកម្មករចំណាកស្រុក ចំនួន១៧នាក់ បានធ្វើតេស្តិ៍វិជ្ជមានជំងឺកូវីដ១៩។ អ្នកឆ្លងដំបូងគឺជាកម្មករអាយុ២៩ឆ្នាំម្នាក់ មកពីប្រទេសមីយ៉ាន់ម៉ា ដែលបានធ្វើតេស្តកាលពីថ្ងៃទី១៣ខែមីនា។ បន្ទាប់ពីនាងត្រូវបានគេរកឃើញថាមានឆ្លងរោគ, DDC បានទៅធ្វើតេស្តកម្មករចំណាកស្រុកនៅជុំវំ Soi Sukhumvit ហើយបានរកឃើញកម្មករឆ្លង១៦នាក់ទៀត ដោយក្នុងនោះមាន មីយ៉ាន់ម៉ា២នាក់ ថៃ៤នាក់ និងខ្មែរ១០នាក់។

លោកវេជ្ជបណ្ឌិត Opas បាននិយាយថា "នៅតាមការដ្ឋានសំណង់មានកត្តាហានិភ័យជាច្រើន។ ក្នុងករណីនេះ កម្មករបានរំលោភលើវិធានការទប់ស្កាត់ជំងឺកូវីដ១៩ ដោយពួកគេបានរៀបចំពិធីជប់លៀងផឹកស៊ី"។ស្របពេលជាមួយគ្នានោះ មជ្ឈមណ្ឌលគ្រប់គ្រងស្ថានភាពជំងឺកូវីដ១៩ (CCSA) បាននិយាយថា ការឆ្លងក្នុងសហគមន៍ចំនួន៤៥ករណី ត្រូវបានកត់ត្រានៅក្នុងមន្ទីរពេទ្យកាលពីថ្ងៃអាទិត្យ ខណៈ៣៦ករណីត្រូវបានរកឃើញតាមរយៈការធ្វើតេស្តទ្រង់ទ្រាយធំ ដែលភាគច្រើនមកពីខេត្ត សាមុតសាខន។ នាពេលបច្ចុប្បន្ននេះ CCSA កំពុងផ្តោតកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការការពារ ការផ្ទុះជំងឺដែលបានចាប់ផ្តើមនៅក្នុងផ្សារ Bang Khae ពីការរីករាលដាលបន្ថែមទៀត ខណៈករណី ដែលជាប់ទាក់ទងជាមួយនឹងការផ្ទុះឡើងនេះ ត្រូវបានគេរកឃើញនៅឆ្ងាយរហូតដល់ សុងក្លា និង ស៊ីសាកេត ឯណោះ៕ ប្រែសម្រួលដោយ៖ Vann Vann ប្រភព៖ Bangkok Post

## ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១

### សូមជួយផ្តល់ព័ត៌មានតាមអនឡាញ ដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ

http://freshnewsasia.com/ 2021-03-22 11:21am

**(ភ្នំពេញ)៖** ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារជាទង្វើខុសច្បាប់ ហើយក៏ជាក្តីបារម្ភមួយនៅក្នុងសង្គមកម្ពុជា ដែលគេកំពុងរួមគ្នាដើម្បីទប់ស្កាត់ផងដែរ។ អង្គការសកម្មភាពដើម្បីកុមារ ហៅកាត់ថា Aple បានបង្កើតបណ្តាញរាយការណ៍តាមអនឡាញមួយ ផ្តល់ឱកាសឱ្យប្រជាពលរដ្ឋរាយការណ៍ពីទង្វើកេងប្រវ័ញ្ចផ្លូវភេទលើកុមារនេះ ដើម្បីចូលរួមទប់ស្កាត់បានទាន់ពេលវេលា។ **លោកអ្នកអាចរាយការណ៍ព័ត៌មាននៃសកម្មភាពកេងប្រវ័ញ្ចផ្លូវភេទលើកុមារដោយវិធីងាយស្រួល និងមានសុវត្ថិភាពខ្ពស់បំផុត។ លោកអ្នកអាចរាយការណ៍ព័ត៌មាននៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមវិធីដូចខាងក្រោម៖**

**១៖** ចូលទៅកាន់គេហទំព័រ internethotlinecambodia.org

**២៖** ចុចលើប៊ូតុង Report Abuse

**៣៖** ជ្រើសរើសទម្រង់នៃការរំលោភបំពាន និងបំពេញទម្រង់បានត្រឹមត្រូវ រួចចុចបញ្ជូនជាការស្រេច។ សូមបញ្ជាក់ថា រាល់សេចក្តីរាយការណ៍របស់អស់លោកអ្នកត្រូវបានរក្សាយ៉ាងសម្ងាត់បំផុត។

# សមត្ថកិច្ចកំពុងសហការជួយនារីចាញ់បោកមេខ្យល់នាំទៅចិន

https://www.postkhmer.com/ គីម សារុំ | Publication date 19 March 2021 | 11:59 ICT

**ព្រះវិហារៈ** នគរបាលប្រឆាំងការជួញដូរមនុស្សខេត្តព្រះវិហារ កំពុងសហការជាមួយសមត្ថកិច្ចនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិជួយដល់នារីខ្មែរម្នាក់ពីប្រទេសចិន បន្ទាប់ពីនារីរងគ្រោះរូបនេះ លើកដៃសំពះបង្ហោះតាមហ្វេសប៊ុកពីប្រទេសចិន សុំឲ្យលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ជួយរំដោះនាងមកប្រទេសកម្ពុជា វិញ។

លោកស្រីឧត្តមសេនីយ៍ត្រី ប្រាំង ជីតា ស្នងការរងផែនការងារប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជនខេត្តព្រះវិហារបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ ពីថ្ងៃ ១៧ មីនាថា នារីរងគ្រោះនោះ ឈ្មោះ អ៊ិន សុខជី អាយុ ១៧ ឆ្នាំ រស់នៅភូមិអូរខ្លែងពណ៌ឃុំប៉ាលហាល ស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ។ ករណីនេះសមត្ថកិច្ចរបស់លោកស្រីកំពុងសហការជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្រសួងការបរទេសកម្ពុជា និងស្ថាប័នពាក់ព័ន្ធដទៃទៀត ដើម្បីជួយអន្តរាគមន៍រំដោះនារីរងគ្រោះយកមកកម្ពុជាវិញ។ លោកស្រីបន្តថា នារីរងគ្រោះបានបង្ហោះសារក្នុងវីដេអូពីថ្ងៃទី ៤ មីនា ឆ្នាំ ២០២១ ប៉ុន្តែនាងមិនបានបញ្ជាក់ពីទីតាំង ឬតំបន់ដែលនាងកំពុងរស់នៅប្រទេសចិន ឲ្យបានច្បាស់ទេ ដោយគ្រាន់តែរៀបរាប់ពីទុក្ខលំបាកដែលត្រូវគេលក់នាងបន្តពីម្នាក់ទៅម្នាក់ប៉ុណ្ណោះ។ លោកស្រី ជីតា បញ្ជាក់ថាៈ «ការងារនេះយើងកំពុងតែធ្វើការយ៉ាងយកចិត្តទុកដាក់ជាមួយនាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៅភ្នំពេញ និងអាជ្ញាធរពាក់ព័ន្ធ។ តែយើងពិបាកស្រាវជ្រាវព្រោះមិនដឹងថា នាងនៅតំបន់ណាក្នុងប្រទេសចិន តែយើងបន្តស្រាវជ្រាវទៀត»។

ពាក់ព័ន្ធករណីនេះ លោក កុយ គួង អ្នកនាំពាក្យក្រសួងការបរទេសកម្ពុជាមិនអាចសុំការអត្ថាធិប្បាយបានទេកាលពីម្សិលមិញ ដោយទូរស័ព្ទលោកគ្មានអ្នកទទួល។ រីឯលោក ជីវផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនៃអគ្គស្នងការដ្ឋាននគរបាលជាតិបានឆ្លើយតាមទូរស័ព្ទថា លោកកំពុងរវល់មិនអាចឆ្លើយជូនបាន។ យ៉ាងណាក្តីលោកឧត្តមសេនីយ៍ឯក ឆាយ គឹមខឿន អ្នកនាំពាក្យអគ្គស្នងការដ្ឋាននគរបាលជាតិបានប្រាប់ពីថ្ងៃ ១៧ មីនាថា ករណីនេះ សមត្ថកិច្ចជំនាញកំពុងសហការជាមួយប្រទេសចិន រួចហើយ ក៏ប៉ុន្តែរហូតមកទល់ពេលនេះ លោកមិនទាន់ដឹងពីលទ្ធផលទេ។

ក៏ប៉ុន្តែបើតាមលោកស្រី ប្រាំង ជីតា ករណីនេះ សមត្ថកិច្ចលោកស្រីធ្លាប់បានឃាត់ខ្លួនស្ត្រីឈ្មោះ ខេង ហ៊ុន អាយុ ៥៥ ឆ្នាំ និងស្ត្រីឈ្មោះ រឿន ភ័ណ្ឌ អាយុ ៤៤ ឆ្នាំ ដាក់ពន្ធនាគារតាមបណ្តឹងរបស់ម្តាយនារីរងគ្រោះកាលពីឆ្នាំ ២០២០ ពាក់ព័ន្ធនឹងការជួយសម្រួលឲ្យកូនស្រីគាត់ឈ្មោះ អ៊ិន សុខជី ទៅចិន។

តាមរយៈរូបភាពនារីរងគ្រោះបង្ហោះបានរៀបរាប់ថា នាងសូមលើកម្រាមដៃ ១០ ឲ្យបងប្អូនខ្មែរជួយយកនាងពីប្រទេសចិន មកកម្ពុជាវិញផង។ ម្យ៉ាងនាងបង្ហោះសារនេះក៏ចង់ឲ្យអ្នកនៅកម្ពុជាបានឃើញ និងជួយចែករំលែកជូនលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានឃើញដើម្បីជួយនាងវិលមកកម្ពុជាវិញ។ នារីរងគ្រោះបានបញ្ជាក់ថាៈ «ខ្ញុំចាញ់បោកមេខ្យល់តាំងពីឆ្នាំ ២០១៩ ពេលនោះខ្ញុំទើបមានអាយុ ១៥ ឆ្នាំ។ គេយកខ្ញុំមកលក់នៅប្រទេសចិន តាំងពីអាយុ ១៥ ឆ្នាំ។ គេឃុំឃាំងខ្ញុំមិនឲ្យខ្ញុំទាក់ទងទៅអ្នកផ្ទះខ្ញុំទេគេវាយដំខ្ញុំ ទាត់ធាក់ខ្ញុំ គេឃុំឃាំងខ្ញុំក្នុងបន្ទប់។ ខ្ញុំអត់ចង់នៅប្រទេសចិន ទៀតទេ ខ្ញុំខ្លាចគេវាយធ្វើបាបខ្ញុំទៀត គេលក់ខ្ញុំពីម្នាក់ទៅម្នាក់»។

ដោយឡែក អ្នកស្រី ឌុច អ៊ីម ជាម្តាយនារីរងគ្រោះបានប្រាប់ ភ្នំពេញ ប៉ុស្តិ៍ ពីថ្ងៃ ១៧ មីនាថា នៅអំឡុងឆ្នាំ ២០១៩ ស្ត្រីឈ្មោះ ខេង ហ៊ុន និងឈ្មោះ រឿន ភ័ណ្ឌ ដែលរស់នៅភូមិជិតគ្នាបានមកបញ្ចុះបញ្ចូលឲ្យកូនស្រីអ្នកស្រីឈ្មោះ អ៊ិន សុខជី ឱ្យយកប្តីចិន ដោយប្រាប់ថា នៅចិនគេរកលុយបានច្រើន។ ប៉ុន្តែគាត់បានប្រកែកមិនព្រមឲ្យកូនទៅព្រោះខ្លាចប្តីចិនធ្វើបាប តែឈ្មោះ ខេង ហ៊ុន អះអាងថា គ្មានអ្នកណាធ្វើបាបទេ ហើយថា បើកូនគាត់គ្មានអត្តសញ្ញាណប័ណ្ណ គឺគេធ្វើបានភ្លាមមិនពិបាកទេ។ បើតាមអ្នកស្រី ឌុច អ៊ីម ក្រោយមកស្ត្រីមេខ្យល់បានបង្ហោះរូប

បុរសចិនចំនួន ៤ នាក់ (បុរសចំណាស់ ២ នាក់ បុរសវ័យក្មេង ២ នាក់) ឲ្យកូនអ្នកស្រីមើល។ ក្រោយឃើញរូបថតបុរសចិននោះ កូនស្រីបានប្រាប់អ្នកស្រីថា នាងដាច់ចិត្តយកប្ដីនៅចិនហើយ ព្រោះនៅស្រុកយើងពិបាក។ បន្ទាប់ពីមានការយល់ព្រមស្ត្រីមេខ្យល់ទាំង ២ នាក់ បាននាំអ្នកស្រី និងកូនស្រីមកភ្នំពេញរត់ការឯកសារធ្វើលិខិតឆ្លងដែន។ បន្ទាប់មកក៏នាំទៅឡើងយន្តហោះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញជិះទៅប្រទេសចិន តែម្តង។

លោកស្រី ម៉ៅ ម៉ាប់ មន្ត្រីសមាគមការពារសិទ្ធិមនុស្សអាដហុកទទួលបន្ទុកស្ត្រី និងកុមារបានថ្លែងថា ករណីនារីរងគ្រោះឈ្មោះ អ៊ិន សុខជី ម្នាក់នេះ លោកស្រីមិនទាន់បានទទួលព័ត៌មានពីមន្ត្រីរបស់លោកស្រីទេ តែលោកស្រីថានឹងតាមដានរឿងនេះ។ លោកស្រីបន្តថា បើនិយាយពីការជួញដូរមនុស្ស គឺមេខ្យល់តែងប្រើគ្រប់មធ្យោបាយដោយខ្លះប្រាប់ជនរងគ្រោះថា ទៅរកការងារធ្វើបានប្រាក់ខែពី ៥០០ ទៅ ១ ០០០ ដុល្លារ ដោយសារគេដឹងថាស្ថានភាពជីវភាពពលរដ្ឋខ្វះខាតខ្លាំងដែលខ្លះជំពាក់បំណុលធនាគារក៏មាន។ លោកស្រីបញ្ជាក់ថា៖ «វិធីបោកប្រាស់របស់មេខ្យល់មានលក្ខណៈជាប្រព័ន្ធ ដូចជាមានអ្នកជួយរត់ឯកសារឲ្យមានអ្នកជូនជនរងគ្រោះទៅដល់ព្រំដែនហើយមានអ្នកនាំបន្តទៅដល់គោលដៅប្រទេសចិន តែម្តង។ បន្ទាប់ពីទៅដល់ហើយមានអ្នកទទួលជនរងគ្រោះ ទៅរកកន្លែងស្នាក់នៅអ៊ីចឹងទៅ»។ លោកស្រីបន្តថា អំពើជួញដូរមនុស្សនេះ មានទាំងជួញដូរពលកម្មជួញដូរផ្លូវភេទ និងមិនមែនទៅតែប្រទេសចិន ទេ មានទៅម៉ាឡេស៊ី និងថៃផង ហើយខេត្តជាគោលដៅដែលមេខ្យល់តែងតែអូសទាញជនរងគ្រោះភាគច្រើន គឺមានខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តបាត់ដំបង និងខេត្តព្រះវិហារ៕

## អភិបាលខេត្តព្រះវិហារ ណែនាំកងកម្លាំងឈរជើងតាមបន្ទាត់ព្រំដែន ត្រូវទប់ស្កាត់ការឆ្លងដែនខុសច្បាប់ ដើម្បីការពារការរីករាលដាលកូវីដ១៩

http://freshnewsasia.com/ 2021-03-22 08:01pm

**(ព្រះវិហារ)៖** លោក ប្រាក់ សុវណ្ណ អភិបាលខេត្តព្រះវិហារ នៅរសៀលថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១នេះ បានដឹកនាំក្រុមការងារចុះត្រួតពិនិត្យស្ថានភាពនៅតាមព្រំដែនកម្ពុជា-ថៃ នៅច្រកអានសេះ ភ្នំទ្រព្យ និងតំបន់មួយចំនួនទៀត ជាមួយនឹងការសួរសុខទុក្ខសំណេះសំណាល និងចែកជូនថវិកា ម៉ាស់ ជាការលើកទឹកចិត្តដល់កងកម្លាំងដែលឈរជើងតាមព្រំដែន។ នៅក្នុងឱកាសនោះដែរ លោកអភិបាលខេត្តព្រះវិហារ បានធ្វើការណែនាំដល់កងកម្លាំងប្រដាប់អាវុធដែលឈរជើងនៅតាមព្រំដែនកម្ពុជា-ថៃ ក្នុងភូមិសាស្ត្រខេត្ត ត្រូវយកចិត្តទុកដាក់ទប់ស្កាត់ឲ្យបានចំពោះបទល្មើសឆ្លងដែនខុសច្បាប់នានា ជាពិសេសបទល្មើសឆ្លងដែនខុសច្បាប់របស់ពលករ គឺមិនត្រូវឲ្យមានជាដាច់ខាត ដែលការទប់ស្កាត់ការឆ្លងដែនដោយខុសច្បាប់នេះ គឺក្នុងទិសដៅមិនឲ្យមានការឆ្លងរីករាលនៃជំងឺកូវីដ១៩។ ជាមួយគ្នានេះដែរលោក ប្រាក់ សុវណ្ណ ក៏បានអំពាវនាវឲ្យកងកម្លាំងដែលឈរជើងនៅតាមព្រំដែនទាំងអស់ត្រូវរក្សាអនាម័យក្នុងការរស់នៅ ដោយហូបស្អាត ផឹកស្អាត រស់នៅស្អាត ដើម្បីឲ្យមានសុខភាពល្អ។ ជាពិសេសត្រូវរក្សាអនាម័យដើម្បីការពារជំងឺកូវីដ១៩ ដោយត្រូវអនុវត្តន៍ឲ្យបានទៀងទាត់តាមការណែនាំរបស់ក្រសួងសុខាភិបាល និងអនុសាសន៍ សម្តេចតេជោហ៊ុន សែន គឺ «៣កុំនិង៣ការពារ» ដែលជាវិធានការដ៏មានប្រសិទ្ធិភាពខ្ពស់បំផុត៕

## ពលករខ្មែរខ្លះបន្តរស់នៅលំបាកក្នុងប្រទេសថៃដោយមិនត្រឡប់ទៅចូលឆ្នាំនៅកម្ពុជា

https://www.rfa.org/khmer/ ដោយ ហេង រស្មី 2021-03-22

ពលករខ្មែរជាច្រើននាក់បន្តអត់ទ្រាំរស់នៅលំបាកក្នុងប្រទេសថៃ ដើម្បីរកប្រាក់ដោះស្រាយជីវភាពគ្រួសារ។ ក្នុងនោះមានពលករខ្លះអត់ការងារធ្វើ និងខ្លះទៀតធ្វើការមិនទៀងទាត់ និងត្រូវបានថៅកែកេងប្រវ័ញ្ចកម្លាំងពលកម្មពួកគាត់។ មន្ត្រីសង្គមស៊ីវិលយល់ថា រឿងនេះកើតឡើងដោយសារតែរដ្ឋាភិបាលប្រទេសទាំងពីរមិនបានយកចិត្តទុកដាក់ជួយដល់ពលករ។ ពលករខ្មែរធ្វើការសំណង់នៅខេត្តជាប់ទីក្រុងបាងកក លោក ហួន ថៃឡូ ប្រាប់អាស៊ីសេរីនៅ

ព្រឹកថ្ងៃទី២២ មីនាថា ចូលឆ្នាំប្រពៃណីខ្មែរឆ្នាំនេះ លោកមិនបានទៅលេងស្រុកកំណើតនោះទេ ដោយសារគ្មានប្រាក់ ព្រោះថៅកែជនជាតិថៃ មិនបានបើកប្រាក់ខែឱ្យលោកចំនួន ៣ខែមកហើយ។ ពលករខ្មែរវ័យ ៥០ឆ្នាំរូបនេះព្រួយបារម្ភខ្លាចដាច់ស្បៀងនៅពេលខាងមុខផង និងព្រួយខ្លាចធនាគាររឹបអូសដីធ្លីនៅស្រុកកំណើតផង ដោយសារគ្មានប្រាក់សងម្ចាស់បំណុលដែលបានខ្ចីគេ ដាំដំឡូងមីកាលពីពេលកន្លងទៅ៖ «យើងរកលុយអត់សូវបានវល់តែជួបគេបោក គេបើកឱ្យយើងបានម៉ាចាយៗ អ៊ីចឹងទៅ ហើយគេថាថ្ងៃនេះថ្ងៃនោះរហូត។ខ្ញុំអំពាវនាវដល់ជូនតាហើយអត់បានអត់បានទៅជួបគាត់ទេ វាមានបញ្ហាច្រើនទី១ជាប់រឿងលុយធនាគារផង ទី២ បញ្ហារាលដាលជំងឺកូវីដផង អ៊ីចឹងទៅយ៉ាងណាក៏ខ្ញុំមិនបានទៅដែរ។ខ្ញុំខាំស្មៅទាល់តែរកប្រាក់សងគេរួចបានខ្ញុំត្រឡប់ទៅស្រុកវិញ»។ នៅថ្ងៃទី ២២ មីនា តំណាងក្រុមពលករ ៣នាក់ បាននាំគ្នាទៅប្ដឹងអង្គការសង្គមស៊ីវិលការពារសិទ្ធិពលករនៅប្រទេសថៃ ឱ្យជួយអន្តរាគមន៍ទៅថៅកែថៃ ដើម្បីឱ្យបើកប្រាក់ខែដល់ពួកគាត់។

ស្រដៀងគ្នានេះដែរ ពលករខ្មែរធ្វើការសំណង់នៅខេត្តសមុទ្រ សាខន (Samuth Sakorn) លោក ធន សុខឿន ថ្លែងថា នៅកន្លែងលោកធ្វើការមានពលករខ្មែរប្រមាណ ៥០នាក់ ក្នុងចំណោមពលករជាង ២០០នាក់អត់ការងារធ្វើ និងពលករខ្លះទៀតធ្វើការមិនទៀងទាត់ ជាច្រើនខែមកហើយ បណ្ដាលមកពីការរាតត្បាតជំងឺកូវីដ១៩។ ពលករវ័យ ៤១ឆ្នាំរូបនេះ ប្រាប់ថា បច្ចុប្បន្នមានពលករជាច្រើននាក់បាននាំគ្នាដើរបេះផ្ទី និងដាក់មងតាមអូរយកត្រីចម្អិនធ្វើម្ហូបប្រចាំថ្ងៃ ដោយសារគ្មានប្រាក់ទិញស្បៀងអាហារហូបចុក។ លោកបញ្ជាក់ថា បើទោះបីជារស់នៅប្រទេសថៃលំបាកយ៉ាងនេះក្ដី ក៏ពួកលោកមិនបានត្រឡប់ទៅកម្ពុជា អំឡុងពេលនេះឡើយ ពីព្រោះគ្មានប្រាក់ហើយម្យ៉ាងទៀតខ្លាចអាជ្ញាធរថៃចាប់ដាក់គុកក្នុងពេលធ្វើដំណើរតាមផ្លូវ៖ «តាមដែលខ្ញុំមើលទៅបម្រាមខ្លាំងតែជនជាតិខ្មែរយើងតែម្ដង សូម្បីតែយើងចង់ចេញទៅណាបើយើងជិះម៉ូតូឌុប ខលហៅម៉ូតូមកយកយើងក៏គេអត់ឱ្យម៉ូតូមកយកដែរ។ប៉ុន្តែបើជនជាតិថៃវិញគេឱ្យតាក់ស៊ីជូនដល់កន្លែង បើចំពោះយើងគេហាមតាក់ស៊ីមិនឱ្យចូលតែម្ដង។វាប៉ះពាល់ខ្លាំងខាងទឹកចិត្ត យើងអត់ថា យើងជាពលករមួយរូបនៅតំបន់ហ្នឹងហេតុអីបានគេរើសអើងយើងសំបើមម្ល៉េះ បើមុនហ្នឹងចេញទៅណាគេត្រួតយើងគេពិនិត្យច្បាប់លាស់»។

អាស៊ីសេរីមិនអាចទាក់ទងមន្ត្រីស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ និងអ្នកនាំពាក្យក្រសួងការងារលោក ហេង សួរ ដើម្បីសុំអត្ថាធិប្បាយជុំវិញពីក្ដីកង្វល់របស់ក្រុមពលករនេះបានទេ នៅថ្ងៃទី២២ មីនា ដោយទូរស័ព្ទចូលជាច្រើនដងពុំមានអ្នកទទួល។

កន្លងមកលោក នាយករដ្ឋមន្ត្រី ហ៊ុន សែន បានអំពាវនាវដល់ពលករខ្មែរ ឱ្យបន្តស្នាក់នៅប្រទេសថៃមួយរយៈ ដើម្បីបង្ការកុំឱ្យឆ្លងជំងឺកូវីដ។ ប៉ុន្តែរដ្ឋាភិបាលមិនបានដោះស្រាយពីទុក្ខលំបាករបស់ពលករក្នុងពេលពួកគាត់ស្នាក់នៅប្រទេសនោះឡើយ។

មន្ត្រីអង្គការសង់ត្រាល់ (Central) ទទួលបន្ទុកផ្នែកពលករ លោក ឌី ថេហូយ៉ា យល់ថា ពលករខ្មែររាប់ពាន់នាក់បន្តរស់នៅលំបាកក្នុងប្រទេសថៃ ដោយសារពួកគាត់អត់ការងារធ្វើ។ បន្ថែមពីនេះមានពលករមួយចំនួនត្រូវបានថៅកែថៃបោកប្រាស់កម្លាំងពលកម្ម ដោយធ្វើការមិនបានប្រាក់ឈ្នួលជាដើម។ មន្ត្រីសង្គមស៊ីវិលរូបនេះនិយាយថា ពលករធ្វើការខុសច្បាប់ប្រឈមនឹងថៅកែថៃកេងប្រវ័ញ្ចកម្លាំងពលកម្មច្រើនជាងគេ ជាពិសេស អ្នកធ្វើការងារសំណង់។ លោកបញ្ជាក់ថា ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលខ្មែរ និងរដ្ឋាភិបាលថៃគួរតែបញ្ជូនមន្ត្រីពាក់ព័ន្ធចុះជួយពលករជាបន្ទាន់ និងចាត់វិធានការផ្លូវច្បាប់លើថៅកែ ដែលកេងចំណេញកម្លាំងពលករ៖ «តួនាទីរបស់រដ្ឋហ្នឹងហាក់ដូចជាផ្ដោតទៅលើកូវីដ ផ្ដោតតែរឿងសេដ្ឋកិច្ចជារួម អ៊ីចឹងវាជាឱកាសដល់និយោជកហ្នឹងប្រើអំណាចកិបកេងកម្លាំងពលករ។ និយាយជារួមមកគឺ ពួកគាត់នៅហ្នឹងក៏ប្រឈមមកវិញក៏ប្រឈម ប៉ុន្តែភាពប្រឈមហ្នឹងវាមានលក្ខណៈខុសគ្នា។ ប្រសិនជាគាត់នៅហ្នឹងអ្នកដែលអត់មានការងារធ្វើគាត់ប្រឈមខ្លាំងណាស់គាត់អត់មានលុយចាយវាយសម្រាប់ការរស់នៅប្រចាំថ្ងៃ ហើយប្រសិនបើគាត់អស់សុពលភាពឯកសារទៀតអាហ្នឹងកាន់តែ

ប្រឈមខ្លាំងហើយ»។ លោក ឌី ថេហូយ៉ា បន្តថា មានពលករមួយចំនួនបានធ្វើដំណើរប្រថុយប្រថានត្រឡប់ទៅកម្ពុជាវិញ វិញខ្លះដែរ ដោយសារពួកគេគ្មានលទ្ធភាពរស់នៅប្រទេសថៃ។ មន្ត្រីសង្គមស៊ីវិលរូបនេះឱ្យដឹងទៀតថា ចាប់តាំងពីចុងឆ្នាំ២០២០ មកដល់ខែមីនានេះ យ៉ាងហោចណាស់មានពលករខ្មែរប្រហែល ៥ម៉ឺននាក់ (៥០.០០០) ហើយ បានត្រឡប់ទៅកម្ពុជា តាមច្រកទ្វារព្រំដែនក្នុងខេត្តបន្ទាយមានជ័យ បាត់ដំបង និងខេត្តឧត្តរមានជ័យជាដើម។ របាយការណ៍អង្គការសង់ត្រាល់ (CENTRAL) ឱ្យដឹងថា បច្ចុប្បន្នមានពលករខ្មែរធ្វើការស្របច្បាប់មិនស្របច្បាប់ប្រមាណ ១លាន ៨សែននាក់ (១.៨០០.០០០) ធ្វើការនៅប្រទេសថៃ៕

## ពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាចំនួន ៤នាក់ ត្រូវបានអាជ្ញាធរបញ្ជូនមកកាន់មណ្ឌលចត្តាឡីស័ក

http://cambodiapolice.com/policekh/ 8:11 pm 22 មីនា 2021

ខេត្តបាត់ដំបង ៖ នៅថ្ងៃចន្ទ ទី២២ ខែមីនា ឆ្នាំ២០២១ តាមការណែនាំរបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨ ១៧ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨ ១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយ កម្លាំងយោធាវរសេនាតូច៥៣៣, កម្លាំងសឹករងស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន ៤ នាក់ , ស្រី ១ នាក់ ក្នុងនោះ ក្មេងប្រុស១ នាក់ និងក្មេងស្រី ១ នាក់ ពីចំណុចភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង និងនៅចំណុចភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ១ នាក់ សរុបទាំងពីរទីតាំង ៥នាក់ ស្រី១នាក់ ។ បន្ទាប់ពីធ្វើការសាកសួររួចក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ចំនួនពលករខ្មែរវិលពីប្រទេសថៃមានចំនួន៥ម៉ឺន២ពាន់២៣៥នាក់

http://cambodiapolice.com/policekh/ 4:27 pm 22 មីនា 2021

ចំនួនពលរដ្ឋ និងពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃវិញ ក្នុងរយៈពេលជិត៣ខែដើមឆ្នាំនេះ មានចំនួនជាង៥ម៉ឺននាក់។ យោងតាមអគ្គស្នងការដ្ឋាននគរបាលជាតិ អ្នកវិលត្រឡប់មកពីប្រទេសថៃ ចំនួន៥ម៉ឺន ២ពាន់ ២៣៥នាក់ រវាងពីខែមករាដល់ខែមីនាគិតត្រឹមថ្ងៃទី២២មីនានេះ ត្រូវបានអនុវត្តការធ្វើចត្តាឡីស័ក តាមវិធានសុខាភិបាលនៅតាមទីតាំងដែលបានកំណត់។ តាមអគ្គស្នងការដ្ឋាននគរបាលជាតិដដែល ការវិលត្រឡប់ មកប្រទេសកម្ពុជាវិញនេះ បានធ្វើតាមច្រកទ្វារព្រំដែននៅយោធភូមិភាគទី៥ ចំនួន៣ម៉ឺន៦ពាន់៣៤៧នាក់ និង តាមយោធភូមិភាគទី៤ ចំនួន១ម៉ឺន៥ពាន់៨៨៨នាក់។

យោងតាមក្រសួងសុខាភិបាលថ្ងៃនេះ ពលករខ្មែរដែល បានវិលត្រឡប់មកពីប្រទេសថៃ និងដែលបានរកឃើញឆ្លងកូវីដ-១៩កន្លងមកនេះ មានចំនួន៩១នាក់ ដែលក្នុងនោះ៩០នាក់ បានទទួលការព្យាបាលជាសះស្បើយហើយ គិតត្រឹមថ្ងៃទី២២មីនានេះ ៕

## ឧត្តមសេនីយ៍ឯក លៀង ភារម្យ ដាក់បទបញ្ជាម៉ឺងម៉ាត់ដល់នគរបាលការពារព្រំដែន នៅតាមច្រកព្រំដែនមិនឲ្យពលរដ្ឋខ្មែរចេញ-ចូលដោយខុសច្បាប់

http://cambodiapolice.com/policekh/ 1:14 pm 22 មីនា 2021

ភ្នំពេញ ៖ ប្រធាននាយកដ្ឋាននគរបាលការពារព្រំដែនគោក ឯកឧត្តម ឧត្តមសេនីយ៍ឯក លៀង ភារម្យ បានដាក់បទបញ្ជាយ៉ាងម៉ឺងម៉ាត់ ចំពោះមន្ត្រីនគរបាលការពារព្រំដែនគោកទាំងអស់ ជាពិសេសព្រំដែនកម្ពុជា-ថៃ ដោយមិនអនុញ្ញាតឲ្យពលរដ្ឋ ឬពលករខ្មែរចេញ-ចូលដោយខុសច្បាប់បន្តទៀតនោះឡើយ ខណៈពលករខ្មែរដែលបានវិលត្រឡប់មកពីប្រទេសថៃវិញ ចាប់ពីខែមករាដល់ខែមីនានេះ ជាងប្រាំម៉ឺននាក់ក៏ត្រូវបានធ្វើចត្តាឡីស័ក ស្របទៅតាមការណែនាំរបស់ក្រសួងសុខាភិបាលដែរនោះ។

ថ្លែងប្រាប់គេហទំព័រអគ្គស្នងការដ្ឋាននគរបាលជាតិ តាមរយៈសារអេឡិចត្រូនិច(តេលេក្រាម) នាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១នេះ ឯកឧត្តម ឧត្តមសេនីយ៍ឯក លៀង ភារម្យ បានបញ្ជាក់ថា ចាប់ពីខែមករា ដល់ពាក់កណ្ដាលខែ មីនា ឆ្នាំ២០២១នេះ មានពលករ និងពលរដ្ឋខ្មែរបានវិលត្រឡប់មកពីប្រទេសថៃវិញ តាមច្រកទ្វារអន្តរជាតិ មានចំនួន៥២.២៣៥នាក់ ដោយក្នុងនោះតាមច្រកទ្វារព្រំដែននៅយោធភូមិភាគទី៥ ចំនួន៣៦.៣៤៧នាក់ តាមយោធភូមិភាគទី៤ ចំនួន១៥.៨៨៨នាក់ ហើយពួកគាត់ត្រូវបានចាត់វិធានការស្របទៅតាមការណែនាំរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្រសួងសុខាភិបាលទាំងអស់ផងដែរ។

ឯកឧត្តមឧត្តមសេនីយ៍ឯក បានបញ្ជាក់បន្ថែមទៀតថា«នគរបាលការពារព្រំដែនគោកទាំងអស់បានអនុវត្តយ៉ាងខ្ជាប់ខ្ជួនចំពោះការណែនាំរបស់រាជរដ្ឋាភិបាល ដែលបានដាក់បទបញ្ជាដោយហាមដាច់ខាត មិនឲ្យមានការលួចឆ្លងដែនខុសច្បាប់ចាប់តាំងពីខែមករាមក ហើយប្រសិន ជាមានគឺដាច់ខាតមិនឲ្យចេញ ហើយមួយទៀតបើចូលគឺត្រូវតែឃាត់ពួកគាត់ដោយឲ្យធ្វើចត្តាឡីស័កគ្រប់ៗគ្នាទាំងអស់ ខណៈបទបញ្ជាថ្មីរបស់រាជរដ្ឋាភិបាលនៅក្នុងខែមីនានេះបងប្អូនចូលពីថៃមកគឺត្រូវតែពិនិត្យសុខភាព វាស់កម្តៅ ហើយបើគ្មានបញ្ហាអ្វីទេគឺតម្រូវឲ្យទៅធ្វើចត្តាឡីស័កក្នុងសហគមន៍»។ ឯកឧត្តមប្រធាននាយកដ្ឋាន បានលើកឡើងផងដែរថា នគរបាលការពារព្រំដែនគោកទាំងអស់បានអនុវត្តយ៉ាងម៉ឺងម៉ាត់រាល់បទបញ្ជាប្រមុខរាជរដ្ឋាភិបាលក៏ដូចជាក្រសួងសុខាភិបាល ដែលបានដាក់ចេញ ហើយជាមួយគ្នានោះមន្ត្រីនគរបាលទាំងអស់ក៏បានរក្សាវិធានការ«៣ការពារ ៣កុំ»បើទោះបីជាពួកគាត់បានប្រឈមជាមួយបងប្អូនពលករផ្ទាល់ក៏ដោយនោះ៕

## តំបន់ព្រំដែនកម្ពុជាបន្តរឹតត្បិតការចេញចូលក្នុងន័យបង្ការការឆ្លងជំងឺកូវីដ១៩

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 21/03/2021 - 07:56 ដោយ៖ជួប នរក្សា

ខេត្តនៅតាមតំបន់ព្រំដែនទាំងកម្ពុជា-ថៃ និងកម្ពុជា-វៀតណាម នៅតែបន្តការរឹតបន្តឹងការចេញចូលក្នុងន័យបង្ការការរាលដាលជំងឺកូវីដ១៩។ ការរឹតបន្តឹងនេះ ធ្វើឡើងជាង៤ខែមកហើយ ក្រោយមានការដាក់បញ្ជាពីលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ឲ្យអាជ្ញាធរតាមខេត្តជាប់ព្រំដែនត្រៀមជើងការ កាលពីថ្ងៃទី២០ធ្នូឆ្នាំ២០២០កន្លងទៅ។ ទាំងអាជ្ញាធរនៅព្រំដែនកម្ពុជា-ថៃ និងព្រំដែនកម្ពុជា-វៀតណាម បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃអាទិត្យនេះ ថាសភាពនៅច្រកព្រំដែននៅបន្តរឹតត្បិត និងមានភាពប្រក្រតី។ រយៈពេលជាង៤ខែ ក្រោយការបង្គាប់បញ្ជាអាជ្ញាធរតាមច្រកព្រំដែនឲ្យមានការយកចិត្តទុកដាក់យកសំណាកលើពលករខ្មែរដែលត្រលប់មកពីប្រទេសថៃ និងការរាលដាលកូវីដ១៩ជាសហគមន៍នៅវៀតណាមថ្ងៃទី៣មករា ពីសំណាក់ប្រមុខរដ្ឋាភិបាលកម្ពុជា លោក ហ៊ុន សែន មក អាជ្ញាធរតាមខ្សែបន្ទាត់ព្រំដែន នៅតែបន្តរឹតត្បិតការចេញចូលនៅច្រកព្រំដែនអន្តរជាតិកម្ពុជាផងដែរ។

ថ្លែងប្រាប់វិទ្យុបារាំងនៅថ្ងៃនេះ លោក ងួត រតនៈ អភិបាលខេត្តបាត់ដំបង ថា អាជ្ញាធរនៅតែបន្តដាក់ពង្រាយកងកម្លាំងនៅចម្ងាយ៧៥គីឡូម៉ែត្រ តាមបន្ទាត់ព្រំដែនជាមួយថៃ ដើម្បីបង្ការការលួចឆ្លងចូលរបស់ពលករខ្មែរដោយមិនបានយកទៅធ្វើចត្តាឡីស័ក។ បើតាមការអះអាងរបស់អភិបាលខេត្ត គិតសរុបមកមានពលករខ្មែរប្រមាណ១មុឺន៥ពាន់នាក់ ចូលមកកម្ពុជាតាមច្រកទ្វារព្រំដែននៃខេត្ត ហើយអាជ្ញាធរខេត្តបានយកទីតាំងចំនួន១៧កន្លែង ដើម្បីធ្វើជាមណ្ឌលចត្តាឡីស័កសម្រាប់ពលករ ក៏ប៉ុន្តែនៅមួយរយៈកាលក្រោយនេះ ចំនួនពលករខ្មែរដែលកំពុងធ្វើចត្តាឡីស័ក នៅសល់តែប្រមាណជាង២០០០នាក់ប៉ុណ្ណោះ។ នេះបើតាមការបញ្ជាក់របស់លោក ងួត រតនៈ។ លោកបានបញ្ជាក់បន្ថែមដែរថា ទោះបីមានយន្តការហាមមិនឲ្យមានការចេញចូលរបស់ពលរដ្ឋនៅតាមច្រកព្រំដែនក៏ពិតមែន តែយ៉ាងណាការដឹកជញ្ជូនទំនិញនៅតែបន្តធ្វើជាប្រក្រតី។ ការដឹកជញ្ជូនទំនិញ ដោយមានតែអ្នកបើក និងអ្នកជញ្ជូនទំនិញតែម្នាក់ប៉ុណ្ណោះ។

ចំណែកឯអភិបាលខេត្តកណ្ដាល លោក គង់ សោភ័ណ្ឌ ក៏បានអះអាងប្រាប់វិទ្យុបារាំងអន្តរជាតិស្រដៀងគ្នានេះដែរ។ ដោយក្នុងនោះ លោកបញ្ជាក់ ចរន្តចេញចូលតាមច្រកព្រំប្រទល់កម្ពុជា-វៀតណាម ក្នុងខេត្តកណ្ដាល នៅតែរឹតបន្តឹងជាបន្ត ព្រមទាំងការចេញចូលរបស់ពលរដ្ឋ និងភ្ញៀវបរទេសមួយចំនួន ក៏ត្រូវបានកាត់ផ្ដាច់ដដែរ។ អ្វីដែលនៅបន្តធ្វើនោះ គឺការដឹកជញ្ជូនចេញចូលទំនិញកម្ពុជា-វៀតណាម តែក្នុងបរិមាណតិចតួចជាងមុនសភាពការផ្ទុះកូវីដ១៩។ ដាច់ឡែកចំពោះភូមិសាស្ត្រដែលកំពុងមានការរាលដាលឆ្លងខ្លាំងនៅក្នុងស្រុកកោះធំ លោក គង់ សោភ័ណ្ឌ ក៏បានបញ្ជាក់បន្ថែមដែរថា តំបន់នោះកំពុងមានការរឹតបន្តឹងខ្ពស់ពីសំណាក់អាជ្ញាធរមូលដ្ឋាន ដោយពលរដ្ឋក្នុងតំបន់មិនអាចចេញចូលដោយសេរីទេ រីឯអ្នកធ្វើដំណើរពីរាជធានីភ្នំពេញក៏មិនត្រូវអនុញ្ញាតឲ្យចេញចូលនៅតំបន់ភូមិជ្រៃធំ និងភូមិមួយចំនួនក្នុងស្រុកកោះធំដែលកំពុងមានការរាលដាលខ្លាំងនោះ។ ការរឹតបន្តឹងរបស់អាជ្ញាធរក្នុងពេលនេះ ក៏ដើម្បីបង្ការហានិភ័យចម្លងជំងឺកូវីដ១៩ជាបន្តដែរ។ នេះបើតាមលោកអភិបាលខេត្តកណ្ដាល។

គិតជាតួលេខចុងក្រោយ កម្ពុជារកឃើញអ្នកឆ្លងជំងឺកូវីដ១៩ ជាពលករខ្មែរចំនួន៩១នាក់ និងព្យាបាលជាចំនួន៩០នាក់។ នេះបើតាមសេចក្ដីប្រកាសព័ត៌មានរបស់ក្រសួងសុខាភិបាលនៅព្រឹកថ្ងៃអាទិត្យនេះ៕

## អភិបាលខេត្តពោធិ៍សាត់ចុះសួរសុខទុក្ខពលករចំណាកស្រុកនៅមណ្ឌលចត្តាឡីស័ក

https://www.khmertimeskh.com/ ខ្មែរថាមស៍ / Khmer Times

**ពោធិ៍សាត់៖** អភិបាលខេត្តពោធិ៍សាត់ និងប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ បានលើកទឹកចិត្តដល់ពលករដែលវិលត្រលប់មកពីប្រទេសថៃ ឲ្យវិលត្រលប់មកវិញរួមជាមួយជំនាញចាំបាច់ដែលអាចនឹងផ្ដល់ផលប្រយោជន៍ដល់ពួកគេក្នុងរយៈពេលវែង។ លោក ម៉ៅ ធនិន អភិបាលខេត្តបាននិយាយទៅកាន់ពលករប្រមាណ ១២០ នាក់នៅសាលាបឋមសិក្សាទន្លេអុំ នៅឃុំស្រែស្ដុក ស្រុកកណ្ដៀងថា៖ «សូមនាំយកនូវជំនាញ និងចំណេះដឹងរបស់អ្នកមកជាមួយផង ដើម្បីស្វែងរកការងារធ្វើនៅក្នុងសហគ្រាស និងឧស្សាហកម្មក្នុងស្រុកដើម្បីចៀសវាង ឬកាត់បន្ថយការធ្វើចំណាកស្រុក»។ លោកបន្តថា៖ «ទីផ្សារការងាររបស់យើងនឹងប្រឈមមុខនឹងកង្វះធនធានមនុស្សនៅពេលដែលជំងឺរាតត្បាតបានធូរស្រាល ហើយឧស្សាហកម្មនឹងចាប់ផ្ដើមផលិតកម្ម ឬដំណើរការឡើងវិញ។ វានឹងមិនអាចទៅរួចទេ ប្រសិនបើពលរដ្ឋនៅតែបន្តធ្វើចំណាកស្រុកទៅកាន់ប្រទេសថៃ»។

លោកបន្ថែមថានេះជាលើកទី ៣ ហើយដែលលោកបានចុះសួរសុខទុក្ខប្រជាជនដែលស្ថិតនៅក្នុងមណ្ឌលចត្តាឡីស័កដើម្បីធានានូវសុខុមាលភាពនិងដោះស្រាយបញ្ហាប្រឈមរបស់ប្រជាជននៅតាមមណ្ឌលផ្សេងៗក្នុងខេត្ត។

ក្នុងឱកាសនោះដែរ លោកក៏បានផ្តាំផ្ញើដល់ពលករទាំងអស់ត្រូវប្រកាន់ខ្ជាប់ និងចូលរួមអនុវត្តឲ្យបានត្រឹមត្រូវនូវគោលការណ៍ណែនាំសុវត្ថិភាពរបស់ក្រសួងសុខាភិបាលក៏ដូចជាវិធានការណ៍ ៣ កុំ និង៣ ការពារ របស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ៕ ប្រែសម្រួលដោយ សៀវ គួយអ៊ី

## ប្រទេសថៃបានបរិច្ចាគថវិកាចំនួន ១០ ម៉ឺនដុល្លារដល់ពលករចំណាកស្រុកកម្ពុជា

https://www.khmertimeskh.com/ Rhea Mae Soco / Khmer Times

រដ្ឋាភិបាលថៃបានផ្តល់ជំនួយថវិកាចំនួន ១០ ម៉ឺនដុល្លារដល់ប្រទេសកម្ពុជាដើម្បីជួយលើកកម្ពស់សុខុមាលភាពរបស់ពលករចំណាកស្រុកកម្ពុជានៅតាមមណ្ឌលចត្តាឡីស័កនៅតាមព្រំដែន។ ជំនួយហិរញ្ញវត្ថុនេះត្រូវបានប្រគល់ដោយលោក Panyarak Poolthup ឯកអគ្គរដ្ឋទូតថៃប្រចាំនៅកម្ពុជាទៅលោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេសកាលពីថ្ងៃសុក្រ។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតថៃបានឲ្យដឹងថា ពលករចំណាកស្រុកកម្ពុជាស្ថិតក្នុងចំណោមកម្លាំងជំរុញសេដ្ឋកិច្ចដ៏សំខាន់បំផុតរបស់ប្រទេសថៃ។ សេចក្តីប្រកាសព័ត៌មានលើកឡើងថា៖ «ដូច្នេះ រាជរដ្ឋាភិបាលថៃបានបង្កើតគោលនយោបាយដើម្បីថែរក្សាសុវត្ថិភាព និងសុខុមាលភាពរបស់ពួកគេ ជាពិសេសអំឡុងពេលមានជំងឺរាតត្បាតនៅពេលដែលពួកគេភាគច្រើនកំពុងស្ថិតនៅក្នុងប្រទេសថៃ»។ សេចក្តីប្រកាសព័ត៌មានបានកត់សំគាល់ថា មានពលករចំណាកស្រុកជាង ១០ ម៉ឺននាក់បានសម្រេចចិត្តវិលត្រឡប់មកប្រទេសកម្ពុជាវិញបន្ទាប់ពីមានការបិទអាជីវកម្មនៅប្រទេសថៃ ដោយសារជំងឺរាតត្បាតកូវីដ-១៩។

លោកឯកអគ្គរដ្ឋទូត Poolthup បាននិយាយថា សុខុមាលភាព និងសុវត្ថិភាពរបស់ពលករចំណាកស្រុកកម្ពុជាគឺស្ថិតក្នុងចំណោមអាទិភាពរបស់យើង មិនថាពួកគេនៅទីណានោះទេ។ លោកបន្តថា៖ «ក្នុងនាមរាជរដ្ឋាភិបាលថៃ ខ្ញុំមានកិត្តិយស និងមានសេចក្តីរីករាយណាស់ ដែលបានប្រគល់វិភាគទានហិរញ្ញវត្ថុចំនួន ១០ ម៉ឺនដុល្លារដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងគោលបំណងផ្តល់ជំនួយ។ យើងទន្ទឹងរងចាំស្វាគមន៍ការត្រលប់មកវិញរបស់ពួកគេនៅពេលដែលការរឹតត្បិតត្រូវបានបន្ធូរបន្ថយ ហើយស្ថានភាពរាតត្បាតទាំងមូលមានភាពប្រសើរឡើងវិញ»។ នៅពេលពលករចំណាកស្រុកវិលត្រឡប់មកមាតុភូមិវិញ ខេត្តជាប់ព្រំដែនប្រទេសកម្ពុជាមានទំនួលខុសត្រូវក្នុងការត្រួតពិនិត្យសុខភាព និងការធ្វើចត្តាឡីស័កដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងទ្រង់ទ្រាយធំ។ រដ្ឋាភិបាលថៃបានតាមដានស្ថានការណ៍នៃពលករចំណាកស្រុកដែលវិលត្រឡប់មកវិញ ហើយមានបំណងគាំទ្ររដ្ឋាភិបាលកម្ពុជា ក៏ដូចជាថែរក្សាសុខភាពរបស់ពលករចំណាកស្រុក។ លោក Poolthup និយាយថាកន្លងមករដ្ឋាភិបាលថៃបានផ្តល់វិភាគទានចំនួន ៦១ ៤៦២.៨១ ដុល្លារដល់ប្រទេសកម្ពុជានៅក្នុងខែឧសភាឆ្នាំ ២០២០ ក្នុងការជួយការពារ និងគ្រប់គ្រងជំងឺរាតត្បាតកូវីដ-១៩។ លោកបានបន្ថែមទៀត៖ «ចាប់តាំងពីចុងឆ្នាំមុន យើងសង្កេតឃើញថាមានការកើនឡើងនៃចំនួនពលករចំណាកស្រុកកម្ពុជាដែលបានវិលត្រឡប់ទៅស្រុកកំណើតវិញ ជាពិសេសតាមរយៈព្រំដែនកម្ពុជា-ថៃ។ ទោះបីរាជរដ្ឋាភិបាលកម្ពុជាបានដោះស្រាយស្ថានការណ៍យ៉ាងមានប្រសិទ្ធិភាពក៏ដោយ ក៏ការគាំទ្របន្ថែមអាចជាជំនួយមួយផ្នែកដល់ការដោះស្រាយនេះផងដែរ»។

យោងតាមលោកឯកអគ្គរដ្ឋទូត ការបរិច្ចាគហិរញ្ញវត្ថុក៏ជានិមិត្តរូបនៃមិត្តភាពពិតប្រាកដ និងយូរអង្វែងរវាងប្រទេសជិតខាងទាំងពីរ ជាមួយនឹងការតភ្ជាប់ប្រជាជនទៅនឹងប្រជាជនដែលជាមូលដ្ឋានគ្រឹះនៃការកសាងមិត្តភាពផងដែរ។ ក្រសួងការបរទេសបានសម្តែងការកោតសរសើរចំពោះជំនួយ ដែលបានបន្តផ្តល់ដោយរដ្ឋាភិបាលថៃក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺរាតត្បាតកូវីដ-១៩ ក៏ដូចជាការជួយសម្រួលដល់ពលករចំណាកស្រុកដែលកំពុងធ្វើការ និងរស់នៅក្នុងប្រទេសថៃ។ ក្រសួងបាននិយាយថា៖ «អំណោយដ៏សប្បុរសនេះមិនត្រឹមតែឆ្លុះបញ្ចាំងពីកាយវិការមនុស្សធម៌ដ៏សប្បុរសប៉ុណ្ណោះទេ តែថែមទាំងបង្កើនស្មារតីមិត្តភាពប្រពៃណី សាមគ្គីភាព និងភាពជាអ្នកជិតខាងល្អរវាងប្រទេសផងដែរ»៕ ប្រែសម្រួលដោយ សៀវ គួយអ៊ី

## ធ្ងន់ធ្ងរណាស់! ពលករចំណាកស្រុកជិត៣០០នាក់ ក្នុងមណ្ឌលឃុំឃាំងជនអន្តោប្រវេសន៍ នៅថៃ ឆ្លងកូវីដ មានទាំងខ្មែរផងដែរ

https://www.kampucheathmey.com/ on March 23, 2021By Sok Sovann

មជ្ឈមណ្ឌលរដ្ឋបាលស្ថានភាពជំងឺកូវីដ១៩ (CCSA) កាលពីថ្ងៃចន្ទ បានរាយការណ៍ថា ពលករចំណាកស្រុកបរទេសជិត ៣០០នាក់ នៅឯមណ្ឌលឃុំឃាំងរបស់ការិយាល័យអន្តោប្រវេសន៍ក្នុងសង្កាត់ Suan Phlu និង Bang Khen បានឆ្លងជំងឺកូវីដ១៩។ អ្នកនាំពាក្យជំនួយការ CCSA លោកស្រី Apisamai Srirangson បាននិយាយថា ជនចំណាកស្រុកបរទេស ចំនួន៩៨នាក់ ក្នុងចំណោម ១,៨៨៨នាក់ នៅឯមណ្ឌលឃុំឃាំង ត្រូវបានធ្វើតេស្តវិជ្ជមានចាប់ពីថ្ងៃទី១១ ខែមីនា ដល់ថ្ងៃសៅរ៍សប្តាហ៍មុន។ នៅថ្ងៃសៅរ៍ មានករណីដែលត្រូវបានបញ្ជាក់ចំនួន ២៩៧ ករណីបន្ថែមទៀត ដែលភាគច្រើនបានចូលក្នុងប្រទេសដោយខុសច្បាប់។ លោកស្រីនិយាយថា ជនជាតិមីយ៉ាន់ម៉ា វៀតណាម និងកម្ពុជាស្ថិតក្នុងចំណោមអ្នកឆ្លងជំងឺ។ លោកស្រីបន្តថា មណ្ឌលទាំងអស់ ឈប់ទទួលយកអ្នកមកថ្មីហើយ។

ទោះបីជាយ៉ាងណាក៏ដោយ លោកស្រីបញ្ជាក់ថា មិនមានរបាយការណ៍ នៃការឆ្លងក្នុងចំណោមមន្ត្រីអន្តោប្រវេសន៍ទេ។ អ្នកជាប់ឃុំដែលឆ្លងរោគ ត្រូវបានបំបែកចេញពីអ្នកដទៃទៀត។ ក្រសួងសុខាភិបាល កំពុងពន្លឿនការចាក់វ៉ាក់សាំងសម្រាប់មន្ត្រីអន្តោប្រវេសន៍ ដែលមានទំនាក់ទំនងជាមួយពលករចំណាកស្រុកដែលជាប់ឃុំ។ មានជនអន្តោប្រវេសន៍ចំនួន ១,៦១៥នាក់ នៅឯមណ្ឌលឃុំឃាំងនានា ដែលពួកគេភាគច្រើនមកពីប្រទេសមីយ៉ាន់ម៉ា។

អគ្គស្នងការនគរបាលជាតិបាននិយាយថា អ្នកជាប់ឃុំដែលឆ្លងរោគ នឹងត្រូវបញ្ជូនទៅមន្ទីរពេទ្យមូលដ្ឋានដើម្បីព្យាបាល។ ស្នងការប៉ូលិសអន្តោប្រវេសន៍លោកឧត្តមសេនីយ៍ Sompong Chingduang បានទទួលស្គាល់ថា ស្ថានភាពចង្អៀតណែនតាន់តាប់របស់មណ្ឌល បានរួមចំណែកដល់ការឆ្លងក្នុងចំណោមអ្នកជាប់ឃុំ៕
ប្រែសម្រួលដោយ៖ Vann Vann ប្រភព៖ Bangkok Post

## ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១

## ប្រជាពលរដ្ឋខ្មែរត្រលប់ពីប្រទេសថៃតាមច្រកភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានចំនួន៣០,០៧៦នាក់

https://kohsantepheapdaily.com.kh/ Banteay Meanchey ២៣ ខែ មីនា ឆ្នាំ ២០២១ ម៉ោង ១៩:៣៩

ខេត្តបន្ទាយមានជ័យ ៖ ប្រត្តិការកូវីដ-១៩ ដែលប្រជាពលរដ្ឋខ្មែរត្រលប់ពីប្រទេសថៃចូលមកកម្ពុជាវិញតាមច្រកភូមិសាស្ត្រខេត្តបន្ទាយមានជ័យ មានចំនួន៣០,០៧៦នាក់ រហូតដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១។ ដោយយោងតាមរបាយការណ៍មន្ទីសុខាភិបាលខេត្តបន្ទាយមានជ័យក្នុងឱកាសប្រត្តិការកូវីដ-១៩ រហូតដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១នេះ ប្រជាពលរដ្ឋខ្មែរត្រលប់ពីប្រទេសថៃចូលមកម្ពុជាវិញតាមច្រកភូមិសាស្ត្រខេត្តបន្ទាយមានជ័យមានចំនួន៣០,០៧៦នាក់ ស្រី១៣,៤៦០នាក់។ ក្នុងនោះអ្នកដែលត្រូវបានយកសំណាកទៅវិភាគវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា មានចំនួន២៩,៤៨៨នាក់ ស្រី១៣,០៦៤នាក់ ប្រជាពលរដ្ឋត្រូវបានបញ្ជូនចេញតាមដាក់តាមមណ្ឌលស្រុកកំណើតមានចំនួន២៧,៣០៦នាក់ ស្រី១២,២២២នាក់ ប្រជាពលរដ្ឋដែលបានធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃមានចំនួន២០,៥៨៣នាក់ ស្រី៩,៤១៦នាក់ ហើយប្រជាពលរដ្ឋពលដែលកំពុងធ្វើចត្តាឡីស័កមានចំនួន២,៧៧០នាក់ ស្រី១,២៣៨នាក់។

របាយការណ៍រដ្ឋបាលស្រុកអូរជ្រៅរហូតដល់ល្ងាចថ្ងៃទី២២ ខែមីនា ឆ្នាំ២០២១ ប្រជាពលរដ្ឋដែលត្រលប់ពីប្រទេសថៃចូលមកកម្ពុជាវិញតាមច្រកអូរបើជាន់ស្រុកអូរជ្រៅមានចំនួន២៨៧នាក់ ស្រី១៣៣នាក់ បើប្រៀបធៀបកាលពីថ្ងៃទី២១ ខែមីនា ឆ្នាំ២០២១នេះមានចំនួន២៩៤នាក់ ស្រី១១៨នាក់។ ប្រជាពលរដ្ឋដែលត្រលប់ពីប្រទេស

ថៃចូលមកកម្ពុជាតាមច្រកអូរបីជាន់ចំនួន២៨៧នាក់ មានប្រជាពលរដ្ឋខេត្តបន្ទាយមានជ័យ៧៦នាក់ ខេត្តបាត់ដំបង២៧នាក់ ខេត្តកំពង់ចាម៧នាក់ ខេត្តកំពង់ឆ្នាំង៣នាក់ ខេត្តកំពង់ស្ពឺ១៤នាក់ ខេត្តកំពង់ធំ២០នាក់ ខេត្តកណ្ដាល១នាក់ ខេត្តព្រះវិហារ១នាក់ ខេត្តព្រៃវែង២១នាក់ ខេត្តពោធិ៍សាត់២១នាក់ ខេត្តរតនគីរី១នាក់ ខេត្តសៀមរាប៥៩នាក់ ខេត្តព្រះសីហនុ១នាក់ ខេត្តស្ទឹងត្រែង១នាក់ ខេត្តតាកែវ៤នាក់ ខេត្តឧត្តរមានជ័យ២នាក់ ខេត្តប៉ៃលិន២នាក់ ខេត្តត្បូងឃ្មុំ៤នាក់៕ ដោយ ៖ ប៊ុន ធឿន

## កម្លាំងជំនាញបង្ក្រាបករណីបង្ខាំងមនុស្សខុសច្បាប់ ឃាត់ខ្លួនជនសង្ស័យ២នាក់

http://cambodiapolice.com/policekh/ 3:55 pm 23 មីនា 2021

ព្រះវិហារ ៖ កម្លាំងជំនាញការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឃាត់ខ្លួនជនសង្ស័យចំនួន ០២នាក់ កាលពីថ្ងៃទី២២ ខែមីនា ឆ្នាំ ២០២១ ពាក់ព័ន្ធនឹងករណីបង្ខាំងមនុស្សដោយខុសច្បាប់ ។

ជនរងគ្រោះឈ្មោះ សួន ស្រីហៀង ភេទស្រី អាយុ២០ឆ្នាំ មុខរបររត់តុ រស់នៅភូមិឡូតជ្ជ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ។ ជងសង្ស័យមានឈ្មោះ យូ យឿន ហៅ ផល្លី ភេទស្រី អាយុ ៥២ឆ្នាំ មុខរបរ មេផ្ទះ រស់នៅឡូតជ្ជ សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ និងឈ្មោះ អិន ប៊ុននឿន ភេទប្រុស អាយុ២៧ឆ្នាំ មុខរបរ លក់ដូរ ត្រូវជាថៅកែហាងផឹកស៊ីឈ្មោះ លុច្ឆសារី «Beer» នៅក្នុងភូមិស្រះឈូក សង្កាត់កំពង់ប្រណាក ក្រុងព្រះវិហារ ខេត្តព្រះវិហារ ។

មុនឈានដល់ការឃាត់ខ្លួនជនសង្ស័យទាំង ០២នាក់ ខាងលើ សមត្ថកិច្ចបានទទួលពាក្យបណ្ដឹងពីជនរងគ្រោះឈ្មោះ សួន ស្រីហៀង ភេទស្រី អាយុ ២០ឆ្នាំ មុខរបររត់តុ ថា រូបនាងត្រូវបានថៅកែហាងរូបនេះ បង្ខាំងទុកក្នុងបន្ទប់ដោយចាក់សោរពីក្រៅ» ។ ក្រោយពីទទួលបានព័ត៌មានពីនារីរងគ្រោះរួច កម្លាំងជំនាញបានចុះទៅពិនិត្យមើលភ្លាមៗដល់ទីតាំងហាង ហើយក៏សុំឱ្យថៅកែហាងវ័យក្មេងរូបនេះ ដែលជាជនសង្ស័យ សហការបើកបន្ទប់ដែលបានចាក់សោពីក្រៅ ក៏បានប្រទះឃើញនារីវ័យក្មេងម្នាក់មានអាការៈស្លេកស្លាំង នៅក្នុងបន្ទប់ពិតប្រាកដមែន ។ ហេតុការនេះកើតឡើងដោយសារនារីរងគ្រោះសុំឈប់ធ្វើការនៅក្នុងហាង តែម្ចាស់ហាងនេះស្រឡាញ់នារីរងគ្រោះមិនឱ្យឈប់ទេ ក៏ចាក់សោរនារីរងគ្រោះក្នុងបន្ទប់តែម្ដងទៅ។ ជនសង្ស័យទាំង ០២នាក់ ខាងលើសមត្ថកិច្ច បានកសាងសំណុំរឿងបញ្ជូនទៅអយ្យការអមសាលាដំបូងខេត្តចាត់ការបន្តតាមនីតិវិធី ៕

## ពលករខ្មែរ១០នាក់ ឆ្លងជំងឺកូវីដ-១៩នៅក្នុងប្រទេសថៃ ខណៈលំហូរពលករចូលកម្ពុជាមានការកើនឡើង

https://www.rfi.fr/km/ ចុះផ្សាយនៅថ្ងៃ៖ 22/03/2021 - 07:42 ដោយ៖ ជួប នរក្សា

យ៉ាងហោចក៏មាន ពលករខ្មែរចំនួន១០នាក់ ដែលកំពុងធ្វើការនៅក្នុងខេត្តសាមុតប្រាកាន ត្រូវបានរកឃើញថាវិជ្ជមានកូវីដ-១៩ នៅក្នុងសហគមន៍ជាចង្កោមថ្មីនៅប្រទេសថៃ។ ខេត្តសាមុតប្រាកាន គឺជាខេត្តទី២ដែលផ្ទុះចេញនូវការឆ្លងជំងឺកូវីដ-១៩ លើពលករចំណាកស្រុកធ្វើការនៅប្រទេសថៃ បន្ទាប់ពីខេត្តសាមុតសាខន។ ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ទៅលើពលករខ្មែរ ស្របពេលដែល មានលំហូរពលករខ្មែរវិលត្រលប់មកកម្ពុជាវិញ ក៏មានការកើនឡើងកាន់តែច្រើនផងដែរ។ ពលករទេសន្តប្រវេសន៍ខ្មែរចំនួន១០នាក់ ក្នុងចំណោមពលករ១៦នាក់ ត្រូវបានអាជ្ញាធរថៃរកឃើញថាវិជ្ជមានកូវីដ-១៩។ ការរកឃើញវិជ្ជមានកូវីដ-១៩ បន្ទាប់ពីអាជ្ញាធរថៃបានយកសំណាកពលករប្រមាណជាង៦០០នាក់ ដែលធ្វើការនៅក្នុងការដ្ឋានសាងសង់ ក្នុងខេត្តសាមុតប្រាកាន។ បើតាមអាជ្ញាធរថៃ អាជ្ញាធរបានរកឃើញការផ្ទុះឆ្លងជំងឺកូវីដ-១៩នោះ ក្រោយពីការធ្វើតេស្តលើពលករភូមាម្នាក់ កាលពីថ្ងៃទី១៣ មីនា ជាមួយនឹងលទ្ធផលវិជ្ជមានកូវីដ-១៩។ ជាបន្តបន្ទាប់ក៏មានការរាលដាលដល់

ពលករភូមា២នាក់ និងថៃ៤នាក់ បន្ថែមទៀត។ នេះបើតាមការសេតក្នុងស្រុកថៃ បាងកកប៉ុស្ត៍ ចេញផ្សាយនៅថ្ងៃចន្ទ នេះ។

លោក លឹង សុផុន មន្ត្រីទទួលបន្ទុកកិច្ចការអន្តោប្រវេសន៍ នៃមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស(Central) បានថ្លែងពីខេត្តឈុនបុរី នៃប្រទេសថៃមកថា ពលករខ្មែរទាំងនោះ ត្រូវបានអាជ្ញាធរថៃដាក់នៅកន្លែងមួយ ដើម្បីព្យាបាលពួកគេ ដោយផ្អែកលើគោលការណ៍ថ្មីរបស់រដ្ឋាភិបាលថៃ។ លោកបានបញ្ជាក់បន្ថែមដែរថា មួយរយៈពេលនេះ ពលករខ្មែរមួយចំនួននៅតែបន្តលួចឆ្លងដែនមកកម្ពុជាវិញជារឿយៗ ខណៈថៃកំពុងរឹតបន្តឹងច្បាប់ប្រទេសរបស់គេ។ តាមលោក លឹង សុផុន ពលករខ្មែរមួយចំនួនព្យាយាមទាក់ទងមេខ្យល់ និងរកមធ្យោបាយគ្រប់បែបយ៉ាង ដើម្បីអាចចូលមកកម្ពុជាវិញ។

នៅចំពោះមុខបញ្ហាលំហូរពលករចូលមកកម្ពុជាវិញនេះ លោក ឌី រ៉ាដូ អភិបាលរងខេត្តឧត្តរមានជ័យ បានប្រាប់វិទ្យុបារាំងអន្តរជាតិ នៅថ្ងៃនេះដែរថា លំហូរពលករខ្មែរចូលមកកម្ពុជាវិញ តាមច្រកទ្វារអន្តរជាតិអូរស្មាច់ មានការកើនឡើងគួរឲ្យកត់សម្គាល់ ដោយមួយរយៈនេះ ក្នុងមួយថ្ងៃមានពលករខ្មែរប្រមាណពី៣០០ទៅ៤០០នាក់ចូលមកកម្ពុជាវិញជាប្រចាំ ខុសពីមួយរយៈមុន ដែលមានពលករ ប្រមាណ១០០នាក់ចូលមកក្នុង១ថ្ងៃ។ ជាការកត់សម្គាល់លោកថា លំហូរនៃពលករខ្មែរ មានការកើនឡើងនេះ ក៏ដោយសារតែកៀកនឹងពិធីបុណ្យចូលឆ្នាំប្រពៃណីខ្មែរ ដែលនឹងធ្វើឡើងនៅពាក់កណ្ដាលខែមេសាខាងមុខនេះ។ ហេតុនេះទើបពលករខ្មែរសម្រុកមកវិញ ដើម្បីជួបជុំក្រុមគ្រួសារ។ បើតាមលោក ឌី រ៉ាដូ អាជ្ញាធរនៅតែបន្តប្រុងជើងការទប់ស្កាត់ការចម្លងជំងឺកូវីដ១៩ នៅទន្ទឹមនឹងលំហូរពលករកំពុងមានការកើនឡើង ដោយពលករទាំងអស់ត្រូវតម្រូវឲ្យធ្វើចត្តាឡីស័កពេលមកដល់កម្ពុជាវិញ ហើយអាជ្ញាធរខេត្តក៏ត្រៀមទីតាំងពហុកីឡាដ្ឋានខេត្តសម្រាប់ធ្វើជាមណ្ឌលចត្តាឡីស័កក្នុងលក្ខខ័ណ្ឌ ដែលលំហូរពលករខ្មែរសម្រុកមកកម្ពុជាកាន់តែច្រើន នៅអំឡុងបុណ្យចូលឆ្នាំខ្មែរខាងមុខ៕

## ការនាំពលករលួចឆ្លងដែនទៅថៃ ពីសំណាក់ពួកមេខ្យល់ តាមច្រកខេត្តប៉ៃលិននៅតែមាន

https://news.btv.com.kh/ 03/24/2021 07:03 PM

ប៉ៃលិន៖ ទោះបីរាជរដ្ឋាភិបាលបានខិតខំទប់ស្កាត់ និងធ្លាប់មានការដាក់ទោសទណ្ឌ ចំពោះមន្ត្រី លួចដោះលែងពួកមេខ្យល់ដោយចិត្តឯង ពាក់ព័ន្ធការនាំពលករលួចឆ្លងដែន អំឡុងនៃការឆ្លងរីករាលដាលជំងឺកូវីដ១៩ តែរហូតមកដល់ពេលនេះ សកម្មភាពនាំពលករលួចឆ្លងដោយខុសច្បាប់នេះ តាមច្រករបៀងនានា ស្ថិតក្នុងភូមិសាស្ត្រខេត្តប៉ៃលិន នៅតែបន្តកើតមាន។ ដោយសកម្មភាពនាំពលករលួចឆ្លងដែន ទៅរកការងារធ្វើនៅប្រទេសថៃនោះភាគច្រើនធ្វើឡើងនៅពេលយប់ជ្រៅ ស្ថិតក្នុងភូមិសាស្ត្រឃុំស្ទឹងកាច់ ស្រុកសាលាក្រៅ ខេត្តប៉ៃលិន ខណៈក៏មានការបើកដៃពីមន្ត្រីមូលដ្ឋាន ។

យោងតាមប្រភពច្បាស់ការមួយ បានឲ្យដឹងថា ការនាំពលករលួចឆ្លងដែននោះ ពួកមេខ្យល់បានប្រមូលពលករពីបណ្ដាខេត្តផ្សេងៗ ទៅលាក់ខ្លួននៅផ្ទះមេខ្យល់ ហើយយប់ឡើងទើបនាំលួចឆ្លងដែន។ ប្រភពបន្តថា ចំពោះការចាប់ខ្លួនពួកមេខ្យល់អំឡុង នៃវិបត្តិជំងឺកូវីដ១៩ កន្លងមកចាប់បាន២ទៅ៣នាក់រួចហើយ ដោយបញ្ជូនទៅតុលាការចាត់ការតាមនីតិវិធីច្បាប់ ប៉ុន្តែមានករណីកាលពីយប់ថ្ងៃទី២០ ខែមិនា ឆ្នាំ២០២១ លោក មាឃ សារ៉ន អធិការស្រុកសាលាក្រៅ ដឹកនាំប៉ុស្តិ៍រដ្ឋបាលឃុំស្ទឹងកាច់ ឃាត់ខ្លួនមនុស្សចំនួន៧នាក់ បម្រុងលួចឆ្លងដែន នៅចំណុចក្រោយទ្រុងជ្រូកចាស់ ស្ថិតក្នុងភូមិអូរឈើក្រំ ឃុំស្ទឹងកាច់។ ប្រភពបន្ថែមថា បន្ទាប់ពីឃាត់ខ្លួនបានហើយនោះ លោកអធិការស្រុកបានធ្វើការណែនាំអប់រំដល់ពលករទាំងអស់នោះ និងធ្វើកិច្ចសន្យាឲ្យត្រឡប់ទៅផ្ទះវិញ មិនបានធ្វើចត្តាឡីស័កនោះទេ ប៉ុន្តែក្នុងចំណោមទាំង៧នាក់នេះ មានម្នាក់ជាមេខ្យល់ គឺលោក មាឃ សារ៉ន អធិការស្រុកសាលាក្រៅ និងប៉ុស្តិ៍រដ្ឋបាលឃុំស្ទឹងកាច់ មិនអនុវត្តតាមច្បាប់លើមេខ្យល់នោះ ។

ពាក់ព័ន្ធនឹងបញ្ហានេះ បើតាមលោក ស៊ឹម សុផល មេប៉ុស្តិ៍រដ្ឋបាលឃុំស្ទឹងកាច់ បានឲ្យដឹងថា កន្លងមកតែងមានសកម្មភាពការនាំពលករលួចឆ្លងដែន ហើយកម្លាំងការពារព្រំដែន គឺបានឃាត់ខ្លួនជាបន្តបន្ទាប់ រួមទាំងធ្វើការអប់រំណែនាំ ហើយធ្វើកិច្ចសន្យាឲ្យត្រឡប់ទៅផ្ទះវិញ ។ លោកបានបញ្ជាក់ថា ជាមួយការឃាត់ខ្លួនពលករនេះ ក៏ចាប់បានពួកមេខ្យល់បញ្ជូនទៅតុលាការផងដែរ ហើយចំពោះករណីកាលពីយប់ថ្ងៃទី២០ ខែមិនានោះ មានការឃាត់ខ្លួនពលករធ្វើកិច្ចសន្យាឲ្យពួកគេទៅផ្ទះពិតមែន ប៉ុន្តែសូមប្រានចោលការចោទថា បានដោះលែងមេខ្យល់ គឺមិនមាននោះទេ៕ អត្ថបទ៖ យន់ វ៉ាន់

## អាជ្ញាធរបញ្ជូនពលរដ្ឋចូលពីថៃចំនួន៤នាក់ទៅមណ្ឌលចត្តាឡីស័ក

http://ppt-news.net/ ចេញផ្សាយ ថ្ងៃទី 23/03/2021

ខេត្តបាត់ដំបង ៖ តាមការណែនាំ របស់លោកឧត្តមសេនីយ៍ទោ សាតគឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង លោកវរសេនីយ៍ឯក ពៅ ថារុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ កាលពីម្សិលមិញ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ៩ សហការជាមួយ កម្លាំងយោធាវរសេនាតូច៥៣៣, កម្លាំងសឹករងស្រុកសំពៅលូន ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ចំនួន ៤ នាក់ , ស្រី ១ នាក់ ក្នុងនោះ ក្មេងប្រុស១ នាក់ និងក្មេងស្រី ១ នាក់ ពីចំណុចភូមិគីឡូ៩ ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង និងនៅចំណុចភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ខេត្តបាត់ដំបង ចំនួន ១ នាក់ សរុបទាំងពីរទីតាំង ៥នាក់ ស្រី១នាក់ ។

បន្ទាប់ពីធ្វើការសាកសួររួចក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងយើងបានប្រគល់ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២តាមការណែនាំរបស់ក្រសួងសុខាភិបាល៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃពុធ ទី២៤ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ២៤៦នាក់ ស្រី ៩៥នាក់ ក្នុងនោះកុមារា ២៩នាក់ កុមារី ១១នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១៤នាក់ ស្រី ៤នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១៨៨នាក់ ស្រី ៧៤នាក់ កុមារា ២៨នាក់ កុមារី ១១នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ៤៤នាក់ ស្រី ១៧នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ២៤៦នាក់ ស្រី ៩៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក

នៅសៀមរាប ក្នុងថ្ងៃនេះ ចំនួន ២៤៦នាក់ ស្រី ៩៥នាក់ ត្រូវបានបញ្ជូនទៅខេត្តសៀមរាបរួចហើយ ។ ដោយៈ មន្ទីរព័ត៌មានខេត្តសៀមរាប

## ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១

## ក្មេងស្រីរងគ្រោះជនជាតិខ្មែរ០៣នាក់មេខ្យល់ឆបោកក្រោមរូបភាព យកទៅរៀបការជាមួយជនជាតិចិន បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញហើយ!

http://cambodiapolice.com/policekh/ 12:05 pm 25 មីនា 2021

រាជធានីភ្នំពេញ ៖ ក្មេងស្រីរងគ្រោះជនជាតិខ្មែរចំនួន០៣នាក់ ដែលត្រូវបានមេខ្យល់ឆបោកទៅប្រទេសចិន បានត្រឡប់មកដល់ប្រទេសកម្ពុជាវិញកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង ២៣:១៥នាទីយប់ ជើងយន្តហោះលេខ.MU759 តាមច្រកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ នេះបើតាមការឲ្យដឹងពី ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ ។ ក្មេងស្រីរងគ្រោះមានឈ្មោះ ៖ ទី១. យ៉េន សុជាតា ទី២.សុខ ណា និងទី៣. សៀន ស្រីណុច មានទីលំនៅ ស្រុកតំបែ ខេត្តត្បូងឃ្មុំ ។ បច្ចុប្បន្នក្មេងស្រីរងគ្រោះខាងលើ បាននិងកំពុងអនុវត្តវិធានចត្តាឡីស័ករយៈពេល ១៤ថ្ងៃ នៅមណ្ឌលចត្តាឡីស័កវិទ្យាល័យពោធិចិនតុង រាជធានីភ្នំពេញ ។

សូមរំលឹកផងដែរថា កាលពីថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០២០ ម្ចាស់គណនីហ្វេសប៊ុកឈ្មោះ Ny Ka Met Ma បានផ្ញើសារចូលក្នុងប្រអប់សារគេហទំព័ររបស់ក្រុមប្រតិកម្មរហ័សនៃអគ្គស្នងការដ្ឋាននគរបាលជាតិឈ្មោះ "ការពិតជា GCNP" ដោយសំណូមពរឲ្យអាជ្ញាធរជួយអន្តរាគមន៍សង្គ្រោះនាងមកកម្ពុជាវិញ ដោយពុំអាចស៊ូទ្រាំនឹងការធ្វើទារុណកម្ម អាហារហូបចុកមិនគ្រប់គ្រាន់ និងបង្ខាំងគ្មានសេរីភាព ព្រមទាំងគំរាមសម្លាប់" ។ បន្ទាប់មានការឯកភាពពី ឯកឧត្តម នាយឧត្តមសេនីយ៍ សន្តិបណ្ឌិត នេត សាវឿន អគ្គស្នងការនគរបាលជាតិ ករណីនេះត្រូវបានបញ្ជូនមកនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ដើម្បីជាសមត្ថកិច្ចអន្តរាគមន៍ដោះស្រាយ ។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី បញ្ជាក់ថា បន្ទាប់ពីទទួលបានបទបញ្ជាពីថ្នាក់ដឹកនាំ ជំនាញនៃនាយកដ្ឋានបានធ្វើការទំនាក់ទំនងសម្របសម្រួលជាមួយឪពុកមាជនរងគ្រោះឲ្យមកដាក់ពាក្យបណ្តឹងនៅក្រសួងមហាផ្ទៃ ដើម្បីឲ្យសមត្ថកិច្ចមានមូលដ្ឋានអនុវត្តគោលការណ៍ជំនាញ និងនីតិវិធី ។ ជាមួយគ្នានោះជំនាញបានធ្វើការទំនាក់ទំនងជាមួយជនរងគ្រោះនៅប្រទេសចិនតាមប្រព័ន្ធ Facebook Messenger ដើម្បីទទួលបានព័ត៌មានលម្អិតក្នុងការកំណត់គោលដៅសង្គ្រោះ ។ នៅថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០២០ នាយកដ្ឋាន បានប្រមូលព័ត៌មានគ្រប់ជ្រុងជ្រោយពីជនរងគ្រោះ និងបានផ្ញើជូនទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងធ្វើការបន្តជាមួយស្ថានទូតនិងអគ្គកុងស៊ុលកម្ពុជាប្រចាំប្រទេសចិន ដើម្បីធ្វើកិច្ចសហប្រតិបត្តិការស្រាវជ្រាវ ។ ក្រោមកិច្ចសហប្រតិបត្តិការល្អរវាងអាជ្ញាធរចិន និងសមត្ថកិច្ចពាក់ព័ន្ធរបស់កម្ពុជា បានស្រាវជ្រាវស្វែងរកឃើញកន្លែងស្នាក់នៅរបស់ក្មេងស្រីរងគ្រោះខាងលើ គឺនៅខេត្តជាំងស៊ី ក្រុងណានឆាង ប្រទេសចិន និងបានសម្របសម្រួលអនុវត្តគោលការណ៍ជំនាញនិងនីតិវិធីនៃប្រទេសទាំងពីរ កម្ពុជា-ចិន ដើម្បីបញ្ជូនជនរងគ្រោះត្រឡប់មកប្រទេសកម្ពុជាវិញ ។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី ថ្លែងថា សូមឲ្យក្រុមគ្រួសារនារីរងគ្រោះ មេត្តាយោគយល់អធ្យាស្រ័យចំពោះភាពយឺតយ៉ាវក្នុងការបញ្ជូននារីរងគ្រោះមកកម្ពុជាវិញ ហើយភាពយឺតយ៉ាវនេះបណ្តាលមកពីតម្រូវការអនុវត្តនីតិវិធីក្នុងការចាត់បញ្ជូនជនរងគ្រោះ រួមជាមួយនឹងការអនុវត្តវិធានចត្តាឡីស័កនៅប្រទេសចិនផងដែរ ។ ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា តាមការស្រាវជ្រាវរបស់អាជ្ញាធរ និងសមត្ថកិច្ចជំនាញរកឃើញស្ត្រីរងគ្រោះជនជាតិខ្មែរសរុបចំនួន ០៤នាក់ត្រូវបានជួយសង្គ្រោះក្នុងប្រតិបត្តិការខាងលើ ប៉ុន្តែអាចបំពេញបែបបទបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញបានចំនួន ៣នាក់ ប៉ុណ្ណោះ ដោយសារតែ ជនរងគ្រោះឈ្មោះ យ៉េន គី អាយុ១៦ ឆ្នាំកំពុងមានផ្ទៃ

ពោះប្រហែល ៨ ខែ មិនអាចជិះយន្តហោះត្រឡប់មកកម្ពុជាវិញបានទេ ដោយរង់ចាំនីតិវិធីបន្ត ។ ឯកឧត្តម ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានឲ្យដឹងទៀតថា ពាក់ព័ន្ធករណីជួញដូរមនុស្សដោយខុសច្បាប់ទៅកាន់ប្រទេសចិនពាក់ព័ន្ធជាមួយនារីរងគ្រោះខាងលើ សមត្ថកិច្ចបាន ឃាត់ខ្លួនមុខសញ្ញាជាមេខ្យល់ឈ្មោះ ស្រេង សិត ភេទស្រី អាយុ ៣៦ ឆ្នាំរស់នៅភូមិឈើទាលជ្រុំ ឃុំគោកស្រុក ស្រុកតំបែ ខេត្តត្បូងឃ្មុំ ដែលបាននាំជនរងគ្រោះឈ្មោះ យ៉េន សុជាតា ទៅប្រទេសចិន បង្ខំអោយរៀបអាពាហ៍ពិពាហ៍ផ្ទុយពីឆន្ទៈ។ ហើយជនត្រូវចោទខាងលើ ត្រូវបានសាលាដំបូងខេត្តត្បូងឃ្មុំសម្រេចបង្គាប់ឲ្យឃុំខ្លួននៅពន្ធនាគារខេត្ត ។

ឧត្តមសេនីយ៍ឯក ជីវ ផល្លី បានបញ្ជាក់បន្ថែមថា ក្នុងនាមថ្នាក់ដឹកនាំអគ្គស្នងការដ្ឋាននគរបាលជាតិ និងក្នុងនាមនាយកដ្ឋានជំនាញ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងស្ថានទូតព្រះរាជាណាចក្រកម្ពុជាប្រចាំសាធារណរដ្ឋប្រជាមានិតចិន ក៏ដូចជាអាជ្ញាធរចិន ដែលតែងតែយកចិត្តទុកដាក់ និងគាំទ្រដោះស្រាយគ្រប់សំណូមពររបស់នាយកដ្ឋានជំនាញ ទទួលបានជោគជ័យជាបន្តបន្ទាប់ និងពិសេសសូមអរគុណចំពោះសាធារណជន អ្នកសារព័ត៌មាន បណ្តាញទំនាក់ទំនងសង្គមដែលតែងតែចូលរួមចំណែកក្នុងកិច្ចការងាររក្សាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម និងក៏ដូចជាការចូលរួមចំណែកស្វែងរកយុត្តិធម៌សង្គម ៕

## នាំខ្លួនពលករខ្មែរ១៩នាក់ឆ្លងចូលពីប្រទេសថៃយកទៅធ្វើចត្តាឡីស័ក

https://www.kampucheathmey.com/ on March 25, 2021By Sokhom Khon

ពលករខ្មែរ១៩នាក់ ដែលបានត្រឡប់ពីប្រទេសថៃចូលតាមច្រករបៀងក្នុងស្រុកសំពៅលូនត្រូវបានកម្លាំងសមត្ថកិច្ចចម្រុះប្រចាំតំបន់ព្រំដែនទទួលយកទៅឲ្យធ្វើចត្តាឡីស័ករយៈពេល១៤ថ្ងៃក្នុងភូមិសាស្ត្រស្រុកសំពៅលូន។ សមត្ថកិច្ចគោលដៅស្រុកសំពៅលូនបានប្រាប់ឲ្យដឹងថា ដើម្បីអនុវត្តតាមវិធានការផ្លូវច្បាប់ពាក់ព័ន្ធនិងការទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ កម្លាំងប៉ុស្តិ៍នគរបាលព្រំដែនគីឡូលេខ៩ សហការជាមួយកម្លាំងយោធាវរសេនាតូច៥៣៣រួមជាមួយកម្លាំងចម្រុះជាច្រើនទៀតនៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២១នេះ បានចុះនាំខ្លួនប្រជាពលរដ្ឋជាពលករខ្មែរប្រុសស្រីរួមទាំងក្មេងផងដែរសរុបចំនួន១៩នាក់ ដែលវិលត្រឡប់មកពីប្រទេសថៃវិញដោយឆ្លងដែនតាមផ្លូវកាត់ច្រករបៀងប្រុងមិនចូលធ្វើចត្តាឡីស័កតាមការណែនាំរបស់រាជរដ្ឋាភិបាល។

ប្រភពខាងលើបន្តថា ប្រជាពលករទាំង១៩នាក់ខាងលើក្នុងនោះមានបុរសពេញវ័យចំនួន៥នាក់ស្ត្រីចំនួន៥នាក់និងក្មេងប្រុសក្មេងស្រីចំនួន៩នាក់ទៀត។ អ្នកទាំងអស់គ្នាបានឆ្លងដែនចេញពីប្រទេសថៃហើយចូលមកទឹកដីប្រទេសកំណើតកាត់តាមចំណុចភូមិសាស្ត្រ ភូមិរស្មីភូមិស្ពានយោលក្នុងឃុំជ្រៃសីមានិងកាត់តាមភូមិសាស្ត្រភូមិគីឡូលេខ១៣ក្នុងឃុំសន្តិភាពស្រុកសំពៅលូនខេត្តបាត់ដំបង។ សមត្ថកិច្ចបានបញ្ជាក់បន្ថែមថា ក្រោយកម្លាំងសមត្ថកិច្ចចម្រុះធ្វើការឃាត់ខ្លួនពលករទាំងអស់កម្លាំងជំនាញបានសាកសួរធ្វើនិងធ្វើកំណត់ហេតុរួចណែនាំអប់រំនិងឲ្យផ្តិតមេដៃសន្យាឈប់ប្រព្រឹត្តហើយប្រគល់ទៅឲ្យក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កអនុវត្តតាមវិធានសុខាភិបាលនៅអនុវិទ្យាល័យកូនភ្នំ៣២ក្នុងស្រុកសំពៅលូនខេត្តបាត់ដំបង៕ អត្ថបទ ៖ សៅ សារិទ្ធ

## តាមមណ្ឌលចត្តាឡីស័ក នៅបាត់ដំបង ចាប់ផ្ដើមធូរស្រាល ខណៈពលករត្រឡប់ពីថៃថយចុះ

https://news.btv.com.kh/ 03/25/2021 05:03 PM

បាត់ដំបង៖ នារយៈពេលប៉ុន្មានថ្ងៃនេះការត្រឡប់ពីប្រទេសថៃ របស់ពលករមានទីលំនៅក្នុងខេត្តបាត់ដំបង មានការថយចុះជាបន្តបន្ទាប់ ដែលស្ថានភាពបែបនេះ បានធ្វើឲ្យមណ្ឌលចត្តាឡីស័កនានា នៅក្នុងខេត្តមានការធូរស្បើយ ខណៈអាជ្ញាធរខេត្តបាត់ដំបង និងខេត្តចាន់បុរី បានបើកដំណើរការឡើងវិញ នូវច្រកព្រំដែនថ្នាក់តំបន់ចំនួន ២នោះ ។

បើតាមលោក សុខ ហឿន អភិបាលស្រុកសង្កែ បានឲ្យដឹងថា ចាប់ពីពេលមានប្រកាសរបស់សម្ដេចតេជោនាយករដ្ឋមន្ត្រី តម្រូវឲ្យពលករទើបត្រឡប់មកពីថៃ អាចធ្វើចត្តាឡីស័កនៅស្រុកកំណើត ឬជិតលំនៅដ្ឋានរបស់ខ្លួននោះ គឺពេលភ្លាមៗ មានពលកររស់នៅស្រុកសង្កែត្រូវបានបញ្ជូនពីព្រំដែនមានជិត ២០០នាក់ ដែលតម្រូវឲ្យអាជ្ញាធរបង្កើនមណ្ឌលចត្តាឡីស័ក ដល់២កន្លែង ។ លោកបានបន្តថា នារយៈពេលប៉ុន្មានថ្ងៃនេះ គឺមានភាពធូរស្រាលដោយពលករទើបមកពីថៃមានតិចតួច និងបញ្ចប់ការធ្វើចត្តាឡីស័ក ត្រឡប់ទៅផ្ទះវិញជាបន្តបន្ទាប់ ប៉ុន្តែក៏មានពលរដ្ឋពាក់ព័ន្ធនឹងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ទើបត្រឡប់មកពីរាជធានីខេត្តមួយចំនួន កំពុងធ្វើចត្តាឡីស័កនៅទីនេះ រួមទាំង មានជនបរទេសផងដែរ ដោយពួកគេក៏ត្រូវបានយកចិត្តទុកដាក់ ក្នុងការពិនិត្យសុខភាព យកសំណាករកជំងឺកូវីដ១៩ ការផ្ដល់អាហារ និងការពារសុខសុវត្ថិភាព ។

យោងតាមរបាយការណ៍រដ្ឋបាលខេត្តបាត់ដំបង បានបង្ហាញថា បច្ចុប្បន្នពលករកំពុងធ្វើចត្តាឡីស័កតាមមណ្ឌលនានាក្នុងខេត្តបាត់ដំបងចំនួន ១៨៨១នាក់ បានកំណត់មុខសញ្ញាពាក់ព័ន្ធក្នុងងព្រឹត្តិការណ៍២០កុម្ភៈ ចំនួន ១៧១នាក់ យកចំណាក ១៧១នាក់ អវិជ្ជមាន ១៧០នាក់ លទ្ធផលវិជ្ជមាន្នាក់ ខណៈអ្នកបានចាក់វ៉ាក់សាំងលើកទី ១ ចំនួន ៦ ២៦១នាក់ និងលើកទី២ ចំនួន ២ ៥៦០នាក់ ។ បាន សុខរិទ្ធ

## អាជ្ញាធរខេត្ត នៅតែបង្កើនការប្រុងប្រយ័ត្នខ្ពស់ចំពោះពលករឆ្លងដែន ខណៈកូវីដ-១៩ ផ្ទុះឡើងខ្លាំងក្នុងសហគមន៍

https://news.btv.com.kh/ 03/25/2021 05:03 PM

ឧត្តរមានជ័យ ៖ ឯកឧត្តម ប៉ែន កុសល្យ អភិបាលខេត្តឧត្តរមានជ័យ ប្រធានគណៈកម្មការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ ខេត្ត បានបន្តបង្កើនការប្រុងប្រយ័ត្នខ្ពស់បន្ថែមទៀតចំពោះពលករឆ្លងដែនមកពីប្រទេសថៃ ខណៈដែលកម្ពុជាកំពុងផ្ទុះឡើងខ្លាំងនូវជំងឺកូវីដ-១៩ ក្នុងសហគមន៍ ២០កុម្ភៈ នៅតែបន្តកើនឡើងនោះ នៅព្រឹកថ្ងៃទី២៥ មីនានេះ។ ឯកឧត្តម អភិបាលខេត្តបានបន្ត ថាបច្ចុប្បន្ននេះស្ថានភាពពលករឆ្លងដែនមកពីប្រទេសថៃឆ្លងតាមច្រកអូរស្មាច់ និងច្រកជាំសាង៉ាំ ហាក់បីដូចជាមានសភាពធូរស្រាលខ្លះៗហើយ មិនមានកំណើនកើនឡើងច្រើនដូចកាលពីមុននោះទេ បញ្ហានេះ ដោយសារតែពលករមួយចំនួនដែលឆ្លងមកកម្ពុជាតាមច្រកសំខាន់ៗ ក្នុងភូមិសាស្ត្រខេត្តឧត្តរមានជ័យ បានធ្វើការសម្រួលទៅតាមខេត្តគោលដៅរបស់ខ្លួន ដើម្បីពិនិត្យនឹងធ្វើចត្តាឡីស័ក បន្តនៅខេត្តសាមីរបស់ខ្លួននោះវិញ កត្តាទាំងអស់នោះហើយធ្វើឲ្យខេត្តជាប់ព្រំដែនមានសភាពធូរស្រាលជាងមុន។

ឯកឧត្តម បានបញ្ជាក់ថា ប៉ុន្តែទោះបីជាស្ថានភាពពលករឆ្លងដែនបច្ចុប្បន្នមានសភាពធូរស្រាលជាងមុនយ៉ាងណាក្តី ក៏អាជ្ញាធរខេត្តរួមទាំងមន្ត្រីចត្តាឡីស័ក ជួរមុខទាំងអស់នៅតែបន្តធ្វើការរិតបន្តឹងយ៉ាងតឹង រ៉ឹងម៉ត់ចត់បំផុតក្នុងការពិនិត្យសុខភាពនឹងផ្សព្វផ្សាយព័ត៌មានផ្សេងៗពាក់ព័ន្ធនឹងជំងឺកូវីដ-១៩ ដល់ពលករគ្រប់ៗគ្នា ស្តីពីវិធានការ ការពារ ៣កុំ ៣ការពារ ដល់ពលករទាំងអស់គ្រប់រូប គ្រប់ពេលវេលាមុននឹងឲ្យពួកគាត់ធ្វើដំណើរបែងចែកគ្នាទៅតាមរថយន្តកងទ័ពតាមខេត្តគោលដៅរបស់ខ្លួនវិញនោះ ដោយមិនមានការធ្វេសប្រហែសដោយប្រការណា

មួយនោះឡើយ។ដោយឡែកបច្ចុប្បន្ននេះ ពលករដែលកំពុងស្នាក់នៅតាមមណ្ឌលធ្វើចត្តាឡីស័ក មានចំនួនតែ ៤៦៩នាក់តែប៉ុណ្ណោះ៕ អត្ថបទ ៖ ឃិនសារិទ្ធ

## អង្គការផ្លែនសហការជាមួយក្រសួងអប់រំរៀបចំវេទិកាស្ដីពីការអប់រំកុមារចំណាកស្រុក

https://www.postkhmer.com/ វ៉ន ដារ៉ា | Publication date 25 March 2021 | 16:28 ICT

**ភ្នំពេញៈ** អង្គការផ្លែនអន្តរជាតិកម្ពុជាសហការជាមួយក្រសួងអប់រំ អង្គការដៃគូ និងក្រុមបណ្ដាញកុមារ និងយុវជនរៀបចំកម្មវិធីវេទិកាកុមារ និងយុវជនថ្នាក់ក្រោមជាតិស្ដីពី«ការទទួលបានការអប់រំរបស់កុមារដែលធ្វើចំណាកស្រុក» ក្រោយពីរកឃើញថា កុមារកម្ពុជានៅពេលត្រឡប់ពីចំណាកស្រុកនៅប្រទេសថៃវិញ មានការលំបាកក្នុងការបន្តការសិស្សា។

លោក ឈឹម ផាន់ណា អ្នកឯកទេសកិច្ចការពារកុមារនៃអង្គការផ្លែនអន្តរជាតិកម្ពុជា ថ្លែងប្រាប់ ភ្នំពេញ ប៉ុស្ដិ៍ នៅថ្ងៃទី ២១ ខែមីនាថា វេទិកានេះមានគោលបំណងលើកកម្ពស់ការយកចិត្តទុកដាក់ពីអ្នកពាក់ព័ន្ធលើបញ្ហាចំណាកស្រុករបស់ឪពុកម្ដាយដែលនាំឱ្យមានការលំបាកដល់កូនៗក្នុងបន្ទុកជាពិសេសការសិក្សារបស់កូនៗ និងជំរុញឱ្យមានការយកចិត្តទុកដាក់លើសេវានានា ជួយដល់កុមារដែលបានចំណាកស្រុកជាពិសេសការទទួលបានការអប់រំពេញលេញនៅគ្រប់ទីកន្លែង។ លោកថ្លែងថា៖«តាមរយៈវេទិកានេះបានជំរុញលើការអនុវត្តសាកល្បងនៃការបង្រៀនពីចម្ងាយលើផ្នែកភាសាខ្មែរសម្រាប់កុមារក្នុងស្រុកក្លងយ៉ៃពីសាលាគោលដៅក្នុងស្រុកមណ្ឌលសីមា ខេត្តកោះកុង ដោយមានការគាំទ្របច្ចេកទេសពីក្រុមការងារបច្ចេកទេសរបស់គម្រោងដែលបានសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា អង្គការផ្លែនអន្តរជាតិ និងអង្គការ Cambodia Acts»។ លោកឱ្យដឹងថា បច្ចុប្បន្នវេទិកានេះទើបចាប់ផ្ដើមធ្វើដោយមានការសម្របសម្រួលពីអង្គការដៃគូរបស់អង្គការផ្លែនអន្តរជាតិកម្ពុជាដូចជាអង្គការCambodia Acts អង្គការ Banteay Srei អង្គការ CRC-Cambodia ជាមួយបណ្ដាញកុមារថ្នាក់ជាតិ Child Advocate Network (CAN) ដឹកនាំសម្របសម្រួលជាមួយក្រុមបណ្ដាញកុមារនៅថ្នាក់ខេត្ត ដូចជាខេត្តសៀមរាប និងខេត្តបាត់ដំបង ដែលជាខេត្តគោលដៅនៃគម្រោង។

បើតាមអង្គការផ្លែនអន្តរជាតិកម្ពុជា និងអង្គការផ្លែនអន្តរជាតិថៃឡង់ បានអនុវត្តរួមគ្នាលើគម្រោងស្ដីពីការបញ្ឈប់ការកេងប្រវ័ញ្ចតាមរយៈការពង្រឹងសេវាកម្មឆ្លើយតប ដែលសមស្របដោយមានការគាំទ្រថវិកាពីប្រទេសស៊ុយអែតរយៈពេល ៣ ឆ្នាំ ដែលបានបញ្ចប់កាលពីឆ្នាំ ២០២០។ តាមរយៈគម្រោងនេះកាលពីចុងឆ្នាំ ២០២០ អង្គការក្នុងស្រុកមួយនៃប្រទេសថៃឈ្មោះថា FRY ដែលជាអង្គការដៃគូជាមួយអង្គការផ្លែនអន្តរជាតិថៃឡង់បានដឹកនាំធ្វើការសិក្សាស្រាវជ្រាវស្ដីពីការសិក្សារបស់កុមារកម្ពុជា ដែលបានធ្វើចំណាកស្រុកទៅប្រទេសថៃជាមួយឪពុកម្ដាយ និងខ្លះបានកើតនៅទីនោះផងដែរ។ តាមរយៈការសិក្សានេះបានរកឃើញថា មានកុមារកម្ពុជាចំនួន ១ ៣២២ នាក់កំពុងសិក្សានៅប្រទេសថៃ ក្នុងខេត្តក្លងយ៉ៃ ជាប់ព្រំប្រទល់នឹងខេត្តកោះកុង។ ក្នុងចំណោមសិស្ស ១ ៣២២ នាក់ (មានចំនួន ៥០០ នាក់កំពុងសិក្សាថ្នាក់ទី ៤ និងទី ៩ នៃសាលារដ្ឋរបស់ប្រទេសថៃឡង់)។ ក៏ប៉ុន្តែចំនួននេះមានការថយចុះនៅពេលដែលកុមារកម្ពុជាមានអាយុច្រើនដោយសារត្រូវត្រឡប់មកកម្ពុជាវិញជាមួយឪពុកម្ដាយ ក្រោយពីផុតសិទ្ធិធ្វើការក្នុងប្រទេសថៃ។

លោក ឈឹម ផាន់ណា បញ្ជាក់ថា៖ «បញ្ហានៅត្រង់ថា ពេលកុមារត្រឡប់មកកម្ពុជាវិញ កុមារមានការលំបាកក្នុងការបន្តការសិស្សាក្នុងកម្រិតថ្នាក់ស្មើគ្នា ដោយសារកុមារមិនអាចនិយាយភាសាខ្មែរបាន ឬកម្មវិធីសិក្សាផ្សេងគ្នា។ ដូច្នេះកុមារចំណាកស្រុកដែលត្រឡប់មកវិញនោះត្រូវបានឱ្យរៀនថ្នាក់ទាបជាងកម្រិតដែលបានសិក្សានៅប្រទេសថៃ»។

លោក រស់ សុវាចាអ្នកនាំពាក្យ ក្រសួងអប់រំ យុវជន និងកីឡាកាលពីម្សិលមិញបានថ្លែងស្វាគមន៍ និងអរគុណចំពោះកិច្ចសហការក្នុងការចូលរួមចំណែកលើកកម្ពស់គុណភាពអប់រំ ដែលត្រូវការការចូលរួមពីគ្រប់តួអង្គពាក់

ព័ន្ធរួមទាំងមាតាបិតា និងអាជ្ញាធរមូលដ្ឋានផង។ លោកថ្លែងថា៖ «ខណៈសាលារៀនផ្អាកជាបណ្តោះអាសន្ន ដោយសារព្រឹត្តិការណ៍ ២០ កុម្ភៈ លោកគ្រូ អ្នកគ្រូបាននិងកំពុងដើរតួនាទីសំខាន់មួយ ក្នុងការចូលរួមបន្តផ្តល់ការរៀនសូត្រតាមអនឡាញ និងយន្តការលើកទឹកចិត្តអ្នកសិក្សាឱ្យបន្តរៀនសូត្រ។ ទន្ទឹមនឹងនេះ ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន រដ្ឋមន្ត្រី ក្រសួងអប់រំបានស្នើឱ្យគណៈអភិបាលខេត្ត ក្រុង ស្រុក ឃុំ ភូមិ ជួយចាត់វិធានការបន្ថែមក្នុងការគ្រប់គ្រង និងតាមដានជនចំណូលស្រុក»។

យុវតី ហួ បុប្ផា ប្រធានក្រុមគាំទ្រកុមារ និងយុវជននៃអង្គការសម្ព័ន្ធសិទ្ធិកុមារកម្ពុជាប្រាប់ភ្នំពេញប៉ុស្ដិ៍នៅថ្ងៃទី ២៣ ខែមីនាថា ក្រុមបណ្តាញដែលដឹកនាំដោយកុមារ និងយុវជនកាលពីថ្ងៃទី ២០-២១ ខែមីនា បានរៀបចំកម្មវិធីវេទិកាកុមារ និងយុវជនថ្នាក់ក្រោមជាតិនៅខេត្តបាត់ដំបង និងសៀមរាបតាមរយៈអនឡាញ (Zoom Meeting) ស្តីពី «ការទទួលបានការអប់រំរបស់កុមារដែលធ្វើចំណាកស្រុក» ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនជាពិសេស អាជ្ញាធរមូលដ្ឋាន អាណាព្យាបាល និងកុមារអំពីសារៈសំខាន់នៃការទទួលបានការអប់រំរបស់កុមារដែលចំណាកស្រុក។ យុវតីរូបនេះប្រាប់ថា៖ «បន្ទាប់ពីបញ្ចប់វេទិកានេះនៅថ្ងៃទី ១៩ ខែមេសា ខាងមុខយើងនឹងជួបជុំគ្នាធ្វើសេចក្តីថ្លែងការណ៍កុមារទាក់ទងជាមួយនឹងការចំណាកស្រុករបស់កុមារកម្ពុជាឆ្លងទៅប្រទេសថៃ។ បន្ទាប់ពីធ្វើសេចក្តីថ្លែងការណ៍នេះ យើងនឹងយកសំណូមពរ និងអនុសាសន៍នេះទៅធ្វើកិច្ចពិភាក្សាជាមួយអ្នកពាក់ព័ន្ធដែលពួកគាត់មានសិទ្ធិក្នុងការធ្វើការងារលើផលវិបាករបស់កុមារចំណាកស្រុកនេះ»៕

## ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១

### កម្ពុជា ត្រូវបានដាក់បញ្ចូលក្នុងបញ្ជីនៃប្រទេសជយលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្ដីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព

https://www.postkhmer.com/ នៅ ស៊ីវុត្ថា | Publication date 28 March 2021 | 10:35 ICT

**ភ្នំពេញ៖** កម្ពុជា ត្រូវបានសម្រេចដាក់បញ្ចូលក្នុងបញ្ជីនៃប្រទេសជយលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តរប្រវេសន៍ ដោយសុវត្ថិភាព រៀបរយ និងស្របច្បាប់ (Global compact for safe, Orderly and Regular Migration-GCM) ដោយអង្គការសហប្រជាជាតិ ស្តីពីទេសន្តរប្រវេសន៍ (UN Network Migration) ក្នុងចំណោមប្រទេសសរុបចំនួន១៨ លើសកលលោក។

លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ថ្លែងនៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០២១ថា ការសម្រេចនេះជាកិត្តិយស និងជាមោទនភាពរបស់កម្ពុជា ក្រោមការដឹកនាំរបស់ លោក នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានពុះពារគ្រប់បែបយ៉ាង ដើម្បីដោះស្រាយបញ្ហាប្រឈមការធ្វើចំណាកស្រុក ឬទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋ។ លោកស្រីថ្លែងថា ការចំណាកស្រុក ឬទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋនាពេលបច្ចុប្បន្ននេះ បានក្លាយជា ប្រធានបទដ៏ក្តៅគគុកមួយ សម្រាប់ពិភពលោក ដែលត្រូវប្រឈមដោះស្រាយ ដោយសារតែការកើនឡើងនូវបរិមាណនៃជនធ្វើទេសន្តរប្រវេសន៍ទាំងស្របច្បាប់ និងមិនស្របច្បាប់។ ជនចំណាកស្រុក ឬជនទេសន្តរប្រវេសន៍ បានប្រឈមនឹងភាពរងគ្រោះកាន់តែច្រើនឡើង និងត្រូវក្លាយជាបន្ទុករបស់ប្រទេសប្រភព និងប្រទេសគោលដៅ លើការងារគ្រប់គ្រង ការរ៉ាប់រងនូវសេវាសន្តិសុខសង្គម ការដោះស្រាយវិបត្តិសេដ្ឋកិច្ច ការដោះស្រាយវិបត្តិនៃការរំលោភបំពានអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើមនុស្សរហូតក្លាយជាទាសភាព ការកើនឡើងនូវឧក្រិដ្ឋកម្មឆ្លងដែនគ្រប់រូបភាព និងក្លាយជាកូនជញ្ជីងនយោបាយយ៉ាងស្រួចស្រាល់ ប្រសិនបើត្រូវគេប្រើប្រាស់។

លោកស្រីបញ្ជាក់ថា៖«ការប្តេជ្ញាចិត្តរបស់ព្រះរាជាណាចក្រកម្ពុជា ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោកនេះមានសារៈសំខាន់ក្នុងការដោះស្រាយបញ្ហានានា ឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់ខ្លួន តាមរយៈកិច្ចសហ

ប្រតិបត្តិការអន្តរជាតិដើម្បីទាញយកឱកាសពីការធ្វើចំណាកស្រុកឱ្យក្លាយជាកាលានុវត្តភាព សម្រាប់ប្រជាជន និងប្រទេសជាតិ»៕

## កម្លាំងនគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនជនសង្ស័យជាមេខ្យល់ទៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីច្បាប់

http://cambodiapolice.com/policekh/ 11:40 am 26 មីនា 2021

**បន្ទាយមានជ័យ៖** ជនសង្ស័យជាមេខ្យល់ម្នាក់ ត្រូវបានកម្លាំងនគរបាលជំនាញការិយាល័យ ប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បញ្ជូនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១នេះ ជាប់ពាក់ព័ន្ធពីបទនាំមនុស្សឆ្លងដែនដោយខុសច្បាប់ទៅប្រទេសថៃ។

លោកវរសេនីយ៍ឯក បេន សំអាត អធិការនគរបាលស្រុកម៉ាឡៃ បានឲ្យដឹងថា៖ជនសង្ស័យជាមេ ខ្យល់ឈ្មោះ ទូច សម្បត្តិ ភេទប្រុស អាយុ៤០ឆ្នាំ នៅភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ខេត្តបាត់ដំបង។ ជននេះត្រូវបានកម្លាំងនគរបាលវរៈសេនាតូចការពារព្រំដែនគោកលេខ ៨១៥ កម្លាំងនគរបាលនៃអធិការដ្ឋាននគរបាលស្រុកម៉ាឡៃ សហការជាមួយកម្លាំងយោធាសិករងស្រុកម៉ាឡៃ ឃាត់ខ្លួននៅវេលាម៉ោង០និង៣០នាទីឈានចូលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២១ នៅចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ។ ក្នុងនោះដកហូតបានៈ រថយន្ត០១គ្រឿង ម៉ាកកាម៉ារី ពណ៌ស ពាក់ ស្លាកលេខ ភ្នំពេញ 2F-5584 មានដឹកពលករខ្មែរចំនួន០៥នាក់ ពីស្រុកសំពៅលូន មកកាន់ស្រុកម៉ាឡៃ ដើម្បីឆ្លងទៅប្រទេសថៃ។ លោកអធិការបានបញ្ជាក់ថា៖ ឆ្លងតាមការបំភ្លឺរបស់ពលករទាំង០៥នាក់ បានរៀបរាប់ថា ពួកខ្លួនត្រូវបានមនុស្ស០១នាក់(មិនស្គាល់អត្តសញ្ញាណ) ខលតាមទូរស័ព្ទប្រាប់ឲ្យរងចាំបន្តិចទៀតមានរថយន្តមកដឹក ពេលនោះមានរថយន្ត០១គ្រឿងម៉ាកកាម៉ារី ពណ៌ស ពាក់ស្លាកលេខ ភ្នំពេញ 2F-5584 មកដឹកពួកខ្លួនទាំង០៥នាក់ ពីស្រុកសំពៅលូន មកកាន់ស្រុកម៉ាឡៃ ដើម្បីឆ្លងទៅប្រទេសថៃ ដោយក្នុង០១នាក់ គេយកថ្លៃ៥០០បាត លុះមកដល់នៅចំណុចភូមិភ្នំរូង ឃុំបឹងបេង ស្រុកម៉ាឡៃ អ្នកបើកឡានឈ្មោះទូច សម្បត្តិនេះ បានឈប់ឡានបើកទ្វារឲ្យពួកខ្លួនរត់ ប៉ុន្តែរត់រួចតែ០២នាក់ ចំណែក០៣នាក់ទៀតចេញពីឡានមិនរួចព្រោះទាស់និងដល់អ្នកបើកបររថយន្តដាក់បង្អប់ដើម្បីលាក់ពលករ។

អធិការនគរបាលស្រុកម៉ាឡៃ លោកវរសេនីយ៍ឯក បេន សំអាត បានបញ្ជាក់ទៀតថា៖បើតាមចម្លើយ របស់ជនសង្ស័យឈ្មោះ ទូច សម្បត្តិ បានសារភាពថា ខ្លួនពិតជាបានទំនាក់ទំនងនិងដឹកពលករទាំង០៥នាក់នោះមែនដោយ០១នាក់គេយកតម្លៃ៥០០បាត ពីស្រុកសំពៅលូន មកស្រុកម៉ាឡៃ និងបានបើកទ្វារឡានឲ្យពលកររត់នៅពេលឃើញសមត្ថកិច្ច ។ លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ ប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិ ជនបានបញ្ជាក់ផងដែរ ដោយផ្អែកលើចម្លើយបំភ្លឺរបស់ពលករទាំង០៥នាក់និងចម្លើយសារភាពរបស់ជនសង្ស័យឈ្មោះ ទូច សម្បត្តិ បច្ចុប្បន្នជននេះ ត្រូវបានបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២១ នេះហើយដែរ៕

## បញ្ជូនខ្លួនមេខ្យល់ចំនួន០២នាក់ នាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ ទៅសាលាដំបូងខេត្តបន្ទាយមានជ័យ

https://gntimes.com/news/ ថ្ងៃ ២៨ ខែ មិនា , ឆ្នាំ ២០២១, (Update on March 28, 2021 at 4:37 pm)

បន្ទាយមានជ័យ ៖ កម្លាំងសមត្ថកិច្ច ឃាត់ខ្លួនជនសង្ស័យជាមេខ្យល់ចំនួន០២នាក់ នាំពលករឆ្លងដែនខុសច្បាប់ទៅប្រទេសថៃ រៀបចំសំណុំរឿងបញ្ជូនខ្លួនទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីចាត់ការតាមនិតិវិធីច្បាប់ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២១ ។ នគរបាលស្រុកម៉ាឡៃបានឲ្យដឹងថា ៖ ជនសង្ស័យទាំង០២នាក់ ដែលសមត្ថកិច្ចឃាត់ខ្លួនរួមមាន៖ ទី១-ឈ្មោះ សៀង ម៉ាច ភេទប្រុស អាយុ៣០ឆ្នាំ ទី២-ឈ្មោះ ថេង ចិន្តា ភេទប្រុស

អាយុ៣០ឆ្នាំ អ្នកទាំង០២ នៅភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ខេត្តបន្ទាយមានជ័យ ។ ជនសង្ស័យទាំង០២នាក់នេះ កាលពីថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង៧យប់ បានលួចនាំពលករចំណាកស្រុកទៅប្រទេសថៃ ដោយខុសច្បាប់ចំនួន០៤នាក់ ស្រី០៣នាក់ នៅចំណុចក្រោលគោនិងគុម្ពឫស្សី ស្ថិតក្នុងភូមិចំបក់ ឃុំបឹងបេង ស្រុកម៉ាឡៃ ត្រូវបានកម្លាំងនគរបាលនៃអធិការដ្ឋានស្រុកម៉ាឡៃ ធ្វើការឃាត់ខ្លួន ទាំងពលករ និងមេខ្យល់មកអធិការដ្ឋាន ដើម្បីសួរនាំ ។ នគរបាលបានបន្តថា នៅចំពោះមុខសមត្ថកិច្ចពលករទាំង០៤នាក់ បានឆ្លើយថា ខ្លួនត្រូវបានឈ្មោះ សៀង ម៉ាច និងឈ្មោះ ថេង ចិន្តា ជាមេខ្យល់ នាំទៅលាក់ខ្លួននៅក្រោលគោក្រោយរបស់គេ រួចមកបន្តទៅលាក់ខ្លួននៅគុម្ពឫស្សីទៀត ដែលនៅក្រោយភូមិ ដើម្បីត្រៀមចេញដំណើរឆ្លងទៅថៃ លុះដល់ម៉ោង៧យប់ ថ្ងៃដដែលក៏ត្រូវបានសមត្ថកិច្ចឃាត់ខ្លួន ។

បើយោងតាមចម្លើយសារភាពរបស់ឈ្មោះ ថេង ចិន្តា បានសារភាពថា ខ្លួនត្រូវឈ្មោះ សៀង ម៉ាច ឲ្យនៅមើល និងគ្រប់គ្រងពលករចំណាកស្រុកដែលបានលាក់ខ្លួននៅក្រោលគោ ហើយផ្លាស់ទៅនៅគុម្ពឫស្សីចល័តចុះឡើង ដើម្បីត្រៀមឆ្លងដែនទៅថៃ ។ ចំណែកឈ្មោះ សៀង ម៉ាច បានសារភាពថា ខ្លួនពិតជាបានលាក់ពលករចំណាកស្រុកចាប់ពី០៨ ទៅ០៩នាក់ នៅក្រោលគោ និងចល័តទៅគុម្ពឫស្សីក្រោយភូមិ ដើម្បីត្រៀមចេញទៅថៃពិតប្រាកដមែន ។

លោកវរសេនីយ៍ឯក ឡាយ គឹមលួន នាយការិយាល័យ នគរបាលប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន បានឲ្យបញ្ជាក់ថា៖ ដោយផ្អែកតាមការបំភ្លឺរបស់ពលករ និងចម្លើយសារភាពរបស់ជនសង្ស័យ ជាមេខ្យល់ឈ្មោះសៀង ម៉ាចនិង ឈ្មោះ ថេង ចិន្តា កម្លាំងការិយាល័យជំនាញ បានបញ្ជូនជនទាំង០២នាក់នេះទៅសាលាដំបូងខេត្តចាត់ការតាមនិតិវិធីច្បាប់៕

## វរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ ទទួលពលរដ្ឋខ្មែរត្រឡប់មកពីប្រទេសថៃ៤៦នាក់ នាំទៅកាន់មណ្ឌលចត្តាឡីស័ក អនុវិទ្យាល័យភ្នំ៣២

http://cambodiapolice.com/policekh/ 7:38 am 28 មីនា 2021

ខេត្តបាត់ដំបង ៖ ដោយអនុវត្តតាមការណែនាំ និងបទបញ្ជារបស់លោកឧត្តមសេនីយ៍ទោ សាត គឹមសាន ស្នងការនគរបាលខេត្តបាត់ដំបង ស្តីពីការត្រួតពិនិត្យពលរដ្ឋឆ្លងដែន និងមេខ្យល់នាំពលករចេញ-ចូលខុសច្បាប់តាមខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃ នៅថ្ងៃសៅរ៍ ទី២៧ ខែមីនា ឆ្នាំ២០២១ លោកវរសេនីយ៍ ឯក ពៅ ថាវុធ ស្នងការរងទទួលការងារវរសេនាតូចនគរបាលការពាព្រំដែនគោកលេខ ៨១៧ ក្រោមការបញ្ជាផ្ទាល់របស់លោកវរសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ ៨១៧ បានចាត់តាំងកម្លាំងប៉ុស្តិ៍នគរបាលព្រំដែនភូនភ្នំ , ប៉ុស្តិ៍នគរបាលព្រំដែនគីឡូ១៣ និងប៉ុស្តិ៍នគរបាលព្រំដែនគីឡូ ៩ ចំណុះឲ្យវរសេនាតូចនគរបាលការពារព្រំដែនគោកលេខ៨១៧ បានសហការជាមួយកម្លាំងយោធាផ្ទៃកសឹករង , កម្លាំងយោធាកងអនុសេនាធំគាំទ្រវរសេនាតូចលេខ៥៣៣ និងកម្លាំងយោធាកងអនុសេនាធំទី១ វរសេនាតូចទី១ ទៅទទួលប្រជាពលរដ្ឋត្រឡប់មកពីប្រទេសថៃ ចូលមកប្រទេសកម្ពុជាវិញ ពីកម្លាំងយោធាថៃ កងអនុសេនាធំលេខ១៣០៥ ចំណុចភូមិគីឡូ១៣ ឃុំសន្តិភាព ស្រុកសំពៅលូន ចំនួន១ នាក់ នៅវេលាម៉ោង១១និង១០នាទីព្រឹក ។ នៅចំណុចភូមិពោធិ៍ជ្រៃ ឃុំសិរីមានជ័យ ស្រុកសំពៅលូន ចំនួន ៣៩នាក់(ស្រី ១៦នាក់) ក្នុងនោះក្មេងប្រុស ៦ នាក់ និងក្មេងស្រី ៤ នាក់ នៅវេលាម៉ោង ១២និង០០នាទី និងនៅចំណុចភូមិរស្មី ឃុំជ្រៃសីមា ស្រុកសំពៅលូន ចំនួន៦នាក់(ស្រី១នាក់) ក្នុងនោះក្មេងប្រុស ៣ នាក់ នៅវេលាម៉ោង ១៣និង១០នាទី ។ សរុបទាំង៣ទីតាំង ចំនួន ៤៦នាក់ (ស្រី ១៧នាក់) ក្នុងនោះក្មេងប្រុស ៩ នាក់ និងក្មេងស្រី ៤ នាក់ ។ បន្ទាប់ពីធ្វើការសាកសួររួច ក៏ធ្វើការអប់រំណែនាំ ហើយកម្លាំងបានប្រគល់

ពួកគាត់ឲ្យទៅក្រុមគ្រូពេទ្យដើម្បីទទួលយកទៅកាន់មណ្ឌលចត្តាឡីស័កនៅអនុវិទ្យាល័យកូនភ្នំ៣២ តាមការណែនាំរបស់ក្រសួងសុខាភិបាល ៕

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអាទិត្យ ទី២៨ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៥២នាក់ ស្រី ៥៥នាក់ ក្នុងនោះកុមារា ៩នាក់ កុមារី ១៤នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ៩នាក់ ស្រី ៤នាក់ កុមារា ០០នាក់ កុមារី ១នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ១២១នាក់ ស្រី ៤៣នាក់ កុមារា ៩នាក់ កុមារី ១២នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៧នាក់ ស្រី ៦នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ១នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ២នាក់ ប្រុសចំនួន ២នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៥២នាក់ ស្រី ៥៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័កនៅសៀមរាប ក្នុងថ្ងៃនេះទាំងអស់ហើយ ៕ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប

## ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃសៅរ៍ ទី២៧ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ១៦៧នាក់ ស្រី ៨៥នាក់ ក្នុងនោះកុមារា ១៦នាក់ កុមារី ១៦នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ០០នាក់ ស្រី ០០នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ១១នាក់ ស្រី ៦នាក់ កុមារា ១នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៩៤នាក់ ស្រី ៥១នាក់ កុមារា ១២នាក់ កុមារី ១៤នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ២៧នាក់ ស្រី ១២នាក់ កុមារា ៣នាក់ កុមារី ២នាក់។

៥-ប្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ៣៥នាក់ ស្រីចំនួន ១៧នាក់ កុមារ ចំនួន ០០នាក់ កុមារីចំនួន ០០នាក់។ 6- ខេត្តប៉ៃលិន ÷ ចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ១៦៧នាក់ ស្រី ៨៥នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអសើហើយ ៕ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ធូ កុសល

## ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១

## ការទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់ គឺធានាបានសុវត្ថិភាព និងគ្មានការរំលោភបំពាន

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១ វិទ្យុជាតិកម្ពុជា ៖ យី វិច្ឆិកា

ភ្នំពេញ៖ អនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានអំពាវនាវឱ្យប្រជាពលរដ្ឋដែលមាន បំណងទៅធ្វើការនៅក្រៅប្រទេស សូមទៅដោយស្របច្បាប់ ដើម្បីធានាបាននូវឧត្តមប្រយោជន៍និងមិនរងការរំលោភបំពាន ។ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃនិងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើ ជួញដូរមនុស្សហៅកាត់ថា(គ.ជ.ប.ជ)បានមានប្រសាសន៍ថា ប្រសិនបើប្រជាពលរដ្ឋមានបំណងទៅធ្វើការនៅក្រៅប្រទេស គឺគិតពីបញ្ហាសុវត្ថិភាព លក្ខខណ្ឌការងារ និងការរៀបចំឯកសារឱ្យបានត្រឹមត្រូវ ដើម្បីឱ្យការធ្វើចំណាកស្រុកទៅក្រៅប្រទេស មានភាពស្របច្បាប់ និងប្រកបដោយសុវត្ថិភាព។ លោកជំទាវបញ្ជាក់ថា ស្ថានភាពនៃការរៀបចំឯកសារច្បាប់ កម្ពុជាបាន ប្រឹងប្រែងធ្វើយ៉ាងណា ដើម្បីកុំឱ្យមានការខាតបង់ទៅដល់ពលករ រហូតដល់ទីភ្នាក់ងារជ្រើសរើសពលករបានចេញ គោលការណ៍រួមគ្នាជាមួយក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ធ្វើយ៉ាងណាឱ្យការជ្រើសរើសពលករ មិនត្រូវបាន បង់លុយមុននោះទេ ដើម្បីកាត់បន្ថយផលលំបាករបស់ពលករប្រថុយប្រថានក្នុងការខ្ចីលុយធនាគារ ខណៈដែលបានទុកឱ្យ ការបង់ថ្លៃឯកសារទាំងអស់នេះជាការរ៉ាប់រងរបស់និយោជក ។

លោកជំទាវបានបញ្ជាក់ថា ប្រជាពលរដ្ឋមួយចំនួនបាននិយាយថា ការទៅដោយស្របច្បាប់ ខាតពេលវេលា ខាតលុយកាក់ និងរង់ចាំយូរ ប៉ុន្តែគាត់ភ្លេចគិតថា ការរង់ចាំមិនបានរបស់ពួកគាត់ សុខចិត្តទៅតាមមេខ្យល់ ដែលពេលនាំទៅអត់មានឯកសារ គ្រប់គ្រាន់ បានធ្វើពួកគាត់រងគ្រោះមួយជីវិត ដូច្នេះការទៅក្រៅប្រទេសគឺត្រូវទៅដោយសុវត្ថិភាព ដែលមានការគាំទ្រពីផ្លូវច្បាប់ ទើបជារឿងដែលល្អប្រសើរ ។ «ប្រទេសយើងខិតខំប្រឹងប្រែងដើម្បីធ្វើយ៉ាងណាឱ្យក្លាយជាប្រទេសជ័យលាភីនៅក្នុងការអនុវត្តកតិកាសញ្ញា ពិភពលោកស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ ប៉ុន្តែទាល់តែប្រជាពលរដ្ឋខ្លួនឯង លោកជួយខ្លួនឯងដែរ ហើយយល់ពីគ្នាថាយើងអត់បានបិទសិទ្ធិពួកគាត់ក្នុងការចេញទៅធ្វើការក្រៅប្រទេសទេ ប៉ុន្តែទោះបី យ៉ាងណា ក្នុងស្ថានភាពណាគាត់ត្រូវតែឈរលើស្ថានភាពនោះ ដោយមិនប្រថុយប្រថាន រហូតដល់ មានគ្រោះថ្នាក់ទេ » ។

សូមបញ្ជាក់ថា កាលពីពេលថ្មីៗនេះ ព្រះរាជាណាចក្រកម្ពុជាទទួលបានជ័យលាភី ក្នុងការអនុវត្តកតិកាសញ្ញាពិភពលោក ស្តីពីទេសន្តប្រវេសន៍ដោយសុវត្ថិភាព រៀបរយនិងស្របច្បាប់ ពីអង្គការសហប្រជាជាតិ ដើម្បីជំរុញការលើកកម្ពស់សិទ្ធិនិង កិច្ចគាំពារពលករខ្មែរដែលធ្វើការនៅក្រៅប្រទេស ៕

# ក្រុមការងារទទួល និងដឹកជញ្ជូនប្រជាពលករខ្មែរ ដែលបានវិលត្រឡប់មកពីប្រទេសថៃ របស់រដ្ឋបាលខេត្តសៀមរាប

https://information.gov.kh/ ចេញផ្សាយ ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២១

សៀមរាប៖ នៅថ្ងៃអង្គារ ទី៣០ ខែមីនា ឆ្នាំ២០២១ នេះ បានរាយការណ៍ឱ្យដឹងថា មានប្រជាពលករខ្មែរ ដែលវិលត្រឡប់មកពីប្រទេសថៃ គិតត្រឹមម៉ោង ០៦៖០០នាទីល្ងាច ដែលចូលមកតាមច្រកអន្តរជាតិប៉ោយប៉ែត, ច្រករបៀងអូរបីជាន់ និងច្រករបៀងម៉ាឡៃ ខេត្តបន្ទាយមានជ័យ, ច្រកអន្តរជាតិអូរស្មាច់ ខេត្តឧត្តរមានជ័យ និងច្រកដូង ស្រុកកំរៀង ខេត្តបាត់ដំបង សម្រាប់ខេត្តសៀមរាប សរុបចំនួន ៩៧នាក់ ស្រី ៣៩នាក់ ក្នុងនោះកុមារា ៧នាក់ កុមារី ៤នាក់ មានដូចខាងក្រោម៖

១-សម្រាប់ច្រកអន្តរជាតិប៉ោយប៉ែត៖ ចំនួន ១នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

២-សម្រាប់ច្រករបៀងអូរបីជាន់៖ ចំនួន ២នាក់ ស្រី ១នាក់ កុមារា ០០នាក់ កុមារី ០០នាក់។

៣-សម្រាប់ច្រករបៀងម៉ាឡៃ៖ ចំនួន ៧៣នាក់ ស្រី ២៧នាក់ កុមារា ៥នាក់ កុមារី ៤នាក់។

៤-សម្រាប់ច្រកអន្តរជាតិអូរស្មាច់÷ ចំនួន ១៩នាក់ ស្រី ៦នាក់ កុមារា ២នាក់ កុមារី ០០នាក់។

៥-ច្រកដូង ស្រុកកំរៀង និងស្រុកសំពៅលូន ខេត្តបាត់ដំបង÷ ចំនួន ២នាក់ ស្រីចំនួន ១នាក់ កុមារាចំនួន ០០នាក់ កុមារីចំនួន ០០នាក់។

៦-ខេត្តប៉ៃលិន ច្រកព្រំ÷ ចំនួន ០០នាក់ ប្រុសចំនួន ០០នាក់ ស្រីចំនួន ០០នាក់ ។

សូមបញ្ជាក់៖ ពួកគាត់ទាំង ៩៧នាក់ ស្រី ៣៩នាក់ ត្រូវបានក្រុមការងារគ្រូពេទ្យ ប្រចាំការតាមច្រកព្រំដែននីមួយៗ ពិនិត្យសុខភាពបឋម ឃើញមានសុខភាពធម្មតា ហើយត្រូវបានធ្វើការដឹកជញ្ជូនមកធ្វើចត្តាឡីស័ក នៅសៀមរាប ក្នុងថ្ងៃនេះទាំងអរសើហើយ ៕ ដោយ៖ មន្ទីរព័ត៌មានខេត្តសៀមរាប សម្រួលផ្សាយដោយ៖ ធូ កុសល